**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et de Science Economiques

Royal University of Law and Economic

# សារណាបញ្ចប់ការសិក្សា

# របបគតិយុត្តនៃការវិនិយោគ នៅប្រទេសកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ធិ ហេងសត្ថា**

សាស្ត្រាចារ្យណែនាំ

លោក **ជិន វណ្ណារ៉ា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៧ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# សេចក្ដីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **ធិ ហេងសត្ថា** ជានិស្សិតសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២៧ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា២០១៨-២០២២។

**សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ ៖**

**លោកឪពុក អ្នកម្ដាយ** ជាទីគោរព និងស្រលាញ់នៃកូនដែលបានផ្ដល់កំណើត ព្រមទាំងប្រឹងប្រែងគ្រប់បែបយ៉ាងក្នុងការចិញ្ចឹមបីបាច់ថែរក្សាការពារ អប់រំទូន្មាន ប្រៀនប្រដៅ ណែនាំដោយទឹកចិត្តព្រហ្មវិហារធម៌ទាំងបួន។ ជាងនេះទៅទៀតនោះ លោកអ្នកមានគុណទាំងពីរ បានខិតខំរកថវិកាមិនខ្លាចនឿយហត់ទាំងថ្ងៃ ទាំងយប់ ពុះពារប្រឈមមុខរាល់ទុក្ខលំបាកគ្រប់បែបយ៉ាង ដើម្បីឱ្យកូនទទួលបានការសិក្សារៀនសូត្រ រហូតដល់បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ដោយទទួលបាននូវលទ្ធផលគួរជាទីមោទនៈបំផុត។ ទាំងនេះហើយបានធ្វើឱ្យកូនចងចាំជានិច្ច ចំពោះគុណូបការៈ និងព្រហ្មវិហារធម៌ របស់លោកអ្នកមានគុណទាំងពីរ ហើយករុណាធិគុណនេះនឹងស្ថិតនៅក្នុងចិត្តកូនជារៀងរហូតគ្មានថ្ងៃបំភ្លេចបានឡើយ។

**សូមគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ ៖**

**ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ លុយ ចន្ណា** សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង រួមទាំងសាស្ត្រាចារ្យទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានចំណាយនូវកម្លាំងចិត្តក្នុងការបង្ហាត់បង្រៀន ផ្ដល់ជាឯកសារ ក៏ដូចជាដំណើរការនៃការសិក្សាក្នុងរយៈពេល៤ឆ្នាំកន្លងមកនេះ និងការសរសេរសារណាដើម្បីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររបស់នាងខ្ញុំផងដែរ។

**លោកសាស្ត្រាចារ្យ ខិន វណ្ណារ៉ា** ដែលជាសាស្ត្រាចារ្យណែនាំផ្ទាល់ក្នុងការសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ។ លោកបានណែនាំ បង្ហាត់បង្រៀន ផ្ដល់ដំបូន្មានល្អៗ និងលើកទឹកចិត្តឱ្យខិតខំប្រឹងប្រែងក្នុងការសម្រេចកិច្ចការនេះ ព្រមទាំងចែករំលែកចំណេះដឹង បទពិសោធន៍ដល់រូបនាងខ្ញុំផងដែរ។ ជាពិសេស លោកសាស្ត្រាចារ្យ បានចំណាយពេលវេលាដ៏មានតម្លៃក្នុងការផ្ដល់នូវសេចក្ដីណែនាំ និងកែលម្អរាល់ចំណុចខ្វះខាតដែលកើតមាននៅក្នុងដំណើរការនៃការសរសេរសារណានេះ។

ជាចុងបញ្ចប់ នាងខ្ញុំសូមឱ្យវត្ថុស័ក្តសិទ្ធិទាំងអស់ក្នុងលោកតាមថែរក្សាការពារ និងប្រសិទ្ធពរជ័យសិរីសួស្ដីដល់លោកអ្នកមានគុណទាំងអស់ ឱ្យជៀសផុតពីជម្ងឺកាចសាហាវ និងជួបប្រទះតែសេចក្ដីសុខសេចក្ដីចម្រើន សុខភាពល្អ កាយសម្បទានរឹងមាំ អាយុយឺនយូរ ជោគជ័យគ្រប់ភារកិច្ច និងជួបតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

## **អារម្ភកថា**

បន្ទាប់ពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អស់រយៈពេល ០៤ឆ្នាំ កន្លងមកនេះ នាងខ្ញុំពិតជាទទួលបាននូវចំណេះដឹងជាច្រើន ពីសំណាក់លោក-លោកស្រីសាស្ត្រាចារ្យ ចាប់តាំងពីការសិក្សាថ្នាក់មូលដ្ឋានរហូតដល់ពេលនេះ។ តាមរយៈការសិក្សាថ្នាក់បរិញ្ញាបត្រនេះ នាងខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើនីតិឯកជន ជាពិសេសនីតិវិនិយោគ ដោយហេតុថាចាប់តាំងពីមានវត្តមានច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជាដំបូងនៅក្នុងឆ្នាំ១៩៩៤ រហូតមកដល់បច្ចុប្បន្ននេះ ទាំងសកម្មភាពវិនិយោគ និងបទប្បញ្ញត្តិច្បាប់ដែលគ្រប់គ្រងនៅក្នុងវិស័យនេះមានការកើនឡើង និងការវិវត្តគួរអោយកត់សម្គាល់ ជាពិសេសការធ្វើបច្ចុប្បន្នភាពនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជណាចក្រកម្ពុជា ដែលស្របតាមកំណែទម្រង់គោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលបានដាក់ចេញនៅគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ (IDP) ដែលបានឆ្លើយតបទៅនឹងការប្រែប្រួលនៃរចនាសម្ព័ន្ធសេដ្ឋកិច្ចនៅក្នុងស្រុក និងសភាពការណ៍ប្រែប្រួលនៃនិម្នាបនកម្មសេដ្ឋកិច្ចតំបន់ និងពិភពលោក។ ទន្ទឹមគ្នានេះដែរ នាងខ្ញុំទទួលបានកាលានុវត្តភាព ព្រមទាំងការអនុញ្ញាតពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងការសរសេរសារណាបញ្ចប់ការសិក្សាក្រោមប្រធានបទ "**របបគតិយុត្តនៃការវិនិយោគនៅប្រទេសកម្ពុជា**"។

កិច្ចការសារណាបញ្ចប់ការសិក្សា ស្តីពី "**របបគតិយុត្តនៃការវិនិយោគនៅប្រទេសកម្ពុជា**" ជាកម្រងនៃការស្រាវជ្រាវដែលធ្វើឡើងដោយផ្អែកទៅតាមច្បាប់ និងបទប្បញ្ញត្តិដែលមានជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជារួមមាន៖ រដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីវិនិយោគ អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត។ ជាងនេះទៅទៀត ក្រោមការចង្អុលបង្ហាញ និងគាំទ្រពីសំណាក់ **លោកសាស្ត្រាចារ្យ ខិន វណ្ណារ៉ា** ដែលជាសាស្ត្រាចារ្យណែនាំ នៅក្នុងការសរសេរសារណានេះឡើង នាងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវយ៉ាងយកចិត្តទុកដាក់ក្នុងការចងក្រង និងរៀបរៀងឡើងនូវកិច្ចការសារណាបញ្ចប់ការសិក្សាមួយនេះប្រកបដោយស្មារតី និងទំនួលខុសត្រូវជាទីបំផុត ដើម្បីជាគុណប្រយោជន៍សម្រាប់ប្អូនៗនិស្សិតជំនាន់ក្រោយ ក៏ដូចជាប្រជាពលរដ្ឋទូទៅ ជាពិសេសអ្នកដែលមានបំណងចង់ធ្វើការវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលចង់ស្វែងយល់អោយកាន់តែច្បាស់ និងអភិវឌ្ឍចំណេះដឹងរបស់ខ្លួនបន្ថែមមួយកម្រិតទៀត។

ជាទីបញ្ចប់ នាងខ្ញុំក៏សូមខន្តីអភ័យទោសនូវរាល់កំហុសឆ្គងនានារួមមានពាក្យពេជន៍ អក្ខរាវិរុទ្ធ និងចំណុចខ្វះខាតទាំងឡាយដែលអាចនឹងកើតមានដោយអចេតនានៅក្នុងសារណាមួយនេះ ហើយនាងខ្ញុំក៏សូមទទួលយកនូវមតិរិះគន់នានាក្នុងន័យស្ថាបនាដើម្បីអោយសារណានេះកាន់តែប្រសើរឡើង។

# មាតិកា

**ទំព័រ**

**បញ្ជីអក្សរកាត់**.......................................................................................... vi

## សេចក្តីផ្តើម

១. លំនាំបញ្ហានៃការស្រាវជ្រាវ............................................................................ ១
២. ចំណោទបញ្ហានៃការស្រាវជ្រាវ ......................................................................៣
៣. គោលបំណងនៃការស្រាវជ្រាវ .........................................................................៣
៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ .................................................................៣
៥. វិធីសាស្ត្រនៃការស្រាវជ្រាវ.............................................................................. ៤
៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........................................................................... ៤

## ជំពូកទី១
## សញ្ញាណទូទៅនៃក្របខណ្ឌវិនិយោគ

**ផ្នែកទី១៖ តើអ្វីទៅជាការវិនិយោគ**? .................................................................. ៥
១.១. និយមន័យនៃការវិនិយោគ............................................................................ ៥
១.២. លក្ខខណ្ឌនៃទុនវិនិយោគ ............................................................................. ៦
១.៣. ឋានៈជាវិនិយោគិន .................................................................................... ៦
**ផ្នែកទី២៖ ទិដ្ឋភាពទូទៅនៃការវិនិយោគនៅប្រទេសកម្ពុជាពីឆ្នាំ១៩៩៤ ដល់បច្ចុប្បន្ន** .....៧
២.១. ការវិនិយោគនៅប្រទេសកម្ពុជាពីឆ្នាំ១៩៩៤ ដល់ឆ្នាំ២០២០....................................... ៨
២.១.១. សញ្ញាណទូទៅនៃបទប្បញ្ញត្តិវិនិយោគ................................................... ៨
២.១.២. បញ្ហាប្រឈមនៅក្នុងការទាក់ទាញការវិនិយោគ.......................................... ៩
២.២. ការវិនិយោគនៅប្រទេសកម្ពុជាពីឆ្នាំ២០២១ ដល់ពេលបច្ចុប្បន្ន..................................១១
២.២.១. កាលៈទេសៈនៃការបង្កើតច្បាប់វិនិយោគថ្មី .............................................១១
២.២.២. លក្ខណៈពិសេសនៃច្បាប់វិនិយោគថ្មី និងភាពទាក់ទាញចំពោះការវិនិយោគ .......... ១២
២.២.២.១. លក្ខណៈពិសេសនៃច្បាប់វិនិយោគថ្មី ............................................ ១២
២.២.២.២. ការវិនិយោគផ្ទាល់ពីបរទេស (FDI)................................................. ១៣

**ផ្នែកទី៣៖ ស្ថាប័នទទួលបន្ទុកកិច្ចការវិនិយោគ** ........................................................ ១៤
៣.១. ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ក.អ.ក. ឬ CDC) ........................................ ១៥
៣.១.១. ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ........................ ១៥
៣.១.១.១. គោលការណ៍នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ........................................ ១៥
ក. គោលបំណងនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ........................................ ១៦
ខ. តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ........................................ ១៦
៣.១.១.២. រចនាសម្ព័ន្ធ និងសមាសភាពរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា .................... ២១
ក. រចនាសម្ព័ន្ធរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ........................................ ២១
ខ. សមាសភាពរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ........................................ ២២
៣.១.១.៣. ប្រភពធនធានរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ........................................ ២៣
៣.២. អនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត ........................................ ២៤
៣.២.១. ការរៀបចំ និងការប្រព្រឹត្តទៅរបស់អនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត ......... ២៤
៣.២.១.១. សមាសភាពរបស់អនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត .................... ២៥
៣.២.១.២. តួនាទី និងភារកិច្ចរបស់អនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត............. ២៦

## ជំពូកទី២

## ភាពលេចធ្លោនៃការវិនិយោគនៅប្រទេសកម្ពុជា និងសំណើវិនិយោគ

**ផ្នែកទី១៖ ភាពលេចធ្លោនៃការវិនិយោគនៅប្រទេសកម្ពុជា** ................................. ២៨
១.១. គោលនយោបាយជម្រុញក្នុងវិស័យវិនិយោគនៅប្រទេសកម្ពុជា ................................ ២៨
១.១.១. អភិបាលកិច្ចរដ្ឋបាលសាធារណៈប្រកបដោយប្រសិទ្ធភាព................................ ២៩
១.១.២. ការកំណត់តំបន់សេដ្ឋកិច្ចពិសេស ........................................ ២៩
១.២. យុត្តិសាស្ត្រជំរុញក្នុងវិស័យវិនិយោគនៅប្រទេសកម្ពុជា........................................ ៣១
១.២.១. ការលើកទឹកចិត្តសម្រាប់ការវិនិយោគក្នុងច្បាប់វិនិយោគថ្មី ................................ ៣២
១.២.១.១. វិស័យ និងសកម្មភាពវិនិយោគដែលទទួលបានការលើកទឹកចិត្ត ................ ៣២
១.២.១.២. ការលើកទឹកចិត្តជាមូលដ្ឋាន ........................................ ៣៤
ក. ករណីជម្រើសទី១........................................ ៣៤
ខ. ករណីជម្រើសទី២........................................ ៣៥

១.២.១.៣. ការលើកទឹកចិត្តបន្ថែម ........................................ ៣៦
១.២.១.៤. ការលើកទឹកចិត្តពិសេស ........................................ ៣៧
១.២.២. ការធានា និងការការពារសម្រាប់វិនិយោគិន ........................................ ៣៧
១.២.២.១. សិទ្ធិ និងបុព្វសិទ្ធិរបស់វិនិយោគិន ........................................ ៣៧
ក. គោលការណ៍មិនរើសអើង ........................................ ៣៧
ខ. សិទ្ធិចរាចររូបិយបណ្ណបរទេស ........................................ ៣៨
គ. ការការពារកម្មសិទ្ធិបញ្ញា ........................................ ៣៩
ឃ. សិទ្ធិទទួលបានសេវាថែទាំវិនិយោគ និងសិទ្ធិផ្សេងៗទៀត ........................................ ៣៩
១.២.២.២. ការទទួលបានការធានាពីរដ្ឋ ........................................ ៣៩
ក. ការមិនធ្វើជាតូបនីយកម្ម ........................................ ៤០
ខ. ការមិនធ្វើអស្សាមិករណ៍ ........................................ ៤០
គ. ការមិនកំណត់ថ្លៃផលិត ឬថ្លៃសេវានានា ........................................ ៤១
១.៣. អត្ថប្រយោជន៍នៃការវិនិយោគនៅប្រទេសកម្ពុជា ........................................ ៤១
១.៣.១. បរិយាកាសវិនិយោគមានអំណោយផល ........................................ ៤១
១.៣.២. កំណើនសេដ្ឋកិច្ចថេរប្រកបដោយចីរភាព ........................................ ៤២
១.៣.៣. បណ្តាញហេដ្ឋារចនាសម្ព័ន្ធពាណិជ្ជកម្ម ........................................ ៤២
១.៣.៤. កម្លាំងពលកម្មមានភាពប្រកួតប្រជែង ........................................ ៤៣
**ផ្នែកទី២៖ សំណើវិនិយោគ** ........................................ ៤៤
២.១. ប្រភេទនៃគម្រោងវិនិយោគ ........................................ ៤៤
២.១.១. គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ........................................ ៤៤
២.១.១.១. គម្រោងវិនិយោគបម្រើឱ្យការនាំចេញ ........................................ ៤៥
២.១.១.២. គម្រោងវិនិយោគដែលជាប្រភេទឧស្សាហ៍កម្មគាំទ្រ ........................................ ៤៥
២.១.១.៣. គម្រោងវិនិយោគមានទិសដៅបម្រើតម្រូវការក្នុងស្រុក ........................................ ៤៥
២.១.២. គម្រោងពង្រីកនៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ........................................ ៤៦
២.១.៣. គម្រោងវិនិយោគដែលទទួលបានត្រឹមតែការធានាលើការវិនិយោគ ........................................ ៤៦
២.២. នីតិវិធីនៃការចុះបញ្ជីគម្រោងវិនិយោគ ........................................ ៤៦
២.២.១. លក្ខខណ្ឌទាក់ទងនឹងការដាក់ពាក្យសុំវិញ្ញាបនបត្រ ........................................ ៤៧

២.២.១.១. ការដាក់ពាក្យសុំ ........................................................................................................៤៧
២.២.១.២. ការជ្រើសរើសការលើកទឹកចិត្ត ....................................................................................៤៩
២.២.៣. នីតិវិធីនៃការសម្រេចចុះបញ្ជីរបស់ស្ថាប័នទទួលបន្ទុកកិច្ចការវិនិយោគ.................៥០
២.២.៣.១. ការពិនិត្យលើទម្រង់នៃពាក្យស្នើសុំ.....................................................................៥០
២.២.៣.២. ការអនុញ្ញាតលើសំណើវិនិយោគ .......................................................................៥១
២.២.៣.៣. ការបដិសេធលើសំណើវិនិយោគ .........................................................................៥២
២.២.៣.៤. ការជូនដំណឹងទៅអ្នកដាក់ពាក្យសុំ......................................................................៥២
២.២.៣.៥. ការចេញវិញ្ញាបនបត្រចុះបញ្ជី............................................................................ ៥៣

## ជំពូកទី៣

## ការប្រព្រឹត្តទៅនៃគម្រោងវិនិយោគ និងនីតិវិធីនៃការដោះស្រាយវិវាទ

**ផ្នែកទី១៖ ការប្រព្រឹត្តទៅនៃគម្រោងវិនិយោគ** ...........................................................៥៤
១.១. ការចាប់ផ្តើមនៃការអនុវត្តគម្រោងវិនិយោគ.........................................................................៥៤
១.២. កាតព្វកិច្ចរបស់អ្នកវិនិយោគ ឬអ្នកអនុវត្តគម្រោងវិនិយោគ ...................................................៥៥
១.២.១. កាតព្វកិច្ចផ្តល់របាយការណ៍ស្តីពីការអនុវត្តគម្រោងវិនិយោគ ..........................................៥៥
១.២.២. កាតព្វកិច្ចចំពោះពន្ធ.......................................................................................................៥៥
១.២.៣. កាតព្វកិច្ចរាយការណ៍ស្តីពីសារពើពន្ធ ..............................................................................៥៧
១.២.៤. កាតព្វកិច្ចរាយការណ៍ស្តីពីការលើកលែងពន្ធគយ ...............................................................៥៧
១.៣. ការកែប្រែគម្រោងវិនិយោគ..................................................................................................៥៨
១.៣.១. ការទិញ និងការលក់នៃគម្រោងវិនិយោគ..........................................................................៥៨
១.៣.២. ការរួមបញ្ចូលគ្នានៃគម្រោងវិនិយោគ ..............................................................................៦០
១.៤. ការបញ្ចប់នៃការអនុវត្តគម្រោងវិនិយោគ..............................................................................៦០
១.៤.១. ការលុបចោលគម្រោងវិនិយោគ .........................................................................................៦០
១.៤.១.១. មូលហេតុនៃការលុបចោលគម្រោងវិនិយោគ................................................................៦១
១.៤.១.២. នីតិវិធីនៃការលុបចោលគម្រោងវិនិយោគ.....................................................................៦១
១.៤.២. ការដកហូត ឬការលុបចោលវិញ្ញាបនបត្រចុះបញ្ជី .................................................................៦២
១.៤.៣. ការជូនដំណឹងអំពីការដកហូតវិញ្ញាបនបត្រចុះបញ្ជី និងការតវ៉ា ............................................៦២

**ផ្នែកទី២៖ នីតិវិធីនៃការដោះស្រាយវិវាទពាក់ព័ន្ធនឹងគម្រោងវិនិយោគ**..................៦៣
២.១. ការដោះស្រាយក្រៅប្រព័ន្ធតុលាការ....................................................................៦៤
២.១.១. យន្តការសម្របសម្រួលដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគ រាជធានី ខេត្ត..................................................................................................................៦៤
២.១.២. ដំណោះស្រាយតាមរយៈមជ្ឈត្តការពាណិជ្ជកម្ម ...........................................៦៥
២.២ ការដោះស្រាយតាមប្រព័ន្ធតុលាការកម្ពុជា ..........................................................៦៨
**សេចក្តីសន្និដ្ឋាន** ...........................................................................................................៧០
**អនុសាសន៍** ..................................................................................................... ៧៣
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

- ក.អ.ក. = ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- គ.ជ.នា = គណៈកម្មាធិការនីតិសម្បទាន និងអភិវឌ្ឍន៍
- គ.វ.ក = គណៈកម្មាធិការវិនិយោគកម្ពុជា
- គ.ស.ព = គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា
- ម.ជ.ម. = មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា
- អ.គ.វ.រ.ខ. = អនុគណៈកម្មាធិការវិនិយោគរាជធានី-ខេត្ត
- CCFTA = កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីកម្ពុជា-ចិន
- FDI = ការវិនិយោគដោយផ្ទាល់ពីបរទេស
- GDP = ផលិតផលក្នុងស្រុកសរុប
- IDP = គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥
- QIP = គម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់
- RCEP = កិច្ចព្រមព្រៀងស្តីពីភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់
- R&D = ការស្រាវជ្រាវ និងអភិវឌ្ឍន៍
- WTO = អង្គការពាណិជ្ជកម្មពិភពលោក
- CDC = Counsel of Development of Cambodia
- CSEZB = Cambodia Special Economic Zone Board
- CamDX = Cambodia Data Exchange
- COC = Certificate of Conformity
- EBA = Everything but Aims
- FDI = Foreign Direct Investment
- GSP = General System of Preferences
- QIP = Qualified Investment Project
- SEZs = Special Economic Zones

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជាបានរៀបចំរចនាសម្ព័ន្ធសេដ្ឋកិច្ចរបស់ខ្លួនឡើងវិញ បន្ទាប់ពីបានឆ្លងកាត់សង្គ្រាមអូសបន្លាយ និងអស្ថិរភាពជាច្រើនទសវត្សកន្លងមកនេះ។ នៅក្នុងឆ្នាំ១៩៨៧ សេដ្ឋកិច្ចកម្ពុជាបានកើនឡើងបន្ទាប់ពីមានការផ្លាស់ប្តូរប្រទេសទៅជាសេដ្ឋកិច្ចទីផ្សារសេរី[1] រួចចាប់ផ្តើមទទួលយកការវិនិយោគពីបរទេសនៅឆ្នាំ១៩៨៩ ក្តីសង្ឃឹមនៃការវិនិយោគបានចាប់ផ្តើមត្រលប់មកវិញ ដែលក្នុងនោះកម្ពុជាបានបើកចំហឱ្យមានពាណិជ្ជកម្ម និងលំហូរមូលធន។ នៅក្នុងឆ្នាំ១៩៩៤ "ច្បាប់ស្តីពីការវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា" ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ៖ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ត្រូវបានបង្កើតឡើងជាលើកដំបូងក្នុងគោលបំណងជម្រុញអោយមានវិនិយោគនៅក្នុងប្រទេស និងទាក់ទាញអ្នកវិនិយោគបរទេសនៅតាមបណ្តាប្រទេសទាំងអស់នៅលើសកលលោក មកបោះទុនវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ដើម្បីធ្វើបច្ចុប្បន្នភាពទៅលើវិធានគ្រប់គ្រងវិស័យវិនិយោគអោយមានលក្ខណៈល្អប្រសើរឡើង ច្បាប់ស្តីពីការវិនិយោគនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានធ្វើវិសោធនកម្មចំពោះមាត្រាមួយចំនួននៅក្នុងឆ្នាំ២០០៣[2] រួមជាមួយនឹងការបង្កើតអនុក្រឹត្យមួយចំនួន[3] ដើម្បីកំណត់បន្ថែម និងផ្តល់ភាពច្បាស់លាស់សម្រាប់ការអនុវត្តនៅក្នុងវិស័យវិនិយោគនៅក្នុងប្រទេសកម្ពុជា។

ផ្អែកទៅលើកំណើនសេដ្ឋកិច្ចរឹងមាំជារៀងរាល់ឆ្នាំ បរិយាកាសវិនិយោគល្អ ទីតាំងវិនិយោគអំណោយផលល្អ នៅចំចំណុចកណ្តាលបេះដូងនៃបណ្តាប្រទេសអាស៊ាន ក្នុងការដឹកជញ្ជូនទំនិញទៅកាន់ប្រទេសក្នុងតំបន់ តាមផ្លូវគោក ផ្លូវអាកាសនិងផ្លូវទឹក កម្លាំងពលកម្មវ័យក្មេងច្រើន ជាពិសេសកត្តាស្ថិរភាពនយោបាយ សន្តិសុខ បានប្រែក្លាយប្រទេសកម្ពុជាពោរពេញទៅដោយឱកាសមាសសម្រាប់ការទាក់ទាញវិនិយោគ។ កំណើនសេដ្ឋកិច្ចនេះត្រូវបានគាំទ្រដោយលំហូរនៃជំនួយអភិវឌ្ឍន៍ផ្លូវការ ការបានចូលទៅកាន់ទីផ្សាររបស់សហគមន៍អឺរ៉ុប និងសហរដ្ឋអាមេរិក ក៏ដូចជាលំហូរនៃការវិនិយោគផ្ទាល់ពីបរទេសយ៉ាងច្រើនសន្ធឹកសន្ធាប់។ អ្វីដែលវិនិយោគិនបរទេសតែងតែចូលមកបណ្តាក់ទុនវិនិយោគ ក្នុងប្រទេសកម្ពុជាគឺ

---

[1] យោងតាមមាត្រា៥៦ កថាខណ្ឌទី១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។

[2] ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣។

[3] អនុក្រឹត្យលេខ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

លក្ខខណ្ឌបើកចំហរ ចំពោះរាល់វិនិយោគិនមកពីគ្រប់ទិសទី ព្រមទាំងអាចដាក់ទុនវិនិយោគ១០០% ដោយមិនចាំបាច់មានការចូលហ៊ុន ឬសហការជាមួយវិនិយោគិនក្នុងស្រុកឡើយ ពិសេសកត្តាសុខសន្តិភាព និងកំណើនសេដ្ឋកិច្ច ស្ថេរភាពនយោបាយ និងសង្គមជាផ្នែកដ៏សំខាន់ ដែលអ្នកវិនិយោគអន្តរជាតិតែងតែសម្លឹងឃើញ។ បើយើងនិយាយពីទិដ្ឋភាពសេដ្ឋកិច្ចនៅប្រទេសកម្ពុជាវិញ យើងឃើញថាប្រទេសកម្ពុជាបានឆ្លងផុតពីប្រទេសដែលមានចំណូលទាប មកជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប និងត្រូវបានគេចាត់ទុកថាជាប្រទេសដែលមានចំណោត់ថ្នាក់ល្អ និងជាប្រទេសដែលមានកំណើនសេដ្ឋកិច្ចដ៏រឹងមាំ។ ហើយដើម្បីជំរុញការវិនិយោគ និងធ្វើឲ្យកំណើនសេដ្ឋកិច្ចជាតិកាន់តែមានភាពរឹងមាំ រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងខិតខំជំរុញនូវវិស័យសំខាន់ៗមួយចំនួន ដូចជាវិស័យកសិកម្ម វិស័យឧស្សាហកម្ម វិស័យអប់រំ វិស័យបច្ចេកវិទ្យា និងវិស័យបដិសណ្ឋារកិច្ច ព្រមទាំងរៀបចំក្រុងព្រះសីហនុឲ្យក្លាយទៅជាតំបន់ពហុវិស័យសេដ្ឋកិច្ចគំរូ ដើម្បីទាក់ទាញ និងសម្រួលដល់ការវិនិយោគគ្រប់កម្រិត។ បច្ចុប្បន្ននេះ ប្រទេសកម្ពុជាបានទទួលយកលំហូរចូលដ៏ច្រើនសន្ធឹកសន្ធាប់នៃមូលធនបរទេសជាថ្មីម្តងទៀត។ ម្តងនេះគឺជាការវិនិយោគពីប្រទេសចិនដែលទទួលបានសន្ទុះយ៉ាងខ្លាំង ជាពិសេស គឺបន្ទាប់ពីឆ្នាំ២០១៦ នៅពេលដែលទីក្រុងភ្នំពេញ និងខេត្តព្រះសីហនុបានរីកដុះដាលឡើងនូវអគារខ្ពស់ៗជាច្រើន។

តាមរយៈផែនការវិនិយោគទាំងអស់នេះ ប្រទេសកម្ពុជាមានកំណើនសេដ្ឋកិច្ចលូតលាស់ទៅមុខជានិច្ច ហើយរំពឹងថា នឹងក្លាយទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងក្លាយជាប្រទេសដែលមានចំនូលខ្ពស់នៅឆ្នាំ២០៥០។ ជាមួយគ្នានេះផងដែរ ប្រទេសកម្ពុជាក៏បាន និងកំពុងធ្វើការកសាងហេដ្ឋារចនាសម្ព័ន្ធទាំងផ្នែករឹង និងទន់ ដើម្បីសម្រួលដល់ការវិនិយោគ និងពាណិជ្ជកម្ម ដែលកំពុងតែមានការរីកលូតលាស់។ ចំពោះវិស័យហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធដឹកជញ្ជូន វិស័យអគ្គិសនី កម្លាំងជំនាញវិជ្ជាជីវៈ និងតំបន់សេដ្ឋកិច្ចពិសេស គឺជាតម្រូវការចាំបាច់សម្រាប់ការអភិវឌ្ឍជាអាទិភាព។ ការពង្រឹង និងពង្រីកហេដ្ឋារចនាសម្ព័ន្ធដើម្បីឲ្យសេដ្ឋកិច្ចជាតិខ្លាំងក្លានេះដែរ ក៏ជាការឆ្លើយតបទៅនឹងគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មឆ្នាំ២០១៥-២០២៥ និងគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់គ្រប់គ្រងវិនិយោគសាធារណៈផងដែរ។

រាជរដ្ឋាភិបាលកម្ពុជាបានធ្វើច្បាប់គោលនយោបាយ និងផែនការចង្អុលបង្ហាញផ្លូវជាច្រើននៅក្នុងការទាក់ទាញការវិនិយោគនៅប្រទេសកម្ពុជាក្នុងរយៈពេលជាងពីរទសវត្សរ៍កន្លងមកនេះ ដើម្បីទាក់ទាញការវិនិយោគពីសំណាក់អ្នកវិនិយោគទាំងក្នុងស្រុក និងការទាក់ទាញលំហូរទុនវិនិយោគផ្ទាល់ពីបរទេស។ ហើយជាលទ្ធផលច្បាប់ស្តីពីវិនិយោគថ្មី ត្រូវបានតាក់តែងឡើងនៅឆ្នាំ២០២១ តាមការចង្អុលបង្ហាញនៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួល

នៃកត្តាភូមិសាស្ត្រនយោបាយ និងសេដ្ឋកិច្ចដែលបង្កឡើងដោយភាពតានតឹងផ្នែកពាណិជ្ជកម្មរវាងប្រទេសមហាអំណាចសេដ្ឋកិច្ច បដិវត្តន៍ឧស្សាហកម្មទី៤ បរិវត្តឌីជីថល និងការរអាក់រអួលនៃខ្សែចង្វាក់តម្លៃសកលដែលបណ្ដាលមកពីការរាតត្បាតនៃជំងឺកូវីដ-១៩។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ការធ្វើបច្ចុប្បន្នភាពនៃច្បាប់ស្តីពីវិនិយោគ គឺជាការចាំបាច់ណាស់នៅក្នុងវិស័យវិនិយោគ ដែលជួយដល់កំណើនសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជាអោយមានភាពរីកចម្រើនទៅមុខ និងផ្តល់ការងារយ៉ាងច្រើនជូនដល់ប្រជាពលរដ្ឋតាមរយៈការបង្កើតសកម្មភាពវិនិយោគ។ ហេតុនេះ តើនៅក្នុងច្បាប់ស្តីពីវិនិយោគថ្មីបានធ្វើការកែប្រែសម្រួលយ៉ាងដូចម្តេចខ្លះ ទៅលើការផ្តល់កាលានុវត្តភាព និងការលើកទឹកចិត្តទៅលើការវិនិយោគអ្វីខ្លះដល់វិនិយោគិន? តើវិនិយោគិនត្រូវធ្វើដូចម្តេចដើម្បីទទួលបានការលើកទឹកចិត្ត និងអនុវត្តសកម្មភាពវិនិយោគនៅក្នុងប្រទេសកម្ពុជាដោយស្របត្រឹមត្រូវតាមបទប្បញ្ញត្តិច្បាប់? ហើយតើស្ថាប័នណាដែលមានសមត្ថកិច្ចនៅក្នុងកិច្ចការវិនិយោគនៅពេលដែលវិនិយោគិនមានបំណងស្នើសុំវិនិយោគ? និងនៅពេលដែលមានវិវាទកើតឡើងនៅក្នុងអនុវត្តសកម្មភាពវិនិយោគ តើគូវិវាទអាចដោះស្រាយតាមវិធីបែបណា និងតាមរយៈស្ថាប័នណាខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ប្រធានបទដែលត្រូវបានយកមកធ្វើការសិក្សាស្រាវជ្រាវនេះ មានគោលបំណងចង់បង្ហាញឱ្យយល់ដឹងអំពីក្របខណ្ឌគតិយុត្តនៅក្នុងវិស័យវិនិយោគនៅប្រទេសកម្ពុជា ដោយហេតុថាសន្ទុះនៃការវិនិយោគនៅក្នុងប្រទេសកម្ពុជាមានការកើនឡើងនាប៉ុន្មានទសវត្សកន្លងមកនេះ ជាមួយនឹងការបង្ហាញអំពីទិដ្ឋភាពនៅការវិនិយោគចាប់តាំងពីឆ្នាំ១៩៩៧។ ជាពិសេសដើម្បីយល់ដឹងអោយកាន់តែច្បាស់ទៅលើប្រភេទនៃគម្រោងវិនិយោគ ទាំងកាលានុវត្តភាពនៃការវិនិយោគនៅក្នុងប្រទេសកម្ពុជា ក៏ដូចជានីតិវិធីនៃការស្នើសុំវិនិយោគស្របតាមបទប្បញ្ញត្តិច្បាប់ដែលគ្រប់គ្រងលើវិស័យវិនិយោគ ក៏ដូចជាស្ថាប័នមានសមត្ថកិច្ច និងពាក់ព័ន្ធនៅក្នុងប្រទេសកម្ពុជា។ ចំពោះកិច្ចការស្រាវជ្រាវនេះនឹងជួយអោយអ្នកអានបានយល់ដឹងកាន់តែច្បាស់ទៅលើវិស័យវិនិយោគនៅក្នុងប្រទេសកម្ពុជា តាមរយៈសញ្ញាណនៃច្បាប់វិនិយោគថ្មីដែលនឹងផ្តល់ផលប្រយោជន៍ដល់វិនិយោគិនទាំងក្នុងប្រទេស និងវិនិយោគិនបរទេស ព្រមទាំងដល់រាជរដ្ឋាភិបាលនៅពេលទំហំវិនិយោគមានការកើនឡើង។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទនេះ គឺត្រូវបានបកស្រាយសំខាន់ទៅលើតែក្របខណ្ឌវិនិយោគនៅក្នុងវិស័យឯកជន ដែលជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងអនុគណៈកម្មាធិការវិនិយោគ

រាជធានី ខេត្ត ក្នុងការគ្រប់គ្រងកិច្ចការវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាកាលានុវត្តភាពនៃការវិនិយោគ តាមរយៈការដាក់ចេញនូវគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល នៅក្នុងការទាក់ទាញ និងធានាការវិនិយោគនៅប្រទេសកម្ពុជា។ ជាមួយគ្នានេះដែរយើងនឹងធ្វើការសិក្សាទៅលើនីតិវិធីនៃការចុះបញ្ជីគម្រោងវិនិយោគ តាមរយៈបទបញ្ញត្តិនៃច្បាប់ស្តីពីវិនិយោគថ្មី ព្រមជាមួយនឹងដំណើរការប្រព្រឹត្តទៅនៃសកម្មភាពវិនិយោគ និងយន្តការដោះស្រាយវិវាទក្នុងរឿងវិនិយោគក្នុងវិស័យឯកជន។ ហេតុនេះប្រធានបទនេះនឹងពិពណ៌នាតែលើគម្រោងវិនិយោគណាដែលជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្តនៅក្នុងវិស័យឯកជនតែប៉ុណ្ណោះ។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

ប្រធានបទនៃសារណាសិក្សាស្រាវជ្រាវដើម្បីបញ្ចប់ការសិក្សានេះ នឹងត្រូវបានធ្វើឡើងដោយប្រើប្រាស់នូវវិធីសាស្ត្រស្រាវជ្រាវមួយចំនួនដូចជាៈ

- ចំពោះការស្រាវជ្រាវលើប្រធានបទ គឺផ្អែកទៅលើការកំណត់ដោយរដ្ឋធម្មនុញ្ញ ច្បាប់ អនុក្រឹត្យ ប្រកាស បទដ្ឋានគតិយុត្តផ្សេងៗ និងសៀវភៅមេរៀន ដែលពាក់ព័ន្ធនឹងវិស័យវិនិយោគនៅប្រទេសកម្ពុជា។
- ចំពោះការស្វែងរកឯកសារ គឺធ្វើឡើងតាមរយៈការស្វែករកនៅក្នុងប្រព័ន្ធអ៊ីនធឺណេត ក្នុងគេហទំព័ររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួង-ស្ថាប័ននានាដែលពាក់ព័ន្ធ និងព័ត៌មាននៅក្នុងកាសែតដែលជាគុណប្រយោជន៍ជួយដល់ការស្រាវជ្រាវប្រធានបទមួយនេះ។

## ៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណាបញ្ចប់ការសិក្សានេះចែកចេញជា ៣ជំពូក។ ជាដំបូង ដោយផ្ដើមពីជំពូកទី១ ការបង្ហាញពីសញ្ញាណទូទៅនៃក្របខណ្ឌវិនិយោគ។ រីឯកាលានុវត្តភាពនៃការវិនិយោគនៅប្រទេសកម្ពុជា និងសំណើវិនិយោគត្រូវបានលើកមកពន្យល់ នៅក្នុងជំពូកទី២ និងជាចុងក្រោយ ជំពូកទី៣ បកស្រាយពីការប្រព្រឹត្តទៅនៃគម្រោងវិនិយោគ និងនីតិវិធីនៃការដោះស្រាយវិវាទ។ លើសពីនេះទៅទៀត នៅក្នុងផ្នែកចុងបញ្ចប់នៃសារណានេះត្រូវបានរៀបចំឱ្យមាននូវសេចក្ដីសន្និដ្ឋាន និងអនុសាសន៍ក្នុងការកំណែទម្រង់លើវិធានគ្រប់គ្រងការវិនិយោគនៅកម្ពុជា ដើម្បីទាក់ទាញអ្នកវិនិយោគ ជាពិសេសអ្នកវិនិយោគផ្ទាល់ពីបរទេសមកធ្វើការវិនិយោគនៅក្នុងប្រទេសកម្ពុជា។

# ជំពូកទី១

# សញ្ញាណទូទៅនៃក្របខណ្ឌវិនិយោគ

# ជំពូកទី១

# សញ្ញាណទូទៅនៃក្របខណ្ឌវិនិយោគ

ការសិក្សាទៅលើសញ្ញាណទូទៅនៃក្របខណ្ឌវិនិយោគ យើងចង់រំលេចឱ្យឃើញអំពីអត្ថន័យជាទូទៅនៃការវិនិយោគនៅក្នុងវិស័យឯកជន ដែលយើងនឹងបកស្រាយនៅក្នុងផ្នែកទី១៖ តើអ្វីទៅជាការវិនិយោគ? ទន្ទឹមនឹងនេះ យើងនឹងស្វែងយល់អំពីទិដ្ឋភាពទូទៅនៃការវិនិយោគនៅប្រទេសកម្ពុជា ទៅលើដំណើរវិវត្តន៍នៅក្នុងវិស័យនេះទាំងបទប្បញ្ញត្តិច្បាប់ បរិយាកាសវិនិយោគ និងការទាក់ទាញការវិនិយោគិននៅប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ១៩៩៤ មកដល់បច្ចុប្បន្ន ដែលយើងនឹងសិក្សាលម្អិតនៅក្នុងផ្នែកទី២៖ ទិដ្ឋភាពទូទៅនៃការវិនិយោគនៅប្រទេសកម្ពុជាពីឆ្នាំ១៩៩៤ ដល់បច្ចុប្បន្ន។ ស្របពេលជាមួយគ្នានេះ យើងក៏សិក្សាអំពីការគ្រប់គ្រងសកម្មភាពវិនិយោគរបស់រាជរដ្ឋាភិបាល តាមរយៈស្ថាប័នមានសមត្ថកិច្ចក្នុងកិច្ចការវិនិយោគនៅក្នុងផ្នែកទី៣៖ ស្ថាប័នទទួលបន្ទុកកិច្ចការវិនិយោគ។

## ផ្នែកទី១៖ តើអ្វីទៅជាការវិនិយោគ?

នៅក្នុងផ្នែកដំបូងនេះយើងនឹងធ្វើការសិក្សាទៅលើសញ្ញាណនៃការវិនិយោគរួមមាន៖ និយមន័យនៃការវិនិយោគ (១.១) លក្ខខណ្ឌនៃទុនវិនិយោគ (១.២) និងឋានៈជាវិនិយោគិន (១.៣)។

### ១.១. និយមន័យនៃការវិនិយោគ

បើយើងនិយាយតាមន័យសាមញ្ញទៅលើពាក្យ "វិនិយោគ" ច្បាស់ជាយល់ឃើញថាជាការវិនិយោគសំដៅទៅលើការបណ្តាក់ទុន ជាប្រាក់កាក់ ពេលវេលា ឬថាមពលក្នុងការធ្វើអ្វីមួយ ឬច្រើនក្នុងគោលបំណងបានផលត្រឡប់មកវិញក្នុងកំឡុងពេលកំណត់ណាមួយនៅថ្ងៃអនាគត។ ការវិនិយោគអាចប្រើប្រាស់បានទៅលើមនុស្សគ្រប់វ័យ និងគ្រប់ស្ថានភាព ជាក់ស្តែងការវិនិយោគទៅលើក្រុមហ៊ុន ការវិនិយោគលើដីធ្លីផ្ទះ ឬក៏ការវិនិយោគទៅលើចំណេះដឹង ជំនាញជាដើម។ ការវិនិយោគត្រូវការទាំងពេលវេលា ប្លង់មេ ការអនុវត្តដោយមនុស្សមួយក្រុម ដែលមានគោលដៅរួម និងដើរតាមប្លង់មេ។

នៅក្នុងច្បាប់វិនិយោគមិនបានកំណត់អំពីនិយមន័យនៃពាក្យវិនិយោគនោះទេ ក៏ប៉ុន្តែបើយើងធ្វើការសិក្សាអោយស៊ីជម្រៅ វាជាពាក្យបច្ចេកទេសខាងសេដ្ឋកិច្ច។ តាមន័យសេដ្ឋកិច្ច "ការវិនិយោគ" គឺជាការធ្វើប្រតិបត្តិការដើម្បីបង្កើតមូលធន ដូចជាទ្រព្យក្នុងការរក្សាស្ថេរភាពសម្រាប់បម្រើសេចក្តីត្រូវការ និងចាំបាច់។ ការវិនិយោគនេះ មានគោលដៅផងដែរដើម្បីបង្កើតតម្លៃនៃបេតិកភណ្ឌ។ ថ្វីបើនៅក្នុងច្បាប់វិនិយោគមិនបានកំណត់អំពីនិយមន័យនៃពាក្យនេះក្តី យើងអាចកំណត់ន័យគតិយុត្ត "ការវិនិយោគ" គឺជាប្រតិបត្តិការប្រើប្រាស់នូវឧបករណ៍គតិយុត្ត ដើម្បីធ្វើឱ្យសេដ្ឋកិច្ចក្នុងសង្គមដំណើរការបានល្អ។ វាអាចជាការបង្កើតឡើង

តាមរយៈការប្រើប្រាស់ទុន ឬហ៊ុនដែលជាដើមទុនសម្រាប់បង្កើតគ្រោងសេដ្ឋកិច្ច ដែលត្រូវបានផ្តល់ឱ្យអ្នកវិនិយោគទុនបានទទួលនូវផលចំណេញក្នុងគម្រោងរបស់អ្នកវិនិយោគទាំងនោះ។

តាមការបកស្រាយខាងលើយើងអាចសន្និដ្ឋានបានថា "ការវិនិយោគ" (*Investment*) គឺជាការប្រើប្រាស់ទុនវិនិយោគដើម្បីស្វែងរកប្រាក់ចំណេញតាមរយៈការបង្កើតគម្រោងវិនិយោគ ពោលគឺការបង្កើនផលិតភាព និងទិន្នផល ដោយចំណាយសម្រាប់ការផលិតផលិតផល ទំនិញ ឬសេវាកម្មផ្សេង (ការបង្កើតរោងចក្រ សហគ្រាស កសិដ្ឋាន ក្រុមហ៊ុនទាំងក្នុង និងក្រៅប្រទេស) ដែលខុសពីពាណិជ្ជកម្មដែលជាការចំណាយសម្រាប់ដាក់ទំនិញ ឬសេវាអោយចរាចរនៅលើទីផ្សារ ដោយស្វែងរកប្រាក់ចំណេញតាមរយៈការបង្កើនតម្លៃទំនិញ ឬសេវា។

## ១.២. លក្ខខណ្ឌនៃទុនវិនិយោគ

លក្ខខណ្ឌនៃទុនវិនិយោគ ត្រូវបានបញ្ញត្តនៅក្នុងអនុក្រឹត្យស្តីពីការអនុវត្តនៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៥ ត្រង់មាត្រា ៤ "ទុនវិនិយោគ សំដៅដល់តម្លៃវិនិយោគដែលបង្ហាញជារូបិយប័ណ្ណដុល្លារអាមេរិក ដោយមិនរាប់បញ្ចូលតម្លៃដីធ្លី និងទុនបង្វិល"។ នៅត្រង់ចំណុចនេះមានការលើកឡើងជាសំណួរថាហេតុអ្វីបានជាទុនវិនិយោគមិនបង្ហាញជារូបិយប័ណ្ណប្រាក់រៀល?

នៅក្នុងវិស័យវិនិយោគ "ដុល្លារូបនីយកម្ម" ពិតជាបានរួមចំណែកដល់ការអភិវឌ្ឍប្រទេសកម្ពុជា ដែលបានបង្កឱ្យមានបរិយាកាសអំណោយផលដល់ការវិនិយោគបរទេស។ ការអនុញ្ញាតឱ្យមានការចរាចរដុល្លារអាមេរិកនឹងអាចទាក់ទាញការវិនិយោគពីបរទេសបានច្រើន ព្រោះអ្នកវិនិយោគយល់ថាមានភាពងាយស្រួលក្នុងការធ្វើប្រតិបត្តិការទូទាត់ បើកប្រាក់ខែបុគ្គលិក និងលក់ទំនិញដោយអាចទូទាត់បានជាដុល្លារអាមេរិក។ នេះជាកត្តាមួយដែលលើកទឹកចិត្តឱ្យអ្នកវិនិយោគទុនចូលមកបណ្តាក់ទុនរកស៊ីក្នុងប្រទេសកម្ពុជា។ ហើយការប្រើប្រាស់ដុល្លារនេះទៀតសោតក៏អាចរក្សាបន្តអ្នកវិនិយោគឱ្យនៅរកស៊ីនៅកម្ពុជាផងដែរ។

គួរបញ្ជាក់៖ រូបិយប័ណ្ណ (Currency) គឺជាមធ្យោបាយនៃការផ្លាស់ប្តូរទំនិញ និងសេវាកម្ម ដែលមានលក្ខណៈជាក្រដាសប្រាក់ ឬកាក់ ជាធម្មតាចេញដោយរដ្ឋាភិបាលហើយមានមុខងារជាមធ្យោបាយទូទាត់ប្រាក់ និងត្រូវបានគេចាត់ទុកជាគ្រឿងតំណាងជាតិ។ ជាក់ស្តែង នៅក្នុងប្រទេសកម្ពុជាយើង ប្រាក់រៀល ត្រូវបានគេចាត់ទុកជារូបិយប័ណ្ណជាតិ ដែលត្រូវបានគេប្រើប្រាស់ជាទូទៅនៅក្នុងទីផ្សារ។

## ១.៣. ឋានៈជាវិនិយោគិន

"វិនិយោគិន" (*Investor*) សំដៅដល់បុគ្គលអនុវត្តគម្រោងវិនិយោគដែលបានចុះបញ្ជីនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬនៅអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត (យោងតាមមាត្រា៣ នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា)។ រីឯនៅក្នុងច្បាប់វិនិយោគចាស់ "វិនិយោគិន" សំដៅតែលើបុគ្គលដែលអនុវត្ត

គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តែប៉ុណ្ណោះ[4]។ ពាក្យ "បុគ្គល" សំដៅលើរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលនីតិបុគ្គលអាចជានីតិបុគ្គលសញ្ជាតិខ្មែរ ឬនីតិវបុគ្គលសញ្ជាតិបរទេស។ នីតិបុគ្គលសញ្ជាតិខ្មែរ (វិនិយោគិនសញ្ជាតិខ្មែរ) សំដៅលើក្រុមហ៊ុនដែលមានទីកន្លែងអាជីវកម្មនិងបានធ្វើការចុះបញ្ជីពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយដែលមានភាគហ៊ុនចាប់ពី៥១ ភាគរយក្នុងក្រុមហ៊ុនត្រូវបានកាន់កាប់ដោយបុគ្គលដែលមានសញ្ជាតិខ្មែរ។[5] ចំណែកឯ នីតិបុគ្គលសញ្ជាតិបរទេស (វិនិយោគិនសញ្ជាតិបរទេស) សំដៅដល់នីតិបុគ្គលដែលមិនមែនសញ្ជាតិខ្មែរ ឬដែលមិនបានបង្កើតឡើងតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។[6] ចំពោះបុគ្គលដែលបានស្នើសុំគម្រោងវិនិយោគហើយទទួលបានវិញ្ញាបនបត្រចុះបញ្ជីវិនិយោគនឹងទទួលបានលិខិតបញ្ជាក់អំពីឋានៈជាវិនិយោគិន ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ឬអនុគណៈកម្មាធិការរាជធានី ខេត្ត ដែលជាស្ថាប័នមានសមត្ថកិច្ចក្នុងកិច្ចការវិនិយោគ។ ការទទួលបានឋានៈជាវិនិយោគិននេះ អាចប្រើប្រាស់ដើម្បីស្នើសុំការអនុញ្ញាតស្នាក់នៅបណ្តោះអាសន្នរយៈពេលវែង បណ្ណការងារ និងសៀវភៅការងារ និងគោលបំណងចាំបាច់ដទៃទៀតស្របតាមនីតិវិធីជាធរមាន។ អ្នកវិនិយោគ ឬវិនិយោគិន (*Investor*) ភាគច្រើនជាជនបរទេស ចូលមករកស៊ីក្នុងប្រទេសណាមួយ ដែលគេសម្លឹងឃើញផលចំណេញធំ។ ដូចបានលើកឡើងខាងលើ វិនិយោគិន សំដៅលើក្រុមហ៊ុន ដែលអាចបង្កើតឡើងរវាងនីតិបុគ្គលសញ្ជាតិខ្មែរជាមួយនឹងនីតិបុគ្គលសញ្ជាតិខ្មែរ ឬនីតិបុគ្គលសញ្ជាតិខ្មែរជាមួយនឹងនីតិបុគ្គលសញ្ជាតិបរទេស និងនីតិបុគ្គលសញ្ជាតិបរទេសជាមួយនឹងនីតិបុគ្គលសញ្ជាតិបរទេស។

**ផ្នែកទី២៖ និន្នាការទូទៅនៃការវិនិយោគនៅប្រទេសកម្ពុជាពីឆ្នាំ១៩៩៤ ដល់បច្ចុប្បន្ន**

ប្រទេសកម្ពុជាបានរៀបចំរចនាសម្ព័ន្ធសេដ្ឋកិច្ចរបស់ខ្លួនឡើងវិញ បន្ទាប់ពីបានឆ្លងកាត់សង្គ្រាមអូសបន្លាយ និងអស្ថិរភាពជាច្រើនឆ្នាំ។ សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាបានកើនឡើងយ៉ាងខ្លាំងក្លាបន្ទាប់ពីមានការផ្លាស់ប្តូរប្រទេសទៅជាសេដ្ឋកិច្ចទីផ្សារសេរី ដែលក្នុងនោះកម្ពុជាបានបើកចំហឱ្យមានពាណិជ្ជកម្ម និងលំហូរមូលធន។ កំណើនសេដ្ឋកិច្ចនេះត្រូវបានគាំទ្រដោយលំហូរនៃជំនួយអភិវឌ្ឍន៍ផ្លូវ ការបានចូលទៅកាន់ទីផ្សាររបស់សហគមន៍អ៊ឺរ៉ុប និងសហរដ្ឋអាមេរិក ក៏ដូចជាលំហូររនៃការវិនិយោគផ្ទាល់ពីបរទេសយ៉ាងច្រើនសន្ធឹក

[4] យោងតាមមាត្រា៥ ពាក្យវាក្យស័ព្ទ នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣។

[5] យោងតាមមាត្រា៣ ពាក្យវាក្យស័ព្ទ នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ៖ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១។

[6] យោងតាមមាត្រា៥ ពាក្យវាក្យស័ព្ទ នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣។

សន្ទាប់។ ដើម្បីស្វែងយល់លម្អិតអំពីទិដ្ឋភាពទូទៅនៃការវិនិយោគនៅប្រទេសកម្ពុជា យើងនឹងធ្វើការសិក្សាជា ០២ដំណាក់កាល ដោយផ្តើមពីការវិនិយោគនៅប្រទេសកម្ពុជាពីឆ្នាំ១៩៩៤ ដល់ឆ្នាំ២០២០ (២.១) និងការវិនិយោគនៅប្រទេសកម្ពុជាពីឆ្នាំ២០២១ ដល់ពេលបច្ចុប្បន្ន (២.២)។

### ២.១. ការវិនិយោគនៅប្រទេសកម្ពុជាពីឆ្នាំ១៩៩៤ ដល់ឆ្នាំ២០២០

នៅចុងទសវត្សរ៍ឆ្នាំ១៩៨០ កម្ពុជាបានចាប់ផ្តើមសេដ្ឋកិច្ចសេរីភាវូបនីយកម្ម និងស្តារវិស័យជាច្រើនដូចជាវិស័យសង្គមកិច្ច វិស័យសុខាភិបាល វិស័យអប់រំ។ តាមការចេញផ្សាយរបស់អង្គការសហប្រជាជាតិនៅក្នុងឆ្នាំ១៩៨៧ ប្រទេសកម្ពុជាបានលុបចោលពាណិជ្ជកម្មបរទេសផ្តាច់មុខរបស់រដ្ឋ រួចចាប់ផ្តើមទទួលយកការវិនិយោគពីបរទេសនៅឆ្នាំ១៩៨៩ ហើយក៏បានឈានទៅចុះកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសនៅឆ្នាំ១៩៩១។ នាពេលប៉ុន្មានឆ្នាំកន្លងមកនេះ ប្រទេសកម្ពុជាបានធ្វើការអភិវឌ្ឍ និងមានការផ្លាស់ប្តូរជាច្រើនវិស័យគិតចាប់តាំងពីឆ្នាំ១៩៩៣ មក សុទ្ធសឹងតែបានមកពីការទទួលយកជំនួយ និងការវិនិយោគពីបណ្តាប្រទេសជាច្រើនដូចជា ប្រទេសចិន សហរដ្ឋអាមេរិក ប្រទេសអូស្ត្រាលី និងប្រទេសជប៉ុន។ ចំពោះការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ក៏ដូចជាសន្តិភាព គឺជាមូលហេតុដែលធ្វើឱ្យប្រទេសកម្ពុជាបានក្លាយខ្លួនជាប្រទេសមួយដែលមានសន្ទុះក្នុងការអភិវឌ្ឍខ្លាំង ហើយបានប្រែខ្លួនជាប្រទេសដែលគួរឱ្យទាក់ទាញនៅក្នុងវិស័យវិនិយោគផងដែរ។ វត្តមានវិនិយោគិនពីបរទេសនេះ បានបង្ហាញពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលក្នុងការចូលរួមស្តារសេដ្ឋកិច្ចប្រទេសកម្ពុជាឡើងវិញ តាមរយៈការបង្កើតនូវបទប្បញ្ញត្តិច្បាប់នានាសម្រាប់គ្រប់គ្រងសកម្មភាពវិនិយោគ។

#### ២.១.១. សញ្ញាណទូទៅនៃបទប្បញ្ញត្តិច្បាប់វិនិយោគ

នៅពេលដែលព្រះរាជាណាចក្រកម្ពុជាបានចាប់កំណើតឡើងវិញម្តងទៀត ក្រោយឆ្លងកាត់សង្គ្រាមស៊ីវិលមក ក្តីសង្ឃឹមនៃការវិនិយោគបានចាប់ផ្តើមត្រលប់មកវិញ ហើយនៅក្នុងឆ្នាំ១៩៩៤ "ច្បាប់ស្តីពីការវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា" ត្រូវបានបង្កើតឡើង។ ច្បាប់នេះមាន៩ជំពូក ២៦មាត្រា ដែលត្រូវបានប្រកាសឱ្យប្រើជាលើកដំបូងនៅថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលមានវិសាលភាពគ្របដណ្តប់លើការវិនិយោគនានា ដែលអនុវត្តនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដោយអ្នកវិនិយោគជាជនជាតិខ្មែរ និង/ឬជនបរទេស[7] ហើយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ត្រូវបានបង្កើតឡើងដើម្បីទទួលខុសត្រូវលើការអភិវឌ្ឍ និងការគ្រប់គ្រងកិច្ចការការវិនិយោគ។ កម្ពុជាបានកំណត់នូវពាក្យវិនិយោគថាជាគំរោងវិនិយោគ

[7] យោងតាមមាត្រា ១ នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤។

ទាំងឡាយណាដែលអ្នកវិនិយោគទទួលបាននូវបុព្វសិទ្ធិពីរាជរដ្ឋាភិបាល ដោយស្របតាមច្បាប់វិនិយោគ និងបទដ្ឋានផ្សេងទៀតនៃព្រះរាជាណាចក្រកម្ពុជា។

នៅក្នុងច្បាប់នេះផងដែរ ប្រទេសកម្ពុជាបានលើកទឹកចិត្តលើការវិនិយោគទុនទៅលើវិស័យជាច្រើន ជាពិសេស គឺវិស័យឧស្សាហកម្ម វិស័យការងារ វិស័យអប់រំ និងវិស័យពាណិជ្ជកម្ម។ ពិតណាស់ បើសិនជាសំអាងតែច្បាប់ស្តីពីការវិនិយោគតែមួយមុខ គឺមិនអាចទៅរួចនោះទេ ដូច្នេះហើយកម្ពុជាក៏បានចេញនូវច្បាប់ និងអនុក្រឹតផ្សេងទៀតក្នុងការរៀបចំខ្លួនទទួលយកការវិនិយោគពីបរទេស ដែលក្នុងនោះផងដែរ មានច្បាប់ស្តីពី រៀបចំទឹកដី នគររូបនីយកម្មនិងសំណង់ឆ្នាំ១៩៩៤ ជាដើម។ ប្រទេសកម្ពុជាក៏ទទួលបានជំនួយពីបរទេសបន្តិចម្តងៗ ដែលជំនួយទាំងនោះបានដើរតួយ៉ាងសំខាន់ក្នុងការទាក់ទាញការវិនិយោគ ក៏ដូចជាបានប្រែក្លាយជាសរសៃឈាមសម្រាប់វិស័យសេដ្ឋកិច្ច។ ក្នុងនោះប្រទេសជប៉ុនបានផ្តល់ជំនួយជាច្រើន និងបានជួសជុលផ្លូវជាតិលេខ ៦ ថែមទាំងស្តារឡើងវិញនូវអគ្គិសនី និងប្រព័ន្ធទឹកផងដែរ។ ផ្លូវជាតិលេខ ៤ ត្រូវបានជួយដោយ US-AID ឯប្រទេសបារាំងបានផ្តល់ទឹកប្រាក់ប្រមាណជាង ១១ លានដុល្លារអាមេរិក នៅក្នុងការពង្រឹង និងវិនិយោគក្នុងវិស័យទេសចរណ៍។

ចាប់តាំងពីច្បាប់ស្តីពីវិនិយោគឆ្នាំ១៩៩៤ ត្រូវបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការមក ច្បាប់នេះត្រូវបានធ្វើវិសោធនកម្មចំនួនមួយលើក ដែលប្រកាសឱ្យប្រើនៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៣ (ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣) ដើម្បីសម្របខ្លួន និងធ្វើឱ្យមានការប្រកួតប្រជែងជាងមុនចំពោះការវិនិយោគនៅកម្ពុជា។ ការធ្វើវិសោធនកម្មនេះ គឺផ្តោតសំខាន់លើគម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIP) ដោយសំដៅទៅលើគម្រោងវិនិយោគទាំងឡាយណាដែលទទួលបាននូវវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរ។ ចំពោះសម្រាប់សកម្មភាពវិនិយោគដើម្បីក្លាយជាគម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIP) លុះត្រាតែការវិនិយោគនោះជាឧស្សាហកម្មជាក់លាក់មួយចំនួន និងអាចបំពេញបាននូវកម្រិតទុនវិនិយោគអប្បបរមាសម្រាប់ការចាប់ផ្តើមវិនិយោគ។ បន្ថែមពីច្បាប់វិនិយោគ រាជរដ្ឋាភិបាលក៏បានបង្កើតអនុក្រឹត្យមួយចំនួនរួមមាន៖ អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៥ អនុក្រឹត្យស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាជាអាទិ៍។

### ២.១.២. បញ្ហាប្រឈមនៅក្នុងការទាក់ទាញការវិនិយោគ

ជាទូទៅការវិនិយោគផ្ទាល់ពីបរទេស (FDI) ត្រូវបានគេមើលឃើញថាជាកម្លាំងជំរុញនូវកំណើនសេដ្ឋកិច្ច និងលើកកម្ពស់ការអភិវឌ្ឍសង្គមទាំងសម្រាប់ប្រទេសអភិវឌ្ឍន៍ និងកំពុងអភិវឌ្ឍន៍ដូចគ្នា។ ជាក់ស្តែង

សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាបានទទួលអត្ថប្រយោជន៍ជាច្រើនពី FDI។ លំហូរវិនិយោគផ្ទាល់ពីបរទេសមកកម្ពុជាបានកើនឡើងយ៉ាងខ្លាំង ចាប់ពីដើមទសវត្សឆ្នាំ២០០០ មកដោយសារគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចប្រកបដោយការប្រុងប្រយ័ត្នខ្ពស់ ស្ថេរភាពនយោបាយ និងការបើកចំហទីផ្សារ ក៏ដូចជាឥទ្ធិពលនៃកំណើនសេដ្ឋកិច្ចក្នុងតំបន់។ បរិយាកាសអំណោយផលទាំងនេះបានផ្ដល់មកនូវឱកាសវិនិយោគដ៏ទាក់ទាញសម្រាប់វិនិយោគិនមកលើប្រទេសកម្ពុជា។

ក្រោយប្រទេសកម្ពុជាបានចូលជាសមាជិកអាស៊ានក្នុងឆ្នាំ១៩៩៩ និងជាសមាជិកតំបន់ពាណិជ្ជកម្មសេរីអាស៊ាន (AFTA) ហើយចូលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក (WTO) ក្នុងឆ្នាំ២០០៤ ដោយមានកិច្ចព្រមព្រៀងអន្តរជាតិជាច្រើន ប្រទេសកម្ពុជាបានធ្វើការអនុគ្រោះពន្ធសម្រាប់ប្រទេសជិតខាងមួយចំនួនដែលជាការទាក់ទាញអ្នកវិនិយោគមកកាន់កម្ពុជាបន្ថែមទៀត។ យោងតាមក្រុមប្រឹក្សាអភិវឌ្ឍន៍ជនបទ រហូតមកដល់ឆ្នាំ២០១៩ ប្រទេសកម្ពុជាទទួលបាននូវកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ ជាពិសេសគឺវិស័យវិនិយោគទុន ដោយមានការកើនឡើងចំនួន ៤៥% បើធៀបនឹងឆ្នាំ២០១៨។ ការវិនិយោគមកកាន់កម្ពុជាភាគច្រើនគឺមកលើវិស័យពាណិជ្ជកម្ម វិស័យទេសចរណ៍ វិស័យការងារ។ ការវិនិយោគ និងជំនួយទាំងនេះបានលេចឡើងនូវការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ រោងចក្រកសិឧស្សាហកម្ម សណ្ឋាគារអន្តរជាតិ និងសំណង់ផ្សេងៗដែលទ្រទ្រង់វិស័យហិរញ្ញវត្ថុផងដែរ។ យោងតាម UNCTAD ទិន្នាការនៃការវិនិយោគផ្ទាល់ពីបរទេសមកកាន់កម្ពុជានៅឆ្នាំ២០១៩ បានកើនឡើងចំនួន ៣,៧ ប៊ីលានដុល្លារអាមេរិក (កើនឡើងចំនួន ១៦% បើធៀបនឹងឆ្នាំ២០១៨ ដែលមានចំនួន ៣,២ ប៊ីលានដុល្លារអាមេរិក។

ដោយសារតែការកើនឡើងនូវការវិនិយោគទាំងនៅក្នុង និងក្រៅប្រទេស ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងរាជរដ្ឋាភិបាលកម្ពុជាបានសម្រេចរៀបចំសេចក្ដីព្រាងច្បាប់ថ្មីស្ដីពីការវិនិយោគ ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលនៃកត្តាភូមិសាស្ត្រនយោបាយ និងសេដ្ឋកិច្ចដែលបង្កឡើងដោយភាពតានតឹងផ្នែកពាណិជ្ជកម្មរវាងមហាអំណាចសេដ្ឋកិច្ច បដិវត្តន៍ឧស្សាហកម្មទី៤ និងបរិវត្តឌីជីថល និងការរអាក់រអួលនៃខ្សែចង្វាក់តម្លៃសកល ដែលបណ្ដាលមកពីការរាតត្បាតនៃជំងឺកូវីដ ១៩ ដែលបានផ្ទុះឡើងនៅចុងឆ្នាំ២០១៩។ ការតាក់តែងច្បាប់ស្ដីពីវិនិយោគថ្មីនេះ សម្រាប់លើកកម្ពស់ភាពទាក់ទាញបង្កើនភាពប្រកួតប្រជែងខ្ពស់ ពោលធ្វើឱ្យមានការប្រកួតប្រជែងជាងមុនចំពោះការវិនិយោគនៅប្រទេសកម្ពុជា និងបង្កើតរបបលើកទឹកចិត្តបើកចំហ និងមានតម្លាភាពជូនដល់វិនិយោគិនទាំងអស់ ព្រមទាំងផ្ដល់នូវការធានា និងការពារវិនិយោគដោយគ្មានការរើសអើង។ នៅដើមឆ្នាំ២០២១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជារួមជាមួយនិងក្រសួង-ស្ថាប័នពាក់ព័ន្ធដទៃទៀត បានប្រឹងប្រែងក្នុងការកែសម្រួលខ្លឹមសាររបស់សេចក្ដីព្រាងច្បាប់ស្ដីពីវិនិយោគថ្មីនេះយ៉ាងលម្អិត ដើម្បីជាការទាក់ទាញ និងពង្រឹងដល់ការវិនិយោគក្នុង និងក្រៅស្រុក និងអាចជាផ្នែកមួយដែលអាចជំរុញប្រទេស

កម្ពុជាឱ្យសម្រេចនូវគោលដៅក្នុងការក្លាយជាប្រទេស ដែលមានចំណូលមធ្យមកម្រិតខ្ពស់នាពេលប៉ុន្មានឆ្នាំខាងមុខនេះ។

## ២.២. ការវិនិយោគនៅប្រទេសកម្ពុជាពីឆ្នាំ២០២១ ដល់ពេលបច្ចុប្បន្ន

នៅក្នុងចំណុចនេះ យើងនឹងលើកឡើងអំពីកាលៈទេសៈនៃការបង្កើតច្បាប់វិនិយោគថ្មី (២.២.១) និងលក្ខណៈពិសេសនៃច្បាប់វិនិយោគថ្មី និងភាពទាក់ទាញចំពោះការវិនិយោគ (២.២.២)។

### ២.២.១. កាលៈទេសៈនៃការបង្កើតច្បាប់វិនិយោគថ្មី

នៅឆ្នាំ២០១៥ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ ( IDP ) ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលនៃរចនាសម្ព័ន្ធសេដ្ឋកិច្ចទាំងក្នុងស្រុក និងសភាពការណ៍ប្រែប្រួលនៃនិម្មាបនកម្មសេដ្ឋកិច្ចតំបន់ និងពិភពលោក។ គោលនយោបាយនេះ គឺជាមគ្គុទេសក៍ជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជា តាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ច ការពង្រឹងភាពប្រកួតប្រជែង និងការលើកកម្ពស់ផលិតភាព ហើយនឹងក្លាយជាឧបករណ៍សំខាន់ ក្នុងការរួមចំណែកសម្រេចបាននូវទិសដៅនៃយុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើនការងារសមធម៌ និងប្រសិទ្ធភាព។

ច្បាប់ស្តីពីវិនិយោគថ្មី ត្រូវបានតាក់តែងឡើងតាមការចង្អុលបង្ហាញនៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥ និងបានឆ្លងកាត់ការសិក្សាស្រាវជ្រាវ និងតាក់តែងឡើងយ៉ាងហ្មត់ចត់ដោយក្រុមការងារនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាចាប់តាំងពីឆ្នាំ២០១៥ រហូតបញ្ចប់នៅចុងឆមាសទី១ ឆ្នាំ២០១៩ ស្របតាមអនុសាសន៍ណែនាំរបស់លោកនាយករដ្ឋមន្ត្រីនៅក្នុងវេទិការាជរដ្ឋាភិបាលផ្នែកឯកជន លើកទី១៨ កាលពីថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៩។ ច្បាប់វិនិយោគថ្មី ត្រូវបានព្រះមហាក្សត្រប្រកាសឱ្យប្រើជាការប្រញាប់តាមរយៈព្រះរាជក្រមលេខ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ (ចាប់ពីផ្នែកនេះទៅច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជាសំដៅលើច្បាប់វិនិយោគថ្មី)។ ការតាក់តែងច្បាប់ស្តីពីវិនិយោគនេះ សម្រាប់លើកកម្ពស់ភាពទាក់ទាញបង្កើនភាពប្រកួតប្រជែងខ្ពស់ និងបង្កើតរបបលើកទឹកចិត្តបើកចំហ និងមានតម្លាភាពជូនដល់វិនិយោគិនទាំងអស់ ព្រមទាំងផ្តល់នូវការធានា និងការពារ វិនិយោគដោយគ្មានគោលការណ៍រើសអើង។ ហើយច្បាប់នេះនឹងដើរតួនាទីជាត្រីវិស័យ និងមូលដ្ឋានច្បាប់ដ៏រឹងមាំសម្រាប់វិនិយោគិន ដើម្បីរួមចំណែកក្នុងការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម និងស្របពេលដែលកម្ពុជាកំពុងស្តារសេដ្ឋកិច្ចឡើងវិញបន្ទាប់ពីការរាតត្បាតនៃជំងឺកូវីដ-១៩។

ការអនុម័តដាក់ឱ្យប្រើប្រាស់ច្បាប់វិនិយោគថ្មីពិតជាមានសារៈសំខាន់ និងចំពេលខណៈប្រទេសកម្ពុជាត្រូវស្តារសេដ្ឋកិច្ចឡើងវិញ បន្ទាប់ពីការរាតត្បាតនៃជំងឺកូវីដ ១៩ ដោយច្បាប់នេះនឹងរួមចំណែកក្នុងការធ្វើឱ្យកម្ពុជាទាញយកផលប្រយោជន៍បានជាអតិបរមាពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនានាតាមរយៈ៖

- ការបង្កើតរបបលើកទឹកចិត្តវិនិយោគមួយដែលមានតម្លាភាព ភាពអាចប៉ាន់ប្រមាណទុកជាមុនបាន គ្មានការរើសអើង មានលក្ខណៈប្រកួតប្រជែង និងគាំទ្រគោលនយោបាយសង្គម-សេដ្ឋកិច្ច។
- ការធ្វើទំនើបកម្ម ការបង្កើនផលិតភាពនៃឧស្សាហកម្មក្នុងស្រុក ការពង្រឹងការតភ្ជាប់ទៅក្នុងខ្សែច្រវាក់ផ្គត់ផ្គង់ក្នុងតំបន់ និងសកលលោក តាមរយៈការជំរុញកំណើនលំហូរចូលមូលធន ការផ្ទេរបច្ចេកវិទ្យា ចំណេះដឹង និងចំណេះធ្វើ។
- ការបង្កើនភាពប្រកួតប្រជែងរបស់កម្ពុជា ដើម្បីធ្វើឱ្យរចនាសម្ព័ន្ធសេដ្ឋកិច្ចអាចធ្វើពិពិធកម្មបាន និងធន់ទៅនឹងវិបត្តិក្នុងតំបន់ និងសកលលោក និង
- ការផ្ដល់ការការពារនូវសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់ដល់វិនិយោគិននៅព្រះរាជាណាចក្រកម្ពុជា តាមរយៈការបង្កើតនូវក្របខណ្ឌគតិយុត្តដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងមានតុល្យភាពស្របទៅនឹងផលប្រយោជន៍ជាតិ។

### ២.២.២. លក្ខណៈពិសេសនៃច្បាប់វិនិយោគថ្មី និងភាពទាក់ទាញចំពោះការវិនិយោគ

ច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលមានចំនួន១២ជំពូក និង៤២មាត្រា ទទួលបានការស្វាគមន៍ពីសំណាក់ភាគីពាក់ព័ន្ធនៅក្នុងវិស័យវិនិយោគ ជាពិសេសពីសំណាក់វិនិយោគិនដែលនៅក្នុងប្រទេសកម្ពុជាតែម្ដង ដោយសង្កេតឃើញពីលក្ខណៈពិសេសនៃច្បាប់វិនិយោគថ្មី (២.២.២.១) ដែលអាចបង្កើនភាពទាក់ទាញចំពោះការវិនិយោគ (២.២.២.២) បើធៀបទៅនឹងច្បាប់វិនិយោគចាស់។

#### ២.២.២.១. លក្ខណៈពិសេសនៃច្បាប់វិនិយោគថ្មី

ច្បាប់ស្ដីពីវិនិយោគថ្មីដែលត្រូវបានតាក់តែងឡើង ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលនៃភូមិសាស្ត្រនយោបាយ និងសេដ្ឋកិច្ចដែលបង្កឡើងដោយភាពតានតឹងផ្នែកពាណិជ្ជកម្មរវាងមហាអំណាចសេដ្ឋកិច្ច បដិវត្តន៍ឧស្សាហកម្មទី៤ បរិវត្តឌីជីថល និងការរអាក់រអួលនៃខ្សែចង្វាក់តម្លៃសកល ដែលបណ្ដាលមកពីការរាតត្បាតនៃជំងឺកូវីដ-១៩ គឺមានលក្ខណៈល្អប្រសើរជាងច្បាប់វិនិយោគចាស់សម្រាប់បរិយាកាសវិនិយោគនៅប្រទេសកម្ពុជានាពេលបច្ចុប្បន្ន និងនាពេលអនាគត។ ចំណុចពិសេសនៃច្បាប់វិនិយោគថ្មីនោះ គឺការលើកទឹកចិត្តមានភាពទាក់ទាញ បន្ថែមជាមួយការធានា និងការការពារសម្រាប់វិនិយោគិន ដែលមានលក្ខណៈកាន់តែអំណោយផលបន្ថែមពីលើអ្វីដែលមានស្រាប់នៅក្នុងច្បាប់បច្ចុប្បន្ន។ ការលើកទឹកចិត្តថ្មីត្រូវបានបង្កើតឡើងដោយផ្អែកលើការពិគ្រោះយោបល់រយៈពេលវែងជាមួយវិស័យឯកជន និងការពិភាក្សាផ្ទៃក្នុង ក្នុងចំណោមភាគីពាក់ព័ន្ធសំខាន់ៗរបស់រាជរដ្ឋាភិបាល ជាពិសេសបានគិតគូរដល់ការលើកកម្ពស់សហគ្រាសធុនតូច និងមធ្យមផងដែរ តាមរយៈការផ្ដល់ការលើកទឹកចិត្តដល់សហគ្រាសធុនតូច និងមធ្យមក្នុងវិស័យអាទិភាព និងជំរុញការតភ្ជាប់ជាមួយសហគ្រាសខ្នាតធំ។

លើសពីនេះ ដំណើរការអនុម័តនៃការចុះបញ្ជីគម្រោងវិនិយោគមានភាពងាយស្រួល ដោយសំណើគម្រោងវិនិយោគត្រូវដាក់ស្នើសុំ និងពិនិត្យតាមរយៈការិយាល័យច្រកចេញ-ចូលតែមួយរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ឬតាមយន្តការវិនិយោគរាជធានី-ខេត្ត។ មិនតែប៉ុណ្ណោះ ច្បាប់នេះបានបំព្រួញពេលវេលាក្នុងការចេញវិញ្ញាបនបត្រចុះបញ្ជីពី ៣១ថ្ងៃនៃថ្ងៃធ្វើការ មកត្រឹម២០ថ្ងៃនៃថ្ងៃធ្វើការ តាមរយៈការលុបបំបាត់វិញ្ញាបនបត្រចុះបញ្ជីមានលក្ខខណ្ឌ និងវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរដោយជំនួសមកវិញនូវការចេញវិញ្ញាបនបត្រចុះបញ្ជីតែមួយគត់ ហើយការបំពេញពាក្យសុំការចុះបញ្ជីអាចធ្វើទៅបានផងដែរតាមរយៈថ្នាលបច្ចេកវិទ្យាព័ត៌មាន។ បន្ថែមពីនេះនៅក្នុងច្បាប់ស្តីពីវិនិយោគ បានកំណត់នូវយន្តការនៃការពិនិត្យ និងសម្រេចលើការវិនិយោគ និងការដោះស្រាយវិវាទពាក់ព័ន្ធនឹងគម្រោងវិនិយោគ តាមរយៈការធ្វើប្រតិភូកម្មអំណាចទៅរដ្ឋបាលរាជធានី-ខេត្ត តាមការសម្រេចរបស់រាជរដ្ឋាភិបាល ដោយបង្កើតអនុគណៈកម្មាធិការវិនិយោគរាជធានី-ខេត្ត តាមរយៈអនុក្រឹត្យដោយឡែក។

ច្បាប់នេះបានការលើកទឹកចិត្តដល់វិនិយោគិន អោយងាកទៅប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាក្នុងការចុះបញ្ជីគម្រោងវិនិយោគ ដើម្បីសម្រួលដល់ការធ្វើការងារអោយកាន់តែជឿនលឿន និងស្របតាមសម័យកាលឧស្សាហកម្ម ៤.០។ ហើយបានផ្តល់ដល់រាជរដ្ឋាភិបាលនូវភាពបត់បែន ក្នុងការផ្តល់ការលើកទឹកចិត្តពិសេសសម្រាប់វិស័យអាទិភាពជាក់លាក់ណាមួយ ដែលយើងមិនអាចព្រាងទុកជាមុនបាន ឬវិស័យឧស្សាហកម្មទើបកកើតថ្មី តាមរយៈការដាក់បញ្ចូលទៅក្នុងច្បាប់ស្តីពី ការគ្រប់គ្រងហិរញ្ញវត្ថុ ដែលត្រូវឆ្លងសភាជារៀងរាល់ឆ្នាំ។

**២.២.២.២. ការវិនិយោគផ្ទាល់ពីបរទេស (FDI)**

ការវិនិយោគដោយផ្ទាល់ពីបរទេស (Foreign Direct Investment = FDI) គឺជាការវិនិយោគមួយដែលបង្កើតឡើងដោយម្ចាស់សហគ្រាស ឬវិនិយោគិនមិនមែននៅក្នុងស្រុក ឬសហការជាមួយសហគ្រាសក្នុងស្រុក ក្រោមការគ្រប់គ្រងដោយជនជាតិបរទេស ដើម្បីបង្កើតសហគ្រាស ក្រុមហ៊ុន រោងចក្រ ឬសាខាបន្ថែមរបស់ក្រុមហ៊ុន។ និយាយឲ្យស្រួលស្តាប់ទៅ ការវិនិយោគដោយផ្ទាល់ពីបរទេស គឺជាការចាក់បញ្ចូលមូលធនពីក្រៅប្រទេសចូលមកក្នុងប្រទេស តាមរយៈការសាងសង់រោងចក្រ សហគ្រាស ផលិតកម្មនានាដើម្បីឲ្យមានដំណើរការផលិតកម្មក្នុងប្រទេស ដើម្បីជម្រុញឲ្យមានចលករសេដ្ឋកិច្ចថ្មីបន្ថែម។

នៅមុនពេលគម្រោងវិនិយោគអាចចាប់ផ្តើមប្រតិបត្តិការសកម្មភាពរបស់ខ្លួនបាន សម្រាប់វិនិយោគិនវាពិតជាកត្តាដ៏សំខាន់ដែលត្រូវយល់ដឹងអំពីច្បាប់ និងបទប្បញ្ញត្តិនានាៗរបស់ព្រះរាជាណាចក្រកម្ពុជាដែលពាក់ព័ន្ធនឹងការគ្រប់គ្រងវិស័យវិនិយោគ ជាពិសេសគឺច្បាប់វិនិយោគ មានន័យថានៅពេលវិនិយោគិនចង់មកវិនិយោគនៅប្រទេសកម្ពុជា គេប្រាកដជាត្រូវទៅមើលច្បាប់ស្តីពីវិនិយោគសិន ហើយនឹងពិចារណាថាតើ

គួរវិនិយោគដែរឬទេ។ តាមរយៈលក្ខណៈពិសេសនៃច្បាប់ស្តីពីវិនិយោគថ្មី ទំហំទុនវិនិយោគនៅក្នុងប្រទេសកម្ពុជាមានការកើនឡើង ជាពិសេសការវិនិយោគផ្ទាល់ពីបរទេស (FDI) នេះបើយោងតាមរបាយការណ៍ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងធនាគារជាតិនៃកម្ពុជា គិតត្រឹមចុងឆ្នាំ២០២១ ការវិនិយោគផ្ទាល់ពីបរទេសនៅប្រទេសកម្ពុជានៅបន្តមានភាពរឹងមាំ និងមានទំហំទឹកប្រាក់ ១៦៨.៨ពាន់ពាន់លានរៀល ឬស្មើទៅនឹង ៤១ពាន់លានដុល្លារ កើន ១១.២% ធៀបចុងឆ្នាំ២០២០ ដែលគាំទ្រដោយវិនិយោគពី ប្រទេសកូរ៉េខាងត្បូង ប្រទេសចិន ប្រទេសវៀតណាម ប្រទេសសិង្ហបុរី និងប្រទេសម៉ាឡេស៊ី ក្នុងវិស័យហិរញ្ញវត្ថុ កម្មន្តសាល សណ្ឋាគារ និងភោជនីយដ្ឋាន កសិកម្ម អចលនទ្រព្យ និងសំណង់ នេះបើយោងតាមស្ថិតិរបស់ធនាគារជាតិនៃកម្ពុជា (សូមពិគ្រោះនៅក្នុងឧបសម្ព័ន្ធទី២៖ រូបភាពបង្ហាញអំពីស្ថានភាពវិនិយោគផ្ទាល់នៅកម្ពុជា គិតត្រឹមចុងឆ្នាំ២០២១)។

នៅក្នុងរយៈពេល៥ខែ នៅឆ្នាំ២០២២នេះ រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ជាសេនាធិការបានសម្រេចអនុម័តគម្រោងវិនិយោគសរុបចំនួន៧២គម្រោង ក្រោមទុនវិនិយោគប្រមាណជាង ២៦០០លានដុល្លារអាមេរិក។ គម្រោងវិនិយោគទាំង៧២គម្រោងនេះ ភាគច្រើនរួមមាន៖ គម្រោងបង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់, គម្រោងបង្កើតរោងចក្រកែច្នៃវេចខ្ចប់ផ្លែឈើ, គម្រោងផលិតសំបកកង់យានយន្ត, រោងចក្រផលិតសម្ភារៈបរិក្ខារប្រើប្រាស់ខ្សែភ្លើង និងផលិតផលប្លាស្ទិក និងគម្រោងលើវិស័យដទៃៗជាច្រើនទៀត។ គម្រោងវិនិយោគនៅប្រទេសកម្ពុជា នឹងនៅតែបន្តមានការកើនឡើង ចាប់ពីពេលនេះរហូតដល់ឆ្នាំក្រោយៗ ដោយសារតែប្រទេសកម្ពុជា មានការអនុវត្តកិច្ចព្រមព្រៀងសេរីពាណិជ្ជកម្មកម្ពុជា-ចិន, កម្ពុជា-កូរ៉េ និងពាណិជ្ជកម្មគ្រប់ជ្រុងជ្រោយ (RCEP) លើសពីនោះទៀត ប្រទេសកម្ពុជា នៅតែមាន EBA ក៏ដូចជា GSP ជាមួយសហគមន៍អឺរ៉ុប សហរដ្ឋអាមេរិក និងអង់គ្លេស។

គួសបញ្ជាក់ថា នៅឆ្នាំ២០២២នេះ ក៏ដូចជាឆ្នាំក្រោយៗទៀត ស្ថាប័នអន្តរជាតិសុទ្ធតែវាយតម្លៃពីការងើបឡើងវិញនៃសេដ្ឋកិច្ចកម្ពុជា ដោយធនាគារពិភពលោក (World Bank) បានព្យាករណ៍ថាសេដ្ឋកិច្ចប្រទេសកម្ពុជានឹងកើនឡើងវិញ ៤.៥% នៅឆ្នាំ២០២២ នេះ កើន ៥.៨% នៅឆ្នាំ២០២៣ និងកើនឡើង ៦.៦% នៅឆ្នាំ២០២៤។ ចំណែកធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានព្យាករណ៍ថា សេដ្ឋកិច្ចកម្ពុជា នឹងកើនឡើង ៥.៣% នៅឆ្នាំ២០២២ និង៦.៥% នៅឆ្នាំ២០២៣។

### ផ្នែកទី៣៖ ស្ថាប័នទទួលបន្ទុកកិច្ចការវិនិយោគ

ស្ថាប័នទទួលបន្ទុករាល់កិច្ចការវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជាគឺ "ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា" ហើយក្រៅពីស្ថាប័ននេះ "អនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត" ក៏មានសមត្ថកិច្ចក្នុងកិច្ចការវិនិយោគ

នេះផងដែរ ដែលត្រូវបានបង្កើតឡើងដោយការធ្វើប្រតិភូកម្មអំណាចទៅអោយរដ្ឋបាលរាជធានី ខេត្ត ដែលជាយន្តការវិនិយោគរាជធានី ខេត្ត។

### ៣.១. ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ក.អ.ក. ឬ CDC)

នៅឆ្នាំ១៩៩៤ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (Counsel of Development of Cambodia) ត្រូវបានបង្កើតឡើងដើម្បីទទួលខុសត្រូវលើការអភិវឌ្ឍ និងការគ្រប់គ្រងកិច្ចការការវិនិយោគ។ ការបង្កើតក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គឺជាផ្នែកមួយនៃកម្មវិធីកំណែទម្រង់របស់រដ្ឋាភិបាលកម្ពុជាជុំវិញការជំរុញការវិនិយោគក្នុងវិស័យឯកជន។ យោងតាមមាត្រា ៤ នៃអនុក្រឹត្យ ស្ដីពីការអនុវត្តច្បាប់ស្ដីពីវិសោធនកម្ម នៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា "ក្រុមប្រឹក្សា" សំដៅលើ "ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា" ដែលបានបង្កើតឡើងតាមមាត្រា ៣ នៃច្បាប់ស្ដីពីវិនិយោគ (ច្បាប់វិនិយោគចាស់ឆ្នាំ១៩៩៤) ដោយឡែកក្រុមប្រឹក្សានេះ ត្រូវបានបញ្ញត្តនៅក្នុងច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០២១ ត្រង់មាត្រា៤។ នៅក្នុងច្បាប់វិនិយោគថ្មី "ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា" ដែលត្រូវបានហៅកាត់ថា "ក.អ.ក." ឬ "CDC" ជាស្ថាប័នប្រតិបត្តិបំពេញមុខងារជាសេនាធិការ និងជាច្រកចេញចូលតែមួយរបស់រាជរដ្ឋាភិបាលលើបេសកកម្មដឹកនាំ និងគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ការវិនិយោគឯកជន និងតំបន់សេដ្ឋកិច្ចពិសេស[8] ដែលរាល់ការរៀបចំ និងការប្រព្រឹត្តទៅរបស់ស្ថាប័ននេះ គឺអនុលោមតាមអនុក្រឹត្យលេខ៦០ អនក្រ.បក ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

#### ៣.១.១. ការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវបានកំណត់ដោយអនុក្រឹត្យដែលបញ្ញត្តពីសមាសភាព តួនាទី និងភារកិច្ច ដូចមានចែងនៅក្នុងអនុក្រឹត្យខាងលើ។ មុននឹងឈានដល់ការបកស្រាយអំពីរចនាសម្ព័ន្ធ និងសមាសភាពរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (៣.១.១.២) យើងគប្បីស្វែងយល់អំពីគោលការណ៍នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (៣.១.១.១) ជាមុនសិន។

##### ៣.១.១.១. គោលការណ៍នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

នៅក្នុងចំណុចនេះយើងនឹងសិក្សាអំពីគោលបំណងនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ក) ដែលជាចំណុចដ៏សំខាន់ក្នុងការស្វែងយល់អំពីគោលបំណងនៃការបង្កើតក្រុមប្រឹក្សានេះឡើង ព្រមទាំងតួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ខ)។

---

[8] យោងតាមមាត្រា ៤ នៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខៈ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១។

### ក. គោលបំណងនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវបានបង្កើតឡើងក្នុងគោលបំណងគ្រប់គ្រងគោលនយោបាយវិនិយោគវិស័យឯកជនរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការទាក់ទាញការវិនិយោគបន្ថែម និងរក្សាបាននូវផលិតភាពនៃការវិនិយោគពីវិស័យឯកជន។ លើសពីនេះ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានចក្ខុវិស័យក្នុងការជំរុញការវិនិយោគជាមួយនឹងលទ្ធផលការងារប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ដែលនឹងផ្តល់ជាគុណប្រយោជន៍ដល់ប្រជាជនកម្ពុជា តាមរយៈការកើតឡើងនៃការវិនិយោគនៅក្នុងប្រទេស។

### ខ. តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលជាស្ថាប័នប្រតិបត្តិរបស់រាជរដ្ឋាភិបាល មានភារកិច្ចដូចតទៅ[9]៖

- ជាសេនាធិការ និងជាច្រកចេញ-ចូលតែមួយ របស់រាជរដ្ឋាភិបាលក្នុងកិច្ចការនីតិសម្បទាន និងអភិវឌ្ឍន៍ និងការវិនិយោគសាធារណៈ ការវិនិយោគឯកជន និងការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស។
- ទាក់ទងជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរាជរដ្ឋាភិបាលទាំងអស់ ក្នុងគោលបំណងធ្វើឱ្យគេយល់ជ្រួតជ្រាបអំពីយុទ្ធសាស្ត្រ និងបណ្តាអាទិភាពរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍប្រទេស ដើម្បីសម្របសម្រួលការទទួល និងការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការឱ្យមានប្រសិទ្ធភាព ស្របតាមសេចក្តីត្រូវការ និងអាទិភាពរបស់ប្រទេសជាតិ ដោយប្រកាន់តួនាទីជាម្ចាស់ សម្រាប់សម្រេចលទ្ធផលជូនប្រទេសជាតិ។
- សម្របសម្រួលការងាររវាងក្រសួង និងស្ថាប័ននានា ដែលមានការពាក់ព័ន្ធជាមួយនឹងដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងជាមួយអ្នកវិនិយោគ។
- បង្កលក្ខណៈងាយស្រួល និងសម្រួលកិច្ចការដល់ដៃគូអភិវឌ្ឍន៍ និងដល់អ្នកវិនិយោគ។
- តម្រង់ទិសក្នុងការបែងចែក និងក្នុងការប្រើប្រាស់ធនធានសាធារណៈ និងធនធានឯកជនក្នុងកិច្ចការអភិវឌ្ឍន៍កម្ពុជា។
- ពិនិត្យ និងសម្រេចរាល់កិច្ចការនីតិសម្បទាន និងអភិវឌ្ឍន៍ និងគម្រោងវិនិយោគរបស់ដៃគូអភិវឌ្ឍន៍ គម្រោងវិនិយោគឯកជន និងការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស។
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវសុំយោបល់សម្រេចពីគណៈរដ្ឋមន្ត្រីលើគម្រោងវិនិយោគទាំងឡាយណាដែលមានលក្ខណៈសម្បត្តិណាមួយដូចខាងក្រោម[10]៖

---

[9] យោងតាមមាត្រា ១០ នៃអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

[10] យោងតាមមាត្រា ១១ នៃអនុក្រឹត្យដដែល។

- ទំហំទុនវិនិយោគសរុបចាប់ពី ៥០ លានដុល្លារអាមេរិកឡើងទៅ
- មានផលប៉ះពាល់ខ្ពស់ផ្នែកបរិស្ថាន[11]ខាងនយោបាយ
- ការរុករក និងការធ្វើអាជីវកម្មរ៉ែ និងធនធានធម្មជាតិ
- អាចបង្កគ្រោះថ្នាក់ដល់បរិស្ថាន
- គម្រោងយុទ្ធសាស្ត្ររយៈពេលវែង
- និងគម្រោងសម្បទាននៃវិស័យហេដ្ឋារចនាសម្ព័ន្ធ។

– ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវទទួលខុសត្រូវចំពោះមុខគណៈរដ្ឋមន្ត្រី អំពីសកម្មភាពរបស់ខ្លួន[12]។

ចំពោះការគ្រប់គ្រងកិច្ចការទាក់ទងនឹងនីតិសម្បទាន និងអភិវឌ្ឍន៍ កិច្ចការវិនិយោគសាធារណៈ កិច្ចការវិនិយោគឯកជន កិច្ចការក្នុងតំបន់សេដ្ឋកិច្ចពិសេស ក្រុមប្រឹក្សាមានភារកិច្ចរួមមានដូចខាងក្រោម៖

### ខ.១. ការគ្រប់គ្រងកិច្ចការនីតិសម្បទាន និងអភិវឌ្ឍន៍

ក្នុងកិច្ចការនីតិសម្បទាន និងអភិវឌ្ឍន៍ ក្រុមប្រឹក្សាមានភារកិច្ចរួមមានដូចតទៅ[13]៖

- បំពេញតួនាទីជា "ច្រកចេញ-ចូលតែមួយ" និងជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការទាក់ទងជាមួយនឹងដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល ដែលផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការឥតសំណងដល់កម្ពុជា និងធ្វើជាចំណុចប្រមូលផ្តុំ ក្នុងការទាក់ទងរវាងស្ថាប័ននានានៃរាជរដ្ឋាភិបាល ដើម្បីសម្របសម្រួលការទទួល និង/ឬការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការទាំងនេះ។
- រៀបចំ និងអនុវត្តយុទ្ធសាស្ត្រស្តីពីការកៀរគរ និងការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ដើម្បីពង្រឹងភាពជាម្ចាស់ និងភាពដឹកនាំរបស់រាជរដ្ឋាភិបាលក្នុងកិច្ចអភិវឌ្ឍន៍ ព្រមទាំងពង្រឹងភាពជាដៃគូជាមួយសហគមន៍ដៃគូអភិវឌ្ឍន៍។
- កៀរគរ និងវិភាជន៍ហិរញ្ញប្បទានសហប្រតិបត្តិការ សម្រាប់អនុវត្តបណ្តាគោលដៅអាទិភាពដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការអភិវឌ្ឍតាមវិស័យ។
- ដឹកនាំផ្ទាល់រាល់កិច្ចការដែលពាក់ព័ន្ធនឹងការបង្កើតប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃហិរញ្ញប្បទានសហប្រតិបត្តិការ។

---

[11] ផលប៉ះពាល់ខ្ពស់ផ្នែកបរិស្ថាន (Sensibilité) ភាពងាយប្រែប្រួលនៃសកម្មភាពសេដ្ឋកិច្ច នៅពេលដែលមានការកើតឡើងនូវហេតុបច្ច័យអ្វីមួយដូចជាគម្រោងការគោលនយោបាយជាអាទិ៍។

[12] យោងតាមមាត្រា ១២ នៃអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

[13] យោងតាមមាត្រា ១៤ នៃអនុក្រឹត្យដដែល។

- ផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃដំណើរការរបស់ក្រុមការងារបច្ចេកទេសចម្រុះ។
- រៀបចំឯកសារចាំបាច់នានា សម្រាប់កិច្ចប្រជុំកម្រិតគោលនយោបាយជាមួយដៃគូអភិវឌ្ឍន៍ដូចជាគណៈកម្មាធិការសម្របសម្រួលរវាងរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ និង "វេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា" ជាដើម ដោយសហការជាមួយបណ្តាក្រសួង និងស្ថាប័នដែលមានការពាក់ព័ន្ធ។
- ចូលរួមរៀបចំផែនការសេដ្ឋកិច្ច សង្គមកិច្ច និងផែនការតាមវិស័យសម្រាប់អភិវឌ្ឍន៍កម្ពុជា។
- ចូលរួមគ្រប់គ្រងកិច្ចការវិនិយោគសាធារណៈ ដោយសហការយ៉ាងជិតស្និទ្ធជាមួយនឹងក្រសួង និងស្ថាប័នទាំងឡាយដែលមានការពាក់ព័ន្ធ។ ការងារនេះពាក់ព័ន្ធសំខាន់ទៅនឹងការសម្របសម្រួល និងការតម្រង់ទិសក្នុងការបែងចែក និងការប្រើប្រាស់ធនធាននៅក្នុងប្រទេស និងធនធានដែលបានមកពីក្រៅប្រទេសដើម្បីកិច្ចការស្តារ និងអភិវឌ្ឍន៍កម្ពុជា។
- តាមការប្រគល់សិទ្ធិពីនាយករដ្ឋមន្ត្រី ចុះហត្ថលេខាតាងនាមរាជរដ្ឋាភិបាលជាមួយនឹងដៃគូអភិវឌ្ឍន៍ដើម្បីទទួល និង/ឬបែងចែកហិរញ្ញប្បទានទាំងនោះ។
- ធ្វើរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំជូនរាជរដ្ឋាភិបាល ដើម្បីរាជរដ្ឋាភិបាលពិនិត្យ និងលើកឡើងនូវវិធានការចាំបាច់សម្រាប់កែលម្អ និងតម្រង់ទិសការងារនីតិសម្បទា និងអភិវឌ្ឍន៍។

### ខ.២. ការគ្រប់គ្រងកិច្ចការវិនិយោគសាធារណៈ

ក្នុងកិច្ចការវិនិយោគសាធារណៈ ក្រុមប្រឹក្សាមានភារកិច្ចជាអ្នកសម្របសម្រួលក្នុងការកំណត់លំដាប់លំដោយអាទិភាពនៃកម្មវិធី និងគម្រោងវិនិយោគរបស់ដៃគូអភិវឌ្ឍន៍សម្រាប់រយៈពេលមធ្យម និងរយៈពេលមួយឆ្នាំ។ "ក.អ.ក" ត្រូវធ្វើទំនាក់ទំនងជាមួយបណ្តាក្រសួង និងស្ថាប័នពាក់ព័ន្ធនានានៃរាជរដ្ឋាភិបាលដែលត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួន ខាងការវិនិយោគសាធារណៈ ដោយសម្របសម្រួលការងារជាមួយគ្នាតាមរយៈយន្តការ "ច្រកចេញ-ចូលតែមួយ"។ ការធ្វើទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សាជាមួយបណ្តាក្រសួង និងស្ថាប័នពាក់ព័ន្ធ ត្រូវបានកំណត់ដូចតទៅ[14]៖

- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដែលជាបង្អួចការទូតផ្លូវការ។
- ក្រសួងផែនការ សហការជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធ ជាអ្នកដឹកនាំក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ៥ឆ្នាំ និងកម្មវិធីវិនិយោគសាធារណៈ។

[14] យោងតាមមាត្រា ១៤ នៃអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាអ្នករៀបចំការព្យាករណ៍ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចរយៈពេលមធ្យម ជាអ្នករៀបចំថវិកាសម្រាប់អនុវត្តកម្មវិធីវិនិយោគសាធារណៈ និងជាអ្នកត្រួតពិនិត្យការប្រើប្រាស់ហិរញ្ញប្បទាន ព្រមទាំងទទួលបន្ទុកកៀរគរ និងគ្រប់គ្រងដោយផ្ទាល់នូវហិរញ្ញប្បទានជាការខ្ចី និងជំនួយបច្ចេកទេសដែលមានការពាក់ព័ន្ធ។
- ក្រសួងជំនាញជាអ្នករៀបចំផែនការអភិវឌ្ឍ និងគម្រោងវិនិយោគសាធារណៈតាមវិស័យដោយសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងផែនការ ជាមួយ "ក.អ.ក" និងជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងជាអ្នកអនុវត្តកម្មវិធី និងគម្រោងវិនិយោគសាធារណៈ ដែលមានការពាក់ព័ន្ធទៅនឹងសមត្ថកិច្ចរបស់ខ្លួន។

### ខ.៣. ការគ្រប់គ្រងកិច្ចការវិនិយោគឯកជន

ក្នុងកិច្ចការវិនិយោគឯកជន ក្រុមប្រឹក្សាមានភារកិច្ចរួមមានដូចតទៅ[15]៖

- បំពេញតួនាទីជា "ច្រកចេញ-ចូលតែមួយ" និងជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការពិនិត្យ និងសម្រេចលើការវិនិយោគនានាដូចបានកំណត់នៅក្នុងមាត្រា ៤ នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។
- ធ្វើការវិភាគ "ការប្រណាំងប្រជែងដណ្តើមឈ្នះ" លើទីផ្សារអន្តរជាតិសម្រាប់ប្រទេសកម្ពុជា លើកឡើងនូវទស្សនៈអនាគតអំពីកិច្ចវិនិយោគឯកជនសម្រាប់ប្រទេសកម្ពុជា និងសម្រេចឱ្យបាននូវទស្សនៈនេះ ដោយធ្វើឱ្យប្រទេសកម្ពុជាក្លាយជា "សាជីវកម្មកម្ពុជា"។ សហការជាមួយក្រសួង និងស្ថាប័នដែលមានការពាក់ព័ន្ធ ដើម្បីរៀបចំយុត្តិសាស្ត្រនៃការវិនិយោគឯកជន និងដើម្បីលើកគម្រោងនានាសម្រាប់ការវិនិយោគឯកជន។
- ផ្សព្វផ្សាយអំពីគម្រោងនានាសម្រាប់ការវិនិយោគឯកជន ដែលរាជរដ្ឋាភិបាលបានលើកឡើង និងផ្តល់គម្រោងទាំងនោះទៅឱ្យអ្នកវិនិយោគ តាមនីតិវិធីដែលមានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុងនៃ "ក.អ.ក"។
- សម្របសម្រួលការគ្រប់គ្រងគម្រោងសម្បទាននៃវិស័យហេដ្ឋារចនាសម្ព័ន្ធ។
- លើកគម្រោង និងផ្តល់យោបល់ជូនរាជរដ្ឋាភិបាលស្តីអំពីការរៀបចំ និងកែលម្អច្បាប់បទប្បញ្ញត្តិ និងលិខិតបទដ្ឋានផ្សេងៗ ដែលទាក់ទិននឹងកិច្ចការវិនិយោគជន ក្នុងគោលបំណងបង្កើតលក្ខខណ្ឌដែលអនុគ្រោះ និងដែលលើកទឹកចិត្តដល់អ្នកវិនិយោគ ដើម្បីបង្កើតប្រសិទ្ធភាពការងារក្នុងវិស័យវិនិយោគជន។

---

[15] យោងតាមមាត្រា ១៧ នៃអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

- រៀបចំចងក្រងឯកសារ និងលិខិតបទដ្ឋាននានាដែលទាក់ទិនទៅនឹងកិច្ចការវិនិយោគជន សម្រាប់ផ្សព្វផ្សាយនៅក្នុងប្រទេស និងក្រៅប្រទេស។
- ធ្វើរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំជូនរាជរដ្ឋាភិបាល ដើម្បីរាជរដ្ឋាភិបាលពិនិត្យ និងលើកឡើងនូវវិធានការចាំបាច់សម្រាប់កែលម្អ និងតម្រង់ទិសការងារវិនិយោគឯកជន។

### ខ.៤. ការគ្រប់គ្រងកិច្ចការក្នុងតំបន់សេដ្ឋកិច្ចពិសេស

ក្នុងកិច្ចការតំបន់សេដ្ឋកិច្ចពិសេស ក្រុមប្រឹក្សាមានភារកិច្ចរួមមានដូចតទៅ[16]៖

- បំពេញតួនាទីជា "ច្រកចេញ-ចូលតែមួយ" និងជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការពិនិត្យ និងសម្រេចលើសំណើសុំបង្កើតតំបន់សេដ្ឋកិច្ចពិសេស ទាំងតាមរូបភាពរដ្ឋ ឯកជនចម្រុះរដ្ឋ និងឯកជននៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- ធ្វើការវិភាគ លើកផែនការយុទ្ធសាស្ត្រ ដើម្បីកំណត់ពីភូមិសាស្ត្រសំខាន់ៗ ដោយសហការជាមួយក្រសួង និងស្ថាប័នដែលមានការពាក់ព័ន្ធ ដើម្បីបង្កើតតំបន់សេដ្ឋកិច្ចពិសេសនៅក្នុងប្រទេស និងលើកឡើងនូវទស្សនៈអនាគតអំពីកិច្ចការតំបន់សេដ្ឋកិច្ចពិសេស សម្រាប់ទាក់ទាញអ្នកអភិវឌ្ឍន៍តំបន់ និងអ្នកវិនិយោគក្នុងតំបន់ និងសម្រេចឱ្យបាននូវទស្សនៈនេះ ដោយធ្វើឱ្យប្រទេសកម្ពុជាក្លាយទៅជាតំបន់សាជីវកម្មទំនើបនាពេលអនាគត។
- ផ្សព្វផ្សាយអំពីគម្រោងនានាសម្រាប់ការវិនិយោគតំបន់សេដ្ឋកិច្ចពិសេស ដែលរាជរដ្ឋាភិបាលបានលើកឡើង និងផ្តល់គម្រោងទាំងនោះទៅឱ្យអ្នកអភិវឌ្ឍន៍តំបន់តាមគ្រប់ប្រព័ន្ធឃោសនានាដែលមានប្រសិទ្ធភាព និងឆាប់រហ័ស។
- ផ្តួចផ្តើម និងសម្របសម្រួលការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសដែលជាអាទិភាពរបស់រាជរដ្ឋាភិបាល។
- លើកគម្រោង និងផ្តល់យោបល់ជូនរាជរដ្ឋាភិបាលស្តីពីការរៀបចំ និងការកែលម្អច្បាប់បទប្បញ្ញត្តិនានា និងដែលទាក់ទិននឹងការវិនិយោគតំបន់សេដ្ឋកិច្ចពិសេស ក្នុងគោលបំណងបង្កើតលក្ខខណ្ឌដែលអនុគ្រោះ និងដែលលើកទឹកចិត្តដល់អ្នកអភិវឌ្ឍន៍តំបន់ ដើម្បីបង្កើនប្រសិទ្ធភាពការងារនៅក្នុងវិស័យវិនិយោគ។
- ចាត់តាំងការគ្រប់គ្រង ផ្តល់ការលើកទឹកចិត្ត និងការធានាលើការវិនិយោគ ការដោះស្រាយសំណូមពរនានា និងការធ្វើអធិការកិច្ចចំពោះតំបន់សេដ្ឋកិច្ចពិសេស ហើយចាត់បញ្ជូនមន្ត្រី ដើម្បីចូលរួមប្រចាំការអចិន្ត្រៃយ៍នៅតាមតំបន់តាមការចាំបាច់ និងតាមតម្រូវការ។

[16] យោងតាមមាត្រា ២១ នៃអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

- ធ្វើរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំជូនរាជរដ្ឋាភិបាល ដើម្បីរាជរដ្ឋាភិបាលពិនិត្យ និងលើកឡើងនូវវិធានការចាំបាច់សម្រាប់កែលម្អ និងតម្រង់ទិសការងារវិនិយោគតំបន់។

### ៣.១.១.២. រចនាសម្ព័ន្ធ និងសមាសភាពរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

នៅក្នុងចំណុចនេះ យើងនឹងធ្វើការបង្ហាញអំពីរចនាសម្ព័ន្ធរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ក) និងសមាសភាពរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ខ) ដែលនឹងបកស្រាយខាងក្រោម។

#### ក. រចនាសម្ព័ន្ធរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

បើយើងធ្វើការពិនិត្យទៅលើច្បាប់វិនិយោគចាស់ឆ្នាំ១៩៩៤ ក្រុមប្រឹក្សានេះ មានតែគណៈកម្មាធិការពីរសម្រាប់ជំនួយការគឺ៖ គណៈកម្មាធិការនីតិសម្បទាន និងអភិវឌ្ឍន៍ និងគណៈកម្មាធិការវិនិយោគកម្ពុជា[17]។ រីឯនៅក្នុងមាត្រា២ នៃអនុក្រឹត្យលេខ៦០ អនក្រ.បក ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រុមប្រឹក្សានេះមានរចនាសម្ព័ន្ធដូចតទៅ៖

- គណៈកម្មាធិការនីតិសម្បទាន និងអភិវឌ្ឍន៍ ហៅកាត់ "គ.ជ.នា" ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គលេខាធិការមួយរូប។
- គណៈកម្មាធិការវិនិយោគកម្ពុជា ហៅកាត់ "គ.វ.ក" ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គលេខាធិការមួយរូប។
- គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ហៅកាត់ "គ.ស.ព" ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គលេខាធិការមួយរូប។
- អគ្គលេខាធិការដ្ឋាននៃ "ក.អ.ក" ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គលេខាធិការ "ក.អ.ក"។

នៅក្នុងច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០២១ បានបញ្ញត្តអំពីរចនាសម្ព័ន្ធរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជារួមមានដូចតទៅ[18]៖

- អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬក.អ.ក
- គណៈកម្មាធិការសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា សរសេរជាអក្សរកាត់ថា គ.ស.អ.ក.
- គណៈកម្មាធិការវិនិយោគកម្ពុជា សរសេរជាអក្សរកាត់ថា គ.វ.ក.។

អគ្គលេខាធិការដ្ឋាននៃ ក.អ.ក. គ.ស.អ.ក. និង គ.វ.ក. ត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូបរៀងៗខ្លួន និងអមដោយអគ្គលេខាធិការរងមួយចំនួនសម្រាប់ជាជំនួយការតាមការចាំបាច់។ ហើយ ក.អ.ក.

[17] យោងតាមមាត្រា ៤ នៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៤។

[18] យោងតាមមាត្រា ៦ នៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ៖ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១។

អាចបង្កើតរចនាសម្ព័ន្ធ ឬយន្តការបន្ថែមទៀតដោយអនុក្រឹត្យផ្អែកលើភាពចាំបាច់។ អគ្គលេខាធិការដ្ឋាននៃ "ក.អ.ក" ដែលស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គលេខាធិការ "ក.អ.ក" រួមមាន "ផ្នែកគាំទ្រ" ចំនួន០៤[19]៖

- ផ្នែកនីតិកម្ម និងដោះស្រាយវិវាទ
- ផ្នែកផែនការនីយកម្មយុទ្ធសាស្ត្រ
- ផ្នែកគ្រប់គ្រងមន្ត្រី និងបុគ្គលិក
- ផ្នែកហិរញ្ញវត្ថុ និងរដ្ឋបាល។

### ខ. សមាសភាពរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវបានដឹកនាំដោយនាយករដ្ឋមន្ត្រីមួយរូបដែលជាប្រធាន ព្រមទាំងមានអនុប្រធានមួយរូប ឬច្រើនរូប និងសមាជិកមួយចំនួនទៀតតាមការចាំបាច់។

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានសមាសភាពដូចតទៅ[20]៖

| | |
|---|---|
| ១- សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី | ប្រធាន |
| ២- ឯកឧត្តម ជិន ប៊ុនសាន ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស | អនុប្រធាន |
| ៣- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ឬតំណាង | សមាជិក |
| ៤- រដ្ឋក្រសួងមហាផ្ទៃ ឬតំណាង | សមាជិក |
| ៥- រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឬតំណាង | សមាជិក |
| ៦- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬតំណាង | សមាជិក |
| ៧- រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬតំណាង | សមាជិក |
| ៨- រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ឬតំណាង | សមាជិក |
| ៩- រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឬតំណាង | សមាជិក |
| ១០- រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល ឬតំណាង | សមាជិក |
| ១១- រដ្ឋមន្ត្រីក្រសួងផែនការ ឬតំណាង | សមាជិក |
| ១២- រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល ឬតំណាង | សមាជិក |
| ១៣- រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬតំណាង | សមាជិក |
| ១៤- រដ្ឋមន្ត្រីក្រសួងបរិស្ថាន ឬតំណាង | សមាជិក |

[19] យោងតាមមាត្រា ៧ នៃអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

[20] យោងតាមមាត្រា ១ នៃអនុក្រឹត្យដដែល។

១៥- រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ឬតំណាង សមាជិក

១៦- រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ឬតំណាង សមាជិក

១៧- រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ឬតំណាង សមាជិក

១៨- រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ឬតំណាង សមាជិក

១៩- រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ឬតំណាង សមាជិក

២០- រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬតំណាង សមាជិក

២១- អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា សមាជិក

២២- ប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ឬតំណាង សមាជិក

២៣- អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា លេខាធិការ

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានសមាសភាពដូចខាងក្រោមៈ

- ឯកឧត្តម សុខ ចិន្តាសោភា រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអគ្គលេខាធិការ
- ឯកឧត្តម ជា វុទ្ធី អគ្គលេខាធិការរង
- ឯកឧត្តម នុត អ៊ុនវ័ណ្ណ៉ា អគ្គលេខាធិការរង
- ឯកឧត្តម ហេង សុខណាង អគ្គលេខាធិការរង
- ឯកឧត្តម យុន ហេង ប្រធាននាយកដ្ឋានវិភាគគម្រោង និងការលើកទឹកចិត្ត
- លោក សួន សុផល ប្រធាននាយកដ្ឋានទំនាក់ទំនងសាធារណៈ និងការជំរុញគម្រោងវិនិយោគឯកជន
- ឯកឧត្តម យុន ហេង ប្រធាននាយកដ្ឋានវិភាគគម្រោង និងការលើកទឹកចិត្ត
- លោក សារ សំបូរ ប្រធាននាយកដ្ឋានរដ្ឋបាល
- លោក សេង សុចិន្តា ប្រធាននាយកដ្ឋានវាយតម្លៃខាងបរិស្ថាន
- លោកស្រី អ៊ឹម ពុទ្ធារី ប្រធាននាយកដ្ឋានសម្របសម្រួលកិច្ចការអន្តរក្រសួង
- លោក មឿង វិសុទ្ធ ប្រធានស្តីទីនាយកដ្ឋានត្រួតពិនិត្យនិងតាមដានគម្រោងវិនិយោគ
- លោកបណ្ឌិត សរ សិនិរ៉ា ប្រធាននាយកដ្ឋាននីតិកម្ម និងច្បាប់វិនិយោគ
- លោក ហ៊ុល បុណ្ណារិទ្ធ ប្រធាននាយកដ្ឋានវិភាគយុទ្ធសាស្ត្រនៃការវិនិយោគឯកជន

### ៣.១.១.៣. ប្រភពធនធានរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

យោងតាមមាត្រា៧ នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា បានបញ្ញត្តថា ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានថវិកាដោយឡែករបស់ខ្លួនដែលជាថវិកាជាតិ និងមានមន្ត្រីរាជការក្របខណ្ឌ និងមន្ត្រីជាប់កិច្ចសន្យា អនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាមាន

ខ្ទង់ចំណូល និងចំណាយថវិការបស់ខ្លួន ដែលការគ្រប់គ្រងចំណូល និងចំណាយថវិកានេះ ត្រូវស្ថិតនៅក្រោមច្បាប់ស្តីពីហិរញ្ញវត្ថុ។ បន្ថែមពីនេះ យោងតាមប្រកាសរួមស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានអនុញ្ញាតអោយក្រុមប្រឹក្សានេះ អនុវត្តការប្រមូលចំណូលពីកម្រៃសេវាសេវាសាធារណៈ ដើម្បីជាគុណប្រយោជន៍ថវិកាជាតិ។[21]

### ៣.២. អនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត

នៅក្នុងច្បាប់វិនិយោគថ្មី បានបញ្ញត្តថា៖ ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការផ្តល់សេវាជូនវិនិយោគិន ការពិនិត្យ និងសម្រេចលើការវិនិយោគឯកជន និងការដោះស្រាយវិវាទពាក់ព័ន្ធនឹងគម្រោងវិនិយោគ ត្រូវធ្វើប្រតិភូកម្មអំណាចទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ស្របតាមការសម្រេចរបស់រាជរដ្ឋាភិបាល តាមរយៈការបង្កើតអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត ធ្វើជាសេនាធិការឱ្យរដ្ឋបាលរាជធានី ខេត្ត។ សិទ្ធិអំណាច ទំហំនៃការវិនិយោគ និងការរៀបចំ និងការប្រព្រឹត្តទៅនៃអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក។[22] តាមរយៈនេះ "អនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត" ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ១២០ អនក្រ.បក ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ ដែលមានអក្សរកាត់ "អ.គ.វ.រ.ខ." ជាសេនាធិការឱ្យរដ្ឋបាលរាជធានី-ខេត្ត ដើម្បីជាយន្តការក្នុងការពិនិត្យសម្រេចលើការវិនិយោគឯកជន និងការដោះស្រាយវិវាទពាក់ព័ន្ធនឹងគម្រោងវិនិយោគ។[23] គួរបញ្ជាប់ផងដែរ នៅក្នុងអនុក្រឹត្យថ្មីនេះ បានផ្តល់សិទ្ធិដល់អនុគណៈកម្មាធិការវិនិយោគរាជធានី-ខេត្ត អាចអនុម័តគម្រោងវិនិយោគដែលមានទំហំទឹកប្រាក់ក្រោម ៥លានដុល្លារ ខណៈដែលកាលពីមុនអនុគណៈកម្មាធិការវិនិយោគរាជធានី-ខេត្ត មានសិទ្ធិអនុម័តគម្រោងមានទំហំទុនវិនិយោគត្រឹម ២លានដុល្លារចុះក្រោមប៉ុណ្ណោះ (អនុក្រឹត្យលេខ ៣៣ អនក្រ.បក ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការបង្កើតអនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង)។

#### ៣.២.១. ការរៀបចំ និងប្រព្រឹត្តទៅរបស់អនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត

យោងតាមអនុក្រឹត្យលេខ១២០ ខាងលើ បានបញ្ញត្តអំពីសមាសភាពរបស់អនុគណៈកម្មាធិការវិនិយោគរាជធានី-ខេត្ត (៣.២.១.១) ព្រមទាំងតួនាទី និងភារកិច្ចរបស់អនុគណៈកម្មាធិការនេះផងដែរ(៣.២.១.២)។

[21] យោងតាមមាត្រា ១ នៃប្រកាសរួមលេខ ៩៩១ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

[22] យោងតាមមាត្រា ៩ នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ៖ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១។

[23] យោងតាមមាត្រា ១ នៃអនុក្រឹត្យលេខ ១២០ អនក្រ.បក ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត។

### ៣.២.១.១. សមាសភាពរបស់អនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត

អនុគណៈកម្មាធិការវិនិយោគរាជធានី-ខេត្ត ដែលមានសមត្ថកិច្ចទៅលើគម្រោងវិនិយោគសមមូលនឹង ៥លានដុល្លារអាមេរិកចុះនេះ មានសមាសភាពដូចខាងក្រោម[24]៖

| | |
|---|---|
| ១- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត | ប្រធាន |
| ២- អភិបាលរងនៃគណៈអភិបាលរាជធានី ខេត្ត ១រូប | អនុប្រធាន |
| ៣- នាយករដ្ឋបាលនៃរដ្ឋបាលរាជធានី ខេត្ត | សមាជិក |
| ៤- ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥- ប្រធានមន្ទីរពាណិជ្ជកម្ម | សមាជិក |
| ៦- ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិក |
| ៧- ប្រធានមន្ទីររ៉ែ និងថាមពល | សមាជិក |
| ៨- ប្រធានមន្ទីរសុខាភិបាល | សមាជិក |
| ៩- ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១០- ប្រធានមន្ទីរបរិស្ថាន | សមាជិក |
| ១១- ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី | សមាជិក |
| ១២- ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៣- ប្រធានមន្ទីរផែនការ | សមាជិក |
| ១៤- ប្រធានមន្ទីរធនធានទឹក និងឧតុនិយម | សមាជិក |
| ១៥- ប្រធានមន្ទីរទេសចរណ៍ | សមាជិក |
| ១៦- ប្រធានមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ១៧- ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៨- តំណាងសាខាគយ និងរដ្ឋាកររាជធានី ខេត្ត | សមាជិក |
| ១៩- តំណាងទីចាត់ការពន្ធដាររាជធានី ឬតំណាងសាខាពន្ធដារខេត្ត | សមាជិក |
| ២០- នាយកទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត | លេខាធិការ |

សមាសភាពជាក់ស្តែង ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋបាលរាជធានី ខេត្ត។ តាមរយៈការកំណត់ខាងលើនេះ សមាសភាពនៃអនុគណៈកម្មាធិការវិនិយោគរាជធានី-ខេត្ត (ទាំង២៥រាជធានី-ខេត្ត) រួម

[24] យោងតាមមាត្រា ២ នៃអនុក្រឹត្យនៃអនុក្រឹត្យលេខ ១២០ អនក្រ.បក ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត។

មាន៖ អភិបាលនៃគណៈអភិបាលរាជធានី-ខេត្តទាំងអស់ គឺជាប្រធាន និងអភិបាលរងនៃគណៈអភិបាលរាជធានី ខេត្ត ចំនួន១រូប គឺជាអនុប្រធាន និងប្រធានមន្ទីរពាក់ព័ន្ធមួយចំនួនជាសមាជិក។

### ៣.២.១.២. តួនាទី និងភារកិច្ចរបស់អនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត

យោងតាមអនុក្រឹត្យខាងលើ អនុគណៈកម្មាធិការវិនិយោគរាជធានី-ខេត្ត ឬ អ.គ.វ.រ.ខ. មានតួនាទី និងភារកិច្ចពិនិត្យ និងសម្រេចលើការចុះបញ្ជី ការផ្តល់ការលើកទឹកចិត្ត ការធានាការទិញ ការលក់ ការរួមបញ្ចូលគ្នា ការលុប និងការដោះស្រាយវិវាទនានាពាក់ព័ន្ធនឹងគម្រោងវិនិយោគឯកជន ដែលមានទុនវិនិយោគសមមូលនឹង៥លានដុល្លារអាមេរិកចុះ នៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលរាជធានី ខេត្តសាមីនីមួយៗ ស្របតាមនីតិវិធីដែលកំណត់ដោយអនុក្រឹត្យដោយឡែក និងស្របតាមច្បាប់វិនិយោគនៃកម្ពុជា។[25]

នៅក្នុងកិច្ចដំណើរការការងាររបស់អនុគណៈកម្មាធិការវិនិយោគរាជធានី-ខេត្ត៖

- អ.គ.វ.រ.ខ. ត្រូវប្រើប្រាស់អង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ដែលជាច្រកសម្រាប់ការទទួល និងផ្តល់សេវារដ្ឋបាលជូនវិនិយោគិនក្នុងការពិនិត្យ និងសម្រេចលើការវិនិយោគ និងការដោះស្រាយវិវាទវិនិយោគដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលរាជធានី ខេត្តសាមី។
- សមាសភាពនៃអនុគណៈកម្មាធិការវិនិយោគរាជធានី-ខេត្ត មានភារកិច្ចចូលរួមក្នុងកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធាន ករណីដែលប្រធានអវត្តមាន។ អ.គ.វ.រ.ខ. អាចដំណើរការប្រជុំក្រោមអធិបតីភាពរបស់អនុប្រធាន តាមរយៈការប្រគល់សិទ្ធិរបស់ប្រធានក្នុងករណីដែលប្រធានអវត្តមាន។
- អ.គ.វ.រ.ខ. ក៏អាចអញ្ជើញតំណាង ឬមន្ត្រីជំនាញពីក្រសួង ស្ថាប័ន មន្ទីរ អង្គភាពពាក់ព័ន្ធ អភិបាលរងនៃគណៈអភិបាលរាជធានី ខេត្ត និងតំណាងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ពាក់ព័ន្ធ ដែលមិនមែនជាសមាជិកនៃអនុគណៈកម្មាធិការនេះ ចូលរួមក្នុងកិច្ចប្រជុំ តាមការចាំបាច់ផងដែរ។
- អ.គ.វ.រ.ខ. មានសិទ្ធិប្រើប្រាស់ត្រារបស់រដ្ឋបាលរាជធានី ខេត្តសាមីនៅក្នុងដំណើរការការងាររបស់ខ្លួន។
- ទីចាត់ការផែនការ និងវិនិយោគនៃរដ្ឋបាលរាជធានី ខេត្ត ត្រូវបំពេញតួនាទីជាលេខាធិការដ្ឋានសម្រាប់ដោះស្រាយកិច្ចការប្រចាំថ្ងៃរបស់ អ.គ.វ.រ.ខ.។
- អ.គ.វ.រ.ខ. មានភារកិច្ចក្នុងការធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ផ្តល់ជូនដល់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា ដើម្បីធ្វើរបាយការណ៍ជូនរាជរដ្ឋាភិលើស

[25] យោងតាមមាត្រា ៣ នៃអនុក្រឹត្យលេខ ១២០ អនក្រ.បក ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត។

ពីនេះ អ.គ.វ.រ.ខ. ចាំបាច់ត្រូវធ្វើសេចក្តីរាយការណ៍ជាទៀងទាត់ជូនក្រុមប្រឹក្សារាជធានី ខេត្ត របស់ខ្លួនក្នុងការអនុវត្តការងារវិនិយោគ។

ចំពោះការធ្វើប្រតិភូកម្មសិទ្ធិអំណាចរបស់គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ជូនមន្ទីរ អង្គភាពខ្សែបណ្តោយរបស់ក្រសួង ស្ថាប័ននៅថ្នាក់រាជធានី ខេត្ត ឬរដ្ឋបាលរាជធានី ខេត្ត ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដើម្បីសម្រេចលើកិច្ចការពាក់ព័ន្ធដល់ការចេញលិខិតអនុញ្ញាត អាជ្ញាប័ណ្ណនានា ក្នុងការចុះបញ្ជីគម្រោងវិនិយោគ ការផ្តល់ការលើកទឹកចិត្ត ការធានា ការទិញ ការលក់ ការរួមបញ្ចូលគ្នា ការលុបគម្រោង និងការដោះស្រាយវិវាទវិនិយោគដែលមានទុនវិនិយោគសមមូលនឹង ៥លានដុល្លារអាមេរិកចុះ។

អ.គ.វ.រ.ខ. ត្រូវចាប់ផ្តើមអនុវត្តការងាររបស់ខ្លួន បន្ទាប់ពីក្រសួង ស្ថាប័នពាក់ព័ន្ធបានធ្វើប្រតិភូកម្មសិទ្ធិអំណាចជូនគ្រប់មន្ទីរ អង្គភាពខ្សែបណ្តោយរបស់ខ្លួន ដែលការធ្វើប្រតិភូកម្មសិទ្ធិអំណាចនេះត្រូវធ្វើក្នុងរយៈពេលមិនលើសពី ៣០ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីរដ្ឋបាលរាជធានី ខេត្ត ចេញសេចក្តីសម្រេចកំណត់ពីសមាសភាពជាក់ស្តែងនៃ អ.គ.វ.រ.ខ.។ សមត្ថកិច្ចក្នុងការពិនិត្យសម្រេចចុះបញ្ជីគម្រោងវិនិយោគ ការផ្តល់ការលើកទឹកចិត្ត និងការធានាលើការវិនិយោគរបស់ អ.គ.វ.រ.ខ. ត្រូវបានកម្រិតត្រឹមគម្រោងវិនិយោគឯកជន ដែលមានទុនវិនិយោគសមមូលនឹង៥លានដុល្លារអាមេរិកចុះ ដោយគម្រោងវិនិយោគដូចខាងក្រោម ត្រូវឆ្លងកាត់តាមយន្តការរបស់ ក.អ.ក. វិញ៖

១- គម្រោងវិនិយោគដែលមានទុនវិនិយោគចាប់ពី ៥លានដុល្លារអាមេរិកឡើងទៅ។

២- គម្រោងវិនិយោគដែលមានទីតាំងស្ថិតក្នុងដែនសមត្ថកិច្ចរបស់រាជធានី ខេត្ត ចាប់ពី ២ឡើងទៅ។

៣- គម្រោងវិនិយោគដែលស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស។

៤- គម្រោងវិនិយោគស្ថិតនៅក្រោមច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋ និងឯកជន។

៥- គម្រោងវិនិយោគដែលមានផលវិបាកខាងនយោបាយ ឬអាចបង្កគ្រោះថ្នាក់ដល់បរិស្ថាន ឬប៉ះពាល់ដល់សន្តិសុខជាតិ ឬប៉ះពាល់ដល់ការងារអភិរក្ស និងការពារជីវៈចម្រុះ ធនធានធម្មជាតិ និងសម្បត្តិវប្បធម៌ជាតិ។

៦- គម្រោងវិនិយោគពាក់ព័ន្ធនឹងការរុករក និងការធ្វើអាជីវកម្មរ៉ែ និងធនធានធម្មជាតិ។

៧- គម្រោងវិនិយោគដែលពាក់ព័ន្ធនឹងវិស័យថាមពល

៨- គម្រោងវិនិយោគដែលស្ថិតនៅក្នុងបញ្ជីអវិជ្ជមានដែលនៅជាធរមាន[26]។

[26] យោងតាមមាត្រា ១០ នៃអនុក្រឹត្យលេខ ១២០ អនក្រ.បក ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត

# ជំពូកទី២
# ការលានុវត្តភាពនៃការវិនិយោគនៅ
# ប្រទេសកម្ពុជា និងសំណើវិនិយោគ

# ជំពូកទី២

# កាលានុវត្តភាពនៃការវិនិយោគនៅប្រទេសកម្ពុជា និងសំណើវិនិយោគ

សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ទទួលបានលទ្ធផលដ៏គួរឱ្យជាទីមោទនៈដែលឆ្លុះបញ្ចាំងចេញពីកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស និងការកាត់បន្ថយភាពក្រីក្រគួរឱ្យកត់សម្គាល់។ មួយផ្នែកនៃការជោគជ័យនេះ គឺជាលទ្ធផលនៃការបើកចំហររបស់ប្រទេសកម្ពុជាឆ្ពោះទៅកាន់វិនិយោគិនបរទេស។ ការវិនិយោគក្នុងស្រុកក៏មានការកើនឡើងផងដែរ បើទោះបីជាមានអត្រាទាបជាងប្រទេសដទៃទៀតនៅក្នុងតំបន់ និងប្រទេសផ្សេងទៀតដែលមានកម្រិតអភិវឌ្ឍន៍ដូចគ្នាក៏ដោយ។ តាមរយៈគោលនយោបាយ និងយុទ្ធសាស្ត្រក្នុងការទាក់ទាញការវិនិយោគរបស់រាជរដ្ឋាភិបាល ដើម្បីសម្រួលដល់វិស័យវិនិយោគឲ្យមានភាពប្រសើរឡើងវិញ បានផ្តល់ឱកាសបន្ថែមដល់វិនិយោគិនទាំងក្នុងស្រុក និងវិនិយោគិនបរទេសក្នុងការបង្កើតសកម្មភាពវិនិយោគកាន់តែច្រើនជាមុន ជាពិសេស ការទទួលបានការធានា និងការលើកទឹកចិត្តវិនិយោគតាមរយៈសំណើវិនិយោគទៅស្ថាប័នមានសមត្ថកិច្ច ដែលចំណុចទាំងនេះយើងនឹងធ្វើការបកស្រាយក្នុងផ្នែកទី១៖ កាលានុវត្តភាពនៃការវិនិយោគនៅប្រទេសកម្ពុជា និងផ្នែកទី២៖ សំណើវិនិយោគ។

## ផ្នែកទី១៖ កាលានុវត្តភាពនៃការវិនិយោគនៅប្រទេសកម្ពុជា

ផ្អែកទៅលើកំណើនសេដ្ឋកិច្ចរឹងមាំជារៀងរាល់ឆ្នាំ បរិយាកាសវិនិយោគល្អ ទីតាំងវិនិយោគអំណោយផលល្អ នៅចំចំណុចកណ្តាលបេះដូងនៃបណ្តាប្រទេសអាស៊ាន កម្លាំងពលកម្មវ័យក្មេងច្រើន ពិសេសកត្តាសន្តិភាព និងស្ថិរភាពនយោបាយកម្ពុជា រួមជាមួយនឹងការលើកទឹកចិត្តមួយចំនួន បានប្រែក្លាយប្រទេសកម្ពុជាពោរពេញទៅដោយឱកាសមាសសម្រាប់ការទាក់ទាញវិនិយោគទុនមកកម្ពុជាជាច្រើន។ ហើយដើម្បីជំរុញការវិនិយោគ និងធ្វើឲ្យកំណើនសេដ្ឋកិច្ចជាតិកាន់តែមានភាពរឹងមាំ រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងខិតខំជំរុញនូវវិស័យសំខាន់ៗមួយចំនួនដូចជា វិស័យកសិកម្ម វិស័យឧស្សាហកម្ម វិស័យបច្ចេកវិទ្យា វិស័យអប់រំ និងវិស័យបដិសណ្ឋារកិច្ច ព្រមទាំងរៀបចំក្រុងព្រះសីហនុឲ្យក្លាយទៅជាតំបន់ពហុវិស័យសេដ្ឋកិច្ចគំរូដើម្បីទាក់ទាញ និងសម្រួលដល់ការវិនិយោគគ្រប់កម្រិត។ នៅក្នុងផ្នែកទី១នេះ យើងនឹងធ្វើការសិក្សាទៅលើគោលនយោបាយជម្រុញសកម្មភាពវិនិយោគនៅប្រទេសកម្ពុជា (១.១) ព្រមទាំងយុត្តិសាស្ត្រជំរុញក្នុងវិស័យវិនិយោគនៅប្រទេសកម្ពុជា(១.២) និងអត្ថប្រយោជន៍នៃការវិនិយោគនៅប្រទេសកម្ពុជា (១.៣)។

### ១.១. គោលនយោបាយជម្រុញសកម្មភាពវិនិយោគនៅប្រទេសកម្ពុជា

រាជរដ្ឋាភិបាលបានបន្តកិច្ចខិតខំប្រឹងប្រែងក្នុងការថែរក្សា និងលើកកម្ពស់បរិយាកាសវិនិយោគប្រកបដោយភាពអំណោយផល ដោយដាក់ចេញនូវគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចប្រកបដោយការប្រុងប្រយ័ត្ន

ដើម្បីរក្សាអត្រាអតិផរណាគ្រប់គ្រងស្ថេរភាពអត្រាប្តូរប្រាក់ ជាពិសេស កម្មវិធីគោលនយោបាយសម្រាប់ការអភិវឌ្ឍ និងការទាក់ទាញការវិនិយោគ និងគោលនយោបាយពាក់ព័ន្ធដទៃផ្សេងទៀតដូចជាកំណែទម្រង់ពន្ធដារគ្រប់ជ្រុងជ្រោយ។ គោលនយោបាយជម្រុញសកម្មភាពវិនិយោគដែលនឹងលើកឡើងរួមតាមរយៈកម្មវិធីគោលនយោបាយសម្រាប់ការអភិវឌ្ឍ និងការទាក់ទាញការវិនិយោគរួមមាន អភិបាលកិច្ចរដ្ឋបាលសាធារណៈប្រកបដោយប្រសិទ្ធភាព (១.១.១) និងការកំណត់តំបន់សេដ្ឋកិច្ចពិសេស (១.១.២)។

### ១.១.១. អភិបាលកិច្ចរដ្ឋបាលសាធារណៈប្រកបដោយប្រសិទ្ធភាព

អភិបាលកិច្ចត្រូវបានគេឲ្យនិយមន័យផ្សេងៗគ្នាជាច្រើន ដែលវាអាស្រ័យនឹងស្ថានភាពជាក់ស្តែង។ ជាសាមញ្ញ **អភិបាលកិច្ច** មានន័យថា "គឺជាវិធីសាស្ត្រដែលរដ្ឋ ស្ថាប័នអង្គភាព ប្រើប្រាស់ក្នុងការគ្រប់គ្រងសេដ្ឋកិច្ច សង្គមកិច្ច និងសន្តិសុខ ដើម្បីបម្រើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ"។ ស្រដៀងគ្នានេះដែរ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP 1997) បានឲ្យនិយមន័យថា "អភិបាលកិច្ច ជាការប្រើប្រាស់អំណាចខាងនយោបាយ សេដ្ឋកិច្ច និងរដ្ឋបាល ដើម្បីគ្រប់គ្រងកិច្ចការរបស់ប្រទេស"។

រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានបង្កើតនូវគោលនយោបាយអភិបាលកិច្ចល្អ ដើម្បីចូលរួមចំណែកក្នុងការលើកកម្ពស់ ការចែករំលែក និងការធានាអោយមាននូវតម្លាភាព ជូនដល់អ្នកវិនិយោគទាំងអស់ដែលបានចូលមកវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ អភិបាលកិច្ចនៅក្នុងរដ្ឋបាលសាធារណៈគឺជាស្នូលនៃយុទ្ធសាស្ត្រចតុកោណ ដោយបានផ្តល់សារៈសំខាន់លើការជំរុញការអនុវត្តកំណែទម្រង់រដ្ឋបាលសាធារណៈ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ព្រមជាមួយនឹងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ដើម្បីធានាភាពយុត្តិធម៌ និងតម្លាភាពជូនដល់ប្រជាពលរដ្ឋ ជាពិសេសចំពោះអ្នកវិនិយោគទុនដែលមកអនុវត្តសកម្មភាពវិនិយោគនៅកម្ពុជា។ រាជរដ្ឋាភិបាលបានបញ្ញត្តិ និងកំណត់នីតិវិធីមួយចំនួននៅក្នុងគណៈកម្មាធិការវិនិយោគ ក្នុងការជម្រុញអោយបានឆាប់រហ័ស និងកាត់បន្ថយការិយាល័យអធិបតេយ្យក្នុងដំណើរការចុះបញ្ជី និងផ្តល់ការអនុញ្ញាតដល់រាល់វិនិយោគិនណា ដែលស្វែងរកអភ័យឯកសិទ្ធិ ព្រមទាំងការធានា និងការលើកទឹកចិត្តដូចមានចែងនៅក្នុងច្បាប់វិនិយោគ និងអនុក្រឹត្យមួយចំនួនដែលពាក់ព័ន្ធផ្សេងទៀត។

ជារួមការអនុវត្តអភិបាលកិច្ចល្អនឹងធានាអោយមានការកាត់បន្ថយអំពើពុករលួយអោយស្ថិតនៅក្នុងកម្រិតទាបហើយអភិបាលកិច្ចប្រកបដោយប្រសិទ្ធភាពនឹងធ្វើឱ្យអ្នកវិនិយោគទុនមានជំនឿទុកចិត្ត ចង់មកវិនិយោគទុន ឬបង្កើតសកម្មភាពវិនិយោគនៅក្នុងព្រះរាជណាចក្រកម្ពុជា។

### ១.១.២. ការកំណត់តំបន់សេដ្ឋកិច្ចពិសេស

រដ្ឋាភិបាលកម្ពុជាបាននឹងកំពុងធ្វើឱ្យមានភាពប្រសើរឡើងនូវសេវាកម្ម ដើម្បីសម្របសម្រួលដល់ការ

វិនិយោគរបស់ខ្លួន។ នៅក្នុងឆ្នាំ២០០៥ រដ្ឋាភិបាលបានបង្កើតក្រុមប្រឹក្សាភិបាលតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា (Cambodia Special Economic Zone Board = CSEZB) ក្រោមការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ក្នុងគោលបំណងលើកកម្ពស់គម្រោងវិនិយោគនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា (Special Economic Zones = SEZs)។ រដ្ឋបាលរបស់តំបន់សេដ្ឋកិច្ចពិសេស ក៏ត្រូវបានបង្កើតឡើងដើម្បីផ្តល់សិទ្ធិដល់តំបន់សេដ្ឋកិច្ចពិសេស ហើយត្រូវបានគេរំពឹងថានឹងផ្តល់សេវាកម្មច្រកចេញចូលតែមួយទៅដល់វិនិយោគិនក្នុងតំបន់នេះ ចាប់ពីដំណើរការចុះឈ្មោះគម្រោងវិនិយោគ រហូតដល់ការអនុម័តទៅលើការនាំចេញ-នាំចូល។

តំបន់សេដ្ឋកិច្ចពិសេស គឺជាតំបន់ដែលមានទីតាំងយុទ្ធសាស្ត្រត្រៀមរួចជាស្រេចសម្រាប់អាជីវកម្ម និងការវិនិយោគ ដែលដំណើរការជាមួយនឹងភាពងាយស្រួលនៃហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន (តំបន់សេដ្ឋកិច្ចពិសេសមានទីតាំងយុទ្ធសាស្ត្រស្ថិតនៅជិតហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ទៅកាន់ព្រលានយន្តហោះ ឬកំពង់ផែ) ហើយជាកន្លែងដែលមានស្ថិរភាព និងសុវត្ថិភាពបំផុតសម្រាប់និយោគិនបរទេស ព្រោះវាមានលក្ខណៈរឹងមាំ និងស្ថិតស្ថេរ ការវិនិយោគមានសុវត្ថិភាព និងហានិភ័យទាបជាងកិច្ចប្រតិបត្តិការក្រៅតំបន់សេដ្ឋកិច្ច។ ជាទូទៅតំបន់សេដ្ឋកិច្ចពិសេសអាចជួយសន្សំសំចៃសម្រាប់អ្នកវិនិយោគបរទេសពីការវិនិយោគបន្ថែមលើការអភិវឌ្ឍដីធ្លីនិងហេដ្ឋារចនាសម្ព័ន្ធ សន្តិសុខ និងសេវាកម្មជួសជុល។ ជាមួយអាជ្ញាប័ណ្ណគម្រោងវិនិយោគដែលមានគុណភាព អ្នកជួលដីក្នុងតំបន់សេដ្ឋកិច្ចពិសេសនឹងត្រូវបានលើកលែងពន្ធលើផលិតផលសម្ភារបរិក្ខារដែលអាស្រ័យលើការនាំចេញ ឬជារោងចក្រក្នុងស្រុក ហើយនៅមានការលើកលែងពន្ធលើប្រាក់ចំណេញថែមទៀតផង។

ការបណ្តាក់ទុកវិនិយោគពីបរទេសនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសនេះ ត្រូវបានរាជរដ្ឋាភិបាលលើកទឹកចិត្តខ្ពស់។ វាល្អត្រង់ថាគម្រោងវិនិយោគដែលបានចុះបញ្ជីជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIP) នឹងទទួលបានអត្ថប្រយោជន៍ជាច្រើនពីការលើកទឹកចិត្តសម្រាប់ការវិនិយោគនៅកម្ពុជា លើសពីនេះនៅតាមតំបន់សេដ្ឋកិច្ចពិសេសនីមួយៗ មានការផ្តល់សេវាកម្មជាច្រើនដូចជាសេវារដ្ឋបាល និងបែបបទនៃការនាំចេញនិងចូលពីអាជ្ញាធរពាក់ព័ន្ធជាដើម (សេវាកម្មច្រកចេញចូលតែមួយនៅនឹងកន្លែង) ព្រមទាំងទទួលបានការយកចិត្តទុកដាក់ទៅលើការផ្គត់ផ្គង់ប្រព័ន្ធទឹក អគ្គិសនី និងអ៊ីនធឺណិតដើម្បីបម្រើដល់ផលិតកម្មជាមួយតម្លៃសមរម្យ។ នេះជាមូលហេតុចម្បង ដែលទាក់ទាញក្រុមហ៊ុនជាច្រើនឲ្យមកបោះទុនវិនិយោគក្នុងតំបន់សេដ្ឋកិច្ចពិសេសកាន់តែច្រើន និងបង្កើតការងារដល់ប្រជាពលរដ្ឋកម្ពុជា។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ទិន្នផលនាំចេញនៃតំបន់សេដ្ឋកិច្ចពិសេសបានកើនឡើងយ៉ាងខ្លាំង។

ជាទូទៅ "តំបន់សេដ្ឋកិច្ចពិសេស" មានទីតាំងស្ថិតនៅតំបន់សមស្របបំផុត ដើម្បីជួយឱ្យអាជីវកម្មរបស់អ្នករីកចម្រើន និងជោគជ័យ (សូមពិគ្រោះនៅក្នុងឧបសម្ព័ន្ធទី២៖ រូបភាពបង្ហាញអំពីទិន្នផលនាំចេញនៃតំបន់សេដ្ឋកិច្ចពិសេស)។ យោងតាមក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា តំបន់សេដ្ឋកិច្ចពិសេសដែលកំពុងដំណើរការចំនួន ២៤ ដែលគ្របដណ្តប់គម្រោងវិនិយោគចំនួន៥៦១ និងការងារជាង១៦០,០០០ (សូមពិគ្រោះនៅក្នុងឧបសម្ព័ន្ធទី២៖ រូបភាពបង្ហាញអំពីផែនទីនៃតំបន់សេដ្ឋកិច្ចពិសេសនៅក្នុងប្រទេសកម្ពុជា)។ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIP) ក្នុងតំបន់សេដ្ឋកិច្ចពិសេសទទួលបានការលើកទឹកចិត្តហិរញ្ញវត្ថុដូចគ្នានឹងគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIP) នៅក្រៅតំបន់សេដ្ឋកិច្ចពិសេស គ្រាន់តែនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសទទួលបានផលប្រយោជន៍ពីយន្តការ "សេវានៅនឹងកន្លែង" ដែលជំរុញដំណើរការនាំចេញ-នាំចូល។

## ១.២. យុត្តិសាស្ត្រជំរុញក្នុងវិស័យវិនិយោគនៅប្រទេសកម្ពុជា

ប្រទេសកម្ពុជាបានដាក់គោលដៅនៅក្នុងយុទ្ធសាស្ត្រជាតិរបស់ខ្លួន ក្នុងការក្លាយជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ២០៣០ និងទទួលបានឋានៈជាប្រទេសមានប្រាក់ចំណូលខ្ពស់ត្រឹមឆ្នាំ២០៥០។ ដើម្បីសម្រេចបាននូវគោលដៅនេះ និងផែនការដទៃទៀត ប្រទេសកម្ពុជាបានបន្តរក្សាបើកចំហរសេដ្ឋកិច្ចរបស់ខ្លួន ដោយផ្តល់ឱកាសវិនិយោគដែលមានសក្តានុពលទៅដល់វិនិយោគិនបរទេស។ គោលបំណង គឺដើម្បីបង្កើនពាណិជ្ជកម្មអន្តរជាតិ ការផ្លាស់ប្តូរទំនិញ និងសេវាកម្មជាមួយទីផ្សារនៅក្នុងតំបន់ និងពិភពលោកដទៃផ្សេងទៀត។ ការអនុវត្តគោលការណ៍សេដ្ឋកិច្ចទីផ្សារសេរី និងស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ក៏ផ្តល់បរិយាកាសវិនិយោគដែលមានភាពទាក់ទាញសម្រាប់ប្រទេសកម្ពុជាផងដែរ។

ដូចមានចែងតាំងពីដំណាក់កាលទី១ នៃយុទ្ធសាស្ត្រចតុកោណរបស់ខ្លួន រាជរដ្ឋាភិបាលបានចាត់ទុកវិស័យឯកជនជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ច។ រដ្ឋាភិបាលបន្តផ្តោតលើការទាក់ទាញវិនិយោគិនមកលើវិស័យឯកជន តាមរយៈការពង្រីកទីផ្សារអន្តរជាតិ ការផ្តល់ការលើកលែងពន្ធ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការពង្រឹងក្របខ័ណ្ឌគតិយុត្តិ ដើម្បីជួយសម្រួលដល់ការវិនិយោគរបស់ឯកជននៅក្នុងវិស័យអាទិភាពដែលមានការប្រកួតប្រជែងប្រកបដោយយុត្តិធម៌ភាព តម្លាភាព និងគណនេយ្យភាព។ ផែនការធ្វើពិពិធកម្មសេដ្ឋកិច្ច ក៏ត្រូវបានដាក់ចេញនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ផងដែរ ជាក់ស្តែងតាមរយៈការខិតខំប្រឹងប្រែងក្នុងការកាត់បន្ថយចំណាយថ្លៃដើម និងពេលវេលាក្នុងការបង្កើតអាជីវកម្ម ក៏ដូចជាលើកកម្ពស់បរិយាកាសពាណិជ្ជកម្ម និងការវិនិយោគឲ្យកាន់តែប្រសើរ។

រាជរដ្ឋាភិបាល ត្រូវធ្វើយ៉ាងណាអោយអ្នកវិនិយោគមានភាពជឿជាក់ និងមានទំនុកចិត្តក្នុងការសម្រេចចិត្តមកវិនិយោគ នៅក្នុងការបង្កើតសកម្មភាពវិនិយោគរបស់ខ្លួននៅក្នុងប្រទេសកម្ពុជា។ តាមន័យ

នេះ រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់យ៉ាងខ្លាំង ក្នុងការជំរុញការលើកទឹកចិត្ត (Generous Incentives) និងធ្វើនិយ័តកម្ម (Regularization) លើការវិនិយោគទាំងឡាយពីសំណាក់នីតិបុគ្គលសញ្ជាតិខ្មែរ និងនីតិបុគ្គលសញ្ជាតិបរទេស ដែលធ្វើឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ការវិនិយោគនៅប្រទេសកម្ពុជា ត្រូវបានការទទួលស្វាគមន៍លើគ្រប់វិស័យទាំងអស់ លើកលែងតែសកម្មភាពវិនិយោគមួយចំនួន ដែលស្ថិតនៅក្នុងបញ្ជីអវិជ្ជមាន (សកម្មភាពវិនិយោគដែលត្រូវបានហាមឃាត់) ដូចមានចែងនៅក្នុងឧបសម្ព័ន្ធទី១ ផ្នែកទី១ នៃអនុក្រឹត្យ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។ ទន្ទឹមនឹងនេះដើម្បីទាក់ទាញការវិនិយោគ ការលើកទឹកចិត្តសម្រាប់ការវិនិយោគក្នុងច្បាប់វិនិយោគថ្មី (១.២.១.) និងការធានា និងការការពារសម្រាប់វិនិយោគិន (១.២.២.) គឺជាយុត្តិសាស្ត្រជំរុញនៅក្នុងការវិនិយោគនៅកម្ពុជា ដែលយើងនឹងយកមកបកស្រាយក្នុងចំណុចខាងក្រោមនេះ។

### ១.២.១. ការលើកទឹកចិត្តសម្រាប់ការវិនិយោគក្នុងច្បាប់វិនិយោគថ្មី

ចំពោះការលើកទឹកចិត្តសម្រាប់ការវិនិយោគ គឺជា ″ការលើកទឹកចិត្តផ្នែកពន្ធ″ ដែលជាយុទ្ធសាស្ត្រដ៏សំខាន់មួយក្នុងការទាក់ទាញការវិនិយោគក្នុងប្រទេសកម្ពុជា លើសពីនេះវាជាលក្ខណៈពិសេសនៃច្បាប់វិនិយោគផងដែរ (ការលើកទឹកចិត្តនេះ មានភាពល្អប្រសើរជាង បើប្រៀបធៀបនឹងច្បាប់វិនិយោគចាស់ៗ)។ ការវិនិយោគនៅក្នុងប្រទេសកម្ពុជា វិនិយោគិននឹងទទួលបានការលើកទឹកចិត្តមួយចំនួនដែលគួរឲ្យទាក់ទាញបំផុតនៅក្នុងតំបន់។ ទោះជាយ៉ាងណា មានតែគម្រោងក្នុងទំហំមួយចំនួនដែលអាចធ្វើការស្នើសុំការលើកទឹកចិត្តសម្រាប់គម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIP) ពោលគឺទៅលើវិស័យ និងសកម្មភាព ដែលទទួលបានការលើកទឹកចិត្ត (១.២.១.១) តាមរយៈយន្តការការលើកទឹកចិត្តផ្នែកពន្ធដែលមានបញ្ញត្តនៅក្នុងច្បាប់វិនិយោគថ្មី រួមមាន៖ ការលើកទឹកចិត្តជាមូលដ្ឋាន (១.២.១.២) ការលើកទឹកចិត្តបន្ថែម (១.២.១.៣) និងការលើកទឹកចិត្តពិសេស (១.២.១.៤)។

#### ១.២.១.១. វិស័យ និងសកម្មភាពវិនិយោគដែលទទួលបានការលើកទឹកចិត្ត

នៅក្នុងច្បាប់ស្តីពីការវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០២១ ត្រង់មាត្រា ២៤ បានបញ្ញត្តអំពីវិស័យ និងសកម្មភាពវិនិយោគចំនួន ១៩ ដែលមានសិទ្ធិទទួលបានការលើកទឹកចិត្តវិនិយោគ រួមមាន៖

១- ឧស្សាហកម្មដែលមានបច្ចេកវិទ្យាខ្ពស់ (High Tech) ប្រកបដោយនវានុវត្តន៍ (Innovative) និងការស្រាវជ្រាវ និងអភិវឌ្ឍ (R&D)

២- ឧស្សាហកម្ម ឬកម្មន្តសាលថ្មីៗ ផ្តល់តម្លៃបន្ថែមខ្ពស់ មាននវានុវត្តន៍ និងភាពប្រកួតប្រជែងខ្ពស់

៣- ឧស្សាហកម្មបម្រើឱ្យខ្សែច្រវាក់ផលិតកម្មតំបន់ និងសកលលោក

៤- ឧស្សាហកម្មគាំទ្រពាក់ព័ន្ធនឹងវិស័យកសិកម្ម ទេសចរណ៍ កម្មន្តសាល ឧស្សាហកម្មបម្រើឱ្យខ្សែច្រវាក់ផលិតកម្មតំបន់ និងសកលលោក និងឧស្សាហកម្មតភ្ជាប់បណ្ដាញផ្គត់ផ្គង់

៥- ឧស្សាហកម្មគ្រឿងអគ្គិសនី និងអេឡិចត្រូនិក

៦- ឧស្សាហកម្មគ្រឿងបន្លាស់ បង្គុំ និងតម្លើង

៧- ឧស្សាហកម្មមេកានិក និងគ្រឿងម៉ាស៊ីន

៨- កសិកម្ម កសិឧស្សាហកម្ម ឧស្សាហកម្មកែច្នៃផលិតផលកសិកម្ម និងឧស្សាហកម្មកែច្នៃចំណីអាហារដែលបម្រើទីផ្សារក្នុងស្រុក ឬការនាំចេញ

៩- សហគ្រាសធុនតូច និងមធ្យមក្នុងវិស័យអាទិភាព និងការអភិវឌ្ឍបណ្ដុំសហគ្រាសធុនតូច និងមធ្យម សួនឧស្សាហកម្ម និងសួនវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

១០- ឧស្សាហកម្មទេសចរណ៍ និងសកម្មភាពពាក់ព័ន្ធនឹងទេសចរណ៍

១១- ការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស

១២- ឧស្សាហកម្មឱជីថល

១៣- ការវិនិយោគក្នុងវិស័យអប់រំ ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងការជំរុញផលិតភាព

១៤- ការវិនិយោគក្នុងវិស័យសុខាភិបាល

១៥- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

១៦- ការវិនិយោគក្នុងវិស័យឡូជីស្ទីក

១៧- ការវិនិយោគក្នុងការគ្រប់គ្រង ការការពារបរិស្ថាន និងការអភិវឌ្ឍជីវៈចម្រុះ និងសេដ្ឋកិច្ចចក្រា

១៨- ការវិនិយោគក្នុងវិស័យថាមពលបៃតង បច្ចេកវិទ្យាដែលរួមចំណែកដល់ការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ

១៩- វិស័យ និងសកម្មភាពវិនិយោគផ្សេងទៀត ដែលមិនមានចែងក្នុងច្បាប់នេះ ក្នុងករណីដែលរាជរដ្ឋាភិបាលយល់ឃើញថាមានសក្ដានុពលដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច។

ចំពោះវិស័យ និងសកម្មភាពវិនិយោគដូចដែលបានរៀបរាប់ខាងលើនេះ ដែលមិនស្ថិតនៅក្នុងបញ្ជីអវិជ្ជមាន ត្រូវទទួលបានការលើកទឹកចិត្តជាមូលដ្ឋានផ្នែកពន្ធដារ និង/ឬពន្ធគយទាំងស្រុង ឬមួយផ្នែកក្រោយទទួលបានវិញ្ញាបនបត្រចុះបញ្ជីបញ្ជាក់ឋានៈជា "គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់" (គ.ល.គ)។ ចំណែកឯវិស័យ និងសកម្មភាពវិនិយោគខាងលើ ដែលពុំទទួលបានការលើកទឹកចិត្តទាំងផ្នែកពន្ធដារ និងពន្ធគយ ត្រូវបានកំណត់ក្នុងបញ្ជីអវិជ្ជមានដែលនឹងចែងដោយអនុក្រឹត្យ (យោងតាមមាត្រា ២៥ នៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា) ។

ចំពោះសកម្មភាពវិនិយោគដែលហាមឃាត់ដោយច្បាប់ និងអនុក្រឹត្យពាក់ព័ន្ធ ដែលមានចែងនៅក្នុងបញ្ជីអវិជ្ជមាន នៅក្នុងឧបសម្ព័ន្ធទី១ ផ្នែកទី១ នៃអនុក្រឹត្យ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា រួមមាន៖

- ផលិតកម្ម កែច្នៃសារធាតុប្រព័ន្ធសរសៃប្រសាទ (Psychotropic Substances) និងសារធាតុ (Narcotic)។
- ផលិតកម្មគ្រឿងគីមីពុល ថ្នាំពុលកសិកម្ម និងទំនិញផ្សេងទៀត តាមរយៈការប្រើប្រាស់សារធាតុគីមី ដែលហាមឃាត់ដោយបទបញ្ញត្តិអន្តរជាតិនានា ឬអង្គការសុខភាពពិភពលោក ដែលធ្វើឲ្យប៉ះពាល់ដល់សុខភាពសាធារណៈ និងបរិស្ថាន។
- ការកែច្នៃការផលិតអគ្គិសនី ដោយប្រើប្រាស់កាកសំណល់គ្រប់ប្រភេទ ដែលនាំចូលពីបរទេស។
- ការធ្វើអាជីវកម្មព្រៃឈើ ដែលច្បាប់ស្តីពីព្រៃឈើហាមឃាត់។

គួរបញ្ជាក់៖ ចំពោះចំណុចទី៥ "សកម្មភាពវិនិយោគផ្សេងៗទៀត ដែលច្បាប់ហាមឃាត់" នៃផ្នែកទី១ ក្នុងឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យនេះ ត្រូវបានលប់ចេញដោយអនុក្រឹត្យលេខ៣៤ អនក្រ.បក ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៧ ស្តីពីការកែសម្រួលផ្នែកទី១ ឧបសម្ព័ន្ធទី១នៃអនុក្រឹត្យលេខ១១១ ពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

ក្រៅពីសកម្មភាពវិនិយោគដែលត្រូវបានហាមឃាត់ នៅក្នុងបញ្ជីអវិជ្ជមាននេះក៏បានកំណត់ពីសកម្មភាពដែលពុំទទួលបានការលើកទឹកចិត្ត និងសកម្មភាពវិនិយោគដែលមានលក្ខណៈពិសេស ហើយដែលត្រូវទទួលការលើកទឹកចិត្តផ្នែកពន្ធគយលើការនាំចូល តែមិនទទួលបានការលើកទឹកចិត្តផ្នែកពន្ធលើប្រាក់ចំណេញ(មានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ)។

**១.២.១.២. ការលើកទឹកចិត្តជាមូលដ្ឋាន**

សកម្មភាពវិនិយោគដែលបានចុះបញ្ជីជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (គ.ល.គ.) មានសិទ្ធិជ្រើសរើសកញ្ចប់លើកទឹកចិត្តជាមូលដ្ឋាន។ ការលើកទឹកចិត្តជាមូលដ្ឋាននេះមាន ០២ ជម្រើស គឺជម្រើសទី១ (ក) និងជម្រើសទី២ (ខ) ដែលអាស្រ័យលើថាវិនិយោគិន ធ្វើការជ្រើសរើសមួយណា។

**ក. ករណីជម្រើសទី១**

នៅក្នុងជម្រើសទី១ វិនិយោគិននឹងទទួលបានការលើកលែងពន្ធលើប្រាក់ចំណូល សម្រាប់រយៈពេលពី៣ ទៅ៩ឆ្នាំ ទៅតាមវិស័យ និងសកម្មភាពវិនិយោគ គិតចាប់ពីពេលទទួលបានប្រាក់ចំណូលលើកដំបូង។ វិស័យ និងសកម្មភាពវិនិយោគ ព្រមទាំងរយៈពេលលើកលែងពន្ធលើប្រាក់ចំណូល នឹងត្រូវកំណត់ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង និង/ឬអនុក្រឹត្យ។ បន្ទាប់ពីផុតរយៈពេលលើកលែងពន្ធលើប្រាក់ចំណូល

គ.ល.គ. មានសិទ្ធិទទួលបានការលើកទឹកចិត្តឱ្យបង់ពន្ធលើប្រាក់ចំណូលតាមអត្រាកំណើនតាមពេលធៀបទៅនឹងប្រាក់ពន្ធត្រូវបង់សរុបដូចតទៅ៖ ២៥% សម្រាប់ ២ឆ្នាំដំបូង, ៥០% សម្រាប់ ២ឆ្នាំបន្ទាប់ និង៧៥% សម្រាប់ ២ឆ្នាំចុងក្រោយ។

លើសពីនេះទៀតជម្រើសនេះរួមបញ្ចូលការលើកលែងផ្សេងទៀតរួមមាន៖

- ការលើកលែងប្រាក់រំដោះពន្ធលើប្រាក់ចំណូលក្នុងអំឡុងពេលលើកលែងពន្ធលើប្រាក់ចំណូល
- ការលើកលែងពន្ធអប្បបរមា ដោយត្រូវមានរបាយការណ៍សវនកម្មឯករាជ្យ
- ការលើកលែងអាករនាំចេញ លើកលែងតែមានចែងដោយឡែកនៅក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត[27]។

**ខ. ករណីជម្រើសទី២**

ចំណែកជម្រើសទី២ គឺផ្តោតសំខាន់ទៅលើការទទួលបានសិទ្ធិកាត់កងចំណាយមូលធន តាមរយៈការរំលស់ពិសេស និងសិទ្ធិកាត់កងរហូតដល់ ២០០% លើចំណាយសំខាន់ៗផ្សេងទៀត សម្រាប់រយៈពេលរហូតដល់ ៩ឆ្នាំ និងការលើកទឹកចិត្តផ្សេងៗទៀត។

<u>ជម្រើសទី២</u> "ការរំលស់ពិសេស"៖

- សិទ្ធិកាត់កងចំណាយមូលធនតាមរយៈការរំលស់ពិសេសដែលមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន។
- សិទ្ធិកាត់កងរហូតដល់ ២០០% លើចំណាយជាក់លាក់ផ្សេងទៀតសម្រាប់រយៈពេលរហូតដល់ ៩ឆ្នាំ។ វិស័យ និងសកម្មភាពវិនិយោគ និងចំណាយជាក់លាក់ ព្រមទាំងរយៈពេលកាត់កងចំណាយ ត្រូវកំណត់ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រង និង/ឬអនុក្រឹត្យ។
- ការលើកលែងប្រាក់រំដោះពន្ធលើប្រាក់ចំណូលក្នុងរយៈពេលជាក់លាក់ណាមួយទៅតាមវិស័យ និងសកម្មភាពវិនិយោគដែលត្រូវកំណត់ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង និង/ឬអនុក្រឹត្យ។
- ការលើកលែងពន្ធអប្បបរមាដោយត្រូវមានរបាយការណ៍សវនកម្មឯករាជ្យ។
- ការលើកលែងអាករនាំចេញ លើកលែងតែមានចែងដោយឡែកនៅក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត។

ក្រៅពីការលើកទឹកចិត្តដែលបានលើកឡើងខាងលើគម្រោងវិនិយោគនឹងទទួលបាន៖

[27] យោងតាមមាត្រា ២៦ នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ៖ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១

ក. ចំពោះ គ.ល.គ. ដែលបម្រើឱ្យការនាំចេញ និង គ.ល.គ. ដែលជាប្រភេទឧស្សាហកម្មគាំទ្រដល់ គ.ល.គ បម្រើឱ្យការនាំចេញ មានសិទ្ធិនាំចូលដោយពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋនូវសម្ភារៈសាងសង់ បរិក្ខារសំណង់ សម្ភារៈបរិក្ខារផលិតកម្ម និងធាតុចូលផលិតកម្ម។

ខ. ចំពោះ គ.ល.គ. បម្រើទីផ្សារក្នុងស្រុកមានសិទ្ធិនាំចូលដោយពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែមសម្រាប់ការនាំចូលសម្ភារៈសាងសង់ បរិក្ខារសំណង់ និងសម្ភារៈបរិក្ខារផលិតកម្ម។ ការលើកទឹកចិត្តចំពោះធាតុចូលផលិតកម្មត្រូវកំណត់ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង និង/ឬអនុក្រឹត្យ[28]។

តាមការលើកឡើងខាងលើជម្រើសទាំង២នេះ មានលក្ខណៈខុសគ្នា និងដូចគ្នាដែលអ្នកវិនិយោគនឹងទទួលបាននៅពេលជ្រើសរើសការលើកទឹកចិត្តជាមូលដ្ឋាន (សូមពិគ្រោះនៅក្នុងឧបសម្ព័ន្ធទី២៖ តារាងប្រៀបធៀបការលើកទឹកចិត្តរវាងជម្រើសទី១ និងជម្រើសទី២)។

**១.២.១.៣. ការលើកទឹកចិត្តបន្ថែម**

ក្រៅពីការលើកទឹកចិត្តជាមូលដ្ឋានខាងលើ សកម្មភាពវិនិយោគដែលបានចុះបញ្ជីជា "គ.ល.គ." មានសិទ្ធិទទួលបានការលើកទឹកចិត្តបន្ថែមផងដែរ។ នៅក្នុងការលើកទឹកចិត្តនេះ រដ្ឋាភិបាលលើកលែងអាករលើតម្លៃបន្ថែម ចំពោះការទិញធាតុចូលផលិតកម្មដែលត្រូវបានផលិតនៅក្នុងស្រុក ក្នុងគោលបំណងផ្សារភ្ជាប់ផលិតករក្នុងស្រុកនៅនឹងខ្សែច្រវាក់ផលិតកម្មរបស់គម្រោងវិនិយោគ ក៏ដូចជាការជំរុញការប្រើប្រាស់ផលិតផលក្នុងស្រុក។ លើសពីនេះ គ.ល.គ អាចទទួលបានការកាត់កងចំណាយ ក្នុងអត្រារហូតដល់ ១៥០% ទៅលើចំណាយពាក់ព័ន្ធទៅនឹងសកម្មភាពដូចខាងក្រោម៖

- ការស្រាវជ្រាវ អភិវឌ្ឍន៍ និងនវានុវត្តន៍
- ការអភិវឌ្ឍធនធានមនុស្ស តាមរយៈការផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងជំនាញដល់កម្មករនិយោជិតខ្មែរ
- ការសាងសង់កន្លែងស្នាក់នៅ កន្លែងបរិភោគអាហារ ឬអាហារដ្ឋានតម្លៃសមរម្យ ទារកដ្ឋាន និងសុខុប-ត្ថម្ភវត្ថុដទៃទៀតសម្រាប់ កម្មករ/និយោជិត
- ការធ្វើទំនើបកម្មលើគ្រឿងម៉ាស៊ីនដើម្បីបម្រើខ្សែច្រវាក់ផលិតកម្ម និង
- ការផ្តល់ការលើកកម្ពស់សុខុមាលភាពដល់កម្មករនិយោជិតខ្មែរ ដូចជាការផ្តល់មធ្យោបាយដឹកជញ្ជូនប្រកបដោយផាសុកភាពដល់កម្មករនិយោជិតក្នុងការធ្វើដំណើរទៅមកពីកន្លែងស្នាក់នៅទៅ

[28] យោងតាមមាត្រា ២៦ នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ៖ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១

រោងចក្រ កន្លែងស្នាក់នៅ កន្លែងបរិភោគអាហារ ឬអាហារដ្ឋានដែលមានតម្លៃសមរម្យ ទារកដ្ឋាន និងសុខុបត្ថម្ភវត្ថុដទៃទៀត។

ការលើកលែងពន្ធលើប្រាក់ចំណូលចំពោះការពង្រីក គ.ល.គ. ដែលត្រូវកំណត់ដោយអនុក្រឹត្យ។[29]

#### ១.២.១.៤. ការលើកទឹកចិត្តពិសេស

រដ្ឋធ្វើការកំណត់ដោយឡែកក្នុងច្បាប់ស្តីពី "ការគ្រប់គ្រងហិរញ្ញវត្ថុ" ក្នុងការទទួលបានការលើកទឹកចិត្តពិសេសដោយឡែកផ្សេងទៀត អាស្រ័យតាមវិស័យ និងសកម្មភាពវិនិយោគជាក់លាក់ណាមួយ ដែលរដ្ឋយល់ថាមានសក្តានុពលក្នុងការចូលរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងសង្គមជាដើម។ គួរបញ្ជាក់ផងដែរថា ការទទួលបានការលើកទឹកចិត្តទាំង៣ប្រភេទខាងលើនេះ អ្នកវិនិយោគិននឹងទទួលបានការលើកទឹកចិត្តជាមូលដ្ឋានដោយស្វ័យប្រវត្តិនៃ គ.ល.គ. លើសពីនេះវិនិយោគិនអាចនឹងទទួលបានការលើកទឹកចិត្តបន្ថែមពីលើទៀតប្រសិនបើ គ.ល.គ. មានសកម្មភាពណាមួយដូចបានរៀបរាប់នៅក្នុងចំណុចខាងលើ (១.២.១.៣.) ព្រមទាំងអាចទទួលបានការលើកទឹកចិត្តពិសេសបន្ថែមពីការទទួលបានការលើកទឹកចិត្តទាំងពីរខាងលើ។

### ១.២.២. ការធានា និងការការពារសម្រាប់វិនិយោគិន

ក្រៅពីការលើកទឹកចិត្តផ្នែកពន្ធខាងលើ វិនិយោគិនទាំងអស់មានសិទ្ធិសេរីភាពដែលត្រូវបានផ្តល់អោយដោយបទបញ្ញត្តិច្បាប់ជាធរមាន ដែលរាល់ការវិនិយោគទាំងអស់នៅក្នុងប្រទេសកម្ពុជា ត្រូវបានធានាលើការវិនិយោគដោយរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា។

#### ១.២.២.១. សិទ្ធិ និងបុព្វសិទ្ធិរបស់វិនិយោគិន

វិនិយោគិនដែលបានចុះបញ្ជីវិនិយោគនៅ ក.អ.ក. ឬ អ.គ.វ.វ.ខ. នឹងទទួលបានសិទ្ធិសំខាន់ៗ រួមមានសិទ្ធិសេរីភាពស្មើគ្នាស្របតាមគោលការណ៍មិនរើសអើង ការការពារកម្មសិទ្ធិបញ្ញា សិទ្ធិចរាចររូបិយបណ្ណបរទេស សិទ្ធិទទួលបានសេវាថែទាំវិនិយោគ និងសិទ្ធិផ្សេងៗទៀត។

##### ក. គោលការណ៍មិនរើសអើង

អនុលោមតាមច្បាប់ស្តីពីវិនិយោគថ្មី វិនិយោគិនមានសិទ្ធិសេរីភាពក្នុងការស្នើសុំគម្រោងវិនិយោគ ហើយដោយឈរលើគោលការណ៍គ្មានការរើសអើង វិនិយោគិនបរទេស មិនត្រូវជាកម្មវត្ថុនៃការរើសអើងដោយសារមូលហេតុសញ្ជាតិបរទេស លើកលែងតែកម្មសិទ្ធិលើដីធ្លី ដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងបទបញ្ញត្តិជាធរមានផ្សេងទៀត។ ក្នុងករណីនេះ ជនបរទេសត្រូវបានរិតត្បិតតែ

[29] យោងតាមមាត្រា ២៧ នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខៈ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១.

លើកម្មសិទ្ធិដីធ្លី ដែលមានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិខ្មែរ ទើបមានសិទ្ធិធ្វើជាម្ចាស់កម្មសិទ្ធិដីធ្លីបាន។ ក៏ប៉ុន្តែ នីតិបុគ្គលដែលបានចុះបញ្ជីនៅកម្ពុជាដែលមានភាគហ៊ុនចាប់ពី៥១% ឡើងទៅ ត្រូវបានកាន់កាប់ដោយរូបវន្តបុគ្គលដែលមានសញ្ជាតិខ្មែរ ឬនីតិបុគ្គលនៃច្បាប់កម្ពុជា អាចជាកម្មសិទ្ធិករនៃអចលនទ្រព្យបាន (ដី)។ ហេតុនេះ វិនិយោគិនមានសិទ្ធិប្រើប្រាស់ដីធ្លីតាមរយៈជាអាទិ៍ សម្បទានដីសេដ្ឋកិច្ច ឬសិទ្ធិជួលអចិន្ត្រៃយ៍ និងការជួលដែលមានអំឡុងពេលកំណត់ស្របតាមបទបញ្ញត្តិច្បាប់ជាធរមាន។

បន្ថែមពីនេះ វិនិយោគិននឹងទទួលបាននូវប្រព្រឹត្តកម្មមិនរើសអើងទាក់ទងនឹងបដិទាន សំណង ឬដំណោះស្រាយជាតម្លៃសេដ្ឋកិច្ចផ្សេងទៀត ក្នុងករណីការវិនិយោគរបស់ខ្លួនបានទទួលរងនូវការខូចខាតដោយសារជម្លោះប្រដាប់អាវុធ ឬកលិយុគស៊ីវិល ឬការដាក់ប្រទេសជាតិក្នុងភាពអាសន្ន ប្រសិនបើមានច្បាប់ និងគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការធ្វើបដិទាន ឬផ្តល់សំណងសមរម្យណាមួយនោះ។ តាមការបកស្រាយខាងលើ សំដៅដល់ការទទួលបានសិទ្ធិស្មើគ្នារវាងវិនិយោគិនបរទេស និងវិនិយោគិនក្នុងស្រុក ក្នុងការធ្វើសកម្មភាពវិនិយោគលើវិស័យអ្វីមួយ ដោយស្មើគ្នាចំពោះមុខច្បាប់ គ្មានការរើសអើងសញ្ជាតិ ឬពូជសាសន៍នោះឡើង។

**ខ. សិទ្ធិចរាចររូបិយបណ្ណបរទេស**

វិនិយោគិនមានសិទ្ធិទិញរូបិយបណ្ណបរទេសដោយសេរី និងបង្វិលទៅបរទេសនូវរូបិយបណ្ណបរទេសទាំងអស់នោះ ដើម្បីទូទាត់កាតព្វកិច្ចខាងហិរញ្ញវត្ថុដែលពាក់ព័ន្ធនឹងការវិនិយោគរបស់ខ្លួន តាមរយៈប្រព័ន្ធធនាគារដែលជាអន្តរការីប្រតិស្រុតិ។ ការផ្ទេរទាំងនេះរាប់បញ្ចូលទាំង៖

- វិភាគទានចំពោះមូលធន រាប់បញ្ចូលទាំងវិភាគទានមូលធនបឋម
- ប្រាក់ចំណូល ចំណេញមូលធន ភាគលាភ កម្រៃសួយសារ កម្រៃអាជ្ញាបណ្ណ កម្រៃនៃការគ្រប់គ្រង និងជំនួយបច្ចេកទេស ការប្រាក់ និងប្រាក់ចំណូលដទៃទៀតដែលកើតពីការវិនិយោគ
- ផលដែលទទួលបានពីការលក់សរុប ឬការលក់មួយផ្នែក ឬការរំលាយក្រុមហ៊ុនដែលអនុវត្តគម្រោងវិនិយោគ។
- ការទូទាត់លើការនាំចូល និងការបង្វិលទៅក្រៅប្រទេសទាំងប្រាក់ដើម និងការប្រាក់នៃប្រាក់កម្ចី
- ការទូទាត់ចំពោះសំណងក្នុងករណីមានកលិយុគស៊ីវិល ក្នុងករណីមានអស្សាមិករណ៍ ឬការដកហូតដោយរដ្ឋ។
- ការទូទាត់កើនឡើងពីដំណោះស្រាយវិវាទដោយមធ្យោបាយណាមួយ រាប់បញ្ចូលទាំងសេចក្តីសម្រេចរបស់តុលាការ ឬសេចក្តីសម្រេចរបស់មជ្ឈត្តការ។

– ចំណូល និងប្រាក់ឈ្នួលដទៃទៀតរបស់និយោជិត។[30]

**គ. ការការពារកម្មសិទ្ធិបញ្ញា**

រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកកិច្ចការពារកម្មសិទ្ធិបញ្ញាថាមានសារៈសំខាន់ចំពោះការលើកស្ទួយការអភិវឌ្ឍសេដ្ឋកិច្ច ជម្រុញការវិនិយោគទុនបរទេស និងការផ្ទេរបច្ចេកវិទ្យា ព្រមទាំងការសម្រួលដល់ទៅសមាហរណកម្មរបស់ប្រទេសកម្ពុជាចូលទៅក្នុងសេដ្ឋកិច្ចពិភពលោក។ ហេតុនេះរាល់កម្មសិទ្ធិបញ្ញារបស់វិនិយោគិនត្រូវបានការពារដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញានៃព្រះរាជាណាចក្រកម្ពុជា។[31]

**ឃ. សិទ្ធិទទួលបានសេវាថែទាំវិនិយោគ និងសិទ្ធិផ្សេងៗទៀត**

យោងតាមមាត្រា២៣ នៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា បានចែងថាៈ វិនិយោគិនមានសិទ្ធិទទួលបាននូវសេវាថែទាំវិនិយោគចំពោះគម្រោងវិនិយោគដែលបានចុះបញ្ជីនៅ ក.អ.ក. ឬអ.គ.វ.រ.ខ.។ ចំពោះលក្ខខណ្ឌបែបបទ និងនីតិវិធីនៃការផ្ដល់សេវាថែទាំវិនិយោគចំពោះគម្រោងវិនិយោគនេះ ត្រូវកំណត់ដោយអនុក្រឹត្យ។ លើសពីនេះ បុគ្គលដែលត្រូវបានចាត់ទុកជាវិនិយោគិន ដែលបានចុះបញ្ជីគម្រោងវិនិយោគនៅ ក.អ.ក. ឬ អ.គ.វ.រ.ខ. ទទួលបានសិទ្ធិផ្សេងៗទៀត រួមមានៈ

- សិទ្ធិជួលនិយោជិតជនបរទេស (ត្រូវពិនិត្យតាមស្ថានភាពជាក់ស្ដែង និងពុំមានលក្ខណៈអចិន្ត្រៃយ៍ទេ)
- សិទ្ធិទទួលបានការអនុញ្ញាតស្នាក់នៅបណ្ដោះអាសន្នរយៈពេលវែងសម្រាប់ខ្លួនឯង សហព័ទ្ធ និងកូនដែលជាអនីតិជន ក្នុងអំឡុងពេលដែលអនុវត្តសកម្មភាពនៃគម្រោងវិនិយោគ។
- សិទ្ធិស្នើសុំការស្នាក់នៅបណ្ដោះអាសន្នរយៈពេលវែងសម្រាប់និយោជិតបរទេស សហព័ទ្ធ និងកូនដែលជាអនីតិជន ក្នុងអំឡុងពេលដែលកិច្ចសន្យាការងារនៅមានសុពលភាព។
- សិទ្ធិទទួលបានបណ្ណការងារ និងសៀវភៅការងារសម្រាប់ខ្លួនឯងផ្ទាល់ និងនិយោជិតបរទេសរបស់ខ្លួន។

**១.២.២.២. ការទទួលបានការធានាពីរដ្ឋ**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានដើរតួនាទីយ៉ាងសំខាន់ក្នុងការធ្វើអោយអ្នកវិនិយោគមានភាពជឿជាក់ និងមានទំនុកចិត្តបន្ថែមទៀត នៅក្នុងបង្កើតសកម្មភាពវិនិយោគរបស់ខ្លួននៅក្នុងប្រទេសកម្ពុជា។ ហេតុនេះបន្ថែមពីការទទួលបានសិទ្ធិខាងលើ អ្នកវិនិយោគនឹងទទួលបានការធានាពីរដ្ឋ លើចំណុច

[30] យោងតាមមាត្រា ១៩ នៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខៈ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១។

[31] យោងតាមមាត្រា ២០ នៃច្បាប់ដដែល។

សំខាន់ៗ គឺការមិនធ្វើជាតូបនីយកម្ម (ក) ការមិនធ្វើអស្សាមិករណ៍ (ខ) និងការមិនកំណត់ថ្លៃផលិត ឬថ្លៃសេវានានា (គ)។

### ក. ការមិនធ្វើជាតូបនីយកម្ម

ជាតូបនីយកម្ម (Nationalization) សំដៅលើការធ្វើ ឬការផ្ទេររបស់អ្វីមួយដែលជារបស់ឯកជន ឬរបស់ជាតិដទៃឱ្យទៅជារបស់ជាតិ ឬរបស់រដ្ឋវិញ។ តាមច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា បានចែងថារដ្ឋមិនត្រូវធ្វើជាតូបនីយកម្ម ដែលនាំឱ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់វិនិយោគិនក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ។[32] ហេតុនេះទ្រព្យសម្បត្តិឯកជនរបស់អ្នកវិនិយោគ ទោះបីជាជនជាតិណាក៏ដោយត្រូវបានទទួលការការពារស្របច្បាប់ ព្រមទាំងអាចគេចផុតពីការរឹបអូសតាមរយៈការធ្វើជាតូបនីយកម្ម ឬការធ្វើអស្សាមិករណ៍ដោយរដ្ឋ។

### ខ. ការមិនធ្វើអស្សាមិករណ៍

ពាក្យថា អស្សាមិករណ៍ (Expropriation) អនុលោមតាមច្បាប់ស្តីពី អស្សាមិករណ៍ សំដៅលើការអនុវត្តនូវសិទ្ធិអំណាចរបស់រដ្ឋ ក្នុងការដកហូតកម្មសិទ្ធិឯកជន ដើម្បីបម្រើជាប្រយោជន៍សាធារណៈ។ ច្បាប់វិនិយោគកម្ពុជាថ្មីបានចែងថា "រដ្ឋមិនត្រូវធ្វើអស្សាមិករណ៍ដែលនាំអោយប៉ះពាល់ដល់គម្រោងវិនិយោគដែលទទួលការអនុម័តនោះឡើយ ទោះបីដោយផ្ទាល់ ឬដោយប្រយោល ឬតាមរយៈវិធានការប្រហាក់ប្រហែលនឹងការធ្វើអស្សមិករណ៍ក្តី"[33]។ នៅក្នុងការវិនិយោគ រដ្ឋាភិបាលបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការធានាទ្រព្យសម្បត្តិរបស់អ្នកវិនិយោគ ហេតុនេះមុននឹងផ្តល់គម្រោងវិនិយោគ ជូនដល់វិនិយោគិន រដ្ឋាភិបាលគួរមានការពិចារណាអោយបានល្អិតល្អន់អំពីទីតាំងនៃគម្រោងវិនិយោគដែលបានស្នើសុំ ដើម្បីជៀសវាងការប៉ះពាល់ដល់ការអនុវត្តគម្រោងវិនិយោគស្ថិតនៅ។

ថ្វីបើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា បានហាមឃាត់រដ្ឋក្នុងការធ្វើអស្សាមិករណ៍ខាងលើក៏ដោយ ច្បាប់នេះក៏បានបញ្ញត្តករណីលើកលែង ដែលអាចអោយរដ្ឋាភិបាលនៅតែអាចធ្វើអស្សាមិករណ៍បានក្នុងករណីបម្រើប្រយោជន៍សាធារណៈ ពោលគឺការធ្វើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តបុគ្គលសាធារណៈ ដែលមានគោលបំណងបម្រើប្រយោជន៍សាធារណៈ និងផលប្រយោជន៍ជាតិ។ ការការធ្វើអស្សមិករណ៍ក្នុងករណីនេះ ត្រូវអនុវត្តតាមលក្ខខណ្ឌរួមមាន៖

- ភាពមិនរើសអើង

[32] យោងតាមមាត្រា ១៦ នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ៖ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១។

[33] យោងតាមមាត្រា ១៧ នៃច្បាប់ដដែល។

- សំណងដោយសមរម្យ និងយុត្តិធម៌ និង
- អនុលោមតាមច្បាប់ និងនីតិវិធីអស្សាមិករណ៍ជាធរមាន (ច្បាប់ស្តីពីអស្សាមិករណ៍ ឆ្នាំ២០១០)។

**គ. ការមិនកំណត់ថ្លៃផលិត ឬថ្លៃសេវានានា**

ច្បាប់វិនិយោគថ្មីបានបញ្ញត្តិថា រាជរដ្ឋាភិបាលមិនត្រូវកំណត់ថ្លៃផលិតផល ឬថ្លៃសេវានានាដែលបង្កើតដោយគម្រោងវិនិយោគនោះឡើយ។[34] ក្នុងន័យនេះរាជរដ្ឋាភិបាលមិនអាចប្រើប្រាស់សិទ្ធិអំណាចលើដែនដីអធិបតេយ្យនៃរដ្ឋរបស់ខ្លួន ក្នុងការដាក់កំហិត និងត្រួតពិនិត្យលើតម្លៃទំនិញ ឬថ្លៃសេវាកម្មផ្សេងៗ ដែលពាក់ព័ន្ធនឹងការវិនិយោគឡើយ ហើយអ្នកវិនិយោគមានសេរីភាពក្នុងការកំណត់ ឬកែប្រែតម្លៃទំនិញ និងសេវាកម្មចំពោះគម្រោងវិនិយោគ។ ការធ្វើបែបនេះគឺស្របតាមគោលការណ៍នៃប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរីដែលប្រទេសកម្ពុជាកំពុងអនុវត្ត។ រាជរដ្ឋាភិបាលធ្វើសកម្មភាព ឬអន្តរាគមន៍នៅក្នុងទីផ្សារតិចតួចបំផុត (នៅក្នុងរបបសេដ្ឋកិច្ចទីផ្សារសេរី គឺរដ្ឋាភិបាលមានតួនាទីជាអ្នកសម្របសម្រួល នៅដំណើរការអភិវឌ្ឍប្រទេសប្រកបដោយនិរន្តរភាព និងកាត់បន្ថយគម្លាតរវាងអ្នកមាននិងអ្នកក្រ ) ពោលគឺវិស័យឯកជនដែលជាអ្នកដើរតួនាទីយ៉ាងសំខាន់នៅក្នុងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរីនេះ។ ក៏ប៉ុន្តែរដ្ឋអាចធ្វើការលុកដៃចូលអន្តរាគមន៍នៅក្នុងទីផ្សារនៃប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី ក្រោមរូបភាពជាការធានាអោយមានការប្រកួតប្រជែងដោយស្មោះត្រង់ ការធានាអោយអ្នកប្រើប្រាស់មានជម្រើសច្រើន ការកំណត់គម្រោងទីផ្សារ ការផ្តល់សេវាសាធារណៈជូនដល់ប្រជាពលរដ្ឋ និងការចូលអន្តរាគមន៍ដើម្បីដោះស្រាយជម្លោះបញ្ហានៃការដួលរលំទីផ្សារ ឬវិបត្តិសេដ្ឋកិច្ចតែប៉ុណ្ណោះ។

## ១.៣. អត្ថប្រយោជន៍នៃការវិនិយោគនៅប្រទេសកម្ពុជា

ហេតុអ្វីវិនិយោគនៅកម្ពុជា? ការវិនិយោគនៅក្នុងប្រទេសកម្ពុជា អ្នកវិនិយោគនឹងទទួលបានអត្ថប្រយោជន៍ជាច្រើន ដោយសារប្រទេសកម្ពុជាមានបរិយាកាសវិនិយោគមានអំណោយផល (១.៣.១) កំណើនសេដ្ឋកិច្ចថេរប្រកបដោយចីរភាព (១.៣.២) ព្រមទាំងមានបណ្តាញហេដ្ឋារចនាសម្ព័ន្ធពាណិជ្ជកម្ម (១.៣.៣) និងកម្លាំងពលកម្មមានភាពប្រកួតប្រជែង (១.៣.៤)។

### ១.៣.១. បរិយាកាសវិនិយោគមានអំណោយផល

បរិយាកាសវិនិយោគមានអំណោយផល ក្រៅពីការលើកទឹកចិត្តផ្នែកពន្ធ ជាមួយការធានា និងការការពារវិនិយោគ៖

[34] យោងតាមមាត្រា ១៨ នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខៈ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១។

- សេដ្ឋកិច្ចកម្ពុជា គឺជាសេដ្ឋកិច្ចដែលមានលក្ខណៈបើកចំហបំផុតមួយនៅអាស៊ី។ រាល់ការវិនិយោគទាំងអស់នៅក្នុងប្រទេសកម្ពុជាត្រូវបានធានាដោយស្មើភាព មិនថាវិនិយោគិនបរទេស ឬក្នុងស្រុក។ ការវិនិយោគនៅកម្ពុជាពុំតម្រូវឱ្យមានចំណែកហ៊ុនរបស់វិនិយោគិនក្នុងស្រុកទេ។
- ដំណើរការអនុម័តគម្រោងវិនិយោគមានភាពងាយស្រួលជាងមុន ដោយសំណើគម្រោងវិនិយោគត្រូវដាក់ស្នើសុំ និងពិនិត្យតាមរយៈការិយាល័យច្រកចេញចូលតែមួយរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC)។ ប្រសិនបើវិស័យរបស់គម្រោងវិនិយោគដែលបានស្នើឡើងនោះមិនស្ថិតនៅក្នុង "បញ្ជីហាមឃាត់" នោះក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានឹងចេញវិញ្ញាបនបត្រចុះបញ្ជីគម្រោងវិនិយោគក្នុងរយៈពេល ២០ថ្ងៃធ្វើការ។

### ១.៣.២. កំណើនសេដ្ឋកិច្ចថេរប្រកបដោយចីរភាព

ផលិតផលក្នុងស្រុកសរុបរបស់កម្ពុជាបាននិងកំពុងកើនឡើងយ៉ាងឆាប់រហ័សប្រមាណ ១០% ក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ។ ហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីក៏កំពុងមានការរីកចម្រើនគួរឱ្យកត់សម្គាល់ផងដែរ ដោយការតម្លៃអគ្គិសនីបានធ្លាក់ចុះជិត ២០% ក្នុងរយៈពេល ១០ឆ្នាំកន្លងមក ហើយសមត្ថភាពផ្គត់ផ្គង់បានកើនឡើង ១០ដងក្នុងរយៈពេល ១៥ឆ្នាំកន្លងមក។ លើសពីនេះ ការវិនិយោគសំខាន់ៗលើហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនកំពុងត្រូវបានកសាង រួមមានផ្លូវល្បឿនលឿនភ្នំពេញ-ព្រះសីហនុដែលមានតម្លៃ ១.៩ពាន់លានដុល្លារ និងគម្រោងផ្លូវក្នុងក្រុងសៀមរាមដែលមានតម្លៃ ១៥០លានដុល្លារ។

បរិយាកាសជំនួញមានស្ថិរភាព ដោយអតិផរណាអត្រាប្តូរប្រាក់ និងអត្រាគ្មានការងារធ្វើនៅកម្ពុជាមានស្ថិរភាពដែលកត្តាទាំងនេះបង្កើតបរិយាកាសអំណោយផលសម្រាប់ការធ្វើជំនួញ និងអាជីវកម្មក្នុងប្រទេសកម្ពុជា (សូមពិគ្រោះនៅក្នុងឧបសម្ព័ន្ធទី២៖ រូបភាពបង្ហាញអំពីអតិផរណារបស់ប្រទេសកម្ពុជាគិតជាភាគរយពីឆ្នាំ២០១៦ មកដល់ឆ្នាំ២០២០)។ លើសពីការយកចិត្តទុកដាក់ទៅលើចីរភាព ដោយគិតត្រឹមឆ្នាំ ២០១៩ សមត្ថភាពផលិតថាមពលអគ្គិសនីនៅក្នុងប្រទេសកម្ពុជាប្រមាណ ៧០% បានមកពីថាមពលកកើតឡើងវិញ។ ជាងនេះទៅទៀត ប្រទេសកម្ពុជាមានការបញ្ចេញឧស្ម័នកាបូនិកទាបបំផុតមួយក្នុងចំណោមប្រទេសទាំងអស់នៅក្នុងតំបន់អាស៊ាន (សូមពិគ្រោះនៅក្នុងឧបសម្ព័ន្ធទី២៖ រូបភាពបង្ហាញអំពីការបញ្ចេញឧស្ម័នកាបូនិកក្នុងចំណោមមនុស្សម្នាក់នៅតំបន់អាស៊ាន) ។

### ១.៣.៣. បណ្តាញហេដ្ឋារចនាសម្ព័ន្ធពាណិជ្ជកម្ម

ប្រទេសកម្ពុជាជាសមាជិកអាស៊ាន ទទួលបានការផ្តល់អត្ថប្រយោជន៍ពាណិជ្ជកម្មក្នុងតំបន់ និងជាផ្នែកមួយនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីក្នុងតំបន់អាស៊ាន ព្រមទាំងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរបស់អាស៊ានជាមួយប្រទេសចិន ជប៉ុន កូរ៉េ ឥណ្ឌា អូស្ត្រាលី និងនូវែលសេឡង់។ លើសពីនេះ កម្ពុជាជាហត្ថលេខី

នៃភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ (RCEP) ដែលជាកិច្ចព្រមព្រៀងពាណិជ្ជកម្មដ៏ធំបំផុតរបស់ពិភពលោក ដែលតភ្ជាប់ប្រមាណ ៣០% នៃចំនួនប្រជាជន និងទិន្នផលពិភពលោក (សូមពិគ្រោះនៅក្នុងឧបសម្ព័ន្ធទី២៖ រូបភាពបង្ហាញអំពីតួលេខរបស់ RCEP)។ គួរបញ្ជាក់ ប្រទេសកម្ពុជាបានចូលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោកផងដែរ។

កិច្ចព្រមពៀងពាណិជ្ជកម្មសេរីទ្វេភាគីកម្ពុជា-ចិន (CCFTA) ត្រូវបានចូលជាធរមាននៅថ្ងៃទី០១ មករា ឆ្នាំ២០២២ ហើយក្នុងថ្ងៃជាមួយគ្នា កិច្ចព្រមពៀងពាណិជ្ជកម្មសេរីក្នុងតំបន់ «RCEP» រវាងប្រទេសទាំង១០នៅអាស៊ាន ជាមួយនឹងប្រទេសចំនួន៥ទៀត ក៏នឹងបានចូលធរមានផងដែរ។ តាមរយៈកិច្ចព្រមព្រៀងទាំង២នេះ គឺបានបើកផ្លូវពាណិជ្ជកម្មយ៉ាងធំរបស់កម្ពុជា ក្នុងការនាំចេញផលិតផលកសិកម្ម ដែលមានសក្តានុពលទៅកាន់ទីផ្សារនៃប្រទេសគោលដៅបានដោយត្រង់។ កិច្ចព្រមព្រៀងពាណិជ្ជកម្មនេះ បានគ្របដណ្តប់លើប្រជាជនជាង២ពាន់លាននាក់(ប្រមាណ៣០ភាគរយ)នៃចំនួនប្រជាជនពិភពលោក ខណៈផលិតផលក្នុងស្រុកសរុប (GDP) របស់ប្រទេសជាសមាជិកទាំង១៥ នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មនេះ គឺស្មើនឹងជាង ៣៣% ឬមួយភាគបីនៃGDPរបស់ពិភពលោក ហើយក៏ស្មើនឹងមួយភាគបីនៃពាណិជ្ជកម្មពិភពលោកផងដែរ។

ការរីកលូតលាស់ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ដែលជាចំណុចស្នូលក្នុងគម្រោងអភិវឌ្ឍច្រករបៀងសេដ្ឋកិច្ចភាគខាងត្បូង (SEC) ដែលតភ្ជាប់ប្រទេសមីយ៉ាន់ម៉ា ថៃ និងវៀតណាម ដែលទីក្រុងភ្នំពេញស្ថិតនៅចំកណ្តាលសម្រាប់តភ្ជាប់ទីក្រុងបាងកក ទៅកាន់ទីក្រុងហូជីមិញ។ ប្រទេសកម្ពុជាមានអាកាសយានដ្ឋានអន្តរជាតិចំនួន ០៣ តភ្ជាប់ទៅកាន់ទីផ្សារសំខាន់ៗជុំវិញពិភពលោក។ តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុស្ថិតនៅតាមបណ្តោយឆ្នេរសមុទ្រកម្ពុជា ត្រូវបានតភ្ជាប់ដោយផ្លូវថ្នល់ ផ្លូវដែក ផ្លូវទឹក និងផ្លូវអាកាសទៅកាន់មជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិសំខាន់នានាៗ។ លើសពីនេះ ការវិនិយោគ ១.៩ ពាន់លានដុល្លារលើផ្លូវល្បឿនលឿនភ្នំពេញ-ព្រះសីហនុ ដែលភ្ជាប់ពីរាជធានីទៅខេត្តជាប់ឆ្នេរសមុទ្រដ៏មានសក្តានុពល នឹងបញ្ចប់ការសាងសង់នាពេលឆាប់ៗនេះ។ ទីតាំងស្ថិតនៅជិតទីផ្សារសំខាន់ៗមានព្រំដែនជាមួយប្រទេសថៃ វៀតណាម និងឡាវ ប្រទេសកម្ពុជាអាចភ្ជាប់ទៅកាន់ទីផ្សារទាំងបីរបស់អាស៊ានបានតែប៉ុន្មានម៉ោងប៉ុណ្ណោះតាមរយៈផ្លូវគោក។ តំបន់សេដ្ឋកិច្ចពិសេសចំនួន៤ ស្ថិតនៅជិតព្រំដែនថៃ ខណៈតំបន់សេដ្ឋកិច្ចពិសេសចំនួន១៣ ស្ថិតនៅព្រំដែនវៀតណាម។

**១.៣.៤. កម្លាំងពលកម្មមានភាពប្រកួតប្រជែង**

កម្លាំងពលកម្មសកម្ម និង នៅក្នុងចំណោមប្រជាជនកម្ពុជាសរុបចំនួន ១៦លាននាក់ ជាង ៦០% មាន

អាយុក្រោម ៣៥ឆ្នាំ។ ជាមួយនឹងអត្រាចូលរួមកម្លាំងពលកម្មប្រមាណ ៨០% ប្រទេសកម្ពុជាមានកម្លាំងពលកម្មវ័យក្មេង និងសកម្មដែលអាចបម្រើគ្រប់វិស័យរបស់អាជីវកម្ម ឬជំនួញរបស់វិនិយោគិន។

លើសពីនេះកម្លាំងពលកម្មមានជំនាញ និងទេពកោសល្យខ្ពស់អត្រាអក្ខរកម្មនៅកម្ពុជាកំពុងកើនឡើងយ៉ាងឆាប់រហ័ស ដោយឈានដល់ជិត ៩០% ក្នុងឆ្នាំ២០១៩។ ចាប់តាំងពីឆ្នាំ២០០៨ មកមានការងារកើនឡើងប្រមាណ ១.៦ដងនៅក្នុងឧស្សាហកម្មគាំទ្រ។ ភាពសម្បូរបែបនៃជំនាញ និងទេពកោសល្យនឹងដល់ជួយដល់ការវិនិយោគរបស់អ្នក។ ហើយប្រាក់ឈ្នួលមានភាពប្រកួតប្រជែង ដោយប្រទេសកម្ពុជាមានប្រាក់ឈ្នួលប្រកួតប្រជែងបំផុតមួយក្នុងតំបន់អាស៊ី ដោយមានកម្រិតប្រាក់ឈ្នួលអប្បបរមាគឺចំនួន ១៩២ដុល្លារក្នុងមួយខែ (សូមពិគ្រោះនៅក្នុងឧបសម្ព័ន្ធទី២៖ រូបភាពបង្ហាញអំពីប្រាក់ឈ្នួលប្រចាំខែអប្បបរមានៅក្នុងពិភពលោកឆ្នាំ២០២១-២០២១ គិតជាដុល្លារអាមេរិក)។

## ផ្នែកទី២៖ សំណើវិនិយោគ

មុននឹងឈានដល់ការបកស្រាយអំពីនីតិវិធីនៃការចុះបញ្ជីគម្រោងវិនិយោគ (២.២) យើងគប្បីសិក្សាអំពីប្រភេទនៃគម្រោងវិនិយោគ (២.១.) ជាមុនសិន។

### ២.១. ប្រភេទនៃគម្រោងវិនិយោគ

គម្រោងវិនិយោគ សំដៅដល់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (២.១.១) គម្រោងពង្រីកនៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (២.១.២) និងគម្រោងវិនិយោគដែលទទួលបានត្រឹមតែការធានាលើការវិនិយោគ (២.១.៣)។[35]

#### ២.១.១. គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់

គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ សរសេរជាអក្សរកាត់ "គ.ល.គ." (Qualified Investment Project ឬ QIP) គឺជារបបលើកទឹកចិត្តដល់គម្រោងវិនិយោគ (Investment Incentive) ដែលទទួលបានវិញ្ញាបនបត្រចុះបញ្ជីពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត ដែលគម្រោងនេះទទួលបានការអនុគ្រោះជាច្រើន ក្នុងគោលដៅដើម្បីជំរុញការវិនិយោគនៅប្រទេសកម្ពុជា។

"គ.ល.គ." មានប្រភេទផ្សេងៗគ្នា អាស្រ័យទៅតាមសកម្មភាពវិនិយោគ[36] និងសកម្មភាពក្នុងការផ្គត់ផ្គង់ផលិតផលដែលបានផលិតនៅក្នុងទីផ្សារ ដែលប្រភេទទាំងនោះរួមមាន គម្រោងវិនិយោគបម្រើឱ្យការនាំ

---

[35] យោងតាមមាត្រា ៣ នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ៖ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១។

[36] សកម្មភាពវិនិយោគ សំដៅដល់សកម្មភាពអាជីវកម្មដែលដំណើរការនៅក្នុងប្រទេសកម្ពុជា ក្រោមរូបភាពជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

ចេញ (២.១.១.១) គម្រោងវិនិយោគដែលជាប្រភេទឧស្សាហ៍កម្មគាំទ្រ (២.១.១.២) និងគម្រោងវិនិយោគមានទិសដៅបម្រើតម្រូវការក្នុងស្រុក (២.១.១.៣)។

**២.១.១.១. គម្រោងវិនិយោគបម្រើឱ្យការនាំចេញ**

គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បម្រើឱ្យការនាំចេញ សំដៅដល់ "គ.ល.គ" ដែលបានលក់ ឬផ្ទេរសមាមាត្រណាមួយនៃផលិតផលរបស់ខ្លួនទៅឱ្យអ្នកទិញ ឬអ្នកទទួលនៅក្រៅព្រះរាជាណាចក្រកម្ពុជា។ គម្រោងវិនិយោគប្រភេទនេះអាចជាគម្រោងវិនិយោគ ដែលបានធ្វើការលក់ផលិតផលរបស់ខ្លួននៅក្នុងព្រះរាជាណាចក្រកម្ពុជាផល និងនាំចេញទៅលក់នៅក្រៅប្រទេសកម្ពុជាផល។

លើសពីនេះគម្រោងនេះត្រូវបានលើកលែងពន្ធគយលើការនាំចូលសម្ភារបរិក្ខារ ផលិតកម្ម សម្ភារសាងសង់ និងធាតុចូលផលិតកម្ម។ ដោយឡែក គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បម្រើឱ្យការនាំចេញ ដែលស្ថិតនៅក្រោមយន្តការភណ្ឌាគារផលិតកម្ម ក្រោមការគ្រប់គ្រងរបស់គយ ការលើកលែងពន្ធគយត្រូវអនុវត្តទៅតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានរបស់យន្តការនោះ។ ធាតុចូលផលិតកម្មដែលកែច្នៃហើយមិនបាននាំចេញ ត្រូវបង់ពន្ធគយនិងអាករឡើងវិញលើធាតុចូល ផលិតកម្មនាពេលនាំចូលក្រោយពីការត្រួតពិនិត្យរបាយការណ៍ប្រចាំត្រីមាស។

**២.១.១.២. គម្រោងវិនិយោគដែលជាប្រភេទឧស្សាហ៍កម្មគាំទ្រ**

គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលជាប្រភេទឧស្សាហ៍កម្មគាំទ្រ សំដៅដល់ "គ.ល.គ" ដែលធ្វើសកម្មភាពបង្កើតផលិតផលរបស់ខ្លួននៅក្នុងសមាមាត្រណាមួយដែលត្រូវផ្គត់ផ្គង់ដល់ឧស្សាហកម្មនាំចេញ ដែលជំនួសវត្ថុធាតុដើម ឬសម្ភារបន្ទាប់បន្សំដែលតែងតែនាំចូល។ គម្រោងវិនិយោគប្រភេទនេះដើរតួនាទីក្នុងការផលិតផលិតផលដែលមិនទាន់សម្រេច ក្នុងការផ្តល់ការផ្គត់ផ្គង់ដល់គម្រោងវិនិយោគផ្សេងទៀតដើម្បីឱ្យក្លាយទៅជាផលិតផលសម្រេច។

**២.១.១.៣. គម្រោងវិនិយោគមានទិសដៅបម្រើតម្រូវការក្នុងស្រុក**

គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បម្រើទីផ្សារក្នុងស្រុក សំដៅដល់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលមិនបម្រើឱ្យការនាំចេញ។ ក្នុងន័យនេះ គម្រោងវិនិយោគប្រភេទនេះមិនធ្វើការលក់ផលិតផលរបស់ខ្លួន ដែលបានមកពីសកម្មភាពវិនិយោគទាំងអស់បម្រើឱ្យតែតម្រូវការក្នុងស្រុកប៉ុណ្ណោះ ពោលគឺធ្វើការផ្គត់ផ្គង់ផលិតផលទាំងអស់របស់ខ្លួន ដែលផលិតបានតែនៅក្នុងប្រទេសកម្ពុជា។

ហើយគម្រោងវិនិយោគប្រភេទនេះ ត្រូវបានលើកលែងពន្ធគយលើការនាំចូលសម្ភារបរិក្ខារ ផលិតកម្ម និងសម្ភារសាងសង់តែប៉ុណ្ណោះ។ ក្នុងករណីដែលគម្រោងប្រភេទនេះមានលទ្ធភាពនាំចេញនូវផ្នែកណាមួយនៃផលិតផល ដែលផលិតបានដោយផ្ទាល់ ឬបានផ្គត់ផ្គង់ដល់ឧស្សាហកម្មនាំចេញ បរិមាណធាតុចូល

ផលិតកម្ម ដែលបានបង់ពន្ធនាំចូលរួច យកទៅផលិតបម្រើការនាំចេញដោយផ្ទាល់ ឬដោយប្រយោលនោះ ត្រូវបានទទួលការលើកលែងពន្ធគយ ក្រោយពីការត្រួតពិនិត្យរបាយការណ៍ប្រចាំត្រីមាស។

### ២.១.២. គម្រោងពង្រីកនៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់

គម្រោងពង្រីកនៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ សរសេរជាអក្សរកាត់ គ.ព.គ.ល.គ. សំដៅលើដល់ការពង្រីកគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលធ្វើឡើងតាមរូបភាពណាមួយ មានជាអាទិ៍ ការពង្រីកផលិតកម្មដែលមានស្រាប់ ការពង្រីកតាមរយៈការធ្វើពិពិធកម្មមុខសញ្ញាផលិតកម្ម ដែលស្ថិតក្នុងសែស្រឡាយផលិតផលជាមួយគ្នា ការពង្រីកតាមរយៈការបំពាក់បច្ចេកវិទ្យាទំនើបថ្មីដែល លើកកម្ពស់ផលិតភាព ឬការពារបរិស្ថាន ការពង្រីកហេដ្ឋារចនាសម្ព័ន្ធបម្រើឱ្យសេវាគមនាគមន៍មូលដ្ឋាន ឬ ការពង្រីកក្រោមរូបភាពផ្សេងទៀតដែលនឹងត្រូវកំណត់ដោយអនុក្រឹត្យ។[37] ទុនពង្រីកគម្រោងវិនិយោគមាន លក្ខណៈសម្បត្តិគ្រប់គ្រាន់ សំដៅដល់ទុនវិនិយោគដែលត្រូវប្រើប្រាស់សម្រាប់តែការវិនិយោគលើសម្ភារៈ សាងសង់ និងសម្ភារៈបរិក្ខារផលិតកម្មថ្មី។

### ២.១.៣. គម្រោងវិនិយោគដែលទទួលបានត្រឹមតែការធានាលើការវិនិយោគ

គម្រោងវិនិយោគដែលទទួលបានត្រឹមតែការធានាលើការវិនិយោគ សរសេរជាអក្សរកាត់ គ.ធ.វ. សំដៅដល់គម្រោងវិនិយោគដែលបានចុះបញ្ជីនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬនៅអនុគណៈកម្មាធិការ វិនិយោគរាជធានី ខេត្ត ដោយមានបញ្ជាក់ច្បាស់លាស់ថាជា គ.ធ.វ. ប៉ុន្តែពុំទទួលបានការលើកទឹកចិត្តផ្នែក សារពើពន្ធ (យោងតាមមាត្រា ៣ នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា)។

## ២.២.នីតិវិធីនៃការចុះបញ្ជីគម្រោងវិនិយោគ

ដើម្បីទទួលបានសិទ្ធិអនុវត្តសកម្មភាពវិនិយោគក្នុងព្រះរាជាណាចក្រកម្ពុជា រាល់បុគ្គលដែលមាន បំណងបង្កើតគម្រោងវិនិយោគ ត្រូវគោរពតាមនីតិវិធីនៃការចុះបញ្ជីគម្រោងវិនិយោគ ស្របទៅនឹងប្បបញ្ញត្តិ នៃច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។ ជាគោលការណ៍គតិយុត្ត បុគ្គលដែលមានបំណងចង់មករកស៊ី ឬវិនិយោគនៅក្នុងប្រទេសកម្ពុជា ជាដំបូង គឺត្រូវឆ្លងកាត់នូវការចុះបញ្ជីពាណិជ្ជកម្មទៅលើក្រុមហ៊ុននោះជា មុនសិន ទើបអាចស្នើសុំចុះបញ្ជីគម្រោងវិនិយោគ ព្រមជាមួយនឹងការស្នើសុំអាជ្ញាប័ណ្ណផ្សេងៗទៀតដែល កំណត់ដោយបទប្បញ្ញត្តិច្បាប់។ ការចុះបញ្ជីពាណិជ្ជកម្មនេះ ធ្វើឡើងដើម្បីធានាអោយបាននូវភាពស្រប ច្បាប់របស់ក្រុមហ៊ុនអ្នកវិនិយោគ រួមទាំងឈ្មោះក្រុមហ៊ុន ប្រភេទក្រុមហ៊ុន ផលិតផល និងសេវាកម្មរបស់ ក្រុមហ៊ុន ដែលត្រូវកំណត់នៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុននោះ។ អ្នកដាក់ពាក្យសុំត្រូវធ្វើការស្នើសុំចុះបញ្ជី

[37] យោងតាមមាត្រា ៣ នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខៈ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១។

នៅក្រសួងពាណិជ្ជកម្ម ដោយបំពេញរាល់សំណុំឯកសារតាមបែបបទដែលក្រសួងបានកំណត់ បន្ទាប់ពីបំពេញរួចរាល់ហើយអ្នកស្នើសុំត្រូវបង់ថ្លៃសេវាក្នុងការសិក្សាសំណុំឯកសារចុះបញ្ជី នៅពេលដែលការចុះបញ្ជីពាណិជ្ជកម្មបានសម្រេចអ្នកស្នើសុំនឹងទទួលបានលិខិតបញ្ជាក់ពីការចុះបញ្ជី ទទួលស្គាល់នីតិបុគ្គលស្របច្បាប់ ដោយនីតិវិធីនេះអនុលោមតាមច្បាប់ស្ដីពីវិធានពាណិជ្ជកម្ម និងចុះបញ្ជីពាណិជ្ជកម្ម និងច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម។ ការចុះបញ្ជីពាណិជ្ជកម្មនេះក៏អាចប្រព្រឹត្តទៅតាមរយៈថ្នាលព័ត៌មានវិទ្យា ដែលនីតិវិធីនៃការចុះបញ្ជីមានកំនត់នៅក្នុងអនុក្រឹត្យស្ដីពីការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។

បន្ទាប់ពីការចុះបញ្ជីពាណិជ្ជកម្មខាងលើរួចមក អ្នកស្នើសុំគម្រោងវិនិយោគ ត្រូវដាក់សំណើសុំចុះបញ្ជីគម្រោងវិនិយោគទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ឬអនុគណៈកម្មាធិការរាជធានី ខេត្ត ក្នុងគោលបំណងបង្កើតគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (គ.ល.គ.) ឬគម្រោងវិនិយោគដែលទទួលបានត្រឹមតែការធានាលើការវិនិយោគ (គ.ធ.វ) ទៅតាមទម្រង់ និងនីតិវិធីដែលមានចែងនៅក្នុងច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចកកម្ពុជា និងបទប្បញ្ញត្តិពាក់ព័ន្ធ ដើម្បីទទួលបានវិញ្ញាបនបត្រចុះបញ្ជីដែលបញ្ជាក់ពីការទទួលស្គាល់គម្រោងវិនិយោគ។ សំណើនេះអាចរាប់បញ្ចូលដំណាក់កាលមួយ ឬច្រើនដោយរួមបញ្ចូលទាំងសំណើសុំពង្រីកគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (គ.ព.គ.ល.គ.)។ ដំណាក់កាលនៃការចុះបញ្ជីគម្រោងវិនិយោគត្រូវចាប់ផ្ដើមពីការបំពេញនូវ "លក្ខខណ្ឌទាក់ទងនឹងការដាក់ពាក្យសុំវិញ្ញាបនបត្រ" (៣.១) មុននឹងឈានដល់ "នីតិវិធីនៃការសម្រេចចុះបញ្ជីរបស់ស្ថាប័នទទួលបន្ទុកកិច្ចការវិនិយោគ" (៣.២)។

### ២.២.១. លក្ខខណ្ឌទាក់ទងនឹងការដាក់ពាក្យសុំវិញ្ញាបនបត្រ

ដើម្បីទទួលបានវិញ្ញាបនបត្រចុះបញ្ជីវិនិយោគ អ្នកដាក់ពាក្យសុំត្រូវបំពេញនូវលក្ខខណ្ឌទម្រង់ដែលចាំបាច់នោះគឺការដាក់ពាក្យសុំ (២.២.១.១) និងការជ្រើសរើសការលើកទឹកចិត្ត (២.២.១.២)។

#### ២.២.១.១. ការដាក់ពាក្យសុំ

នៅក្នុងដំណាក់កាលនៃការដាក់ពាក្យស្នើសុំនេះ ត្រូវតែឆ្លងកាត់ស្ថាប័នមានសមត្ថកិច្ចទទួលបន្ទុកកិច្ចការវិនិយោគ គឺត្រូវដាក់ពាក្យសុំទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ឬអនុគណៈកម្មាធិការរាជធានី ខេត្តតាមរយៈយន្តការច្រកចេញចូលតែមួយ ដែលវាអាស្រ័យទៅលើចំនួនទឹកប្រាក់នៃគម្រោងវិនិយោគដែលស្នើសុំនោះ។ ចំពោះគម្រោងវិនិយោគដែលមានទុនវិនិយោគសមមូលនឹង ៥.០០០.០០០ ដុល្លារអាមេរិកចុះ អ្នកស្នើត្រូវដាក់ពាក្យសុំទៅ "អនុគណៈកម្មាធិការរាជធានី ខេត្ត" ទៅតាមដែនសមត្ថកិច្ចរបស់រដ្ឋបាលរាជធានីខេត្តសាមីនីមួយៗ រីឯគម្រោងវិនិយោគដែលមានទុនវិនិយោគចាប់ពី ៥.០០០.០០០ ដុល្លារអាមេរិកឡើងទៅ អ្នកស្នើត្រូវដាក់ពាក្យសុំទៅ "CDC" ។

រាល់បុគ្គលដែលមានបំណងអនុវត្ត **គ.ល.គ.** ឬ**គ.ព.គ.ល.គ.** ឬ**គ.ធ.វ.** ត្រូវដាក់សំណើសុំចុះបញ្ជីជាលាយលក្ខណ៍អក្សរនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ឬអនុគណៈកម្មាធិការរាជធានី ខេត្ត។ អ្នកស្នើសុំចុះបញ្ជីវិនិយោគ ត្រូវអនុវត្តតាមទម្រង់បែបបទនៃការដាក់ពាក្យសុំ ដែលត្រូវបំពេញអោយបានសព្វគ្រប់ ហើយចុះហត្ថលេខាត្រឹមត្រូវដោយម្ចាស់គម្រោងដែលមានសិទ្ធិ ឬអ្នកតំណាងអោយអ្នកដាក់ពាក្យសុំដែលមានប្រគល់សិទ្ធិត្រឹមត្រូវ និងត្រូវបង់ថ្លៃចុះបញ្ជី ចំនួន ១៥.០០០.០០០ រៀល (យោងតាមប្រកាសរួមស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា) នៅ CDC ឬអនុគណៈកម្មាធិការរាជធានី ខេត្ត ដែលជាថ្លៃសេវារដ្ឋបាលដើម្បីទទួលបាននូវរាល់ការយល់ព្រម ការអនុញ្ញាត អាជ្ញាប័ណ្ណ ឬបញ្ជីការនានាពីគ្រប់ក្រសួង ស្ថាប័ន មន្ទីរមានសមត្ថកិច្ចពាក់ព័ន្ធទាំងអស់រួមទាំងពន្ធប្រថាប់ត្រាផលដែរ។ ចំពោះទម្រង់បែបបទនៃពាក្យសុំ មានកំណត់នៅក្នុងឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យលេខ១១១ អនក្រ.បក. ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា (សូមពិគ្រោះនៅក្នុងឧបសម្ព័ន្ធទី២៖ តារាងបង្ហាញអំពីការដាក់សំណើទៅស្ថាប័នមានសមត្ថកិច្ចតាមទំហំទឹកប្រាក់)។

អនុលោមតាមច្បាប់វិនិយោគថ្មី សំណើសុំចុះបញ្ជីគម្រោងវិនិយោគអាចត្រូវបានធ្វើឡើងតាមរយៈថ្នាលបច្ចេកវិទ្យាព័ត៌មាន (តាមរយៈប្រព័ន្ធអនឡាញ)[38] តាមរយៈ http://qip.cdc.gov.kh/login។ អ្នកស្នើសុំក៏អាចចុះបញ្ជីតាមរយៈ https://www.registrationservices.gov.kh ដែលជាគេហទំព័រចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលត្រូវបានរៀបចំឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោយប្រើប្រាស់ប្រព័ន្ធ Cambodia Data Exchange - CamDX ដែលជាថ្នាល់ផ្លាស់ប្តូរទិន្នន័យកម្ពុជា។ តាមរយៈ CamDX អ្នកស្នើសុំអាចប្រើប្រាស់ CamDigiKey គឺជាកម្មវិធីទូរស័ព្ទសម្រាប់ផ្ទៀងផ្ទាត់អត្តសញ្ញាណតាមរយៈ QR Code របស់រាជរដ្ឋាភិបាលកម្ពុជាដែលភ្ជាប់អ្នកប្រើប្រាស់ទៅនឹងសេវាកម្មរដ្ឋាភិបាលឌីជីថលទាំងអស់នៅកម្ពុជា ដោយអនុលោមតាមអនុក្រឹត្យស្តីពីការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (សូមពិគ្រោះនៅក្នុងឧបសម្ព័ន្ធទី២៖ រូបភាពបង្ហាញអំពីនីតិវិធីនៃការចុះបញ្ជីតាមរយៈថ្នាលបច្ចេកវិទ្យាព័ត៌មាន)។ ការចុះបញ្ជីតាមរយៈថ្នាលបច្ចេកវិទ្យាព័ត៌មានផ្តល់អត្ថប្រយោជន៍ដូចខាងក្រោម៖

- លុបបំបាត់ការបំពេញឯកសារដដែលៗ និងចំណាយពេលវេលារង់ចាំយ៉ាង
- ចំណាយថវិកាតិចជាងមុនច្រើន

[38] យោងតាមមាត្រា ១០ នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ៖ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១។

- ទូទាត់ថ្លៃសេវាទាំងអស់ក្នុងការចុះបញ្ជីអាជីវកម្មក្នុងពេលតែមួយតាមអនឡាញ
- វិញ្ញាបនបត្រចុះបញ្ជីគម្រោងតាមទម្រង់ឌីជីថល។

**ក. ការដាក់ពាក្យសុំដោយអ្នកតំណាង**

អ្នកតំណាងចុះបញ្ជី សំដៅដល់បុគ្គលដែលទទួលស្គាល់ដោយក្រសួង-ស្ថាប័នមានសមត្ថកិច្ច និងទទួលបានការផ្ទេរសិទ្ធិពីបុគ្គលស្នើសុំ ដើម្បីដាក់ពាក្យសុំចុះបញ្ជីគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដោយបំពេញបែបបទ និងលក្ខខណ្ឌតម្រូវព័ត៌មានដែលមានកំណត់បទប្បញ្ញត្តិច្បាប់។ នៅក្នុងករណីដែលសំណើនៃគម្រោងវិនិយោគ ចុះហត្ថលេខាដោយអ្នកតំណាងរបស់អ្នកដាក់ពាក្យសុំ ឯកសារភស្តុតាងស្តីពីការទទួលសិទ្ធិអោយចុះហត្ថលេខារបស់អ្នកតំណាង ត្រូវដាក់ជូនទៅ CDC ឬអនុគណៈកម្មាធិការរាជធានីខេត្ត។[39] បុគ្គលស្នើសុំ ក៏អាចផ្ទេរសិទ្ធិអោយអ្នកតំណាងចុះបញ្ជី ដើម្បីធ្វើការចុះបញ្ជីគម្រោងវិនិយោគតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានខាងលើក្នុងនាមបុគ្គលស្នើសុំ ដោយមានភ្ជាប់មកជាមួយនូវឯកសារផ្ទេរសិទ្ធិ ឬ/និង ឯកសារពាក់ព័ន្ធ ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។[40]

**ខ. ករណីគម្រោងពហុសកម្មភាព**

ប្រសិនបើបុគ្គលណាម្នាក់ ឬមួយក្រុមមានបំណងចង់ធ្វើការវិនិយោគ និងដំណើរការលើសកម្មភាពវិនិយោគលើសពីមួយឡើងទៅ ហើយប្រសិនបើគម្រោងត្រូវបានចុះបញ្ជី ដើម្បីដំណើរការជា គ.ល.គ បុគ្គលនោះត្រូវដាក់សំណើវិនិយោគដាច់ដោយឡែកពីគ្នាសម្រាប់សកម្មភាពវិនិយោគនីមួយៗ។[41]

**២.២.១.២. ការជ្រើសរើសការលើកទឹកចិត្ត**

នៅពេលបំពេញទម្រង់នៃពាក្យស្នើសុំវិនិយោគ អ្នកស្នើសុំ ត្រូវជ្រើសរើសរវាងការលើកលែងពន្ធលើប្រាក់ចំណេញ រំលោះពិសេស ឬដើម្បីទទួលបានតែការធានាលើការវិនិយោគ (មិនទាមទារការលើកទឹកចិត្ត) ដែលនៅក្នុងចំណោមជម្រើសទាំងនេះ វិនិយោគិនមានសិទ្ធិជ្រើសរើសបានតែមួយគត់។ ការជ្រើសរើសនេះវាអាស្រ័យលើថាតើគម្រោងវិនិយោគនោះជា គ.ល.គ.ដែរឬទេ ទើបអាចទទួលបានការលើកទឹកចិត្ត។ ករណីដែលគម្រោងវិនិយោគមិនមែនជា គ.ល.គ. ក៏វិនិយោគិនអាចជ្រើសរើសការការធានាលើការវិនិយោគលើគម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិមិនគ្រប់គ្រាន់បានដែរ។

[39] យោងតាមមាត្រា ៥ ចំណុច ៥.៣ នៃអនុក្រឹត្យលេខ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

[40] យោងតាមមាត្រា ៥ កថាខណ្ឌទី២ នៃអនុក្រឹត្យលេខ៨៤ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។

[41] យោងតាមមាត្រា ៥ ចំណុច ៥.៤ នៃអនុក្រឹត្យលេខ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

### ២.២.៣. នីតិវិធីនៃការសម្រេចចុះបញ្ជីរបស់ស្ថាប័នទទួលបន្ទុកកិច្ចការវិនិយោគ

ស្ថាប័នទទួលបន្ទុកកិច្ចការវិនិយោគ មានតួនាទីក្នុងការចេញវិញ្ញាបនបត្រចុះបញ្ជីនៃគម្រោងវិនិយោគដែលបានដាក់ជូន ដោយការពិនិត្យ និងសម្រេចទៅលើសំណើនោះ។ ការចេញសេចក្ដីសម្រេចយល់ព្រម ឬបដិសេធនៃសំណើវិនិយោគត្រូវឆ្លងកាត់ដំណាក់កាលពិនិត្យស្ថានភាព និងការជូនដំណឹងដល់អ្នកស្នើសុំតាមនីតិវិធីដូចខាងក្រោម។

#### ២.២.៣.១. ការពិនិត្យលើទម្រង់នៃពាក្យស្នើសុំ

នៅពេលទទួលបានសំណើចុះបញ្ជីគម្រោងវិនិយោគ CDC ត្រូវពិនិត្យ និងសម្រេចលើសំណើនេះតាមយន្តការច្រកចេញ-ចូលតែមួយ ដែលជាយន្តការពិនិត្យ និងសម្រេចក្នុងការចុះបញ្ជីគម្រោងវិនិយោគដោយតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធដែលប្រចាំការនៅ CDC ទៅតាមការចាត់តាំង និងប្រតិភូកម្មសិទ្ធិអំណាចពីប្រធានក្រសួង-ស្ថាប័ន ក្រោមការសម្របសម្រួលរបស់ CDC[42]។ ចំពោះការពិនិត្យ និងសម្រេចចុះបញ្ជីលើសំណើវិនិយោគរបស់អនុគណៈកម្មាធិការរាជធានី ខេត្ត ត្រូវប្រើប្រាស់អង្គភាពយន្តការច្រកចេញ-ចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ដែលជាច្រកសម្រាប់ទទួល និងផ្ដល់សេវារដ្ឋបាលដល់វិនិយោគិន ដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់រដ្ឋបាលរាជធានី ខេត្តសាមីនីមួយៗ។

##### ក. លក្ខខណ្ឌទាក់ទងនឹងក្រសួង-ស្ថាប័នពាក់ព័ន្ធ

តាមរយៈយន្តការច្រកចេញ-ចូលតែមួយ ក្រសួង-ស្ថាប័នពាក់ព័ន្ធនឹងការចុះបញ្ជីនៃគម្រោងវិនិយោគត្រូវចូលរួមពិនិត្យ និងសម្រេចក្នុងការចុះបញ្ជីគម្រោងវិនិយោគ ក្រោមការសម្របសម្រួលរបស់ CDC ឬអនុគណៈកម្មាធិការរាជធានី ខេត្ត ដោយចាត់តាំងតំណាងក្រសួង-ស្ថាប័នរបស់ខ្លួននៅប្រចាំការនៅ CDC និងនៅថ្នាក់រាជធានី ខេត្ត ឬរដ្ឋបាលរាជធានី ខេត្ត ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមានទៅតាមការចាត់តាំង និងប្រតិភូកម្មសិទ្ធិអំណាចពីប្រធានក្រសួង-ស្ថាប័ន ដើម្បីសម្រេចលើកិច្ចការពាក់ព័ន្ធដល់ការចេញលិខិតអនុញ្ញាត អាជ្ញាប័ណ្ណនានា ក្នុងការចុះបញ្ជីគម្រោងវិនិយោគ និងការផ្ដល់ការលើកទឹកចិត្ត ការធានា ព្រមទាំងការទិញលក់ ការរួមបញ្ចូលគ្នា ការលុបគម្រោង និងការដោះស្រាយវិវាទវិនិយោគដែលមានទុនវិនិយោគសមមូលនឹង ៥លានដុល្លារអាមេរិកចុះ។

##### ក.១. ការស្នើសុំការយល់ព្រមនានាពីក្រសួង-ស្ថាប័នពាក់ព័ន្ធ

ការស្នើសុំការយល់ព្រមនានាពីក្រសួង-ស្ថាប័នពាក់ព័ន្ធ ធ្វើឡើងក្នុងគោលបំណងទទួលបាននូវការយល់ព្រម ការអនុញ្ញាត អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬបញ្ជីការនានា ដើម្បីអោយគម្រោងវិនិយោគនោះនឹង

[42] យោងតាមមាត្រា ១២ កថាខណ្ឌទី២ នៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ៖ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១។

ដំណើរការស្របច្បាប់។ ជាក់ស្តែងការវិនិយោគលើវិស័យសំណង់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីមានតួនាទីក្នុងការពិនិត្យសំណុំឯកសារ និងលក្ខខណ្ឌចាំបាច់ ក្នុងការផ្តល់លិខិតអនុញ្ញាតសាងសង់សម្រាប់គម្រោងវិនិយោគនោះ។ ស្ថាប័នពាក់ព័ន្ធផ្សេងទៀតនៅក្នុងវិស័យនេះ រួមមានក្រសួងទេសចរណ៍ និងក្រសួងបរិស្ថាន។ ការសុំអនុញ្ញាតពីក្រសួងទេសចរណ៍ពិតជាមានភាពចាំបាច់ណាស់ ករណីដែលអគារធ្វើឡើងក្នុងបំណងបង្កើតអាជីវកម្មអ្វីមួយ លើសពីនេះមុននឹងសាងសង់សំណង់នៅកន្លែងណាមួយ គឺត្រូវពិនិត្យទៅលើផលប៉ះពាល់នៃបរិស្ថាន ដែលជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថានក្នុងការត្រួតពិនិត្យ។ ការធ្វើបែបនេះវាអាចជៀសវាងពីការប្រឈមនឹងការលុបគម្រោងវិនិយោគ ដោយហេតុថាគម្រោងវិនិយោគនេះ ប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថាន (មូលហេតុនៃការលុបគម្រោងវិនិយោគ នឹងយកមកបកស្រាយលម្អិតនៅជំពូកទី៣)។

**ក.២. ការជួយអន្តរាគមន៍របស់ស្ថាប័នទទួលបន្ទុកកិច្ចការវិនិយោគ**

អនុលោមតាមមាត្រា ៧ ចំណុច ៧.១. នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ៖ក្រុមប្រឹក្សា ឬអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត ត្រូវជួយសុំការយល់ព្រម ការអនុញ្ញាតផ្សេងៗ និងត្រូវទទួលយកជំនួសមុខអោយអ្នកដាក់ពាក្យសុំ នូវការយល់ព្រម ការអនុញ្ញាត អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬបញ្ជីការនានាពីក្រសួង នាយកដ្ឋាន អាជ្ញាធរ មន្ទីរនានាចំណុះខេត្ត ក្រុង ឬដែលមានការពាក់ព័ន្ធផ្សេងៗ របស់រាជរដ្ឋាភិបាល។ ការជួយអន្តរាគមន៍របស់ស្ថាប័នទទួលបន្ទុកកិច្ចការវិនិយោគនេះ គឺដើម្បីជម្រុញដំណើរការឆាប់រហ័ស និងធានាការអនុវត្តគម្រោងវិនិយោគនោះអោយដំណើរការស្របច្បាប់ មុននឹងអនុញ្ញាតលើសំណើវិនិយោគ។

**២.២.៣.២. ការអនុញ្ញាតលើសំណើវិនិយោគ**

ប្រសិនបើគម្រោងវិនិយោគដែលបានដាក់ពាក្យស្នើសុំឡើងមិនស្ថិតនៅក្នុង "បញ្ជីអវិជ្ជមាន" ដែលមានកំណត់នៅក្នុងឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យលេខ១១១ អនក្រ.បក. ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា (បញ្ជីគម្រោងហាមឃាត់នេះ នឹងយកតាមអនុក្រឹត្យថ្មី ស្តីពីការអនុវត្តច្បាប់វិនិយោគថ្មីនៃព្រះរាជាណាចក្រកម្ពុជា ដែលនឹងអនុម័តក្នុងពេលឆាប់ៗខាងមុខនេះ) CDC ឬអនុគណៈកម្មាធិការរាជធានី ខេត្ត ត្រូវពិនិត្យលើភាពត្រឹមត្រូវនៃលក្ខខណ្ឌតម្រូវព័ត៌មាន និងឯកសារភ្ជាប់ដែលត្រូវបានបំពេញគ្រប់គ្រាន់ និងត្រឹមត្រូវ មុននឹងផ្តល់វិញ្ញាបនបត្រចុះបញ្ជី ជូនអ្នកដាក់ពាក្យសុំក្នុងអំឡុងពេលមិនលើសពី ២០ ថ្ងៃនៃថ្ងៃធ្វើការ។ បើយោងតាមនីតិវិធីថ្មីសម្រាប់ការចុះបញ្ជីនៃច្បាប់វិនិយោគថ្មី ចំពោះវិញ្ញាបនបត្រចុះបញ្ជីមានលក្ខខណ្ឌ និងវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរ ត្រូវបានរួមបញ្ចូលគ្នាដោយ CDC ឬអនុគណៈកម្មាធិការរាជធានី ខេត្ត ចេញជា

វិញ្ញាបនបត្រតែមួយហៅថា "**វិញ្ញាបនបត្រចុះបញ្ជី**"។ រាល់ពាក្យស្នើសុំចុះបញ្ជីគម្រោងវិនិយោគដែលគោរព តាមនីតិវិធី និងលក្ខខណ្ឌនៃការស្នើសុំនឹងទទួលបានការអនុញ្ញាតចុះបញ្ជី ក៏ប៉ុន្តែ CDC ឬអនុគណៈកម្មាធិការ រាជធានី ខេត្ត ក៏អាចបដិសេធទៅលើពាក្យស្នើសុំចុះបញ្ជីនោះផងដែរ ក្នុងករណីដែលសំណើវិនិយោគរបស់ វិនិយោគិន ពុំបានឆ្លើយតបតាមលក្ខខណ្ឌនៃការដាក់ពាក្យសុំ។

**២.២.៣.៣. ការបដិសេធលើសំណើវិនិយោគ**

តាមការលើកឡើងខាងលើនៅក្នុងករណីដែលសំណើវិនិយោគរបស់វិនិយោគិន ពុំបានឆ្លើយតបតាម លក្ខខណ្ឌនៃការដាក់ពាក្យសុំទេ CDC ឬអនុគណៈកម្មាធិការរាជធានី ខេត្ត ត្រូវចេញលិខិតបដិសេធជូន ទៅអ្នកស្នើសុំនូវការបដិសេធសំណើវិនិយោគនោះ។ ការពុំឆ្លើយតបតាមលក្ខខណ្ឌនៃការដាក់ពាក្យ រួមមាន ការមិនបានផ្តល់ជូននូវព័ត៌មានគ្រប់គ្រាន់ សំណើវិនិយោគដែលពាក់ព័ន្ធទៅនឹងសកម្មភាពវិនិយោគដែល ស្ថិតក្នុងបញ្ជីអវិជ្ជមាន ឬដែលពីមុនបាន ឬបច្ចុប្បន្នកំពុងដំណើរការដោយអ្នកវិនិយោគ ឬបុគ្គលផ្សេង ហើយដែលបានទទួលរួចហើយនូវការលើកទឹកចិត្តតាមច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។[43] ហេតុនេះរាល់លិខិតបដិសេធត្រូវជូនដំណឹងទៅអ្នកស្នើសុំ និងត្រូវមានបញ្ជាក់ពីមូលហេតុច្បាស់លាស់ អំពី ការមិនអាចទទួលសំណើវិនិយោគនោះ រួមទាំងព័ត៌មានបន្ថែម ដើម្បីផ្តល់លទ្ធភាពដល់ CDC ឬអនុគណៈ កម្មាធិការរាជធានី ខេត្ត អាចចេញវិញ្ញាបនបត្រចុះបញ្ជី លើសំណើដែលបានកែតម្រូវនោះ។[44]

**២.២.៣.៤. ការជូនដំណឹងទៅអ្នកដាក់ពាក្យសុំ**

ប្រសិនបើសំណើវិនិយោគដែលបានដាក់ជូន CDC ឬអនុគណៈកម្មាធិការរាជធានី ខេត្ត មិនស្រប តាមនីតិវិធី និងលក្ខខណ្ឌទម្រង់នោះទេ ក្នុងរយៈពេលយ៉ាងយូរ ២០ថ្ងៃនៃថ្ងៃធ្វើ បន្ទាប់ពីថ្ងៃទទួលបាន សំណើនោះ CDC ឬអនុគណៈកម្មាធិការរាជធានី ខេត្ត ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកដាក់ ពាក្យសុំ ដោយស្នើសុំអោយកែតម្រូវសំណើវិនិយោគ ហើយដាក់សំណើនោះជាថ្មីជូន CDC ឬអនុគណៈ កម្មាធិការរាជធានី ខេត្ត។ ការខកខានមិនបានចេញវិញ្ញាបនបត្រចុះបញ្ជី និងការខកខានមិនបានជូន ដំណឹងអំពីការបដិសេធសំណើតាមរយៈលិខិតបដិសេធរបស់ CDC ឬអនុគណៈកម្មាធិការរាជធានី ខេត្ត ក្នុងរយៈពេល២០ថ្ងៃនៃថ្ងៃធ្វើទេ សំណើវិនិយោគត្រូវបានចាត់ទុកថាបានចុះបញ្ជី ហើយ CDC ឬអនុគណៈ កម្មាធិការរាជធានី ខេត្ត ត្រូវចេញវិញ្ញាបនបត្រចុះបញ្ជី ជូនអ្នកដាក់ពាក្យស្នើសុំជាបន្ទាន់[45]

---

[43] យោងតាមមាត្រា ៦ ចំណុច ៦.១ នៃអនុក្រឹត្យលេខ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តី ពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

[44] យោងតាមមាត្រា ៦ ចំណុច ៦.៦ នៃអនុក្រឹត្យដដែល។

[45] យោងតាមមាត្រា ៦ ចំណុច ៦.៤ នៃអនុក្រឹត្យដដែល។

**២.២.៣.៥. ការចេញវិញ្ញាបនបត្រចុះបញ្ជី**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការរាជធានី ខេត្ត នឹងចេញវិញ្ញាបនបត្រចុះបញ្ជីជូនអ្នកដាក់ពាក្យសុំក្នុងអំឡុងពេលមិនលើសពី ២០ថ្ងៃនៃថ្ងៃធ្វើការ ប្រសិនពុំមានការបដិសេធលើសំណើនោះទេ។ ការចេញវិញ្ញាបនបត្រនៅក្នុងច្បាប់វិនិយោគចាស់រួមមាន២ដំណាក់កាល គឺការចេញវិញ្ញាបនបត្រចុះបញ្ជីមានលក្ខខណ្ឌ (ដំណាក់កាលស្នើសុំការអនុញ្ញាតពីក្រសួងស្ថាប័នពាក់ព័ន្ធ) និងវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរ (ដំណាក់កាលទទួលបានការអនុញ្ញាត និងអាជ្ញាប័ណ្ណនានាពីដំណាក់កាលទី១) ដែលផ្ទុយពីច្បាប់ស្តីពីវិនិយោគថ្មី ការចេញវិញ្ញាបនបត្រទាំងពីរនេះត្រូវបានរួមបញ្ចូលតែមួយដែលហៅថា "វិញ្ញាបនបត្រចុះបញ្ជី"។ វិញ្ញាបនបត្រចុះបញ្ជី ត្រូវមានភ្ជាប់នូវបារកូដដែលមានលេខសម្គាល់ ឬឃ្យូអរកូដ (QR Code) ឬប្រព័ន្ធបច្ចេកវិទ្យាដទៃទៀត ដែលផ្ទុកទិន្នន័យបឋមមួយចំនួនពាក់ព័ន្ធនឹងគម្រោងវិនិយោគ ដែលត្រូវបានចុះបញ្ជី ដើម្បីជាប្រយោជន៍ដល់ការចុះបញ្ជីពាក់ព័ន្ធនានា និងសម្រាប់ការអនុវត្តគម្រោងវិនិយោគ។ លើសពីនេះ ការចុះបញ្ជីតាមរយៈថ្នាលបច្ចេកវិទ្យាព័ត៌មានខាងលើ នឹងទទួលបានវិញ្ញាបនបត្រឌីជីថល ដែលអាចបោះពុម្ពបានសម្រាប់ប្រើប្រាស់ជាផ្លូវការ ជូនបុគ្គលស្នើសុំតាមរយៈគេហទំព័រចុះបញ្ជី[46]។

វិញ្ញាបនបត្រចុះបញ្ជីដែលកំណត់នៅក្នុងច្បាប់វិនិយោគថ្មីនេះ ក្រសួងស្ថាប័នដែលពាក់ព័ន្ធ នឹងការចុះបញ្ជីពាក់ព័ន្ធផ្សេងទៀត និងការពិនិត្យអនុលោមភាពនៃការអនុវត្តគម្រោងវិនិយោគ មិនអាចតម្រូវឲ្យអ្នកដាក់ពាក្យស្នើសុំ ឬអ្នកអនុវត្តគម្រោងវិនិយោគផ្តល់នូវឯកសារនានា ដែលមានស្រាប់នៅក្នុងបាកូដ ដែលមានលេខសំគាល់ ឬឃ្យូអរកូដ (QR Code) ឬប្រព័ន្ធបច្ចេកវិទ្យាដទៃទៀត ដែលជាប់នៅលើវិញ្ញាបនបត្រចុះបញ្ជីដែលចេញដោយ CDC ឬអនុគណៈកម្មាធិការរាជធានី ខេត្ត បានទេ។

[46] យោងតាមមាត្រា ១១ នៃអនុក្រឹត្យស្តីពីការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។

# ជំពូកទី៣
# ការប្រព្រឹត្តទៅនៃគម្រោងវិនិយោគ
# និងនីតិវិធីនៃការដោះស្រាយវិវាទ

# ជំពូកទី៣

# ការប្រព្រឹត្តទៅនៃគម្រោងវិនិយោគ និងនីតិវិធីនៃការដោះស្រាយវិវាទ

គម្រោងវិនិយោគដែលបានទទួលវិញ្ញាបនបត្រចុះបញ្ជីពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬគណៈកម្មាធិការវិនិយោគរាជធានី-ខេត្តរួចហើយ គម្រោងវិនិយោគទាំងនោះអាចចាប់ផ្ដើមសកម្មភាពរបស់ខ្លួនបានដោយស្វ័យប្រវត្តិ ដែលយើងនឹងធ្វើការពន្យល់នៅក្នុងផ្នែកទី១៖ ការប្រព្រឹត្តទៅនៃគម្រោងវិនិយោគ។ លើសពីនេះនៅក្នុងការប្រព្រឹត្តទៅនៃការអនុវត្តសកម្មភាពវិនិយោគ វាជៀសមិនផុតអំពីវិវាទដែលអាចនឹងកើតឡើងជាយថាហេតុដែលកើតឡើងរវាងវិនិយោគិន និងវិនិយោគិន ឬវិនិយោគិន និងរាជរដ្ឋាភិបាល ឬក៏វិនិយោគិនជាមួយនឹងប្រជាពលរដ្ឋ ដែលការដោះស្រាយវិវាទទាំងនេះ ដែលចំណុចនេះយើងនឹងធ្វើការបកស្រាយក្នុងផ្នែកទី២៖ នីតិវិធីនៃការដោះស្រាយវិវាទពាក់ព័ន្ធនឹងគម្រោងវិនិយោគ។

## ផ្នែកទី១៖ ការប្រព្រឹត្តទៅនៃគម្រោងវិនិយោគ

ច្បាប់ស្តីពីវិនិយោគថ្មីបានបញ្ញត្តថា គម្រោងវិនិយោគដែលទទួលបានវិញ្ញាបនបត្រចុះបញ្ជី អាចចាប់ផ្ដើមអនុវត្តបានដោយស្វ័យប្រវត្តិ។[47] ហេតុនេះការប្រព្រឹត្តទៅនៃគម្រោងវិនិយោគនឹងចាប់ផ្ដើមពីការអនុវត្តគម្រោងវិនិយោគ (១.១) រួមជាមួយកាតព្វកិច្ចរបស់អ្នកអនុវត្តគម្រោងវិនិយោគ (១.២) លើសពីនេះនៅពេលកំពុងអនុវត្តក៏អាចធ្វើការកែប្រែគម្រោងវិនិយោគ (១.៣) ដូចជាការទិញលក់ ឬការរួមបញ្ចូលគ្នា មុននឹងឈានដល់ការលុបចោលគម្រោងវិនិយោគ (១.៤)។

### ១.១. ការចាប់ផ្ដើមនៃការអនុវត្តគម្រោងវិនិយោគ

គម្រោងវិនិយោគចាប់ផ្ដើមនៅថ្ងៃចេញវិញ្ញាបនបត្រចុះបញ្ជី ហើយចំពោះគម្រោងវិនិយោគ ដែលទទួលបានការលើកទឹកចិត្តនឹងចាប់ផ្ដើមរយៈពេលគន្លឹះ សម្រាប់ការគណនារយៈពេលលើកលែងពន្ធលើប្រាក់ចំណេញ។ គួរបញ្ជាក់ផងដែល ការទទួលបានវិញ្ញាបនបត្រចុះបញ្ជី មិនមែនជាការលើកលែងអោយគម្រោងវិនិយោគរួចផុតពីការទទួលនូវលិខិតអនុញ្ញាតតាមការកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិនានាឡើយ ដូចមានចែងនៅក្នុងច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០២១ ត្រង់មាត្រា១៣។ តាមន័យនេះ គម្រោងវិនិយោគ ដែលទទួលបានវិញ្ញាបនបត្រចុះបញ្ជី មិនមែនជាការលើកលែងអោយគម្រោងវិនិយោគរួចផុតពីការទទួលនូវលិខិតអនុញ្ញាតតាមការកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិនានាឡើយ។ ពោលគឺអ្នកដាក់ពាក្យស្នើសុំ ឬអ្នកអនុវត្តគម្រោងវិនិយោគចាំបាច់ត្រូវស្នើសុំការយល់ព្រមនានាពី

[47] យោងតាមមាត្រា ១៣ កថាខណ្ឌទី១ នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ៖ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១។

ស្ថាប័នពាក់ព័ន្ធ តាមរយៈការជួយអន្តរាគមន៍របស់ ក.អ.ក. ឬ អ.គ.វ.រ.ខ.។

### ១.២. កាតព្វកិច្ចរបស់អ្នកវិនិយោគ ឬអ្នកអនុវត្តគម្រោងវិនិយោគ

នៅក្នុងការអនុវត្តសកម្មភាពវិនិយោគ អ្នកអនុវត្តគម្រោងវិនិយោគមានកាតព្វកិច្ចជូនរដ្ឋ ដែលរួមមាន៖ កាតព្វកិច្ចផ្តល់របាយការណ៍ស្តីពីការអនុវត្តគម្រោងវិនិយោគ (១.២.១) កាតព្វកិច្ចចំពោះពន្ធ (១.២.២) កាតព្វកិច្ចរាយការណ៍ស្តីពីសារពើពន្ធ (១.២.៣) និងកាតព្វកិច្ចរាយការណ៍ស្តីពីការលើកលែងពន្ធគយ (១.២.៤)។

#### ១.២.១. កាតព្វកិច្ចផ្តល់របាយការណ៍ស្តីពីការអនុវត្តគម្រោងវិនិយោគ

រាល់គម្រោងវិនិយោគត្រូវជាកម្មវត្ថុនៃការតាមដាន និងត្រួតពិនិត្យតាមរយៈយន្តការច្រកចេញ-ចូលតែមួយសម្របសម្រួលដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ដើម្បីធានានូវអនុលោមភាពគតិយុត្ត និងលក្ខខណ្ឌនានាដែលជាមូលហេតុនៃការទទួលបានវិញ្ញាបនបត្រចុះបញ្ជី។ ហេតុនេះ អ្នកអនុវត្តគម្រោងវិនិយោគត្រូវផ្តល់របាយការណ៍ស្តីពីការអនុវត្តគម្រោងវិនិយោគ ទៅតាមកាលវិភាគជាក់លាក់ដែលកំណត់ដោយ CDC (ទម្រង់ និងបែបបទលម្អិតនៃគំរូរបាយការណ៍ត្រូវកំណត់ដោយសេចក្តីណែនាំរបស់ CDC )។ កាតព្វកិច្ចក្នុងការផ្តល់របាយការណ៍នេះ ពុំមែនជាមូលដ្ឋាននៃការរួចផុតពីការពិនិត្យអនុលោមភាពក្នុងការអនុវត្តគម្រោងនៅនឹងកន្លែងអនុវត្តគម្រោងទេ ប្រសិនបើ CDC សន្មតថាមានភាពចាំបាច់ ឬមានការតវ៉ាណាមួយពីបុគ្គលដែលអះអាងថាបានទទួលរងនូវផលប៉ះពាល់ពីការអនុវត្តគម្រោងវិនិយោគ[48]។

#### ១.២.២. កាតព្វកិច្ចចំពោះពន្ធ

ជាគោលការណ៍ច្បាប់ អ្នកវិនិយោគត្រូវមានកាតព្វកិច្ចចំពោះពន្ធ និងត្រូវប្រតិបត្តិតាមបទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ ច្បាប់ស្តីពីសារពើពន្ធ ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងបទប្បញ្ញត្តពាក់ព័ន្ធ។ ការលើកលែងទាំងស្រុង ឬមួយផ្នែកនៃពន្ធអាករ និងពន្ធគយ ត្រូវអនុវត្តចំពោះតែពន្ធលើប្រាក់ចំណេញ និងពន្ធគយ ដែលការលើកលែងនេះ ពុំរាប់បញ្ចូលនូវពន្ធអាករដូចខាងក្រោមនេះទេ[49]៖

ក. ពន្ធលើប្រាក់បៀវត្ស ពន្ធកាត់ទុក និងពន្ធលើប្រាក់ចំណេញបន្ថែមលើការបែងចែកភាគលាភ និង

ខ. អាករលើតម្លៃបន្ថែម អាករពិសេសលើទំនិញ និងសេវាមួយចំនួន អាករដែលត្រូវបង់នៅពេលនាំ

---

[48] យោងតាមមាត្រា ១៣ នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ៖ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១។

[49] យោងតាមមាត្រា ១៤ នៃអនុក្រឹត្យលេខ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

ចូល និងពន្ធអាករដទៃទៀត ដូចមានចែងនៅក្នុងច្បាប់មានសុពលភាពជាធរមាន។

យោងអនុក្រឹត្យស្តីពីការកែសម្រួលមាត្រា១៥ នៃអនុក្រឹត្យលេខ១១១ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា "ពន្ធលើប្រាក់ចំណូល" រួមជាមួយនឹងបទប្បញ្ញត្តិនៅក្នុងច្បាប់វិនិយោគថ្មី៖ រយៈពេលលើកលែងពន្ធលើប្រាក់ចំណូលរួមមានរយៈពេលពី៣ ទៅ៩ឆ្នាំ។ រយៈពេលលើកលែងពន្ធលើប្រាក់ចំណូល ជារយៈពេលដែលចាប់ផ្តើមពីថ្ងៃចេញវិញ្ញាបនបត្រចុះបញ្ជីវិនិយោគ និងបញ្ចប់នៅថ្ងៃចុងក្រោយនៃឆ្នាំជាប់ពន្ធណាមួយ។ ដូចបានលើកឡើងនៅក្នុងជំពូកទី២ ចំណុច ១.២.១.២. "ការលើកទឹកចិត្តជាមូលដ្ឋាន" បន្ទាប់ពីផុតរយៈពេលលើកលែងពន្ធលើប្រាក់ចំណូល គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (គ.ល.គ.) មានសិទ្ធិទទួលបានការលើកទឹកចិត្តឱ្យបង់ពន្ធលើប្រាក់ចំណូលតាមអត្រាកំណើនតាមពេលធៀបទៅនឹងប្រាក់ពន្ធត្រូវបង់សរុបដូចតទៅ៖ ២៥% សម្រាប់ ២ឆ្នាំដំបូង, ៥០% សម្រាប់ ២ឆ្នាំបន្ទាប់ និង៧៥% សម្រាប់ ២ឆ្នាំចុងក្រោយ។ គួរបញ្ជាក់ផងដែរថា អត្រាពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ គឺ២០% ចំពោះប្រាក់ចំណេញដែលសម្រេចដោយនីតិបុគ្គល (ក្រុមហ៊ុនឯកជន) អនុលោមតាមច្បាប់ស្តីពីសារពើពន្ធ។[50] តាមន័យយើងអាចបង្ហាញបានថាអ្នកវិនិយោគនឹងបង់ពន្ធលើប្រាក់ចំណូល ក្រោយផុតរយៈពេលលើកលែងពន្ធពី៣ឆ្នាំ ទៅ៩ឆ្នាំ (គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ខ្លះទទួលបានការលើកលែងពន្ធរយៈពេល ៣ឆ្នាំ ឬ ៥ឆ្នាំ ឬ៧ឆ្នាំជាអាទិ៍) នឹងមិនទាន់បង់ពន្ធ២០%លើប្រាក់ចំណេញភ្លាមនោះទេ ពោលគឺនៅក្នុងរយៈពេល២ឆ្នាំដំបូងក្រោយរយៈពេលលើកលែងពន្ធ គឺត្រូវបង់៥% ហើយរយៈពេល២ឆ្នាំបន្ទាប់ គឺត្រូវបង់៧.៥% និងរយៈពេល២ឆ្នាំចុងក្រោយ គឺត្រូវបង់១០% មុននឹងត្រូវបង់ ២០%ពេញ។[51] គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មានកាតព្វកិច្ចកាន់កត់ត្រាបញ្ជិកាគណនេយ្យអោយបានត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ និងបទប្បញ្ញត្តិគតិយុទ្ធដទៃទៀតនៃព្រះរាជាណាចក្រកម្ពុជា។ ករណីដែលគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មិនបានកាន់កត់ត្រាបញ្ជិកាគណនេយ្យត្រឹមត្រូវ ពន្ធអប្បបរមាត្រូវអនុវត្តតាមអត្រា ១%នៃផលរបរ គិតរួមបញ្ចូលទាំងពន្ធទាំងអស់លើកលែងតែអាករលើតម្លៃបន្ថែម ដូចមានចែងនៅក្នុងមាត្រា២៤ថ្មី (ពីរ) នៃច្បាប់ស្តីពីសារពើពន្ធ។[52]

[50] យោងតាមមាត្រា២០ ថ្មី ចំណុចទី១ នៃច្បាប់ស្តីពីសារពើពន្ធ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ៖ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧។

[51] យោងតាមប្រសាសន៍របស់ ឯកឧត្តម សុខ ចិន្តាសោភា រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអគ្គលេខាធិការនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា តាមរយៈកិច្ចសម្ភាសន៍នៅក្នុងកម្មវិធីជជែកពីច្បាប់លើប្រធានបទ៖ ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

[52] យោងតាមមាត្រា ១៥ នៃអនុក្រឹត្យលេខ៣៣ អនក្រ.បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ ស្តីពីការកែសម្រួលមាត្រា១៥ នៃអនុក្រឹត្យលេខ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ការអនុវត្តច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

### **១.២.៣. កាតព្វកិច្ចរាយការណ៍ស្តីពីសារពើពន្ធ**

កាតព្វកិច្ចរាយការណ៍ស្តីពីសារពើពន្ធ ដូចបានកំណត់ក្នុងមាត្រា១០៤ថ្មីនៃច្បាប់ស្តីពីសារពន្ធ ចាប់ពីថ្ងៃចេញវិញ្ញាបនបត្រចុះបញ្ជីវិនិយោគ ដែលគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទាំងអស់ ត្រូវដាក់លិខិតប្រកាសសារពើពន្ធប្រចាំខែសម្រាប់ខែនីមួយៗ និងលិខិតប្រកាសសារពើពន្ធប្រចាំឆ្នាំសម្រាប់ឆ្នាំសារពើពន្ធនោះ និងបង់ពន្ធអាករទាំងអស់តាមបទប្បញ្ញត្តិនៃពន្ធនីមួយៗ ជូននាយកដ្ឋានពន្ធដារ ដោយត្រូវដាក់ភ្ជាប់នូវវិញ្ញាបនបត្របញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋសម្រាប់ឆ្នាំសារពើពន្ធ។[53]

វិញ្ញាបនបត្របញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋ ត្រូវបានចេញជាស្វ័យប្រវត្តិជូនគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្នុងរយៈពេល ៩០ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីដំណាច់ឆ្នាំសារពើពន្ធនីមួយៗ។ ការផ្តល់កិច្ចសម្រួលដល់អ្នកវិនិយោគដើម្បីទទួលបានវិញ្ញាបនបត្របញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋ "Certificate of Conformity ឬ C.O.C" សំដៅជួយសម្រួលដល់ក្រុមហ៊ុនអាចបន្តទទួលបាននូវកញ្ចប់លើកទឹកចិត្ត សម្រាប់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់របស់ខ្លួន។ ចំពោះឯកសារសម្រាប់សំណើសុំវិញ្ញាបនបត្របញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋ C.O.C រួមមាន (សូមពិគ្រោះនៅក្នុងឧបសម្ព័ន្ធទី២៖ រូបភាពបង្ហាញអំពីសំណើសុំវិញ្ញាបនបត្របញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋ C.O.C)៖

- ពាក្យស្នើសុំ (ចុះហត្ថលេខាដោយអ្នកមានសិទ្ធិ) (០២ ច្បាប់ដើម)
- បញ្ជីអង្កេតព័ត៌មានវិនិយោគទម្រង់ CIB-01S (០២ច្បាប់ ដើម)
- របាយការណ៍នាំចូល-ចេញប្រចាំ (០២ច្បាប់ ដើម)
- វិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរ ឬ C.O.C ឆ្នាំចាស់ (០១ច្បាប់ ថតចម្លង)
- លិខិតបញ្ជាក់ពីការបំពេញកាតព្វកិច្ចសារពើពន្ធពីអគ្គនាយកដ្ឋានពន្ធដារ (០១ ច្បាប់ ថតចម្លង)
- របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ (០១ច្បាប់ ថតចម្លង)
- លិខិតបញ្ជាក់ស្ថានភាពបំណុលតតិយជន (កម្មករ-និយោជិត) ដែលបានជម្រះ "ប្រសិនបើមាន" (០១ច្បាប់ ថតចម្លង)

### **១.២.៤. កាតព្វកិច្ចរាយការណ៍ស្តីពីការលើកលែងពន្ធគយ**

កាតព្វកិច្ចរាយការណ៍ស្តីពីការលើកលែងពន្ធគយ ចំពោះរាល់សម្ភារៈបរិក្ខារផលិតកម្ម និងសម្ភារៈសាងសង់នាំចូលដោយគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវតែបំពេញបែបបទគយអោយ

---

[53] យោងតាមមាត្រា ១៧ ចំណុច១៧.១ នៃអនុក្រឹត្យលេខ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

បានសព្វគ្រប់ត្រឹមត្រូវ។ ក្នុងរយៈពេល ៣០ថ្ងៃនៃថ្ងៃធ្វើការ ក្រោយការនាំចូល គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវដាក់ជូនក្រុមប្រឹក្សា និងនាយកដ្ឋានពន្ធដារ នូវច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវទៅលើឯកសារបំពេញបែបបទគយ ដែលក្នុងនោះមានទាំងឯកសារបញ្ជាក់អំពីតម្លៃទំនិញពីភ្នាក់ងារដែលរាជរដ្ឋាភិបាលបានជ្រើសរើសអោយទទួលភារកិច្ចផង។[54]

### ១.៣. ការកែប្រែគម្រោងវិនិយោគ

ក្នុងពេលប្រតិបត្តិការគម្រោងវិនិយោគរយៈពេលវែង និងរយៈពេលខ្លី ក្នុងអំឡុងពេលវិនិយោគនេះ អ្នកវិនិយោគអាចធ្វើការកែប្រែគម្រោងវិនិយោគបាន។ ការកែប្រែគម្រោងវិនិយោគ សំដៅដល់ការផ្លាស់ប្តូរមួយចំនួនដូចជា អាស័យដ្ឋាន ទីស្នាក់ការ ទីតាំងអាជីវកម្ម នាមករណ៍ ភាគហ៊ុន ឬការផ្លាស់ប្តូរលម្អិតផ្សេងៗទៀត ដែលមាននៅក្នុងសំណើវិនិយោគ និងនៅក្នុងលក្ខន្តិកៈរបស់អ្នកវិនិយោគ។ ដើម្បីធ្វើការកែប្រែនេះឲ្យមានប្រសិទ្ធិភាព ជាគោលការណ៍ក្នុងរយៈពេលមុនធ្វើការប្តូរ ១០ថ្ងៃនៃថ្ងៃធ្វើការ អ្នកស្នើសុំមានកាតព្វកិច្ចត្រូវដាក់ពាក្យសុំទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការរាជធានី ខេត្ត ដើម្បីចេញសេចក្តីសម្រេចយល់ព្រម ក្នុងរយៈពេលយ៉ាងយូរ ១០ថ្ងៃនៃថ្ងៃធ្វើការ។ មូលហេតុដែលតម្រូវឲ្យមានការកែប្រែនេះឡើងបណ្តាលមកពីករណី២យ៉ាងរួមមាន៖ ការទិញ និងលក់នៃគម្រោងវិនិយោគ និងការរួមបញ្ចូលគ្នានៃគម្រោងវិនិយោគ។

សិទ្ធិ និងបុព្វសិទ្ធិត្រូវបានបញ្ញត្តក្នុងច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០២១ ត្រង់មាត្រា២៩ "សិទ្ធិ បុព្វសិទ្ធិ ឬសិទ្ធិដទៃទៀត ដែល គ.ល.គ. បានទទួលមិនអាចផ្ទេរទៅតតិយជនណាមួយបានទេ លើកលែងតែការផ្ទេរតាមរយៈការការទិញ ការលក់ ឬការរួមបញ្ចូលគ្នានៃគម្រោងវិនិយោគ"។ លើសពីនេះ គម្រោងវិនិយោគអាចត្រូវបានទិញ លក់ ឬរួមបញ្ចូលគ្នា ដោយមិនបាត់បង់ការលើកទឹកចិត្តការធានាលើការវិនិយោគ និងកាតព្វកិច្ចទាំងឡាយដែលនៅមានបន្ត ប្រសិនបើការទិញ ការលក់ ឬការរួមបញ្ចូលគ្នានោះស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ហើយត្រូវស្នើសុំជាលាយលក្ខណ៍អក្សរទៅ ក.អ.ក. ឬ អ.គ.វ.រ.ខ. ដែលនីតិវិធីលម្អិតត្រូវកំណត់ដោយអនុក្រឹត្យ[55]។

#### ១.៣.១. ការទិញ និងការលក់នៃគម្រោងវិនិយោគ

យោងតាមអនុក្រឹត្យលេខ១១១ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃ

[54] យោងតាមមាត្រា ១៧ ចំណុច១៧.២ នៃអនុក្រឹត្យលេខ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

[55] យោងតាមមាត្រា ៣០ នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ៖ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១

ព្រះរាជាណាចក្រកម្ពុជា ការទិញគម្រោងវិនិយោគមាន ០២ប្រភេទ៖

- ការទិញយកគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដោយបុគ្គលដែលមិនបានចុះបញ្ជី
- និងការទិញយកគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដោយអ្នកវិនិយោគផ្សេងទៀត។

ប្រសិនបើបុគ្គលដែលមិនបានចុះបញ្ជី ទិញគម្រោងវិនិយោគមានលក្ខណគ្រប់គ្រាន់ ហើយចង់ដំណើរការអនុវត្ត គ.ល.គ. នៃអ្នកវិនិយោគ និងទទួលបានសិទ្ធិលើការលើកទឹកចិត្ត និងការធានាលើការវិនិយោគ ដែលមានបញ្ជាក់នៅក្នុងវិញ្ញាបនបត្រចុះបញ្ជី បុគ្គលដែលទិញត្រូវស្នើសុំការសម្រេចជាលាយលក្ខណ៍អក្សរទៅ CDC ឬ អ.គ.វ.រ.ខ. តាមនីតិវិធីដើម្បីចុះបញ្ជីជាអ្នកវិនិយោគ និងស្នើសុំផ្ទេរវិញ្ញាបនបត្រចុះបញ្ជី នៃគ.ល.គ. មកអោយនីតិបុគ្គលថ្មីក្នុងរយៈពេល ១០ថ្ងៃ នៃថ្ងៃធ្វើការ មុននឹងធ្វើការរំលាយបញ្ចូលគ្នា និងមុនការផ្ទេរវិញ្ញាបនបត្រចុះបញ្ជី[56]។ CDC ឬ អ.គ.វ.រ.ខ. នឹងធ្វើការត្រួតពិនិត្យលើពាក្យស្នើសុំ ហើយត្រូវជូនដំណឹងទៅនីតិបុគ្គលអ្នកទិញជាលាយលក្ខណ៍អក្សរពីការសម្រេចលើសំណើយល់ព្រម ឬមិនយល់ព្រម នៃការចុះបញ្ជី និងការផ្ទេរវិញ្ញាបនបត្រចុះបញ្ជី ក្នុងរយៈពេល១០ថ្ងៃ បន្ទាប់ពីទទួលពាក្យស្នើសុំនោះ។ ករណីបើការផ្ទេរភាគហ៊ុនរបស់អ្នកវិនិយោគបណ្តាលអោយការ "គ្រប់គ្រង" (គ្រប់គ្រង សំដៅដល់អ្នកកាន់កាប់ភាគហ៊ុនយ៉ាងតិច ២០% នៃភាគហ៊ុនរបស់អ្នកវិនិយោគ) ត្រូវបានទទួលដោយអ្នកត្រូវទទួលការផ្ទេរ អ្នកវិនិយោគត្រូវស្នើសុំទៅ CDC ឬ អ.គ.វ.រ.ខ.តាមនីតិវិធីនូវការផ្ទេរឈ្មោះ និងអាស័យដ្ឋាននៃអ្នកទទួលការផ្ទេរ ក្នុងរយៈពេល ១០ថ្ងៃនៃថ្ងៃធ្វើការ មុននឹងធ្វើការផ្ទេរភាគហ៊ុននោះ ដើម្បីអោយ CDC ឬ អ.គ.វ.រ.ខ. សម្រេចជូនយ៉ាងយូរក្នុងរយៈពេល ១០ថ្ងៃ។

ប្រសិនបើអ្នកវិនិយោគដែលបានចុះបញ្ជីមួយមានបំណងទិញយកភាពជាម្ចាស់ នៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់របស់អ្នកវិនិយោគផ្សេងទៀត ហើយចង់ទទួលបាននូវការលើកទឹកចិត្តវិនិយោគ និងការធានាលើការវិនិយោគនៃ គ.ល.គ. ដែលដំណើរការដោយអ្នកវិនិយោគនោះ អ្នកវិនិយោគដែលជាអ្នកទិញ ត្រូវស្នើសុំការសម្រេចជាលាយលក្ខណ៍អក្សរទៅ CDC ឬ អ.គ.វ.រ.ខ. តាមនីតិវិធីនូវការទិញយកក្នុងរយៈពេល ១០ថ្ងៃ មុនការទិញយកនោះ ដើម្បីទទួលបាននូវសិទ្ធិទាំងនោះ។ CDC ឬ អ.គ.វ.រ.ខ. ធ្វើការពិនិត្យសម្រេចដូចករណីនៃការទិញគម្រោងវិនិយោគដោយបុគ្គលមិនបានចុះបញ្ជីដែល។

ករណីអ្នកវិនិយោគដែលជាអ្នកទិញទាំងពីរប្រភេទខាងលើ ខកខានមិនបានស្នើសុំការសម្រេចទៅ CDC ឬ អ.គ.វ.រ.ខ. ដើម្បីចុះបញ្ជីវិនិយោគតាមនីតិវិធីដូចមានចែងនៅក្នុងអនុក្រឹត្យខាងលើនោះទេ នោះ

[56] យោងតាមមាត្រា ៩ ចំណុច ៩.១ នៃអនុក្រឹត្យលេខ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

អ្នកវិនិយោគដែលជាអ្នកទិញ មិនមានសិទ្ធិទទួលបាននូវការលើកទឹកចិត្ត និងការធានាលើការវិនិយោគណាមួយរបស់ គ.ល.គ.។

### ១.៣.២. ការរួមបញ្ចូលគ្នានៃគម្រោងវិនិយោគ

ប្រសិនបើអ្នកវិនិយោគពីរ ឬច្រើនបានយល់ព្រមដាក់បញ្ចូលគ្នានូវវិនិយោគរបស់ខ្លួន តាមការព្រមព្រៀងរំលាយបញ្ចូលគ្នា បង្កើតទៅជានីតិបុគ្គលថ្មី ហើយនីតិបុគ្គលថ្មីនោះមានបំណងអនុវត្ត គ.ល.គ. របស់អ្នកវិនិយោគ និងមានសិទ្ធិទទួលបាននូវការលើកទឹកចិត្ត និងការធានាលើការវិនិយោគដែលមានចែងនៅក្នុងវិញ្ញាបនបត្រចុះបញ្ជីនៃ គ.ល.គ. នីតិបុគ្គលថ្មីនោះ ត្រូវស្នើសុំការសម្រេចជាលាយលក្ខណ៍អក្សរទៅ CDC ឬ អ.គ.វ.រ.ខ. តាមនីតិវិធី ដើម្បីសុំចុះបញ្ជីជាអ្នកវិនិយោគ និងស្នើសុំផ្ទេរវិញ្ញាបនបត្រចុះបញ្ជី នៃគ.ល.គ. មកអោយនីតិបុគ្គលថ្មីក្នុងរយៈពេល ១០ថ្ងៃ នៃថ្ងៃធ្វើការ មុននឹងធ្វើការរំលាយបញ្ចូលគ្នា និងមុនការផ្ទេរវិញ្ញាបនបត្រចុះបញ្ជី[57]។

ក្រោយពីទទួលបានសំណើខាងលើ CDC ឬ អ.គ.វ.រ.ខ. ត្រូវធ្វើការត្រួតពិនិត្យថា តើព្រម ឬមិនព្រមនៃការចុះបញ្ជី និងការផ្ទេរវិញ្ញាបនបត្រចុះបញ្ជី និងត្រូវជូនដំណឹងទៅនីតិបុគ្គលថ្មីជាលាយលក្ខណ៍អក្សរពីការសម្រេចលើសំណើក្នុងរយៈពេល១០ថ្ងៃ បន្ទាប់ពីទទួលពាក្យស្នើសុំនោះ។ ករណីនីតិបុគ្គលថ្មីខាងលើខកខានមិនបានស្នើសុំការសម្រេចទៅ CDC ឬ អ.គ.វ.រ.ខ. ដើម្បីចុះបញ្ជីវិនិយោគតាមនីតិវិធី នឹងមិនមានសិទ្ធិទទួលបាននូវការលើកទឹកចិត្ត និងការធានាលើការវិនិយោគណាមួយរបស់ គ.ល.គ. (សូមពិគ្រោះនៅក្នុងឧបសម្ព័ន្ធទី២៖ រូបភាពបង្ហាញអំពីនីតិវិធីនៃការស្នើសុំសម្រាប់ការទិញ និងរំលាយបញ្ចូលគ្នា)។

## ១.៤. ការបញ្ចប់នៃការអនុវត្តគម្រោងវិនិយោគ

នៅក្នុងការប្រព្រឹត្តទៅនៃសកម្មភាពវិនិយោគ គម្រោងវិនិយោគក៏អាចត្រូវបានបញ្ចប់ទៅវិញផងដែរ តាមរយៈការលុបចោលនៃគម្រោងវិនិយោគ ឬការដកហូតវិញ្ញាបនបត្រចុះបញ្ជី ក្រោមមូលហេតុដែលមានចែងនៅក្នុងបទប្បញ្ញត្តិច្បាប់។ នៅក្នុងចំណុចនេះយើងនឹងបានស្វែងយល់អំពីការលុបចោលគម្រោងវិនិយោគ (១.៤.១) ការដកហូតវិញ្ញាបនបត្រចុះបញ្ជី (១.៤.២) និងការជូនដំណឹងអំពីការដកហូតវិញ្ញាបនបត្រចុះបញ្ជី និងការតវ៉ា (១.៤.៣) ដែលនឹងត្រូវបកស្រាយនៅចំណុចខាងក្រោមនេះ។

### ១.៤.១. ការលុបចោលគម្រោងវិនិយោគ

ការលុបចោលគម្រោងវិនិយោគអាចមកពីមូលហេតុផ្សេងៗគ្នា ហេតុនេះនីតិវិធីនៃការលុបចោលគម្រោងវិនិយោគក៏មានលក្ខណៈខុសគ្នាផងដែរ។ មុននឹងឈានដល់ការបកស្រាយអំពីនីតិវិធីនៃការលុប

[57] យោងតាមមាត្រា ៩ ចំណុច ៩.១ នៃអនុក្រឹត្យលេខ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

ចោលគម្រោងវិនិយោគ (១.៤.១.២) ចាំបាច់យើងត្រូវដឹងអំពីមូលហេតុនៃការលុបចោលគម្រោងវិនិយោគ (១.៤.១.១) ជាមុនសិន។

### ១.៤.១.១. មូលហេតុនៃការលុបចោលគម្រោងវិនិយោគ

គម្រោងវិនិយោគមិនមែនសុទ្ធតែចង់បង្កើតហើយលុបទៅវិញបានតាមតែចិត្តនោះទេ មូលហេតុនៃការលុបចោលគម្រោងត្រូវបានបញ្ញត្តក្នុងច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ត្រង់មាត្រា៣១ "វិនិយោគអាចត្រូវបានលុបចោលក្នុងករណីណាមួយដូចខាងក្រោម"៖

១. អលទ្ធភាពនៅក្នុងការអនុវត្ត គ.ល.គ. បន្តទៀត

២. នីតិបុគ្គលដែលអនុវត្ត គ.ល.គ. ត្រូវបានរំលាយ

៣. ការខកខានអនុវត្តកាតព្វកិច្ចដែលច្បាប់បានកំណត់ក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន

៤. តាមសំណើរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ លើគម្រោងដែលមានផលប៉ះពាល់ធ្ងន់ធ្ងរជាអាទិ៍ ដល់បរិស្ថាន ឬសន្តិសុខជាតិ ឬផលប្រយោជន៍សាធារណៈ ឬសុខុមាលភាពប្រជាពលរដ្ឋ ឬតាមសំណើរបស់វិនិយោគិន។

ក្រោមមូលហេតុខាងលើទាំងនេះទើបវិនិយោគិនដែលជាម្ចាស់គម្រោងវិនិយោគ ព្រមទាំងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ អាចស្នើសុំលុបគម្រោងវិនិយោគដោយស្របនីតិវិធីដែលច្បាប់បញ្ញត្តជាធរមាន។ លើសពីនេះយើងមើលឃើញថាតាមរយៈច្បាប់ស្តីពីវិនិយោគថ្មី បានផ្តល់សិទ្ធិអំណាចអោយស្ថាប័នមានសមត្ថកិច្ចអាចលុបគម្រោងវិនិយោគដោយឆន្ទានុសិទ្ធិស្របតាមមូលហេតុខាងលើ។

### ១.៤.១.២. នីតិវិធីនៃការលុបចោលគម្រោងវិនិយោគ

ដូចបានលើកឡើងខាងលើ នីតិវិធីនៃការលុបចោលគម្រោងវិនិយោគវាអាស្រ័យទៅលើមូលហេតុនៃការលុបគម្រោងវិនិយោគ។ ចំពោះមូលហេតុទី១ និងទី២ ខាងលើ នីតិវិធីត្រូវអនុវត្តដូចខាងក្រោម៖

- ករណីការលុបចោលដោយមូលហេតុទី១ "អលទ្ធភាពនៅក្នុងការអនុវត្ត គ.ល.គ."៖ វិនិយោគិនត្រូវដាក់ពាក្យស្នើសុំលុបដោយផ្ទាល់ ឬតាមរយៈអ្នកតំណាងដែលមានសិទ្ធិ ទៅក.អ.ក. ឬទៅអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត។ លិខិតស្នើសុំនេះត្រូវចុះហត្ថលេខាដោយវិនិយោគិន ឬអ្នកតំណាងដែលមានសិទ្ធិ ដោយត្រូវបញ្ជាក់អំពីមូលហេតុនៃអលទ្ធភាពនេះ និងត្រូវភ្ជាប់មកជាមួយនូវឯកសារគាំទ្រផ្សេងៗ។
- ករណីការលុបចោលដោយមូលហេតុទី២ "នីតិបុគ្គលដែលអនុវត្ត គ.ល.គ. ត្រូវបានរំលាយ"៖ ប្រសិនបើការរំលាយនេះធ្វើឡើងដោយការជម្រះបញ្ជី និងរំលាយក្រុមហ៊ុនដោយស្ម័គ្រចិត្ត នោះវិនិយោគិនត្រូវដាក់សុំលុបដោយផ្ទាល់ ឬតាមរយៈអ្នកតំណាងដែលមានសិទ្ធិទៅក.អ.ក. ឬទៅអនុគណៈកម្មាធិការ

វិនិយោគរាជធានី ខេត្ត។ ប្រសិនបើការរំលាយនេះធ្វើឡើងដោយសេចក្តីសម្រេចរបស់តុលាការ វិនិយោគិនអាចដាក់សុំលុបដោយផ្ទាល់ ដោយភ្ជាប់មកជាមួយនូវសេចក្តីសម្រេចស្ថាពររបស់តុលាការ និងឯកសារពាក់ព័ន្ធអំពីការរំលាយនីតិបុគ្គលដែលអនុវត្ត គ.ល.គ. និងសេចក្តីបញ្ជាក់ពីទំនាក់ទំនងផលប្រយោជន៍ជាមួយ គ.ល.គ. ដែលត្រូវលុបចោលនេះផងដែរ។

ចំពោះមូលហេតុទី៣ "ការខកខានអនុវត្តកាតព្វកិច្ច"៖ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ អាចត្រូវបានលុបចោលដោយឆន្ទានុសិទ្ធិរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬរបស់អនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត។ នីតិវិធីលម្អិតស្តីពីការលុបដោយឆន្ទានុសិទ្ធិរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬរបស់អនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្តដូចមានកំណត់ពីចំណុច១ដល់៤ នៃមូលហេតុលុបគម្រោងវិនិយោគ ត្រូវកំនត់ដោយអនុក្រឹត្យ។[58] គួរបញ្ជាក់ផងដែរ ទោះបីជាគម្រោងវិនិយោគត្រូវបានលុបក៏ដោយ វិនិយោគិនមិនអាចរួចផុតពីកាតព្វកិច្ចសារពើពន្ធ និងកាតព្វកិច្ចដទៃទៀតឡើយ[59]។

### ១.៤.២. ការដកហូត ឬការលុបចោលវិញ្ញាបនបត្រចុះបញ្ជី

ប្រសិនបើគម្រោងវិនិយោគត្រូវបានលុបចោលតាមការស្នើសុំរបស់វិនិយោគិន នោះវិញ្ញាបនបត្រចុះបញ្ជីនឹងត្រូវបានដកហូត ឬលុបចោលដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត។ ក៏ប៉ុន្តែ វិញ្ញាបនបត្រចុះបញ្ជីក៏អាចត្រូវបានដកហូតទៅវិញផងដែរ ដោយសារតែការទទួលវិញ្ញាបនបត្រចុះបញ្ជី ឬវិញ្ញាបនបត្របញ្ជាក់ពីការបំពេញកាតព្វកិច្ចចំពោះរដ្ឋ តាមរយៈឯកសារក្លែងបន្លំ ឬមិនត្រឹមត្រូវ ឬមិនបានចាប់ផ្តើមធ្វើសកម្មភាពក្នុងរយៈពេល ៦ខែ ក្រោយពេលទទួលបាននូវឯកសារទាំងអស់អំពីការអនុញ្ញាត ឬអាជ្ញាប័ណ្ណពាក់ព័ន្ធនានាដើម្បីអនុវត្តសកម្មភាពវិនិយោគនោះ។ ការដកហូត ឬលុបចោលវិញ្ញាបនបត្រចុះបញ្ជីដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត នឹងត្រូវគិតចាប់ពីថ្ងៃដែលផ្តល់ជូននូវវិញ្ញាបនបត្រចុះបញ្ជីនោះ។

### ១.៤.៣. ការជូនដំណឹងអំពីការដកហូតវិញ្ញាបនបត្រចុះបញ្ជី និងការតវ៉ា

នៅពេលដែលក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត សម្រេចដកហូតវិញ្ញាបនបត្រចុះបញ្ជី ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរស្តីពីការដកហូតនោះ ជូនទៅអ្នកវិនិយោគ។ ការជូនដំណឹងនេះធ្វើឡើងក្នុងគោលបំណងអោយវិនិយោគិនបានទទួលព័ត៌មាន និងបើកផ្លូវតវ៉ាចំពោះការដកហូតវិញ្ញាបនបត្រចុះបញ្ជីនោះ។

---

[58] យោងតាមមាត្រា ៣២ នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ៖ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១។

[59] យោងតាមមាត្រា ៣៣ នៃច្បាប់ដដែល។

នៅក្នុងច្បាប់វិនិយោគ បានផ្តល់សិទ្ធិដល់វិនិយោគិនអាចធ្វើការតវ៉ាចំពោះការលុបគម្រោងវិនិយោគបាន តាមរយៈការដាក់ពាក្យតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្តស្របតាមនីតិវិធីជាធរមាន។ ករណីមានការតវ៉ាក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគរាជធានី ត្រូវធ្វើសេចក្តីសម្រេចចំពោះការតវ៉ាខាងលើ។ ហើយករណីមិនពេញចិត្តនឹងសេចក្តីសម្រេចចំពោះការតវ៉ាខាងលើ ហើយវិនិយោគិនដែលបានតវ៉ា អាចដាក់ពាក្យបណ្តឹងទៅតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា (យោងតាមមាត្រា៣៤ នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា)។ រយៈពេលនៃការដាក់ពាក្យតវ៉ាត្រូវដាក់ជូនទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត ក្នុងរយៈពេល២០ថ្ងៃនៃថ្ងៃធ្វើការ ចាប់ពីថ្ងៃទទួលបានការជូនដំណឹង។[60]

គួរបញ្ជាក់ផងដែរ នៅក្នុងករណីដែលគម្រោងវិនិយោគត្រូវបានលុប វិនិយោគិនអាចផ្ទេរទ្រព្យសម្បត្តិដែលសេសសល់ ទៅក្រៅប្រទេស ឬប្រើនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ករណីដែលគម្រោងវិនិយោគបានប្រើសម្ភារៈសាងសង់ បរិក្ខារសំណង់ សម្ភារៈបរិក្ខារផលិតកម្ម និងធាតុចូលផលិតកម្ម ដែលបាននាំចូលដោយលើកលែងពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែម ជាបន្ទុករបស់រដ្ឋក្នុងអំឡុងពេលតិចជាង ០៥ឆ្នាំ វិនិយោគិនមានកាតព្វកិច្ចបង់ពន្ធលើសម្ភារៈសាងសង់ បរិក្ខារសំណង់ សម្ភារៈបរិក្ខារផលិតកម្ម និងធាតុចូលផលិតកម្មផ្សេងៗទាំងនោះ ដែលត្រូវកំណត់ដោយអនុក្រឹត្យស្របតាមបទប្បញ្ញត្តិច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។[61]

## ផ្នែកទី២៖ នីតិវិធីនៃការដោះស្រាយវិវាទពាក់ព័ន្ធនឹងគម្រោងវិនិយោគ

នៅក្នុងការអនុវត្តសកម្មភាពនៃគម្រោងវិនិយោគ (គ.ល.គ. គ.ព.គ.ល.ព. និង គ.អ.វ ) វាអាចនឹងមានការប៉ះពាល់ដល់ផលប្រយោជន៍មួយចំនួនរបស់អ្នកវិនិយោគដទៃទៀត ដែលជាហេតុបង្កអោយមានវិវាទកើតឡើង។ ចំពោះបញ្ហាប្រឈមនេះ បទដ្ឋានគតិយុត្តដែលគ្រប់គ្រងទៅលើការវិនិយោគបានបង្ហាញអំពីសញ្ញាណមួយចំនួន ដែលមានជាប់ពាក់ព័ន្ធទៅនឹងវិវាទវិនិយោគ និងដំណោះស្រាយនៅបណ្តាស្ថាប័នមានសមត្ថកិច្ចនៅលើគម្រោងវិនិយោគ។ វិវាទទាក់ទងនឹងគម្រោងវិនិយោគ ដែលកើតឡើងរវាងវិនិយោគិននិងវិនិយោគនៅក្នុងប្រទេសកម្ពុជា អាចត្រូវបានដោះស្រាយតាមរយៈមធ្យោបាយ ០២ប្រភេទ គឺការដោះស្រាយក្រៅប្រព័ន្ធតុលាការ (២.១) និងការដោះស្រាយតាមប្រព័ន្ធតុលាការ (២.២)។

---

[60] យោងតាមមាត្រា ៨ ចំណុច ៨.៤ នៃអនុក្រឹត្យលេខ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

[61] យោងតាមមាត្រា ៣៥ នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ៖ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១។

### ២.១. ការដោះស្រាយក្រៅប្រព័ន្ធតុលាការ

ការដោះស្រាយវិវាទវិនិយោគក្រៅប្រព័ន្ធតុលាការ មានលក្ខណៈទន់ភ្លន់ដោយសារតែរាល់ការសម្រេចសេចក្តីគឺមានការបត់បែនទៅតាមការសម្រេចរបស់គូភាគី។ បើយោងតាមបទដ្ឋានគតិយុត្តដែលគ្រប់គ្រងទៅលើស្ថាប័នមានសមត្ថកិច្ចលើកិច្ចការវិនិយោគ បានបង្ហាញអោយឃើញថាទាំងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត សុទ្ធសឹងតែមានសមត្ថកិច្ចក្នុងការដោះស្រាយវិវាទពាក់ព័ន្ធនឹងគម្រោងវិនិយោគនៅក្នុងប្រទេសកម្ពុជា។ ការផ្តល់សមត្ថកិច្ចនេះ គឺជាមូលដ្ឋានគ្រឹះនៃការដោះស្រាយវិវាទរវាងវិនិយោគិន និងវិនិយោគិន ដោយភាគីវិវាទចាំបាច់ត្រូវឆ្លងកាត់យន្តការដោះស្រាយវិវាទនេះ មុននឹងភាគីសម្រេចដោះស្រាយវិវាទតាមរយៈមជ្ឈត្តការជាតិ ឬមជ្ឈត្តការអន្តរជាតិ ឬតាមប្រព័ន្ធតុលាការ។ ហេតុនេះដំណោះស្រាយវិវាទវិនិយោគក្រៅប្រព័ន្ធតុលាការចែកចេញជា ២ដំណាក់កាល៖ ដំណាក់កាលទី១ គឺយន្តការសម្របសម្រួលដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត និងដំណាក់កាលទី២ គឺមជ្ឈត្តការពាណិជ្ជកម្ម។

#### ២.១.១. យន្តការសម្របសម្រួលដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត

យោងតាមមាត្រា ៣៦ នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជាបានបញ្ញត្តថា៖ រាល់វិវាទទាក់ទងនឹងគម្រោងវិនិយោគដែលកើតមានឡើង អាចត្រូវបានដោះស្រាយតាមយន្តការសម្របសម្រួលដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត តាមនីតិវិធីជាធរមាន។ តាមន័យនេះ ការដោះស្រាយវិវាទពាក់ព័ន្ធនឹងគម្រោងវិនិយោគ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់ "ក.អ.ក." និង "អ.គ.វ.រ.ខ." (ដែលមានតួនាទីក្នុងការដោះស្រាយវិវាទនានាពាក់ព័ន្ធនឹងគម្រោងវិនិយោគឯកជន ដែលមានទុនវិនិយោគសមមូលនឹង៥លានដុល្លារអាមេរិកចុះ នៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលរាជធានី ខេត្តសាមីនីមួយៗ) តាមនីតិវិធីមានចែងនៅក្នុងច្បាប់ស្តីពីវិនិយោគ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀតជាមុនសិន ទើបអាចឈានទៅតុលាការមានសមត្ថកិច្ច។ នៅក្នុងករណីដែលការដោះស្រាយតាមយន្តការសម្របសម្រួលសម្របសម្រួលខាងលើពុំទទួលបានជោគជ័យនោះទេ វិវាទអាចត្រូវបានដោះស្រាយតាមរយៈមជ្ឈត្តការជាតិ ឬមជ្ឈត្តការអន្តរជាតិតាមការយល់ព្រមរបស់ភាគីវិវាទនោះ។

ចំពោះយន្តការនៃការដោះស្រាយវិវាទតាមរយៈ "ក.អ.ក." ឬ "អ.គ.វ.រ.ខ." តម្រូវអោយ៖

- ភាគីវិវាទណាមួយ ត្រូវស្នើសុំជាលាយលក្ខណ៍អក្សរទៅ "ក.អ.ក." ឬ "អ.គ.វ.រ.ខ."

- ក្នុងរយៈពេល ៣០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃសំណើសុំជាលើលាយលក្ខណ៍អក្សរ "ក.អ.ក." ឬ "អ.គ.វ.រ.ខ." ត្រូវចាត់ចែងរៀបចំការសម្របសម្រួលជាមួយវិនិយោគិន និងអង្គភាពពាក់ព័ន្ធដទៃទៀតទៅតាមការចាំបាច់ ដើម្បីទទួលបានដំណោះស្រាយសមរម្យមួយ។

ក្នុងករណីដែលការដោះស្រាយតាមយន្តការសម្របសម្រួលខាងលើ ពុំទទួលបានជោគជ័យនោះទេ វិវាទអាចត្រូវបានដោះស្រាយតាមរយៈមជ្ឈត្តការជាតិ ឬមជ្ឈត្តការអន្តរជាតិ តាមការយល់ព្រមរបស់គូភាគីវិវាទនោះ។ គួរបញ្ជាក់ផងដែរ នៅក្នុងច្បាប់វិនិយោគថ្មី ពុំបានចែងពីរយៈពេលដែលតម្រូវអោយភាគីលើកវិវាទនោះទៅសុំធ្វើការដោះស្រាយដោយមជ្ឈត្តកម្មនោះទេ ផ្ទុយពីច្បាប់វិនិយោគចាស់ឆ្នាំ២០០៣ ដែលកំណត់រយៈពេល ២ខែ បន្ទាប់ពីភាគីមិនអាចរកដំណោះស្រាយបញ្ចប់វិវាទបាន តាមរយៈយន្តការសម្របសម្រួលដោយ "ក.អ.ក." ឬ "អ.គ.វ.រ.ខ.។

### ២.១.២. ដំណោះស្រាយតាមរយៈមជ្ឈត្តការពាណិជ្ជកម្ម

តាមការលើកឡើងខាងលើ វិវាទអាចត្រូវបានដោះស្រាយតាមរយៈមជ្ឈត្តការជាតិ ឬមជ្ឈត្តការអន្តរជាតិ តាមការយល់ព្រមរបស់គូភាគីវិវាទនោះ នៅក្នុងករណីដែលយន្តការនៃការដោះស្រាយវិវាទតាមរយៈ "ក.អ.ក." ឬ "អ.គ.វ.រ.ខ." ពុំទទួលបានជោគជ័យ។

វិនិយោគិនទាំងអស់អាចជ្រើសរើសយកការដោះស្រាយវិវាទរបស់ខ្លួន តាមរយៈមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ។ ការដោះស្រាយតាមរយៈ ម.ជ.ម. (មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា) បានផ្តល់នូវផលប្រយោជន៍ជាច្រើនដល់អ្នកវិនិយោគដែលអនុវត្តគម្រោងវិនិយោគនៅកម្ពុជា ពោលគឺប្រកបដោយយុត្តិធម៌ ឆាប់រហ័ស មានប្រសិទ្ធភាព និងដោយមិនបង្អង់ ស្របតាមវិធានស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ត្រង់ប្រការ ៦ ។ លើសពីនេះរាល់ដំណើរការមជ្ឈត្តការទាំងអស់ គឺធ្វើឡើងជាការសម្ងាត់ ដែលនេះគឺជាកត្តាសំខាន់សម្រាប់គូភាគីវិវាទ តាមរយៈដំណើរការនីតិវិធីពន្លឿន ដំណើរការមជ្ឈត្តករបន្ទាន់សម្រាប់វិធានការបណ្តោះអាសន្ន និងដំណើរការវេទិកាមជ្ឈត្តកម្ម តាមសំណើរបស់គូភាគីជម្លោះ និងស្របតាមនីតិវិធីដូចមានចែងនៅក្នុងវិធានស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។

ម.ជ.ម. អាចចាប់ផ្តើមដំណើរការមជ្ឈត្តកម្មរបស់ខ្លួនបាន បន្ទាប់ពីពេលដែលគូភាគីវិវាទបានព្រមព្រៀងលើកវិវាទអោយ ម.ជ.ម. ធ្វើការដោះស្រាយ។ នៅមុនពេលវេទិកាមជ្ឈត្តកម្មត្រូវបានបង្កើត គូភាគីវិវាទអាចស្នើសុំដំណើរការនីតិវិធីពន្លឿនទៅអគ្គលេខាធិការដ្ឋានរបស់ ម.ជ.ម. អោយអនុវត្តដំណើរការនេះ ក្នុងករណីដែលវិវាទពិសេសបន្ទាន់ខ្លាំង ហើយកម្មវត្ថុនៃវិវាទមានតម្លៃមិនលើសពី ៣លានដុល្លារអាមេរិក

ដោយរាប់បញ្ចូលសរុបទាំងអស់តម្លៃកម្មវត្ថុនៃការទាមទារ បណ្តឹងតប និងការដោះស្រាយតាមការកាត់កងនានា[62]។

បន្ទាប់ពីគណៈកម្មាធិការតែងតាំង និងនីតិវិធី (ជាគណៈកម្មាធិការមួយរបស់ ម.ជ.ម ដែលមានតួនាទីក្នុងការតែងតាំងមជ្ឈត្តករ និងបំពេញកិច្ចការផ្សេងៗទៀត) ធ្វើការពិចារណាលើសំណើរបស់គូភាគី ដោយពិនិត្យលើកាលៈទេសៈរបស់សំណុំរឿង បើសំណើនេះត្រូវបានទទួល នោះដំណើរការនៃនីតិវិធីពន្លឿនត្រូវយកមកអនុវត្តដូចខាងក្រោម[63]៖

- សំណុំរឿងត្រូវបញ្ជូនទៅវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករ ១រូប លើកលែងតែគូភាគីសម្រេចអនុវត្តតាមកិច្ចសន្យាមជ្ឈត្តកម្មដែលបានកំណត់យកវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករ ៣រូប វិញ។
- បន្ទាប់ពីបានពិភាក្សាជាមួយគូភាគីវិវាទ វេទិកាមជ្ឈត្តកម្មអាចសម្រេចថាតើវិវាទនោះមានត្រូវសម្រេចដោយផ្អែកតែឯកសារ ឬទាមទារអោយមានសវនាការសម្រាប់ការសាកសួរសាក្សី និងអ្នកជំនាញក៏ដូចជាការទាញហេតុផលផ្ទាល់មាត់ណាមួយ។
- មជ្ឈត្តវិនិច្ឆ័យស្ថាពរនឹងត្រូវចេញក្នុងអំឡុងពេល ២៧០ថ្ងៃប្រតិទិន (៩ខែ) គិតចាប់ពីថ្ងៃដែលវេទិកាមជ្ឈត្តកម្មបានបង្កើត លើកលែងតែករណីពិសេសដែលគណៈកម្មាធិការតែងតាំង និងនីតិវិធីអាចពន្យារពេលកំណត់សម្រាប់ចេញមជ្ឈត្តវិនិច្ឆ័យស្ថាពរ។

បន្ថែមពីនីតិវិធីពន្លឿន ភាគីវិវាទណាមួយអាចស្នើសុំវិធានការបណ្តោះអាសន្នទៅអគ្គលេខាធិការដ្ឋានរបស់ ម.ជ.ម. នៅពេលលើកវិវាទទៅ ម.ជ.ម.។ មជ្ឈត្តករបន្ទាន់នឹងធ្វើសេចក្តីសម្រេចលើសំណើសុំវិធានការបណ្តោះអាសន្នដែលស្នើដោយភាគីវិវាទក្នុងអំឡុងពេល ១៥ថ្ងៃ បន្ទាប់ពីមជ្ឈត្តករបន្ទាន់ត្រូវបានតែងតាំង។ ដំណើរការមជ្ឈត្តករបន្ទាន់ និងបទប្បញ្ញត្តិផ្សេងៗ ពាក់ព័ន្ធនឹងមជ្ឈត្តករបន្ទាន់ ត្រូវបានកំណត់លម្អិតនៅក្នុងជំពូកទី៥ នៃវិធានស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។

នៅក្នុងដោះស្រាយវិវាទដោយ ម.ជ.ម. ចាំបាច់ត្រូវបង្កើតវេទិកាមជ្ឈត្តកម្ម (Arbitral Tribunal) ករណីដែលពុំអនុវត្តនីតិវិធីពន្លឿន។ នៅគ្រប់ករណីទាំងអស់ វេទិកាមជ្ឈត្តកម្មត្រូវមានសមាសភាពមជ្ឈត្តករជាចំនួនសេស។ វេទិកាមជ្ឈត្តកម្មត្រូវមានមជ្ឈត្តករចំនួន ៣រូប លើកលែងតែគូវិវាទបានព្រមព្រៀងផ្សេងពីនេះ[64]។ ការតែងតាំងវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករ ៣រូប ឬច្រើនរូប ត្រូវកំណត់ក្នុងអំឡុងពេល ៣០ថ្ងៃ ករណីដែលគូភាគីមិនបានព្រមព្រៀងលើអំឡុងពេលសម្រាប់ការតែងតាំង ដូចមានចែងនៅក្នុងប្រការ ២៥

[62] យោងតាមប្រការ ៩.១ នៃវិធានស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។

[63] យោងតាមប្រការ ៩.២ នៃវិធានដដែល។

[64] យោងតាមប្រការ ២៤ នៃវិធានស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។

នៃវិធានខាងលើនេះ។ ចំពោះវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករតែមួយរូប គូភាគីត្រូវតែងតាំងក្នុងអំឡុងពេល ១៥ថ្ងៃ។ ប្រសិនបើភាគីខកខានក្នុងតែងតាំងក្នុងអំឡុងពេលកំណត់ខាងលើទេ មជ្ឈត្តករនឹងត្រូវតែងតាំងដោយ ម.ជ.ម. ដោយផ្អែកលើលក្ខណៈសម្បត្តិ រួមបញ្ចូលទាំងសញ្ជាតិរបស់មជ្ឈត្តករដែលតម្រូវតាមភាពជាក់លាក់នៃវិវាទ។ ទីកន្លែងធ្វើមជ្ឈត្តការនៃមជ្ឈត្តកម្មទាំងអស់ដែលធ្វើឡើងដោយ ម.ជ.ម. គឺរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា លើកលែងតែគូភាគីវិវាទបានព្រមព្រៀងផ្សេង ឬដោយសារកាលៈទេសៈនានានៃសំណុំរឿង ដែលសម្រេចថាទីកន្លែងធ្វើមជ្ឈត្តការនៃមជ្ឈត្តកម្មផ្សេងទៀតមានលក្ខណៈសមស្របជាង ដូចមានចែងនៅក្នុងប្រការ ៣៩.៣. នៃវិធានស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម[65]។

លើសពីនេះគូភាគីមានសេរីភាពក្នុងការព្រមព្រៀងយកច្បាប់ ឬបទប្បញ្ញត្តិគតិយុត្តិណាមួយ ដែលវេទិកាមជ្ឈត្តកម្មត្រូវយកមកអនុវត្តចំពោះខ្លឹមសារនៃវិវាទ និងភាសាណាមួយ ឬច្រើនមកប្រើក្នុងដំណើរការមជ្ឈត្តការ ( ក្រោមវិធានរបស់ ម.ជ.ម. ដំណើរការនីតិវិធីមជ្ឈត្តការអាចប្រព្រឹត្តទៅបានជាភាសាណាមួយក៏បាន)។ វេទិកាមជ្ឈត្តកម្មត្រូវសម្រេចពីរបៀបនៃការធ្វើសវនាការ (ដោយផ្ទាល់មាត់ ដោយឯកសារ និងលិខិតស្នាមផ្សេងៗ)។ ក្នុងករណីដែលសវនាការដោយផ្ទាល់មាត់នឹងត្រូវធ្វើឡើង វេទិកាមជ្ឈត្តកម្មអាចសម្រេចថា សវនាការនោះត្រូវធ្វើឡើងដោយមានការចូលរួមដោយផ្ទាល់ ឬពីចម្ងាយតាមរយៈសន្និសីទវីដេអូ ទូរស័ព្ទ ឬមធ្យោបាយអេឡិចត្រូនិចផ្សេងទៀត។ នៅក្នុងដំណើរការសវនាការ ភាគីវិវាទនីមួយៗមានបន្ទុកបង្ហាញភស្តុតាង និងមានសិទ្ធិក្នុងអញ្ជើញសាក្សី រួមទាំងសាក្សីជំនាញផងដែរ។

វេទិកាមជ្ឈត្តកម្មត្រូវប្រកាសបញ្ចប់ដំណើរការក្នុងអំឡុងពេល ៤៥ថ្ងៃ បន្ទាប់ពីថ្ងៃដាក់សេចក្តីថ្លែងការចុងក្រោយ ឬដំណើរការមជ្ឈត្តការត្រូវបញ្ចប់ដោយមូលហេតុគូភាគីវិវាទព្រមព្រៀងបញ្ចប់ ឬមូលហេតុចាំបាច់ផ្សេងទៀត។ មជ្ឈត្តករជាសមាជិកនៃវេទិកាមជ្ឈត្តកម្មនីមួយៗ ត្រូវចេញមជ្ឈត្តវិនិច្ឆ័យ តាមការសម្រេចដោយសម្លេងភាគច្រើនដោយប្រៀប។

មជ្ឈត្តវិនិច្ឆ័យ ជាការសំរេចដែលធ្វើឡើងដោយវេទិកាមជ្ឈត្តកម្ម មានលក្ខណៈស្ថាពរ ហើយមិនត្រូវបានពិនិត្យឡើងវិញលើអង្គសេចក្តីទេ។ ដូច្នេះគូភាគីវិវាទអាចជៀសវាងដំណើរការវែងឆ្ងាយនៃបណ្តឹងឧទ្ធរណ៍ធម្មតាក្រោមប្រព័ន្ធតុលាការជាតិ។ ការអនុវត្តសាលដីការបស់តុលាការបរទេស គឺមានភាពស្មុគស្មាញ ហើយភាគច្រើនមិនអាចធ្វើទៅបាន ដោយសារគ្មានការទទួលស្គាល់បដិការរវាងប្រទេសកម្ពុជា និងបណ្តាប្រទេសភាគច្រើននៅលើពិភពលោក។ ផ្ទុយទៅវិញ ដោយសារប្រទេសកម្ពុជាជាប្រទេសហត្ថលេខី

[65] យោងតាមប្រការ ៣១ នៃវិធានដដែល។

នៃអនុសញ្ញាទីក្រុងញូវយ៉កស្តីពីការទទួលស្គាល់ និងការអនុវត្តមជ្ឈត្តវិនិច្ឆ័យបរទេស មជ្ឈត្តវិនិច្ឆ័យដែលចេញដោយ ម.ជ.ម. គឺអាចអនុវត្តបានក្នុងប្រទេសជាង ១៦០ ដូចគ្នាទៅនឹងមជ្ឈត្តវិនិច្ឆ័យដែលចេញដោយមជ្ឈមណ្ឌលអន្តរជាតិ ឬមជ្ឈមណ្ឌលក្នុងតំបន់ណាមួយផងដែរ។ អនុសញ្ញានេះតម្រូវឱ្យរដ្ឋនីមួយៗទទួលស្គាល់ និងអនុវត្តមជ្ឈត្តវិនិច្ឆ័យបរទេសដោយមិនធ្វើការពិនិត្យឡើងវិញលើអង្គសេចក្តីទេ។

ហើយក្រៅពី "ម.ជ.ម." គូភាគីក៏អាចលើកវិវាទទៅធ្វើការដោះស្រាយតាមរយៈមជ្ឈត្តការអន្តរជាតិ។ មជ្ឈមណ្ឌលអន្តរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនេះរួមមាន មជ្ឈមណ្ឌលមជ្ឈត្តវិនិច្ឆ័យអន្តរជាតិហុងកុង មជ្ឈមណ្ឌលមជ្ឈត្តវិនិច្ឆ័យអន្តរជាតិសិង្ហបុរី និងមជ្ឈមណ្ឌលមជ្ឈត្តវិនិច្ឆ័យអន្តរជាតិប្រចាំតំបន់នៅទីក្រុងកូឡាឡាំពួរជាដើម។

## ២.២ ការដោះស្រាយតាមប្រព័ន្ធតុលាការកម្ពុជា

ករណីដែលការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការពុំទទួលបានជោគជ័យនោះទេ ឬភាគីវិវាទណាមួយមិនពេញចិត្តនឹងការសម្រេចនោះ ការដោះស្រាយវិវាទតាមផ្លូវតុលាការជាវិធីសាស្ត្រចុងក្រោយ ដែលភាគីណាមួយនៃគូវិវាទអាចសុំជំនុំជម្រះក្តីពីសាលាជំរះក្តីនៃព្រះរាជាណាចក្រកម្ពុជាបាន។ ការដោះស្រាយតាមរយៈសាលាជំរះក្តី គឺអនុវត្តទៅតាមនីតិវិធីរបស់តុលាការ ពោលគឺចាប់ផ្តើមពីការដាក់ពាក្យបណ្តឹងទៅសាលាដំបូងរាជធានី-ខេត្ត ដែលអាចធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់បាន ប្រសិនបើសាលក្រមរបស់តុលាការមិនទាន់ចូលជាស្ថាពរនៅឡើយ។ នៅក្នុងច្បាប់វិនិយោគថ្មី ពុំបានចែងពីរយៈពេលដែលតម្រូវអោយភាគីលើកវិវាទនោះទៅសុំធ្វើការដោះស្រាយដោយតុលាការនោះទេ ផ្ទុយពីច្បាប់វិនិយោគចាស់ឆ្នាំ២០០៣ ដែលកំណត់រយៈពេល ២ខែ បន្ទាប់ពីភាគីមិនអាចរកដំណោះស្រាយបញ្ចប់វិវាទបាន តាមរយៈយន្តការសម្របសម្រួលដោយ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគរាជធានី-ខេត្ត ឬតាមរយៈមជ្ឈត្តការពាណិជ្ជកម្ម។ ការដោះស្រាយវិវាទដែលពាក់ព័ន្ធនឹងរឿងពាណិជ្ជកម្មភាគច្រើនគេនិយមដោះស្រាយដោយមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ប៉ុន្តែក្រោយពេលដែលប្រទេសកម្ពុជាបង្កើតតុលាការពាណិជ្ជកម្ម គ្រប់រឿងក្តីទាំងអស់ដែលទាក់ទងនឹងវិវាទពាណិជ្ជកម្មត្រូវស្ថិតក្រោមសមត្ថកិច្ចរបស់តុលាការពាណិជ្ជកម្ម លើកលែងតែគូវិវាទជ្រើសរើសយករបៀបដោះស្រាយណាមួយដែលបានព្រមព្រៀងគ្នា។

ការដោះស្រាយតាមផ្លូវតុលាការត្រូវតែគោរពទៅតាមនីតិវិធី ដែលបានកំណត់នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ជាពិសេសរបៀបដាក់ពាក្យបណ្តឹង និងចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹង[66]

[66] យោងតាមមាត្រា៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ៖ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

ដែលលំហូរនៃនីតិវិធីចាំបាច់ដំណាក់កាលផ្សះផ្សា ដែលត្រូវមានភ្ជាប់មកជាមួយនឹងកំណត់ហេតុជាលាយលក្ខណ៍អក្សរអំពីការផ្សះផ្សា ទោះបីជាការផ្សះផ្សានោះទទួលបានជោគជ័យ ឬបរាជ័យក៏ដោយ។ ប្រសិនបើការផ្សះផ្សាមានការបរាជ័យ តុលាការត្រូវធ្វើការរៀបចំសំណុំរឿងក្តីនោះដើម្បីធ្វើការស៊ើបអង្កេត។ នៅក្នុងដំណាក់នៃការស៊ើបអង្កេតនេះ តុលាការធ្វើការប្រមូលភស្តុតាងយកចម្លើយបំភ្លឺរបស់អ្នកចូលរួមក្នុងនីតិវិធី សិក្សាអំពីកម្មវត្ថុនៃវិវាទ វាយតម្លៃ និងបកស្រាយភស្តុតាងទាំងនោះ ដើម្បីបំភ្លឺការងារជំនុំជម្រះអោយប្រព្រឹត្តទៅសម្រេចបានត្រឹមត្រូវតាមអង្គហេតុ និងអង្គច្បាប់នៃរឿងក្តី។ ចំពោះភស្តុតាងអាចត្រូវបានផ្តល់អោយតាមរយៈគ្រប់មធ្យោបាយចំពោះវិវាទដែលទាក់ទងនឹងរឿងពាណិជ្ជកម្ម។ នៅពេលទទួលបានភស្តុតាងគ្រប់គ្រាន់ហើយ វិវាទនឹងឈានដល់នីតិវិធីនៃការជំនុំជម្រះចេញសេចក្តីសម្រេច ដែលគូភាគីវិវាទចាំបាច់ត្រូវតែគោរពតាមសេចក្តីសម្រេចដែលចូលជាស្ថាពរជាដាច់ខាត។ ប្រសិនបើនៅក្នុងនីតិវិធីមានការខកខានមិនបានអនុវត្តនូវការផ្សះផ្សាធ្វើអោយសាលក្រម ឬសេចក្តីសម្រេចត្រូវទុកជាមោឃៈដោយកំហុសនីតិវិធី។ ក្រោយពេលដោះស្រាយវិវាទរួចរាល់ ហើយក្នុងករណីដែលវិនិយោគិនមានបំណងចង់បញ្ចប់សកម្មភាពរបស់ខ្លួនដែលកំពុងអនុវត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា វិនិយោគិននោះត្រូវផ្តល់ព័ត៌មានទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា តាមរយៈលិខិតអនុសិដ្ឋ ឬលិខិតប្រគល់ផ្ទាល់ដៃដោយមានបញ្ជាក់អំពីមូលហេតុនៃការបញ្ចប់សកម្មភាព និងចុះហត្ថលេខាដោយអ្នកវិនិយោគ ឬមេធាវីតំណាងផ្ទាល់ ដូចបានរៀបរាប់លម្អិតនៅក្នុងផ្នែកទី១ នៃចំណុចខ១.៤ ខាងលើ។

# សេចក្តីសន្និដ្ឋាន
# និង
# អនុសាសន៍

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានសិក្សាលើប្រធានបទស្តីពី "របបគតិយុត្តនៃការវិនិយោគនៅប្រទេសកម្ពុជា" រួចមក បានបង្ហាញអោយឃើញថានៅក្នុងក្របខណ្ឌវិនិយោគនៅក្នុងវិស័យឯកជន ចាំបាច់ត្រូវមានវិធានសម្រាប់គ្រប់គ្រងការប្រព្រឹត្តទៅនៃសកម្មភាពវិនិយោគ ជាពិសេសគឺការកំណត់ស្ថាប័នដែលមានសមត្ថកិច្ចនៅក្នុងកិច្ចការវិនិយោគនៅក្នុងប្រទេសកម្ពុជា។ នៅក្នុងការស្នើសុំគម្រោងវិនិយោគតាមរយៈស្ថាប័នមានសមត្ថកិច្ចត្រូវធ្វើឡើងជាច្រើនដំណាក់កាល ដើម្បីអោយការអនុវត្តសកម្មភាពវិនិយោគនោះប្រកបដោយភាពត្រឹមត្រូវ និងស្របតាមអ្វីដែលប្រព័ន្ធច្បាប់នៅប្រទេសកម្ពុជាបានកម្រិត ជាពិសេសស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងវិធានគតិយុត្តពាក់ព័ន្ធដទៃទៀត។

ការស្រាវជ្រាវមួយនេះបានរំលេចអោយឃើញអំពីអត្ថន័យនៃសញ្ញាណច្បាប់ស្តីពីវិនិយោគថ្មី ដែលរាជរដ្ឋាភិបាលកម្ពុជាបានធ្វើបច្ចុប្បន្នភាព ក្នុងគោលបំណងធ្វើអោយបរិកាសវិនិយោគនៅប្រទេសកម្ពុជាមានភាពប្រសើរឡើង ឆ្លើយតបទៅនឹងការប្រែប្រួលនៃរចនាសម្ព័ន្ធសេដ្ឋកិច្ចក្នុងស្រុក និងសភាពការណ៍ប្រែប្រួលនៃនិម្មាបនកម្មសេដ្ឋកិច្ចតំបន់ និងពិភពលោក។ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានយកចិត្តទុកដាក់យ៉ាងខ្លាំង ដោយធ្វើយ៉ាងណាបង្កើនសកម្មភាពវិនិយោគនៅក្នុងប្រទេសកម្ពុជា តាមរយៈការដាក់ចេញនូវគោលនយោបាយ និងយុទ្ធសាស្ត្រដើម្បីទាក់ទាញវិនិយោគិន ជាពិសេសគឺវិនិយោគិនបរទេស (ការវិនិយោគផ្ទាល់ពីបរទេស)។ តាមរយៈច្បាប់វិនិយោគថ្មី ដែលផ្តល់នូវជម្រើស៣ប្រភេទ រួមមានការលើកទឹកចិត្តជាមូលដ្ឋាន ការលើកទឹកចិត្តបន្ថែម និងការលើកទឹកចិត្តពិសេស ជាមួយនឹងការធានាពីរដ្ឋរួមមាន ការមិនធ្វើជាតូបនីយកម្ម ការមិនធ្វើអស្សាមិករណ៍ និងការមិនកំណត់ថ្លៃផលិត ឬថ្លៃសេវានានាដែលមានលក្ខណៈល្អប្រសើរជាងច្បាប់វិនិយោគចាស់ នៅក្នុងការបង្កើននូវកាលានុវត្តភាពនៃការវិនិយោគនៅប្រទេសកម្ពុជា ជាមួយនឹងលក្ខណៈអំណោយផលរបស់ប្រទេសកម្ពុជាទាំងស្ថេរភាពនយោបាយ កត្តាសន្តិសុខ ធនធានធម្មជាតិ ធនធានមនុស្ស ព្រមទាំងជាប្រទេសដែលជាសមាជិកអាស៊ាន អង្គការពាណិជ្ជកម្មពិភពលោក ព្រមទាំងជាហត្ថលេខីនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីកម្ពុជា-ចិន និងកិច្ចព្រមព្រៀងស្តីពីភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ជាអាទិ៍។ ហើយចំពោះនីតិវិធីនៃការចុះបញ្ជីវិនិយោគដែលធ្លាប់តែមានលក្ខណៈស្មុគស្មាញ និងចំណាយពេលវេលាច្រើន ត្រូវបានកែសម្រួលតាមរយៈយន្តការច្រកចេញ-ចូលតែមួយរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត ព្រមទាំងការធ្វើប្រតិភូកម្មអំណាចទៅរដ្ឋបាលថ្នាក់ក្រោមជាតិ របស់ក្រសួង-ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនៅក្នុងការចុះបញ្ជីគម្រោងវិនិយោគ។ ចំណុចពិសេសទៀតនោះ សំណើសុំចុះបញ្ជីគម្រោងវិនិយោគអាចត្រូវ

បានធ្វើឡើងតាមរយៈថ្នាលបច្ចេកវិទ្យាព័ត៌មាន (តាមរយៈប្រព័ន្ធអនឡាយ) ស្របតាមសម័យកាលឧស្សាហកម្ម ៤.០ ដែលវិញ្ញាបនបត្រនេះភ្ជាប់ជាមួយនូវបារកូដដែលមានលេខសម្គាល់ ឬយូអរកូដ (QR Code) ឬប្រព័ន្ធបច្ចេកវិទ្យាដទៃទៀត ដែលផ្ទុកទិន្នន័យបឋមមួយចំនួនពាក់ព័ន្ធនឹងគម្រោងវិនិយោគ ដែលត្រូវបានចុះបញ្ជីដើម្បីជាប្រយោជន៍ដល់ការចុះបញ្ជីពាក់ព័ន្ធនានា និងសម្រាប់ការអនុវត្តគម្រោងវិនិយោគ។ បន្ថែមពីនេះការចុះបញ្ជីតាមរយៈថ្នាលបច្ចេកវិទ្យាព័ត៌មានខាងលើ នឹងទទួលបានវិញ្ញាបនបត្រឌីជីថល ដែលអាចបោះពុម្ពបានសម្រាប់ប្រើប្រាស់ជាផ្លូវការ ជូនបុគ្គលស្នើសុំតាមរយៈគេហទំព័រចុះបញ្ជី។

លើសពីនេះតាមការបកស្រាយខាងលើ គម្រោងវិនិយោគដែលទទួលបានវិញ្ញាបនបត្រចុះបញ្ជីពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត រួចហើយអាចអនុវត្តសកម្មភាពបានដោយស្វ័យប្រវត្ត ជាពិសេសចំពោះការប្រព្រឹត្តទៅនៃគម្រោងវិនិយោគ វិនិយោគិនអាចធ្វើការលក់ទិញ ឬរួមបញ្ចូលគម្រោងវិនិយោគនោះបានផងដែរ។ ថ្វីបើគម្រោងវិនិយោគត្រូវបានបង្កើតរួចហើយក៏ដោយ ច្បាប់វិនិយោគក៏បានបញ្ញត្តអំពីមូលហេតុបញ្ចប់នៃគម្រោងវិនិយោគ ដែលជាហេតុធ្វើអោយវិនិយោគិនបាត់បង់វិញ្ញាបនបត្រចុះបញ្ជី និងការលើកទឹកចិត្តផងដែរ ដែលមូលហេតុទាំងនោះរួមមានអលទ្ធភាពនៅក្នុងការអនុវត្តគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (គ.ល.គ.) បន្តទៀត នីតិបុគ្គលដែលអនុវត្ត គ.ល.គ. ត្រូវបានរំលាយ ការខកខានអនុវត្តកាតព្វកិច្ចដែលច្បាប់បានកំណត់ក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន និងតាមសំណើរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ លើគម្រោងដែលមានផលប៉ះពាល់ធ្ងន់ធ្ងរជាអាទិ៍ដល់បរិស្ថាន ឬសន្តិសុខជាតិ ឬផលប្រយោជន៍សាធារណៈ ឬសុខុមាលភាពប្រជាពលរដ្ឋ ឬតាមសំណើរបស់វិនិយោគិន។ នៅក្នុងការប្រព្រឹត្តទៅនៃសកម្មភាពវិនិយោគ វិវាទអាចត្រូវបានកើតមានឡើងដែលនីតិវិធីនៃការដោះស្រាយវិវាទនៅក្នុងវិស័យវិនិយោគ អាចត្រូវបានដោះស្រាយតាមរយៈយន្តការសម្របសម្រួលដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត មជ្ឈត្តការពាណិជ្ជកម្ម និងការដោះស្រាយតាមប្រព័ន្ធតុលាការ។

យ៉ាងណាមិញយើងក៏បានឃើញផងដែរ នូវផលវិបាកដែលបានកើតចេញពីការអនុវត្តសកម្មភាពនៃគម្រោងវិនិយោគដែលបានចុះបញ្ជីវិនិយោគរួចហើយ តាមរយៈតថភាពមួយចំនួនដែលបានចោតជាបញ្ហានៅពេលអនុវត្តគម្រោងវិនិយោគនៅក្នុងទឹកដីនៃព្រះរាណាចក្រកម្ពុជា ជាក់ស្តែងនៅក្នុងការអនុវត្តគម្រោងវិនិយោគនោះបានបង្កផលប៉ះពាល់ដល់ធនធានធម្មជាតិ ជាពិសេសតំបន់អភិរក្សសត្វព្រៃជាអាទិ៍ ដែលបង្កអោយមានការតវ៉ាពីសំណាក់ប្រជាពលរដ្ឋនៅក្នុងការទាមទារអោយបញ្ឈប់សកម្មភាពវិនិយោគនោះតែម្តង។ គម្រោងវិនិយោគមួយចំនួនមិនបានគិតគូរដល់បរិស្ថាននោះទេ ភាគច្រើនគម្រោងវិនិយោគលើអចលនវត្ថុមួយចំនួនដូចជាបុរី មិនបានគិតគូរដល់ការគ្រប់គ្រងសំណល់ ធ្វើអោយមានការបំពុលបរិស្ថានជាដើម។

ម៉្យាងវិញទៀត ភាពខ្វះខាតមួយចំនួនដែលពាក់ព័ន្ធនឹងវិស័យវិនិយោគនៅតែជាបញ្ហាចោទដែលតម្រូវអោយធ្វើការកែតម្រូវ ឬបច្ចុប្បន្នភាពបន្ថែមទៀតទៅលើក្របខណ្ឌគតិយុត្តវិនិយោគនៅប្រទេសកម្ពុជា ជាមួយនឹងការផ្សព្វផ្សាយ និងណែនាំអំពីការវិនិយោគដល់សាធារណៈជន។

# អនុសាសន៍

ការសិក្សាទៅលើប្រធានបទមួយនេះ ពិតជាបានផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនទាក់ទងទៅនឹងវិស័យវិនិយោគ ជាពិសេសការវិនិយោគវិស័យឯកជន។ យ៉ាងណាមិញ គម្រោងវិនិយោគមួយចំនួនដែលអនុវត្តសកម្មភាពរបស់ខ្លួនដែលភាគច្រើនជាគម្រោងវិនិយោគអចលនវត្ថុដូចជាបុរី ដែលផលប៉ះពាល់ដល់បរិស្ថាន សម្រាប់ម្ចាស់គម្រោងវិនិយោគគួររៀបចំគិតគូរអំពីការគ្រប់គ្រងកាកសំណល់ ក៏ដូចជាប្រព័ន្ធលូ និងទឹកកខ្វក់ឡើងវិញ។ ហើយមុននឹងចាប់ផ្តើមអនុវត្តគម្រោងវិនិយោគ ទាំងរាជរដ្ឋាភិបាល និងវិនិយោគិនត្រូវពិចារណាជាចម្បងទៅលើផលប្រយោជន៍សាធារណៈ ឬសុខុមាលភាពប្រជាពលរដ្ឋជាមុនសិន ជៀសវាងការប៉ះពាល់ដល់ប្រជាពលរដ្ឋហើយប្រឈមនឹងការលុបចោលគម្រោងវិនិយោគនោះ ជាក់ស្តែងការអនុវត្តគម្រោងវិនិយោគមួយចំនួនបានប៉ះពាល់ដល់ធនធានធម្មជាតិ ជាពិសេសតំបន់អភិរក្សសត្វព្រៃជាអាទិ៍ដែលបង្កអោយមានការមិនពេញចិត្តពីសំណាក់ប្រជាពលរដ្ឋ ហើយតវ៉ាទាមទារអោយបញ្ឈប់សកម្មភាពវិនិយោគនោះតែម្តង។

ភាពខ្វះខាតមួយចំនួនទៀតដែលទាក់ទិននឹងវិស័យវិនិយោគ ដែលតម្រូវអោយរាជរដ្ឋាភិបាលកម្ពុជា ជាពិសេសក្រសួង-ស្ថាប័នមានសមត្ថកិច្ចទទួលបន្ទុក និងពាក់ព័ន្ធក្នុងកិច្ចការវិនិយោគ ត្រូវយកចិត្តទុកដាក់ និងធ្វើការកែតម្រូវបន្ថែមទៀតទៅលើក្របខណ្ឌគតិយុត្តវិនិយោគនៅប្រទេសកម្ពុជា។ ការធ្វើបច្ចុប្បន្នភាពនៃច្បាប់ស្តីពីវិនិយោគតែមួយមុខនៅមិនទាន់គ្រប់គ្រាន់នោះទេ ពោលវិធានបទដ្ឋានគតិយុត្តពាក់ព័ន្ធដទៃទៀតក៏ចាំបាច់ត្រូវធ្វើកែតម្រូវអោយមានខ្លឹមសារស្របតាមបទប្បញ្ញត្តិនៃច្បាប់វិនិយោគថ្មី និងបំពេញបន្ថែមដល់ការគ្រប់គ្រងលើវិស័យវិនិយោគនេះផងដែរ។ ជាក់ស្តែងចំពោះអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលក្រសួង-ស្ថាប័នមានសមត្ថកិច្ចត្រូវខិតខំធ្វើយ៉ាងណាសម្រេចអោយបាននៅក្នុងការតាក់តែងអនុក្រឹត្យថ្មីនេះអោយបានឆាប់រហ័ស ក្នុងន័យសម្រួលដល់ការប្រព្រឹត្តទៅនៃការគ្រប់គ្រងកិច្ចការវិនិយោគ ហើយគួរធ្វើការត្រួតពិនិត្យច្បាប់ និងការអនុវត្តអោយបានខ្ជាប់ខ្ជួន ដើម្បីធានាការអនុវត្តច្បាប់មានលក្ខណៈល្អប្រសើរឡើង និងប្រកបដោយតម្លាភាព។

លើសពីនេះ ក្រសួង-ស្ថាប័នមានសមត្ថកិច្ច ត្រូវខិតខំផ្សព្វផ្សាយអំពីគម្រោងនានាសម្រាប់ការវិនិយោគឯកជន ដែលរាជរដ្ឋាភិបាលបានលើកឡើង និងផ្តល់គម្រោងទាំងនោះទៅឱ្យអ្នកវិនិយោគ។ ជាពិសេសក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គួររៀបចំគេហទំព័រផ្លូវការរបស់ខ្លួននៅក្នុងការផ្តល់នូវព័ត៌មាននានារួមមានទាំងរចនាសម្ព័ន្ធរបស់ក្រុមប្រឹក្សា ដំណើរការនៃនីតិវិធីនៃការចុះបញ្ជីវិនិយោគ ព្រមទាំងឯកសារគតិយុត្តពាក់ព័ន្ធអោយមានលក្ខណៈប្រសើរជាងមុនទៀត ព្រោះបើយើងធ្វើការប្រៀបធៀបជាមួយបណ្តាក្រសួងដទៃទៀតគឺនូវមានកម្រិតនៅឡើយទេ។ ហើយចំពោះរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបវបន្តកិច្ចខិតខំប្រឹងប្រែង

ក្នុងការថែរក្សា និងលើកកម្ពស់បរិយាកាសវិនិយោគប្រកបដោយភាពអំណោយផលជាមួយរបបលើកទឹកចិត្តផ្នែកពន្ធ និងគយ ព្រមទាំងធានាអោយបាននូវការទាក់ទាញការវិនិយោគនៅក្នុងប្រទេសកម្ពុជាពីសំណាក់វិនិយោគិនបរទេស តាមរយៈការជួយជ្រោមជ្រែងក្នុងការផ្សព្វផ្សាយច្បាប់ស្តីពីវិនិយោគថ្មី ជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជូនដល់វិនិយោគិនឲ្យបានទូលំទូលាយទាំងក្នុងប្រទេស និងក្រៅប្រទេស ហើយជួយផ្សព្វផ្សាយបន្ត និងសម្រេចចិត្តបណ្តាក់ទុនវិនិយោគនៅប្រទេសកម្ពុជាបន្ថែមទៀត។

# ឯកសារយោង

# ឯកសារយោង

## ១. បទដ្ឋានគតិយុត្ត

### ១.១. រដ្ឋធម្មនុញ្ញ

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានសភាធម្មនុញ្ញសម្រេចអនុម័តនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ និងប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣

### ១.២. ក្រម

- ក្រមនីតិវិធីរដ្ឋប្បវេណី ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ៖ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

### ១.៣. ច្បាប់

- ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ៖ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១
- ច្បាប់ស្តីពីសារពើពន្ធ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ៖ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧។
- ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ៖ នស/រកម/១១៩៩/១២ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩។
- ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ៖ នស/រកម/០៥០៦/០១០ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៩។

### ១៤. អនុក្រឹត្យ

- អនុក្រឹត្យលេខ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។
- អនុក្រឹត្យលេខ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស។
- អនុក្រឹត្យលេខ៣៤ អនក្រ.បក ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៧ ស្តីពីការកែសម្រួលផ្នែកទី១ ឧបសម្ព័ន្ធទី១នៃអនុក្រឹត្យលេខ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ការអនុវត្តច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។
- អនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

- អនុក្រឹត្យលេខ៣៣ អនក្រ.បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ ស្តីពីការកែសម្រួលមាត្រា១៥ នៃអនុក្រឹត្យលេខ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ការអនុវត្តច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។
- អនុក្រឹត្យលេខ៨៤ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន
- អនុក្រឹត្យលេខ១២០ អនក្រ.បក ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត។

**១.៥. ប្រកាស**

- ប្រកាសរួមលេខ ៩៩១ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**១.៦. វិធាន**

- វិធានស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលត្រូវបានអនុម័តដោយមហាសន្និបាតរបស់ ម.ជ.ម. នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១។

**២. សៀវភៅ**

**២.១. សៀវភៅ (អ្នកនិពន្ធខ្មែរ)**

- រៀបរៀងដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, Cambodia Investment Guidebook បោះពុម្ពផ្សាយនៅឆ្នាំ២០១៣
- រៀបរៀងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, សៀវភៅមគ្គុទេសក៍ "ដំណើរការចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន" បោះពុម្ពផ្សាយនៅឆ្នាំ២០២០
- និពន្ធដោយនិស្សិតឈ្មោះ ក.លី ហ្គេចហ៊ុយ, ក្របខណ្ឌគតិយុត្តនៃការវិនិយោគរវាងព្រះរាជណាចក្រកម្ពុជា និងសាធារណៈរដ្ឋប្រជាមានិតចិន ឆ្នាំសរសេរសារណា២០១៥។
- និពន្ធដោយនិស្សិតឈ្មោះ ហេង ប៊ុនខេង, ការវិនិយោគនៅប្រទេសកម្ពុជាតាមរយៈគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់៖ កាលានុវត្តភាព និងបញ្ហាប្រឈម ឆ្នាំសរសេរសារណា២០២០។

**២.២. សៀវភៅ (អ្នកនិពន្ធជាជនបរទេស)**

- រៀបរៀងដោយក្រុមហ៊ុនសវនកម្ម KPMG, Investing in Cambodia, Seize the Opportunity 2020 and Beyond, បោះពុម្ពផ្សាយនៅឆ្នាំ២០២០

## ៣. គោលនយោបាយ

- គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ របស់រាជរដ្ឋាភិបាលដែលទទួលបានការឯកភាពពីគណៈរដ្ឋមន្ត្រីនាសម័យប្រជុំពេញអង្គ នៅថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៥

## ៤. គេហទំព័រ និងបណ្តាញសង្គមផ្សេងៗ

- http://www.libraryrule.com បានចូលពិគ្រោះនៅម៉ោង១៥:00 ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២២។
- https://m.postkhmer.com/business/2021-11-11-1106-226587.html បានចូលពិគ្រោះនៅម៉ោង០៩:00 ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២។
- https://www.google.com/amp/s/www.asianvision.org/archives/11518/amp បានចូលពិគ្រោះនៅម៉ោង០៩:00 ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២។
- https://www.rasmeinews.com/archives/585635 បានចូលពិគ្រោះនៅម៉ោង១០:00ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២២។
- https://cdc.gov.kh/km/ បានចូលពិគ្រោះនៅម៉ោង១០:00ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២២។
- https://www.propertyarea.asia/archives/65696 បានចូលពិគ្រោះនៅម៉ោង០៨:00 ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២២។
- សិក្ខាសាលាស្តីពីច្បាប់វិនិយោគកម្ពុជា Workshop on Law on Investment of Cambodia. | ការិយាល័យមេធាវី អូវីធី ឡាយអិន "អូវីធី ច្បាប់" OVT LION LAW OFFICE "OVT LAW" បានចូលពិគ្រោះនៅម៉ោង១៤:00 ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២២។
- សមាគមសាលាត្រាជូ - Sala Traju Association | RedCircle បានចូលពិគ្រោះនៅម៉ោង០៨:00 ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២២។

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

| ឧបសម្ព័ន្ធទី១៖ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត | |
|---|---|
| ល.រ | ចំណងជើង |
| ១ | ព្រះរាជក្រមលេខ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ ស្ដីពីច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។ |
| ២ | អនុក្រឹត្យលេខ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្ដីពីការអនុវត្តច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។ |
| ៣ | អនុក្រឹត្យលេខ៦០ អនក្រ.បក ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ |
| ៤ | អនុក្រឹត្យលេខ១២០ អនក្រ.បក ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត។ |
| ៥ | អនុក្រឹត្យលេខ៣៣ អនក្រ.បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ ស្ដីពីការកែសម្រួលមាត្រា១៥ នៃអនុក្រឹត្យលេខ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ការអនុវត្តច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។ |
| ៦ | ប្រកាសរួមលេខ៩៩១ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្ដីពីការផ្ដល់សេវាសាធារណៈរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ |
| ឧបសម្ព័ន្ធទី២៖ បញ្ជីតារាង និងរូបភាព | |
| ១ | រូបភាពបង្ហាញអំពីស្ថានភាពវិនិយោគផ្ទាល់នៅកម្ពុជា គិតត្រឹមចុងឆ្នាំ២០២១ |
| ២ | រូបភាពបង្ហាញអំពីទិន្នផលនាំចេញនៃតំបន់សេដ្ឋកិច្ចពិសេស |
| ៣ | រូបភាពបង្ហាញអំពីផែនទីនៃតំបន់សេដ្ឋកិច្ចពិសេសនៅក្នុងប្រទេសកម្ពុជា |
| ៤ | តារាងប្រៀបធៀបការលើកទឹកចិត្តរវាងជម្រើសទី១ និងជម្រើសទី២ |
| ៥ | រូបភាពបង្ហាញអំពីអតិផរណារបស់ប្រទេសកម្ពុជាគិតជាភាគរយពីឆ្នាំ២០១៦ មកដល់ឆ្នាំ២០២០ |
| ៦ | រូបភាពបង្ហាញអំពីការបញ្ចេញឧស្ម័នកាបូនិកក្នុងចំណោមមនុស្សម្នាក់នៅតំបន់អាស៊ាន |
| ៧ | រូបភាពបង្ហាញអំពីតួលេខរបស់ RCEP |

| | |
|---|---|
| ៨ | រូបភាពបង្ហាញអំពីប្រាក់ឈ្នួលប្រចាំខែអប្បបរមា នៅក្នុងពិភពលោកឆ្នាំ២០២១-២០២១ គិតជាដុល្លារអាមេរិក |
| ៩ | តារាងបង្ហាញអំពីការដាក់សំណើទៅស្ថាប័នមានសមត្ថកិច្ចតាមទំហំទឹកប្រាក់ |
| ១០ | រូបភាពបង្ហាញអំពីនីតិវិធីនៃការចុះបញ្ជីតាមរយៈថ្នាលបច្ចេកវិទ្យាព័ត៌មាន |
| ១១ | រូបភាពបង្ហាញអំពីនីតិវិធីនៃការស្នើសុំសម្រាប់ការទិញ និងរំលាយបញ្ចូលគ្នា |
| ១២ | រូបភាពបង្ហាញអំពីសំណើសុំវិញ្ញាបនបត្របញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋ C.O.C |
| ១៣ | ទំហំវិនិយោគពីបរទេសនៅក្នុងប្រទេសកម្ពុជា |
| ១៤ | ការវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័តតាមវិស័យ |
| ១៥ | ការវាយតម្លៃកំណើនសេដ្ឋកិច្ចកម្ពុជា នៅចុងឆ្នាំ២០២១ |
| **ឧបសម្ព័ន្ធទី៣៖ ឯកសារបន្ថែម** | |
| ១ | ពាក្យសុំវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជា |
| ២ | សេចក្តីសង្ខេបពិសេស "ច្បាប់ស្តីពីវិនិយោគ" |

# ឧបសម្ព័ន្ធទី១
# ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

# ច្បាប់

# ស្តីពី

# វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ក្រុមប្រឹក្សាធម្មនុញ្ញ... / អគ្គលេខាធិការដ្ឋាន
ចូល
លេខ:....១៩៣..........
ថ្ងៃ:..ពុធ..ទី..២០..ខែ.តុលា.ឆ្នាំ២០២១
ម៉ោង:.....១៧..:..០០..........

# ព្រះរាជក្រម

នស/រកម/១០២១/០១៤

## យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៨/០០៥ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មមាត្រា២៦ មាត្រា២៧ថ្មី មាត្រា២៨ មាត្រា៣១ និងមាត្រា៣២នៃច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១ នាសម័យប្រជុំពេញអង្គលើកទី៧ នីតិកាលទី៤ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្ដីសម្រេចលេខ [illegible]/២០២១ កបធ.ច ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ ហើយដែលមានសេចក្ដីទាំងស្រុង

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

ច្បាប់នេះមានគោលបំណងបង្កើតនូវក្របខ័ណ្ឌគតិយុត្តដែលបើកចំហ មានតម្លាភាព អាចប៉ាន់ប្រមាណទុកជាមុនបាន ប្រកបដោយភាពអំណោយផលសម្រាប់ការវិនិយោគ ដើម្បីទាក់ទាញនិងលើកកម្ពស់ការវិនិយោគដោយបុគ្គលសញ្ជាតិខ្មែរឬបរទេសប្រកបដោយគុណភាព ប្រសិទ្ធភាព និងប្រសិទ្ធផល សំដៅអភិវឌ្ឍសង្គម-សេដ្ឋកិច្ច នៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈ៖

១- ការបង្កើនភាពប្រកួតប្រជែងរបស់កម្ពុជា ដើម្បីធ្វើឱ្យរចនាសម្ព័ន្ធសេដ្ឋកិច្ចអាចធ្វើពិពិធកម្ម និងធន់ទៅនឹងវិបត្តិក្នុងតំបន់និងសកលលោក។

២- ការធ្វើទំនើបកម្ម ការបង្កើនផលិតភាពនៃឧស្សាហកម្មក្នុងស្រុក ការពង្រឹងការតភ្ជាប់ទៅក្នុងខ្សែច្រវាក់ផ្គត់ផ្គង់ក្នុងតំបន់និងសកលលោក តាមរយៈការជំរុញកំណើនលំហូរចូលមូលធន ការផ្ទេរបច្ចេកវិទ្យា ចំណេះដឹងនិងចំណេះធ្វើ។

៣- ការបង្កើតរបបលើកទឹកចិត្តវិនិយោគមួយដែលមានតម្លាភាព ភាពអាចប៉ាន់ប្រមាណទុកជាមុនបាន គ្មានការរើសអើង មានលក្ខណៈប្រកួតប្រជែង និងគាំទ្រគោលនយោបាយសង្គម-សេដ្ឋកិច្ច។

៤- ការផ្តល់ការការពារសិទ្ធិនិងផលប្រយោជន៍ស្របច្បាប់របស់វិនិយោគិននៅព្រះរាជាណាចក្រកម្ពុជា តាមរយៈការបង្កើតនូវក្របខ័ណ្ឌគតិយុត្តដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយនិងមានតុល្យភាពស្របទៅនឹងផលប្រយោជន៍ជាតិ។

**មាត្រា២.-**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះរាល់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ គម្រោងពង្រីកនៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងគម្រោងវិនិយោគដែលទទួលបានត្រឹមតែការធានាលើការវិនិយោគដែលបានចុះបញ្ជីនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាឬអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត។

**មាត្រា៣.-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះ ត្រូវបានកំណត់និយមន័យដូចតទៅ៖

**គម្រោងវិនិយោគ** សំដៅដល់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ គម្រោងពង្រីកនៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងគម្រោងវិនិយោគដែលទទួលបានត្រឹមតែការធានាលើការវិនិយោគ។

**គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់** សរសេរជាអក្សរកាត់ គ.ល.គ. សំដៅដល់គម្រោងវិនិយោគដែលទទួលបានវិញ្ញាបនបត្រចុះបញ្ជីពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាឬអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បម្រើឱ្យការនាំចេញ** សំដៅដល់ គ.ល.គ. ដែលបានលក់ឬបានផ្ទេរសមាមាត្រណាមួយនៃផលិតផលរបស់ខ្លួនទៅឱ្យអ្នកទិញឬអ្នកទទួលនៅក្រៅព្រះរាជាណាចក្រកម្ពុជា។

**គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលជាប្រភេទឧស្សាហកម្មគាំទ្រ** សំដៅដល់ **គ.ល.គ** ដែលផលិតផលរបស់ខ្លួនក្នុងសមាមាត្រណាមួយ ត្រូវផ្គត់ផ្គង់ដល់ឧស្សាហកម្មនាំចេញ។

**គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បម្រើទីផ្សារក្នុងស្រុក** សំដៅដល់ គ.ល.គ. ដែលមិនបម្រើឱ្យការនាំចេញ។

**គម្រោងពង្រីកនៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់** សរសេរជាអក្សរកាត់ **គ.ព.គ.ល.គ** សំដៅដល់ការពង្រីកនៃ គ.ល.គ. ដែលធ្វើឡើងតាមរូបភាពណាមួយ មានជាអាទិ៍ ការពង្រីកផលិតកម្មដែលមានស្រាប់ ការពង្រីកតាមរយៈការធ្វើពិពិធកម្មមុខសញ្ញាផលិតកម្មដែលស្ថិតក្នុងខ្សែស្រឡាយផលិតផលជាមួយគ្នា ការពង្រីកតាមរយៈការបំពាក់បច្ចេកវិទ្យាទំនើបថ្មីដែលលើកកម្ពស់ផលិតភាព ឬការពារបរិស្ថាន ការពង្រីកហេដ្ឋារចនាសម្ព័ន្ធបម្រើឱ្យសេវាទូរគមនាគមន៍មូលដ្ឋាន ឬការពង្រីកក្រោមរូបភាពផ្សេងទៀតដែលនឹងត្រូវកំណត់ដោយអនុក្រឹត្យ។

**គម្រោងវិនិយោគដែលទទួលបានត្រឹមតែការធានាលើការវិនិយោគ** សរសេរជាអក្សរកាត់ **គ.ធ.វ.** សំដៅដល់គម្រោងវិនិយោគដែលបានចុះបញ្ជីនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាឬនៅអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត ដោយមានបញ្ជាក់ច្បាស់ថាជា គ.ធ.វ. ប៉ុន្តែពុំទទួលបានការលើកទឹកចិត្តផ្នែកសារពើពន្ធ។

**ថ្ងៃធ្វើការ** សំដៅដល់ថ្ងៃប្រតិទិនដែលជាថ្ងៃធ្វើការជាផ្លូវការរបស់រាជរដ្ឋាភិបាលកម្ពុជា។

**ធាតុចូលផលិតកម្ម** សំដៅដល់វត្ថុធាតុដើម ផលិតផលពាក់កណ្តាលសម្រេច និងសម្ភារៈបន្ទាប់បន្សំរួមទាំងទំនិញ ដែលត្រូវបំប្លែងនៅក្នុងកិច្ចដំណើរការផលិតកម្ម លើកលែងតែផលិតផលតេលសិលានិងគ្រឿងបន្លាស់យានយន្ត។

**នីតិបុគ្គលសញ្ជាតិខ្មែរ** សំដៅដល់ក្រុមហ៊ុនដែលមានទីកន្លែងអាជីវកម្មនិងបានធ្វើការចុះបញ្ជីពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយដែលមានភាគហ៊ុនចាប់ពី៥១(ហាសិបមួយ)ភាគរយក្នុងក្រុមហ៊ុន ត្រូវបានកាន់កាប់ដោយបុគ្គលដែលមានសញ្ជាតិខ្មែរ។

**បរិក្ខារសំណង់** សំដៅដល់បរិក្ខារដែលត្រូវបានផ្គុំ បង្កើត ឬផលិតឡើង ដើម្បីប្រើប្រាស់ឬបំពាក់ភ្ជាប់នឹងសំណង់ ដើម្បីបង្កើនគុណភាព ផាសុកភាព និងភាពងាយស្រួលនៃការប្រើប្រាស់សំណង់ មានជាអាទិ៍ អំពូលភ្លើង ខ្សែភ្លើង ខ្សែកាបអុបទិក ឡាវ៉ាបូ រ៉ូប៊ីណេ ផើងងូតទឹក ជណ្តើរយន្ត និងទុយោ លើកលែងតែម៉ាស៊ីនត្រជាក់។ ការនាំចូលម៉ាស៊ីនត្រជាក់សម្រាប់សកម្មភាពឬគម្រោងវិនិយោគក្នុងវិស័យជាក់លាក់ណាមួយនឹងទទួលបានការលើកទឹកចិត្តដោយឡែក ដែលនឹងត្រូវកំណត់នៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឬនៅក្នុងអនុក្រឹត្យ។

**បុគ្គល** សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គល។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**វិញ្ញាបនបត្រចុះបញ្ជី** សំដៅដល់វិញ្ញាបនបត្រដែលចេញដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាឬដោយអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត បញ្ជាក់ពីការទទួលស្គាល់គម្រោងវិនិយោគ។

**វិនិយោគិន** សំដៅដល់បុគ្គលអនុវត្តគម្រោងវិនិយោគដែលបានចុះបញ្ជីនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬនៅអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត។

**សកម្មភាពវិនិយោគ** សំដៅដល់សកម្មភាពធុរកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជាដែលត្រូវបានបង្កើតឡើង ឬត្រូវបានទិញយក ឬត្រូវបានលក់ ឬត្រូវបានធ្វើអនុប្បទាន ឬត្រូវបានពង្រីក ឬត្រូវបានរួមបញ្ចូលគ្នា និងត្រូវបានអនុញ្ញាតជាលាយលក្ខណ៍អក្សរដោយស្ថាប័នទទួលបន្ទុកដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**សំណើសុំចុះបញ្ជីគម្រោងវិនិយោគ** សំដៅដល់សំណើដែលបានដាក់ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬដាក់ជូនអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត ដោយបុគ្គលណាមួយក្នុងគោលបំណងបង្កើត **គ.ល.គ** និង**គ.ធ.វ.**។ សំណើនេះអាចរាប់បញ្ចូលដំណាក់កាលមួយឬច្រើន ដោយរួមបញ្ចូលទាំងសំណើសុំពង្រីក គ.ល.គ.។

**សម្ភារៈបរិក្ខារផលិតកម្ម** សំដៅដល់គ្រឿងចក្រ គ្រឿងម៉ាស៊ីន និងឧបករណ៍ផ្សេងៗ សម្រាប់ប្រើប្រាស់ជាមូលដ្ឋានសំខាន់ក្នុងខ្សែច្រវាក់ផលិតកម្ម លើកលែងតែយានយន្ត។ ចំពោះការនាំចូលយានយន្តសម្រាប់សកម្មភាពឬគម្រោងវិនិយោគក្នុងវិស័យជាក់លាក់ណាមួយ នឹងទទួលបានការលើកទឹកចិត្តដោយឡែកដែលនឹងត្រូវកំណត់នៅក្នុងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឬនៅក្នុងអនុក្រឹត្យ។

**សម្ភារៈសាងសង់** សំដៅដល់សម្ភារៈសំណង់ដែលបានបំប្លែងឬបានប្រើប្រាស់ទាំងស្រុងនៅក្នុងការសាងសង់សំណង់នានា រួមបញ្ចូលទាំង បរិក្ខារសំណង់ សម្រាប់ គ.ល.គ. ប្រើប្រាស់ ដើម្បីដំណើរការសកម្មភាពវិនិយោគរបស់ខ្លួន នៅក្នុងដំណាក់កាលសាងសង់ដំបូងឬពង្រីក។

បរិក្ខារសំណង់ សម្ភារៈសាងសង់ និងសម្ភារៈបរិក្ខារផលិតកម្ម ដូចមានចែងក្នុងមាត្រានេះត្រូវមានលក្ខខណ្ឌបច្ចេកទេសនិងបរិមាណសមស្របទៅនឹងគម្រោងវិនិយោគ។

**អ្នកដាក់ពាក្យសុំ** សំដៅដល់បុគ្គលដាក់សំណើសុំចុះបញ្ជីគម្រោងវិនិយោគនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាឬនៅអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត។

**អនុក្រឹត្យ** សំដៅដល់អនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## ស្ថាប័នក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**មាត្រា៤.-**

ត្រូវបានបង្កើតក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលសរសេរជាអក្សរកាត់ថា **ក.អ.ក.** ជាស្ថាប័នប្រតិបត្តិដែលមានមុខងារជាសេនាធិការនិងជាច្រកចេញចូលតែមួយរបស់រាជរដ្ឋាភិបាលលើបេសកកម្មដឹកនាំនិងគ្រប់គ្រងកិច្ចប្រតិបត្តិការអភិវឌ្ឍន៍ ការវិនិយោគឯកជន និងតំបន់សេដ្ឋកិច្ចពិសេស។

**មាត្រា៥ .–**

ក.អ.ក. មាននាយករដ្ឋមន្ត្រីជាប្រធាន ព្រមទាំងមានអនុប្រធានមួយរូបឬច្រើនរូប និងសមាជិកមួយចំនួន តាមការចាំបាច់។ អាស្រ័យដោយឆន្ទានុសិទ្ធិរបស់ខ្លួន នាយករដ្ឋមន្ត្រីអាចប្រគល់សិទ្ធិដល់ឥស្សរជនជាសមាជិកនៃរាជរដ្ឋាភិបាលឬជាថ្នាក់ដឹកនាំនៃ ក.អ.ក. ដើម្បីដឹកនាំជំនួសក្នុងកម្រិតណាមួយឬក្នុងផ្នែកណាមួយនៃការងាររបស់ ក.អ.ក. ក្នុងគោលដៅធានាប្រសិទ្ធភាពនៃការបំពេញបេសកកម្មដែលមានកំណត់ក្នុងមាត្រា៤នៃច្បាប់នេះរួមបញ្ចូលនូវការគ្រប់គ្រង និងការចាត់ចែងប្រើប្រាស់ថវិកា និងធនធានមនុស្ស ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ការតែងតាំងសមាសភាពនៃ ក.អ.ក. ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ។

**មាត្រា៦ .–**

ក.អ.ក. មានរចនាសម្ព័ន្ធដូចតទៅ៖

- អគ្គលេខាធិការដ្ឋាននៃ ក.អ.ក.
- គណៈកម្មាធិការសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា សរសេរជាអក្សរកាត់ថា **គ.ស.អ.ក.**
- គណៈកម្មាធិការវិនិយោគកម្ពុជា សរសេរជាអក្សរកាត់ថា **គ.វ.ក.**។

អគ្គលេខាធិការដ្ឋាននៃ **ក.អ.ក. គ.ស.អ.ក.** និង **គ.វ.ក.** ត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូបរៀងៗខ្លួន និងអមដោយអគ្គលេខាធិការរងមួយចំនួនសម្រាប់ជាជំនួយការតាមការចាំបាច់។

**ក.អ.ក.** អាចបង្កើតរចនាសម្ព័ន្ធឬយន្តការបន្ថែមទៀតដោយអនុក្រឹត្យផ្អែកលើភាពចាំបាច់។

**មាត្រា៧ .–**

ក.អ.ក. មានថវិកាដោយឡែករបស់ខ្លួនដែលជាថវិកាជាតិ និងមានមន្ត្រីរាជការក្របខ័ណ្ឌនិងមន្ត្រីជាប់កិច្ចសន្យា អនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៨ .–**

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ **ក.អ.ក.** ត្រូវកំណត់ដោយព្រះរាជក្រឹត្យ។

## ជំពូកទី៣
## យន្តការវិនិយោគរាជធានី ខេត្ត

**មាត្រា៩ .–**

ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការផ្តល់សេវាជូនវិនិយោគិន ការពិនិត្យ និងសម្រេចលើការវិនិយោគឯកជននិងការដោះស្រាយវិវាទពាក់ព័ន្ធនឹងគម្រោងវិនិយោគ ត្រូវធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ស្របតាមការសម្រេចរបស់រាជរដ្ឋាភិបាល តាមរយៈការបង្កើតអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត ធ្វើប្រត្យាសេទាធិការឱ្យរដ្ឋបាលរាជធានី ខេត្ត។ សិទ្ធិ អំណាច ទំហំនៃការវិនិយោគ និងការរៀបចំនិងការប្រព្រឹត្តទៅនៃអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក។

## ជំពូកទី៤
## ការចុះបញ្ជីនិងការអនុវត្តគម្រោងវិនិយោគ

**មាត្រា១០.-**

បុគ្គលដែលមានបំណងអនុវត្ត គ.ល.គ. ឬគ.ព.គ.ល.គ. ឬគ.ធ.វ. ត្រូវដាក់សំណើសុំចុះបញ្ជីជាលាយលក្ខណ៍អក្សរនៅក.អ.ក. ឬអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត។

សំណើសុំចុះបញ្ជីគម្រោងវិនិយោគខាងលើនេះ អាចធ្វើឡើងតាមរយៈថ្នាលបច្ចេកវិទ្យាព័ត៌មាន។

**មាត្រា១១.-**

សំណើសុំចុះបញ្ជីគម្រោងវិនិយោគត្រូវភ្ជាប់ជាមួយនូវព័ត៌មានមួយចំនួនដែលនឹងកំណត់នៅក្នុងអនុក្រឹត្យ។

**មាត្រា១២.-**

នៅពេលទទួលបានសំណើសុំចុះបញ្ជីគម្រោងវិនិយោគ ក.អ.ក. ត្រូវពិនិត្យនិងសម្រេចលើសំណើនេះតាមយន្តការច្រកចេញ-ចូលតែមួយ។

យន្តការច្រកចេញ-ចូលតែមួយក្នុងការពិនិត្យសំណើសុំចុះបញ្ជីគម្រោងវិនិយោគ ដូចបានកំណត់ក្នុងកថាខណ្ឌទី១នៃមាត្រានេះ គឺជាយន្តការពិនិត្យនិងសម្រេចក្នុងការចុះបញ្ជីគម្រោងវិនិយោគដោយតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធដែលប្រចាំការនៅក.អ.ក. ទៅតាមការចាត់តាំងនិងប្រតិភូកម្មសិទ្ធិអំណាចពីប្រធានក្រសួង ស្ថាប័ន ក្រោមការសម្របសម្រួលរបស់ក.អ.ក.។

ប្រសិនបើគម្រោងវិនិយោគដែលត្រូវបានស្នើសុំនេះមិនស្ថិតក្នុងបញ្ជីអវិជ្ជមានដែលនឹងត្រូវកំណត់ដោយឡែកក្នុងអនុក្រឹត្យ ក.អ.ក. ត្រូវចេញវិញ្ញាបនបត្រចុះបញ្ជីជូនអ្នកដាក់ពាក្យសុំក្នុងអំឡុងពេលមិនលើសពី២០(ម្ភៃ)ថ្ងៃនៃថ្ងៃធ្វើការ។

វិញ្ញាបនបត្រចុះបញ្ជីត្រូវមានភ្ជាប់នូវបារកូដដែលមានលេខសម្គាល់ ឬឃ្យូអរកូដ ឬប្រព័ន្ធបច្ចេកវិទ្យាដទៃទៀត ដែលផ្ទុកទិន្នន័យបឋមមួយចំនួនពាក់ព័ន្ធនឹងគម្រោងវិនិយោគដែលត្រូវបានចុះបញ្ជី ដើម្បីជាប្រយោជន៍ដល់ការចុះបញ្ជីពាក់ព័ន្ធនានា និងសម្រាប់ការអនុវត្តគម្រោងវិនិយោគ។

ក្រសួង ស្ថាប័នដែលពាក់ព័ន្ធនឹងការចុះបញ្ជីពាក់ព័ន្ធនិងការពិនិត្យអនុលោមភាពនៃការអនុវត្តគម្រោងវិនិយោគមិនអាចតម្រូវឱ្យអ្នកដាក់ពាក្យស្នើសុំ ឬអ្នកអនុវត្តគម្រោងវិនិយោគផ្តល់នូវឯកសារនានា ដែលមានស្រាប់នៅក្នុងបារកូដដែលមានលេខសម្គាល់ ឬឃ្យូអរកូដ ឬប្រព័ន្ធបច្ចេកវិទ្យាដទៃទៀត ដែលជាប់នៅលើវិញ្ញាបនបត្រចុះបញ្ជីដែលចេញដោយក.អ.ក. បានទេ។

**មាត្រា១៣.-**

គម្រោងវិនិយោគដែលទទួលបានវិញ្ញាបនបត្រចុះបញ្ជី អាចចាប់ផ្តើមអនុវត្តបានដោយស្វ័យប្រវត្តិ។ ការទទួលបានវិញ្ញាបនបត្រចុះបញ្ជីមិនមែនជាការលើកលែងឱ្យគម្រោងវិនិយោគរួចផុតពីការទទួលនូវលិខិតអនុញ្ញាតតាមការកំណត់ដោយច្បាប់និងបទប្បញ្ញត្តិនានាឡើយ។

រាល់គម្រោងវិនិយោគត្រូវជាកម្មវត្ថុនៃការតាមដាននិងត្រួតពិនិត្យតាមរយៈយន្តការច្រកចេញ-ចូលតែមួយសម្របសម្រួលដោយក.អ.ក. ដើម្បីធានានូវអនុលោមភាពគតិយុត្តនិងលក្ខខណ្ឌនានាដែលជាមូលហេតុនៃការទទួលបានវិញ្ញាបនបត្រចុះបញ្ជី។

អ្នកអនុវត្តគម្រោងវិនិយោគត្រូវផ្តល់របាយការណ៍ស្តីពីការអនុវត្តគម្រោងវិនិយោគ ទៅតាមកាលវិភាគជាក់លាក់ ដែលកំណត់ដោយក.អ.ក.។ ទម្រង់និងបែបបទលម្អិតនៃគំរូរបាយការណ៍ ត្រូវកំណត់ដោយសេចក្តីណែនាំរបស់ក.អ.ក.។

ការផ្តល់របាយការណ៍ស្តីពីការអនុវត្តគម្រោងវិនិយោគ ពុំមែនជាមូលដ្ឋាននៃការរួចផុតពីការពិនិត្យអនុលោមភាពក្នុងការអនុវត្តគម្រោងនៅនឹងកន្លែងអនុវត្តគម្រោងទេ ប្រសិនបើក.អ.ក.សន្មតថាមានភាពចាំបាច់ ឬប្រសិនបើមានការតវ៉ាណាមួយពីបុគ្គលដែលអះអាងថាបានទទួលរងនូវផលប៉ះពាល់ពីការអនុវត្តគម្រោងវិនិយោគ។

**មាត្រា១៤.-**

នីតិវិធីចុះបញ្ជីគម្រោងវិនិយោគនៅអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក។

## ជំពូកទី៥
## ការធានានិងការការពារវិនិយោគ

**មាត្រា១៥.-**

វិនិយោគិននឹងទទួលបាននូវប្រព្រឹត្តកម្មមិនរើសអើងទាក់ទងនឹងបដិទាន សំណង ឬដំណោះស្រាយជាតម្លៃសេដ្ឋកិច្ចផ្សេងទៀត ក្នុងករណីការវិនិយោគរបស់ខ្លួនបានទទួលរងនូវការខូចខាត ដោយសារជម្លោះប្រដាប់អាវុធ ឬកលិយុគស៊ីវិល ឬការដាក់ប្រទេសជាតិស្ថិតនៅក្នុងភាពអាសន្ន ប្រសិនបើមានច្បាប់និងគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការធ្វើបដិទានឬផ្តល់សំណងសមរម្យណាមួយនោះ។

វិនិយោគិនបរទេសមិនត្រូវជាកម្មវត្ថុនៃការរើសអើង ដោយសារមូលហេតុសញ្ជាតិបរទេស លើកលែងតែកម្មសិទ្ធិលើដីធ្លី ដូចដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជានិងបទប្បញ្ញត្តិទាំងឡាយជាធរមាន។

**មាត្រា១៦.-**

រដ្ឋមិនត្រូវធ្វើជាតូបនីយកម្មដែលនាំឱ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់វិនិយោគិនក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ។

**មាត្រា១៧.-**

រដ្ឋមិនត្រូវធ្វើអស្សាមិករណ៍ដែលនាំឱ្យប៉ះពាល់ដល់គម្រោងវិនិយោគដែលបានទទួលការអនុម័តនោះឡើយ ទោះបីដោយផ្ទាល់ឬដោយប្រយោល ឬតាមរយៈវិធានការប្រហាក់ប្រហែលនឹងការធ្វើអស្សាមិករណ៍ក្តី

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

លើកលែងតែក្នុងករណីបម្រើប្រយោជន៍សាធារណៈ ដែលការធ្វើអស្សាមិករណ៍នេះត្រូវអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម៖

១- ភាពមិនរើសអើង

២- សំណងដោយសមរម្យនិងយុត្តិធម៌ និង

៣- អនុលោមតាមច្បាប់និងនីតិវិធីអស្សាមិករណ៍ជាធរមាន។

**មាត្រា១៨.-**

រាជរដ្ឋាភិបាលមិនត្រូវកំណត់ថ្លៃផលិតផលឬថ្លៃសេវានានាដែលបង្កើតដោយគម្រោងវិនិយោគនោះឡើយ។

**មាត្រា១៩.-**

ដោយអនុលោមទៅតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន វិនិយោគិនមានសិទ្ធិទិញរូបិយបណ្ណបរទេសដោយសេរី និងបង្វិលទៅបរទេសនូវរូបិយបណ្ណបរទេសទាំងអស់នោះដើម្បីទូទាត់កាតព្វកិច្ចខាងហិរញ្ញវត្ថុដែលពាក់ព័ន្ធនឹងការវិនិយោគរបស់ខ្លួន តាមរយៈប្រព័ន្ធធនាគារដែលជាអន្តរការីប្រតិស្រុតិ។ ការផ្ទេរទាំងនេះរាប់បញ្ចូលទាំង៖

១- វិភាគទានចំពោះមូលធន រាប់បញ្ចូលទាំងវិភាគទានមូលធនបឋម

២- ប្រាក់ចំណូល ចំណេញមូលធន ភាគលាភ កម្រៃសួយសារ កម្រៃអាជ្ញាបណ្ណ កម្រៃនៃការគ្រប់គ្រង និងជំនួយបច្ចេកទេស ការប្រាក់ និងប្រាក់ចំណូលដទៃទៀតដែលកើតពីការវិនិយោគ

៣- ផលដែលទទួលបានពីការលក់សរុប ឬការលក់មួយផ្នែក ឬការរំលាយក្រុមហ៊ុនដែលអនុវត្តគម្រោងវិនិយោគ

៤- ការទូទាត់លើការនាំចូល និងការបង្វិលទៅក្រៅប្រទេសទាំងប្រាក់ដើម និងការប្រាក់នៃប្រាក់កម្ចី

៥- ការទូទាត់ចំពោះសំណងក្នុងករណីមានកលិយុគស៊ីវិល ក្នុងករណីមានអស្សាមិករណ៍ឬការដកហូតដោយរដ្ឋ

៦- ការទូទាត់កើតឡើងពីដំណោះស្រាយវិវាទដោយមធ្យោបាយណាមួយ រាប់បញ្ចូលទាំងសេចក្ដីសម្រេចរបស់តុលាការឬសេចក្ដីសម្រេចរបស់មជ្ឈត្តការ និង

៧- ចំណូលនិងប្រាក់ឈ្នួលដទៃទៀតរបស់និយោជិត។

**មាត្រា២០.-**

កម្មសិទ្ធិបញ្ញារបស់វិនិយោគិនត្រូវបានការពារដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញានៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២១.-**

កម្មសិទ្ធិលើដីធ្លីរបស់វិនិយោគិនសម្រាប់បម្រើឱ្យគោលដៅអនុវត្តគម្រោងវិនិយោគ ត្រូវបានអនុញ្ញាតចំពោះរូបវន្តបុគ្គលដែលមានសញ្ជាតិខ្មែរស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

វិនិយោគិនមានសិទ្ធិប្រើប្រាស់ដីធ្លីតាមរយៈជាអាទិ៍ សម្បទានដីសេដ្ឋកិច្ច ឬសិទ្ធិជួលអចិន្ត្រៃយ៍ និងការជួលដែលមានអំឡុងពេលកំណត់ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា២២.-**

បុគ្គលដែលត្រូវបានចាត់ទុកជាវិនិយោគិន ដោយផ្អែកទៅលើច្បាប់នេះ មានសិទ្ធិដូចខាងក្រោមៈ

១- សិទ្ធិជួលនិយោជិតបរទេស ដើម្បីគ្រប់គ្រងឬប្រតិបត្តិការគម្រោងវិនិយោគក្នុងចំនួនមិនលើសពីចំនួនដែលបានកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ក្នុងករណីពុំអាចរកនិយោជិតខ្មែរដែលមានជំនាញដើម្បីគ្រប់គ្រងឬប្រតិបត្តិការគម្រោងវិនិយោគនោះ។ ការអនុញ្ញាតឱ្យជួលនិយោជិតបរទេសនេះ គឺត្រូវពិនិត្យទៅតាមស្ថានភាពជាក់ស្ដែង និងពុំមានលក្ខណៈអចិន្ត្រៃយ៍ទេ។

២- សិទ្ធិទទួលបានការអនុញ្ញាតស្នាក់នៅបណ្ដោះអាសន្នរយៈពេលវែងសម្រាប់ខ្លួនឯងផ្ទាល់សម្រាប់សហព័ទ្ធនិងកូនដែលជាអនីតិជន ក្នុងអំឡុងពេលដែលគម្រោងវិនិយោគរបស់ខ្លួនមានប្រតិបត្តិការ។

៣- សិទ្ធិស្នើសុំការអនុញ្ញាតស្នាក់នៅបណ្ដោះអាសន្នរយៈពេលវែងសម្រាប់និយោជិតបរទេស និងសម្រាប់សហព័ទ្ធនិងកូនដែលជាអនីតិជនរបស់និយោជិតបរទេសទាំងនេះ ក្នុងអំឡុងពេលដែលកិច្ចសន្យាការងារនៅមានសុពលភាព។

៤- សិទ្ធិទទួលបានបណ្ណការងារនិងសៀវភៅការងារសម្រាប់ខ្លួនឯងផ្ទាល់និងសម្រាប់និយោជិតបរទេសរបស់ខ្លួន។

ក.អ.ក.ឬអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្តត្រូវចេញលិខិតបញ្ជាក់អំពីឋានៈជាវិនិយោគិនជូនបុគ្គលពាក់ព័ន្ធនឹងគម្រោងវិនិយោគទៅតាមការស្នើសុំរបស់វិនិយោគិន ដើម្បីប្រើប្រាស់សម្រាប់ការស្នើសុំការអនុញ្ញាតស្នាក់នៅបណ្ដោះអាសន្នរយៈពេលវែង បណ្ណការងារនិងសៀវភៅការងារ និងគោលបំណងចាំបាច់ដទៃទៀតស្របតាមនីតិវិធីជាធរមាន។

នីតិវិធីពិសេសសម្រាប់ការស្នើសុំបណ្ណការងារនិងសៀវភៅការងារ ដូចមានចែងក្នុងមាត្រានេះត្រូវកំណត់នៅក្នុងប្រកាសរួមរវាងក.អ.ក. និងក្រសួងទទួលបន្ទុកវិស័យការងារ។

បែបបទនិងនីតិវិធីពិសេសសម្រាប់ការស្នើសុំការអនុញ្ញាតស្នាក់នៅបណ្ដោះអាសន្នរយៈពេលវែងដូចមានចែងក្នុងមាត្រានេះត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក។

**មាត្រា២៣.-**

វិនិយោគិនមានសិទ្ធិទទួលបាននូវសេវាថែទាំវិនិយោគចំពោះគម្រោងវិនិយោគដែលបានចុះបញ្ជីនៅក.អ.ក.ឬអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្ដល់សេវាថែទាំវិនិយោគចំពោះគម្រោងវិនិយោគដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ ត្រូវកំណត់ដោយអនុក្រឹត្យ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

## ជំពូកទី៦

## ការលើកទឹកចិត្តវិនិយោគ

**មាត្រា២៤.-**

វិស័យនិងសកម្មភាពវិនិយោគដូចខាងក្រោម ត្រូវទទួលការលើកទឹកចិត្តៈ

១- ឧស្សាហកម្មដែលមានបច្ចេកវិទ្យាខ្ពស់ ប្រកបដោយនវានុវត្តន៍ និងការស្រាវជ្រាវនិងអភិវឌ្ឍ

២- ឧស្សាហកម្មឬកម្មន្តសាលថ្មីៗ ផ្តល់តម្លៃបន្ថែមខ្ពស់ មាននវានុវត្តន៍ និងភាពប្រកួតប្រជែងខ្ពស់

៣- ឧស្សាហកម្មបម្រើឱ្យខ្សែច្រវាក់ផលិតកម្មតំបន់និងសកលលោក

៤- ឧស្សាហកម្មគាំទ្រពាក់ព័ន្ធនឹងវិស័យកសិកម្ម ទេសចរណ៍ កម្មន្តសាល ឧស្សាហកម្មបម្រើឱ្យខ្សែច្រវាក់ផលិតកម្មតំបន់និងសកលលោក និងឧស្សាហកម្មតភ្ជាប់បណ្តាញផ្គត់ផ្គង់

៥- ឧស្សាហកម្មគ្រឿងអគ្គិសនីនិងអេឡិចត្រូនិក

៦- ឧស្សាហកម្មគ្រឿងបន្លាស់ បង្គុំ និងតម្លើង

៧- ឧស្សាហកម្មមេកានិកនិងគ្រឿងម៉ាស៊ីន

៨- កសិកម្ម កសិឧស្សាហកម្ម ឧស្សាហកម្មកែច្នៃផលិតផលកសិកម្ម និងឧស្សាហកម្មកែច្នៃចំណីអាហារដែលបម្រើទីផ្សារក្នុងស្រុកឬការនាំចេញ

៩- សហគ្រាសធុនតូចនិងមធ្យមក្នុងវិស័យអាទិភាព និងការអភិវឌ្ឍបណ្តុំសហគ្រាសធុនតូច និងមធ្យម សួនឧស្សាហកម្ម និងសួនវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

១០- ឧស្សាហកម្មទេសចរណ៍និងសកម្មភាពពាក់ព័ន្ធនឹងទេសចរណ៍

១១- ការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស

១២- ឧស្សាហកម្មឌីជីថល

១៣- ការវិនិយោគក្នុងវិស័យអប់រំ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការជំរុញផលិតភាព

១៤- ការវិនិយោគក្នុងវិស័យសុខាភិបាល

១៥- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

១៦- ការវិនិយោគក្នុងវិស័យឡូជីស្ទីក

១៧- ការវិនិយោគក្នុងការគ្រប់គ្រង ការការពារបរិស្ថាន និងការអភិរក្សជីវៈចម្រុះ និងសេដ្ឋកិច្ចចក្រា

១៨- ការវិនិយោគក្នុងវិស័យថាមពលបៃតង បច្ចេកវិទ្យាដែលរួមចំណែកដល់ការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ

១៩- វិស័យនិងសកម្មភាពវិនិយោគផ្សេងទៀតដែលមិនមានចែងក្នុងច្បាប់នេះ ក្នុងករណីដែលរាជរដ្ឋាភិបាលយល់ឃើញថាមានសក្តានុពលដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច។

**មាត្រា២៥.-**

វិស័យនិងសកម្មភាពវិនិយោគដែលមានចែងក្នុងមាត្រា២៤នៃច្បាប់នេះដែលមិនស្ថិតនៅក្នុងបញ្ជីអវិជ្ជមាន ត្រូវទទួលបានការលើកទឹកចិត្តជាមូលដ្ឋានផ្នែកពន្ធដារ និង/ឬពន្ធគយទាំងស្រុងឬមួយផ្នែក ក្រោយពីបានវិញ្ញាបនបត្រចុះបញ្ជីបញ្ជាក់ឋានៈជា គ.ល.ត.។

វិស័យនិងសកម្មភាពវិនិយោគដែលមានចែងក្នុងមាត្រា២៤នៃច្បាប់នេះដែលពុំទទួលបានការលើកទឹកចិត្តទាំងផ្នែកពន្ធដារនិងពន្ធគយត្រូវបានកំណត់ក្នុងបញ្ជីអវិជ្ជមានដែលនឹងចែងដោយអនុក្រឹត្យ។

**មាត្រា២៦.-**

សកម្មភាពវិនិយោគដែលបានចុះបញ្ជីជា គ.ឈ.គ មានសិទ្ធិជ្រើសរើសការលើកទឹកចិត្តជាមូលដ្ឋានជាពីរជម្រើសដូចខាងក្រោមៈ

**១. ជម្រើសទី១**

- ការលើកលែងពន្ធលើប្រាក់ចំណូល សម្រាប់រយៈពេលចាប់ពី៣(បី)ឆ្នាំ រហូតដល់៩(ប្រាំបួន)ឆ្នាំ ទៅតាមវិស័យនិងសកម្មភាពវិនិយោគ គិតចាប់ពីពេលដែលទទួលបានប្រាក់ចំណូលលើកដំបូង។ វិស័យនិងសកម្មភាពវិនិយោគ ព្រមទាំងរយៈពេលលើកលែងពន្ធលើប្រាក់ចំណូល នឹងត្រូវកំណត់ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង និង/ឬ អនុក្រឹត្យ។ បន្ទាប់ពីផុតរយៈពេលលើកលែងពន្ធលើប្រាក់ចំណូល គ.ឈ.គ. មានសិទ្ធិទទួលបានការលើកទឹកចិត្តឱ្យបង់ពន្ធលើប្រាក់ចំណូលតាមអត្រាកំណើនតាមពេលធៀបទៅនឹងទឹកប្រាក់ពន្ធត្រូវបង់សរុប ដូចខាងក្រោមៈ
  - ២៥(ម្ភៃប្រាំ)ភាគរយ សម្រាប់២(ពីរ)ឆ្នាំដំបូង
  - ៥០(ហាសិប)ភាគរយ សម្រាប់២(ពីរ)ឆ្នាំបន្ទាប់ និង
  - ៧៥(ចិតសិបប្រាំ)ភាគរយ សម្រាប់២(ពីរ)ឆ្នាំចុងក្រោយ។
- ទទួលបានការលើកលែងប្រាក់រំដោះពន្ធលើប្រាក់ចំណូល ក្នុងអំឡុងពេលលើកលែងពន្ធលើប្រាក់ចំណូល។
- ទទួលបានការលើកលែងពន្ធអប្បបរមា ដោយត្រូវមានរបាយការណ៍សវនកម្មឯករាជ្យ។
- ទទួលបានការលើកលែងអាករនាំចេញ លើកលែងតែមានចែងដោយឡែកនៅក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត។ ឬ

**២. ជម្រើសទី២**

- មានសិទ្ធិកាត់កងចំណាយមូលធនតាមរយៈរំលស់ពិសេស ដូចមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន។
- មានសិទ្ធិកាត់កងរហូតដល់២០០(ពីររយ)ភាគរយ លើចំណាយជាក់លាក់ផ្សេងទៀត សម្រាប់រយៈពេលរហូតដល់៩(ប្រាំបួន)ឆ្នាំ។ វិស័យ និងសកម្មភាពវិនិយោគ និងចំណាយជាក់លាក់ព្រមទាំងរយៈពេលកាត់កងចំណាយ ត្រូវកំណត់ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង និង/ឬ អនុក្រឹត្យ។
- ទទួលបានការលើកលែងប្រាក់រំដោះពន្ធលើប្រាក់ចំណូល ក្នុងរយៈពេលជាក់លាក់ណាមួយទៅតាមវិស័យ និងសកម្មភាពវិនិយោគ ដែលត្រូវកំណត់ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង និង/ឬ អនុក្រឹត្យ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

- ទទួលបានការលើកលែងពន្ធអប្បបរមា ដោយត្រូវមានរបាយការណ៍សវនកម្មឯករាជ្យ។
- ទទួលបានការលើកលែងអាករនាំចេញ លើកលែងតែមានចែងដោយឡែកនៅក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមានផ្សេងទៀត។

ក្រៅពីការលើកទឹកចិត្តក្នុងកថាខណ្ឌទី១នៃមាត្រានេះ៖

ក. គ.ល.គ. បម្រើឱ្យការនាំចេញ និង គ.ល.គ. ដែលជាប្រភេទឧស្សាហកម្មគាំទ្រដល់ គ.ល.គ. បម្រើឱ្យការនាំចេញ មានសិទ្ធិនាំចូលដោយពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋនូវសម្ភារៈសាងសង់ បរិក្ខារសំណង់ សម្ភារៈបរិក្ខារផលិតកម្ម និងធាតុចូលផលិតកម្ម។

ខ. គ.ល.គ. បម្រើទីផ្សារក្នុងស្រុក មានសិទ្ធិនាំចូលដោយពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋនូវសម្ភារៈសាងសង់ បរិក្ខារសំណង់ និងសម្ភារៈបរិក្ខារផលិតកម្ម។ ការលើកទឹកចិត្តចំពោះធាតុចូលផលិតកម្ម ត្រូវកំណត់ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង និង/ឬ អនុក្រឹត្យ។

គ.ល.គ. ដែលមានទីតាំងនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស មានសិទ្ធិទទួលបាននូវការលើកទឹកចិត្តនិងការការពារដូចគ្នានឹង គ.ល.គ. ផ្សេងៗទៀត ដូចមានចែងក្នុងច្បាប់នេះ។

**មាត្រា២៧.-**

ក្រៅពីការលើកទឹកចិត្តជាមូលដ្ឋាន ដែលមានចែងក្នុងមាត្រា២៦នៃច្បាប់នេះ សកម្មភាពវិនិយោគដែលបានចុះបញ្ជីជា គ.ល.គ. ទទួលបានការលើកទឹកចិត្តបន្ថែម ដូចខាងក្រោម៖

១- ទទួលបានការលើកលែងអាករលើតម្លៃបន្ថែម ចំពោះការទិញធាតុចូលផលិតកម្មដែលផលិតក្នុងស្រុកសម្រាប់បម្រើដល់ការអនុវត្ត គ.ល.គ.។

២- ទទួលបានការកាត់កងចំណាយក្នុងអត្រា ១៥០(មួយរយហាសិប)ភាគរយ ពីមូលដ្ឋានគិតពន្ធចំពោះសកម្មភាពណាមួយដូចខាងក្រោម៖

ក. ការស្រាវជ្រាវ អភិវឌ្ឍន៍ និងនវានុវត្តន៍

ខ. ការអភិវឌ្ឍធនធានមនុស្ស តាមរយៈការផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងជំនាញដល់កម្មករនិយោជិតខ្មែរ

គ. ការសាងសង់កន្លែងស្នាក់នៅ កន្លែងបរិភោគអាហារ ឬអាហារដ្ឋានដែលមានតម្លៃសមរម្យ ទារកដ្ឋាន និងសុខុបត្ថម្ភវត្ថុដទៃទៀតសម្រាប់កម្មករនិយោជិត

ឃ. ការធ្វើទំនើបកម្មលើគ្រឿងម៉ាស៊ីនដើម្បីបម្រើឱ្យខ្សែច្រវាក់ផលិតកម្ម

ង. ការផ្តល់ការលើកកម្ពស់សុខុមាលភាពដល់កម្មករនិយោជិតខ្មែរ ដូចជាការផ្តល់មធ្យោបាយដឹកជញ្ជូនប្រកបដោយជាសុវត្ថិភាពដល់កម្មករនិយោជិត ក្នុងការធ្វើដំណើរទៅមកពីកន្លែងស្នាក់នៅទៅរោងចក្រ កន្លែងស្នាក់នៅ កន្លែងបរិភោគអាហារ ឬអាហារដ្ឋានដែលមានតម្លៃសមរម្យ ទារកដ្ឋាន និងសុខុបត្ថម្ភវត្ថុដទៃទៀត។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៣- ទទួលបានការលើកលែងពន្ធលើប្រាក់ចំណូល ចំពោះការពង្រីកនៃ គ.ល.គ. ដែលត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២៨ .-**

បន្ថែមពីលើការលើកទឹកចិត្តដូចមានកំណត់ក្នុងមាត្រា២៦និងមាត្រា២៧នៃច្បាប់នេះ វិស័យនិងសកម្មភាពវិនិយោគជាក់លាក់ណាមួយដែលមានសក្តានុពលខ្ពស់ក្នុងការចូលរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ អាចទទួលការលើកទឹកចិត្តពិសេសដោយឡែកផ្សេងទៀត ដែលត្រូវកំណត់នៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង។

## ជំពូកទី៧

## ការទិញ ការលក់ ឬការរួមបញ្ចូលគ្នានៃគម្រោងវិនិយោគ

**មាត្រា២៩ .-**

សិទ្ធិ បុព្វសិទ្ធិ ឬសិទ្ធិដទៃទៀត ដែល គ.ល.គ. បានទទួលមិនអាចផ្ទេរទៅតតិយជនណាមួយបានទេ លើកលែងតែការផ្ទេរតាមរយៈការទិញ ការលក់ និងការរួមបញ្ចូលគ្នានៃគម្រោងវិនិយោគ។

**មាត្រា៣០ .-**

គម្រោងវិនិយោគអាចត្រូវបានទិញ លក់ ឬរួមបញ្ចូលគ្នាដោយមិនបាត់បង់ការលើកទឹកចិត្ត ការធានាលើការវិនិយោគ និងកាតព្វកិច្ចទាំងឡាយដែលនៅមានបន្ត ប្រសិនបើការទិញ ការលក់ ឬការរួមបញ្ចូលគ្នានោះស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ហើយត្រូវបានធ្វើឡើងតាមរយៈការស្នើសុំជាលាយលក្ខណ៍អក្សរទៅក.អ.ក ឬទៅអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត ដែលនីតិវិធីលម្អិតត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៨

## ការលុបគម្រោងវិនិយោគ

**មាត្រា៣១ .-**

គម្រោងវិនិយោគអាចត្រូវបានលុបក្នុងករណីណាមួយដូចខាងក្រោម៖

១- អលទ្ធភាពក្នុងការអនុវត្ត គ.ល.គ. បន្តទៀត។

២- នីតិបុគ្គលដែលអនុវត្ត គ.ល.គ. ត្រូវបានរំលាយ។

៣- ការខកខានអនុវត្តកាតព្វកិច្ចដែលបានកំណត់ក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

៤- តាមសំណើរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ លើគម្រោងដែលមានផលប៉ះពាល់ធ្ងន់ធ្ងរជាអាទិ៍ដល់បរិស្ថាន ឬសន្តិសុខជាតិ ឬផលប្រយោជន៍សាធារណៈ ឬសុខុមាលភាពប្រជាពលរដ្ឋ ឬតាមសំណើរបស់វិនិយោគិន។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា៣២.–**

ក្នុងករណីការលុបដោយលក្ខខណ្ឌដូចមានចែងក្នុងចំណុច១នៃមាត្រា៣១នៃច្បាប់នេះ វិនិយោគិនត្រូវដាក់ពាក្យស្នើសុំលុបដោយផ្ទាល់ ឬតាមរយៈអ្នកតំណាងដែលមានសិទ្ធិ ទៅក.អ.ក.ឬទៅអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត។ លិខិតស្នើសុំខាងលើនេះត្រូវចុះហត្ថលេខាដោយវិនិយោគិន ឬអ្នកតំណាងដែលមានសិទ្ធិ ដោយត្រូវបញ្ជាក់អំពីមូលហេតុនៃអលទ្ធភាពនេះ និងត្រូវភ្ជាប់មកជាមួយនូវឯកសារគាំទ្រផ្សេងៗ។

ក្នុងករណីការលុបដោយការរំលាយដូចមានចែងក្នុងចំណុច២នៃមាត្រា៣១នៃច្បាប់នេះ ប្រសិនបើការរំលាយនេះធ្វើឡើងដោយការជម្រះបញ្ជីនិងរំលាយក្រុមហ៊ុនដោយស្ម័គ្រចិត្ត នោះវិនិយោគិនត្រូវដាក់ពាក្យស្នើសុំលុបដោយផ្ទាល់ ឬតាមរយៈអ្នកតំណាងដែលមានសិទ្ធិ ទៅក.អ.ក.ឬទៅអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត។

ក្នុងករណីការលុបដោយការរំលាយដូចមានចែងក្នុងចំណុច២នៃមាត្រា៣១នៃច្បាប់នេះ ប្រសិនបើការរំលាយនេះធ្វើឡើងដោយសេចក្ដីសម្រេចរបស់តុលាការ វិនិយោគិនអាចដាក់ពាក្យស្នើសុំលុបដោយផ្ទាល់ទៅក.អ.ក.ឬទៅអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត ដោយភ្ជាប់មកជាមួយនូវ សេចក្ដីសម្រេចស្ថាពររបស់តុលាការនិងឯកសារពាក់ព័ន្ធអំពីការរំលាយនីតិបុគ្គលដែលអនុវត្ត គ.ល.គ. និងសេចក្ដីបញ្ជាក់ពីទំនាក់ទំនងផលប្រយោជន៍ជាមួយ គ.ល.គ. ដែលត្រូវលុបនេះផងដែរ។

គ.ល.គ. អាចត្រូវបានលុបដោយឆន្ទានុសិទ្ធិរបស់ក.អ.ក.ឬរបស់អនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត ដោយអនុលោមតាមលក្ខខណ្ឌដូចមានកំណត់ក្នុងចំណុច៣នៃមាត្រា៣១នៃច្បាប់នេះ។

នីតិវិធីលម្អិតស្ដីពីការស្នើសុំលុបនិងការលុបដោយឆន្ទានុសិទ្ធិ ដូចមានកំណត់ពីចំណុច១ ដល់ចំណុច៤នៃមាត្រា៣១នៃច្បាប់នេះ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៣៣.–**

ទោះបីជាគម្រោងវិនិយោគត្រូវបានលុបក៏ដោយ វិនិយោគិនមិនអាចរួចផុតពីកាតព្វកិច្ចសារពើពន្ធនិងកាតព្វកិច្ចដទៃផ្សេងៗទៀតឡើយ។

**មាត្រា៣៤.–**

វិនិយោគិនអាចធ្វើការតវ៉ាចំពោះការលុបគម្រោងវិនិយោគបាន តាមរយៈការដាក់ពាក្យតវ៉ាជាលាយលក្ខណ៍អក្សរទៅក.អ.ក.ឬទៅអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត ស្របតាមនីតិវិធីជាធរមាន។

ក្នុងករណីមានការតវ៉ា ក.អ.ក.ឬអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត ត្រូវធ្វើសេចក្ដីសម្រេចចំពោះការតវ៉ាខាងលើ។

ក្នុងករណីមិនពេញចិត្តនឹងសេចក្ដីសម្រេចចំពោះការតវ៉ាខាងលើ វិនិយោគិនដែលបានតវ៉ា អាចដាក់ពាក្យបណ្ដឹងទៅតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣៥.–**

ក្នុងករណីដែលគម្រោងវិនិយោគត្រូវបានលុប វិនិយោគិនអាចផ្ទេរទ្រព្យសម្បត្តិដែលសេសសល់ ទៅក្រៅប្រទេស ឬប្រើនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្នុងករណីដែលគម្រោងវិនិយោគបានប្រើសម្ភារៈសាងសង់

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

បរិក្ខារសំណង់ សម្ភារៈបរិក្ខារផលិតកម្ម និងធាតុចូលផលិតកម្ម ដែលបាននាំចូលដោយលើកលែងពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែម ជាបន្ទុករបស់រដ្ឋ ក្នុងអំឡុងពេលតិចជាង៥(ប្រាំ)ឆ្នាំ វិនិយោគិនមានកាតព្វកិច្ចបង់ពន្ធលើសម្ភារៈសាងសង់ បរិក្ខារសំណង់ សម្ភារៈបរិក្ខារផលិតកម្ម និងធាតុចូលផលិតកម្មផ្សេងៗទាំងនោះ ដែលត្រូវកំណត់ដោយអនុក្រឹត្យស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៩
## វិវាទនិងការដោះស្រាយវិវាទ

**មាត្រា៣៦.-**

វិវាទរវាងវិនិយោគិននិងវិនិយោគិនពាក់ព័ន្ធទៅនឹងគម្រោងវិនិយោគ អាចត្រូវបានដោះស្រាយតាមយន្តការសម្របសម្រួលដោយក.អ.ក.ឬដោយអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត តាមនីតិវិធីជាធរមាន តាមការស្នើសុំជាលាយលក្ខណ៍អក្សរទៅក.អ.ក.ឬអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត ដោយភាគីវិវាទណាមួយ។

ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ បន្ទាប់ពីទទួលបានសំណើសុំជាលាយលក្ខណ៍អក្សរដែលស្នើសុំសម្របសម្រួល ក.អ.ក.ឬអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត ត្រូវចាត់ចែងរៀបចំការសម្របសម្រួលជាមួយវិនិយោគិននិងអង្គពាក់ព័ន្ធដទៃទៀតទៅតាមការចាំបាច់ សំដៅទទួលបានដំណោះស្រាយសមរម្យមួយ។

ប្រសិនបើការដោះស្រាយតាមយន្តការសម្របសម្រួលខាងលើពុំទទួលបានជោគជ័យ វិវាទអាចត្រូវបានដោះស្រាយតាមរយៈ៖

១- មជ្ឈត្តការជាតិឬមជ្ឈត្តការអន្តរជាតិដែលយល់ព្រមដោយគូវិវាទ

២- តុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី១០
## ការអនុវត្ត

**មាត្រា៣៧.-**

បន្ទាប់ពីច្បាប់នេះចូលជាធរមាន រាជរដ្ឋាភិបាលត្រូវចេញអនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីអនុវត្តបទប្បញ្ញត្តិនៃច្បាប់នេះឱ្យមានប្រសិទ្ធភាពនិងគ្រប់ជ្រុងជ្រោយ។

## ជំពូកទី១១
## អន្តរប្បញ្ញត្តិ

**មាត្រា៣៨.-**

អនុក្រឹត្យដូចខាងក្រោមត្រូវបន្តមានសុពលភាពរហូតដល់មានអនុក្រឹត្យឬលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស៖

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

១. អនុក្រឹត្យលេខ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្ដីពីការអនុវត្តច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

២. អនុក្រឹត្យលេខ៧៩ អនក្រ.បក ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២១ ស្ដីពីការបង្កើតអនុគណៈកម្មាធិការវិនិយោគរាជធានី-ខេត្ត។

៣. អនុក្រឹត្យលេខ៣៤ អនក្រ.បក ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៧ ស្ដីពីការកែសម្រួលផ្នែកទី១ ឧបសម្ព័ន្ធទី១នៃអនុក្រឹត្យលេខ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្ដីពីការអនុវត្តច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

៤. អនុក្រឹត្យលេខ៦០ អនក្រ.បក ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

៥. អនុក្រឹត្យលេខ៣៣ អនក្រ.បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ ស្ដីពីការកែសម្រួលមាត្រា១៥ នៃអនុក្រឹត្យលេខ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្ដីពីការអនុវត្តច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

៦. អនុក្រឹត្យលេខ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្ដីពីការបង្កើតនិងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស។

៧. លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត។

**មាត្រា៣៩.-**

ក.អ.ក ត្រូវបន្តអនុវត្តភារកិច្ចរបស់ខ្លួន រហូតដល់មានព្រះរាជក្រឹត្យស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាមកជំនួស។

**មាត្រា៤០.-**

ការវិនិយោគទាំងឡាយដែលបានទទួលការលើកទឹកចិត្ត និងដែលបានទទួលការអនុញ្ញាតដោយច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៩៤ និងច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ និងអនុក្រឹត្យនានា ត្រូវបានចាត់ទុកជា គ.ល.ត. ដូចមានចែងក្នុងច្បាប់នេះនិងអនុក្រឹត្យពាក់ព័ន្ធ។

ការវិនិយោគទាំងឡាយដែលពុំបានទទួលការលើកទឹកចិត្តឬទទួលបានត្រឹមតែលើការធានាការវិនិយោគ និងដែលបានទទួលការអនុញ្ញាតដោយច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៩៤ និងច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ និងអនុក្រឹត្យនានា ត្រូវបានចាត់ទុកជា **គធវ** ដូចមានចែងក្នុងច្បាប់នេះនិងអនុក្រឹត្យពាក់ព័ន្ធ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

គ.ល.គ. ដែលមានសិទ្ធិទទួលបាននូវការលើកលែងពន្ធលើប្រាក់ចំណូល មុនពេលប្រកាសឱ្យប្រើនូវច្បាប់នេះ ហើយដែលសិទ្ធិទទួលបាននេះត្រូវបានអនុម័តជាលាយលក្ខណ៍អក្សរដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាឬដោយអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត ត្រូវបន្តទទួលបាននូវសិទ្ធិនិងការលើកលែងពន្ធលើប្រាក់ចំណូលត្រឹមទំហំដែលនៅសេសសល់តែប៉ុណ្ណោះ។

## ជំពូកទី១២
## អវសានបញ្ញត្តិ

**មាត្រា៤១.-**

ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៩៤ ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍។

**មាត្រា៤២.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃសុក្រ ៧កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ២០២១

នស.រកម.១០២១.០១៦

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:១១១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

*****

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និង ព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ/បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និង អនុក្រឹត្យវិសោធនកម្ម លេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងលេខ១៣០ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីការធ្វើវិសោធនកម្ម លើអនុក្រឹត្យលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៩

- បានឃើញអនុក្រឹត្យលេខ៧០អនក្រ/បកចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និង អនុក្រឹត្យវិសោធនកម្មលេខ ១១២ អនក្រ. បក ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០២ និងលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការធ្វើវិសោធនកម្ម លើអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០០៥

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

### មាត្រា ១: ទំហំវិសាលភាពនៃអនុក្រឹត្យ

១.១ គោលដៅ: អនុក្រឹត្យនេះ បំពេញបន្ថែម និង ចាត់ចែង គ្រប់គ្រងការអនុវត្តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និង មានគោលដៅ ជំរុញការលើកទឹកចិត្ត និង ធ្វើនិយ័តកម្មលើការវិនិយោគទាំងឡាយរបស់នីតិបុគ្គលសញ្ជាតិខ្មែរ និង នីតិបុគ្គលសញ្ជាតិបរទេស នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

១.២ ការអនុវត្ត: អនុក្រឹត្យនេះ អនុវត្តទៅលើរាល់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ "គ.ល.គ" ទាំងអស់ ដែលបានចុះបញ្ជីនៅក្រុមប្រឹក្សា និងនៅអនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ។

### មាត្រា ២: វិស័យសម្រាប់វិនិយោគ

សកម្មភាពវិនិយោគ: អនុក្រឹត្យនេះអនុវត្តលើគ្រប់សកម្មភាពវិនិយោគ លើកលែងតែសកម្មភាពនោះបានកំណត់នៅក្នុងបញ្ជីអវិជ្ជមានដែលមានក្នុងឧបសម្ព័ន្ធទី១ ផ្នែកទី១ នៃអនុក្រឹត្យនេះ ដូចដែលមានចែងក្នុងមាត្រា ៧ ថ្មី នៃច្បាប់ស្តីពីវិនិយោគ ។

### មាត្រា ៣: ការវិនិយោគរបស់បុគ្គលសញ្ជាតិបរទេស និង បុគ្គលសញ្ជាតិខ្មែរ

៣.១ ការវិនិយោគរបស់បុគ្គលសញ្ជាតិបរទេស និង បុគ្គលសញ្ជាតិខ្មែរ: រាជរដ្ឋាភិបាលស្វាគមន៍ចំពោះការវិនិយោគពីសំណាក់បុគ្គលសញ្ជាតិបរទេស និងបុគ្គលសញ្ជាតិខ្មែរលើគ្រប់វិស័យសេដ្ឋកិច្ចទាំងអស់ លើកលែងតែសកម្មភាពដែលស្ថិតនៅក្រោមការដាក់កំហិតដូចមានចែងនៅក្នុងមាត្រា ២ នៃអនុក្រឹត្យនេះ។

៣.២ ការប្រើប្រាស់អ្នកតំណាង: គ្មានបុគ្គលសញ្ជាតិខ្មែរណា អាចធ្វើសកម្មភាព ឬ ធ្វើតំណាងដោយផ្ទាល់ ឬ ដោយប្រយោលឱ្យបុគ្គលសញ្ជាតិបរទេស ក្នុងគោលបំណងដើម្បីពង្វាងនូវការអនុវត្តបទប្បញ្ញត្តិណាមួយនៃអនុក្រឹត្យនេះ ដែលដាក់កំហិត ឬ ហាមឃាត់ ចំពោះសកម្មភាពរបស់បុគ្គលសញ្ជាតិបរទេសនោះបានឡើយ ។

**មាត្រា ៤: និយមន័យ**

ក្នុងន័យនៃអនុក្រឹត្យនេះ វាក្យស័ព្ទ:

ក្រុមប្រឹក្សា: សំដៅដល់ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលបានបង្កើតឡើងតាមមាត្រា ៣ នៃ ច្បាប់ស្តីពីវិនិយោគ។

ការធានាលើការវិនិយោគ: សំដៅដល់ ការធានាដែលបានកំណត់នៅក្នុងជំពូក ៤ នៃច្បាប់ស្តីពីវិនិយោគ ហើយដែលមានចែងក្នុងអនុក្រឹត្យនេះ សម្រាប់ផ្តល់ជូនដល់អ្នកវិនិយោគណា ដែលបំពេញតាមលក្ខខណ្ឌទាំងឡាយនៃអនុក្រឹត្យនេះ។

ការលើកទឹកចិត្តវិនិយោគ: សំដៅដល់ ការលើកទឹកចិត្តដែលមានកំណត់នៅក្នុងជំពូកទី៥ នៃច្បាប់ស្តីពីវិនិយោគហើយដែលមានចែងក្នុងអនុក្រឹត្យនេះ សម្រាប់ផ្តល់ជូនអ្នកវិនិយោគណា ដែលបំពេញតាមលក្ខខណ្ឌទាំងឡាយ នៃអនុក្រឹត្យនេះ។

គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ : សំដៅដល់ គម្រោងវិនិយោគដែលទទួលបានវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ។

គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មានទិសដៅបម្រើតម្រូវការក្នុងស្រុក: សំដៅដល់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលមិនបម្រើឱ្យការនាំចេញ។

គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បម្រើឱ្យការនាំចេញ: សំដៅដល់ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលបានលក់ ឬបានផ្ទេរសមាមាត្រណាមួយនៃផលិតផលរបស់ខ្លួន ទៅឱ្យអ្នកទិញ ឬអ្នកទទួលនៅក្រៅព្រះរាជាណាចក្រកម្ពុជា ។

គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលជាប្រភេទឧស្សាហកម្មគាំទ្រ: សំដៅដល់ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលផលិតផលរបស់ខ្លួន ១០០ (មួយរយ) ភាគរយ ត្រូវផ្គត់ផ្គង់ដល់ឧស្សាហកម្មនាំចេញ ជំនួសវត្ថុធាតុដើម ឬ សម្ភារៈបន្ទាប់បន្សំដែលតែងតែនាំចូល។

ច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ: សំដៅដល់ ច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ។

ច្បាប់ស្តីពីវិនិយោគ: សំដៅដល់ ច្បាប់ស្តីពីវិនិយោគដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ ០៣/នស៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ និង ដែលបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៣។

ច្បាប់ស្តីពីសារពើពន្ធ: សំដៅដល់ ច្បាប់ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ និង ដែលបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសារពើពន្ធ ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣។

ថ្ងៃធ្វើការ: សំដៅដល់ ថ្ងៃប្រតិទិន ដែលជាថ្ងៃធ្វើការជាផ្លូវការរបស់រាជរដ្ឋាភិបាលកម្ពុជា ។

ទុនវិនិយោគ: សំដៅដល់ តម្លៃវិនិយោគដែលបង្ហាញជា រូបិយប័ណ្ណ ដុល្លារអាមេរិក ដោយមិនរាប់បញ្ចូល ថ្លៃដីធ្លី និង ទុនបង្វិលទេ។

ធាតុចូលផលិតកម្ម: សំដៅដល់ ទំនិញ រួមបញ្ចូលទាំងវត្ថុធាតុដើម ផលិតផលពាក់កណ្ដាលសម្រេច និង សម្ភារៈបន្ទាប់បន្សំបម្រើផលិតកម្មដែលត្រូវបានបំប្លែង ឬ ត្រូវបានប្រើប្រាស់យ៉ាងពេញលេញនៅក្នុងកិច្ចដំណើរការផលិតកម្មរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មិនអោយហួសពីរយៈពេល ២(ពីរ) ឆ្នាំ បន្ទាប់ពីបាននាំចូល ។

និយមន័យនេះ មិនគិតបញ្ចូលផងទេ នូវសម្ភារៈ និង គ្រឿងសង្ហារឹមសម្រាប់ប្រើប្រាស់ក្នុងការិយាល័យ ផលិតផលគេលសិលា យានយន្ត និង គ្រឿងបន្លាស់យានយន្ត ។

ធាតុចេញផលិតកម្ម: សំដៅដល់ ទំនិញ ដែលបានផលិតចេញពីធាតុចូលផលិតកម្ម ដែលត្រូវបានបំប្លែង ។

នីតិបុគ្គលសញ្ជាតិខ្មែរ: សំដៅដល់ ក្រុមហ៊ុនដែលមានទីកន្លែងធ្វើអាជីវកម្ម និង ដែលបានធ្វើការចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងភាគហ៊ុន ៥១ (ហាសិបមួយ) ភាគរយ ឬ លើសក្នុងក្រុមហ៊ុន ត្រូវបានកាន់កាប់ដោយបុគ្គលមានសញ្ជាតិជាខ្មែរ ។

នីតិបុគ្គលសញ្ជាតិបរទេស: សំដៅដល់ នីតិបុគ្គលដែលមិនមែនសញ្ជាតិខ្មែរ ឬ ដែលមិនបានបង្កើតឡើងតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

បុគ្គល: សំដៅដល់ រូបវន្តបុគ្គល ឬនីតិបុគ្គល ។

បញ្ជីអវិជ្ជមាន: សំដៅដល់ បញ្ជីគម្រោងវិនិយោគ ដែលកំណត់នៅក្នុងឧបសម្ព័ន្ធទី ១ នៃអនុក្រឹត្យនេះ និង ដែលតាមមាត្រា ៧ ថ្មី នៃច្បាប់ស្ដីពីវិនិយោគ ជាបញ្ជីនៃសកម្មភាពវិនិយោគ ដែលមិនអាចចាត់ទុកថាជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។

បំណែកនៃម៉ាស៊ីន: សំដៅដល់ បំណែកនៃសម្ភារៈបរិក្ខារផលិតកម្ម ដែលមានរយៈពេលប្រើប្រាស់តិចជាង ២ (ពីរ) ឆ្នាំ ដោយរួមបញ្ចូលទាំងគ្រឿងបន្លាស់នៃបំណែកសម្ភារៈទាំងនោះផង ។

ពន្ធគយ: សំដៅដល់ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស ដែលបានដាក់ឱ្យប្រើប្រាស់នៅក្នុងតារាងពន្ធគយ ចំពោះទំនិញដែលត្រូវបង់នាពេលនាំចូលដែនគយ ឬ នាំចេញពីដែនគយ ។

វិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ: សំដៅដល់ ឯកសារដែលចេញដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ដូចមានចែងក្នុងកថាខណ្ឌ ៣ មាត្រា ៧ថ្មី នៃច្បាប់ស្ដីពីវិនិយោគ និងមាត្រា ៦ ចំណុច ៦.៣ នៃអនុក្រឹត្យនេះ ។

វិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ: សំដៅដល់ ឯកសារដែលចេញដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ដូចមានចែងក្នុងកថាខណ្ឌ ៧ មាត្រា៧ថ្មី នៃច្បាប់ស្ដីពីវិនិយោគ និងមាត្រា ៧ ចំណុច ៧.៣ នៃអនុក្រឹត្យនេះ ។

វិញ្ញាបនប័ត្របញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋ: សំដៅដល់ វិញ្ញាបនប័ត្របញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចដែលតម្រូវឱ្យបំពេញតាមមាត្រា ១៤ ថ្មី ចំណុច ២ ឬ មាត្រា ២៤ ថ្មី នៃច្បាប់ស្ដីពីវិនិយោគ ហើយចេញជូន តាមមាត្រា ១៨ ចំណុច ១៨.២ នៃអនុក្រឹត្យនេះ ។

សំណើវិនិយោគ: សំដៅដល់ សំណើដែលបានដាក់ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ដោយបុគ្គលណាមួយ ក្នុងគោលបំណង បង្កើតគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។

សម្ភារៈសាងសង់: សំដៅដល់ សម្ភារៈសំណង់ រួមទាំងឧបករណ៍ បរិក្ខារ បំពាក់ឱ្យសំណង់ ដែលបានបំប្លែង ឬ បានប្រើប្រាស់ទាំងស្រុង នៅក្នុងការសាងសង់សំណង់នានា សម្រាប់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ប្រើប្រាស់ ដើម្បីដំណើរការសកម្មភាពវិនិយោគរបស់ខ្លួន នៅក្នុងដំណាក់កាលសាងសង់ដំបូង ឬ ពង្រីក។

សកម្មភាពវិនិយោគ: សំដៅដល់ សកម្មភាពអាជីវកម្មដែលដំណើរការនៅក្នុងប្រទេសកម្ពុជា ក្រោមរូបភាពជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

សម្ភារៈបរិក្ខារផលិតកម្ម: សំដៅដល់ គ្រឿងម៉ាស៊ីន ឧបករណ៍ ដែលបានប្រើប្រាស់ជាមូលដ្ឋានសំខាន់ក្នុងការបំប្លែងធាតុចូលផលិតកម្ម ហើយដែលវត្ថុទាំងនោះ មិនអាចបំប្លែងដោយខ្លួនឯង ឬ មិនត្រូវបានប្រើប្រាស់អស់ក្នុងរយៈពេល ២ (ពីរ)ឆ្នាំបន្ទាប់ពីបាននាំចូល ។ គ្រឿងម៉ាស៊ីន និង ឧបករណ៍ទាំងនោះ មិនត្រូវគិតបញ្ចូលផងទេនូវឧបករណ៍ផ្នែកព័ត៌មានវិទ្យា ឬ យានយន្ត ដែលប្រើប្រាស់សម្រាប់គោលបំណងផ្សេង ក្រៅពីកិច្ចដំណើរការផលិតកម្មរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

សេវាកម្មវិជ្ជាជីវៈ: សំដៅដល់ សេវាទាំងឡាយ ដែលមានជាអាទិ៍ សេវាកម្មច្បាប់ ហិរញ្ញវត្ថុ គណនេយ្យ សវនកម្ម ទីប្រឹក្សាសារពើពន្ធ ស្ថាបត្យកម្ម វិស្វកម្ម សេវាកម្មបច្ចេកវិទ្យាព័ត៌មាន ផ្សព្វផ្សាយពាណិជ្ជកម្ម សេវាកម្មគ្រប់គ្រង។

អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង: សំដៅដល់ អនុគណៈកម្មាធិការវិនិយោគរបស់ខេត្ត ក្រុង ដែលបានបង្កើតឡើងដោយអនុក្រឹត្យ ដើម្បីពិនិត្យសម្រេចចុះបញ្ជីវិនិយោគតាមខេត្ត ក្រុង ដែលមានទុនវិនិយោគចាប់ពី ២.០០០.០០០ (ពីរលាន) ដុល្លារអាមេរិក ចុះក្រោម។

អ្នកដាក់ពាក្យសុំ: សំដៅដល់ បុគ្គល ឬ ក្រុមបុគ្គលដែលដាក់សំណើវិនិយោគនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង។

អ្នកវិនិយោគ: សំដៅដល់ បុគ្គលដែលអនុវត្តគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។

អ្នកវិនិយោគសញ្ជាតិខ្មែរ: សំដៅដល់ អ្នកវិនិយោគសញ្ជាតិខ្មែរ ឬ នីតិបុគ្គលសញ្ជាតិខ្មែរ។

អនុក្រឹត្យរបស់ក្រុមប្រឹក្សា: សំដៅដល់ អនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និង អនុក្រឹត្យវិសោធនកម្ម លេខ ១១២ អនក្រ.បក ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០២ និង លេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១។

## ជំពូកទី ២

## សំណើវិនិយោគ និង វិញ្ញាបនបត្រចុះបញ្ជីវិនិយោគ

### មាត្រា ៥: ការស្នើសុំវិញ្ញាបនបត្រចុះបញ្ជីមានលក្ខខណ្ឌ

៥.១ ពាក្យសុំ និង ថ្ងៃចុះបញ្ជី: បុគ្គលណាមួយដែលមានបំណងស្នើសុំការលើកទឹកចិត្ត និង ការធានាលើការវិនិយោគ ឬ តែការធានាលើការវិនិយោគ ត្រូវដាក់ជូនក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង

នូវសំណើវិនិយោគ តាមទម្រង់បែបបទនៃការដាក់ពាក្យសុំ ដែលបានបំពេញសព្វគ្រប់ ហើយចុះហត្ថលេខាត្រឹមត្រូវដោយម្ចាស់គម្រោងដែលមានសិទ្ធិ ឬអ្នកតំណាងឱ្យអ្នកដាក់ពាក្យសុំដែលមានការប្រគល់សិទ្ធិត្រឹមត្រូវ និងត្រូវបង់ថ្លៃចុះបញ្ជី ចំនួន ៧.០០០.០០០ (ប្រាំពីរលាន) រៀល នៅក្រុមប្រឹក្សា ឬនៅអនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ដែលជាថ្លៃសេវារដ្ឋបាលដើម្បីទទួលបាននូវ រាល់ការយល់ព្រម ការអនុញ្ញាត អាជ្ញាប័ណ្ណ ឬ បញ្ជីការនានាពីគ្រប់ក្រសួង ស្ថាប័ន មន្ទីរមានសមត្ថកិច្ចពាក់ព័ន្ធទាំងអស់រួមទាំងពន្ធប្រថាប់ត្រាផងដែរ ។

៥.២ ទម្រង់បែបបទនៃពាក្យសុំ: ទម្រង់បែបបទសម្រាប់សំណើវិនិយោគ មានកំណត់នៅក្នុងឧបសម្ព័ន្ធទី ២ នៃអនុក្រឹត្យនេះ ។

៥.៣ ភស្តុតាងស្តីពីសិទ្ធិអំណាចក្នុងការចុះហត្ថលេខា: ប្រសិនបើសំណើវិនិយោគនោះ ចុះហត្ថលេខាដោយតំណាងរបស់អ្នកដាក់ពាក្យសុំ ឯកសារភស្តុតាងស្តីពីការទទួលសិទ្ធិអោយចុះហត្ថលេខានេះ ត្រូវដាក់ជូនទៅក្រុមប្រឹក្សា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ដោយភ្ជាប់ជាមួយនឹងសំណើវិនិយោគ ។

៥.៤ គម្រោងពហុសកម្មភាព: ប្រសិនបើបុគ្គលមានបំណងធ្វើការវិនិយោគ និង ដំណើរការលើសពីសកម្មភាពវិនិយោគមួយឡើងទៅ ហើយប្រសិនបើគម្រោងត្រូវបានចុះបញ្ជី ដើម្បីដំណើរការជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ បុគ្គលនោះត្រូវដាក់សំណើវិនិយោគដាច់ដោយឡែកពីគ្នាសម្រាប់សកម្មភាពវិនិយោគនីមួយៗ ។

៥.៥ ការជ្រើសរើសការលើកលែងពន្ធលើប្រាក់ចំណេញ: អ្នកដាក់ពាក្យសុំ ដែលចង់ទទួលបានការលើកលែងពន្ធលើប្រាក់ចំណេញតាមមាត្រា ១៤ ចំណុច ១៤.១ នៃច្បាប់ស្តីពីវិនិយោគ ដោយអនុលោមទៅតាមមាត្រា ១៥ នៃអនុក្រឹត្យនេះនៅពេលទទួលវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ ត្រូវធ្វើការជ្រើសរើសជាលាយលក្ខណ៍អក្សរនូវការលើកទឹកចិត្តដែលខ្លួនចង់បាននៅក្នុងសំណើវិនិយោគ ។

៥.៦ ការជ្រើសរើសដោយបដិសេធនូវរំលោះពិសេសផ្នែកសារពើពន្ធផ្សេងៗ : ក្នុងការជ្រើសរើសតាមកថាខ័ណ្ឌ ៥.៥ អ្នកដាក់ពាក្យសុំទទួលស្គាល់ថា. ការជ្រើសរើសដើម្បីប្រើប្រាស់រយៈពេលលើកលែងពន្ធលើប្រាក់ចំណេញ ដែលមានចែងនៅក្នុងមាត្រា ១៤ ចំណុច ១៤.១ នៃច្បាប់ស្តីពីវិនិយោគ នឹងធ្វើឱ្យអ្នកវិនិយោគគ្មានសិទ្ធិក្នុងការទាមទាររំលោះពិសេសផ្នែកវិនិយោគ ដែលអនុវត្តសម្រាប់អ្នកវិនិយោគតាមច្បាប់ស្តីពីសារពើពន្ធទាក់ទងទៅនឹងគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នោះឡើយ ។

៥.៧ ការជ្រើសរើសយកតែការធានាលើការវិនិយោគ: អ្នកដាក់ពាក្យសុំ ដែលមានបំណងចង់ទទួលបាននូវផលប្រយោជន៍តែការធានាលើការវិនិយោគ អាចធ្វើការជ្រើសរើសជាលាយលក្ខណ៍អក្សរនៅក្នុងទម្រង់បែបបទនៃពាក្យស្នើសុំ ដោយអ្នកដាក់ពាក្យសុំនោះមិនមែនជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទេ តែស្ថិតនៅក្រោមការធានាលើការវិនិយោគនៃច្បាប់ស្តីពីវិនិយោគ ។ ក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ត្រូវចេញនូវអាជ្ញាប័ណ្ណមួយដោយឡែក ដើម្បីបញ្ជាក់ជូនអ្នកដាក់ពាក្យសុំសម្រាប់ករណីនេះ ។

## មាត្រា ៦: ការចុះបញ្ជី ឬ ការបដិសេធពាក្យសុំ

៦.១ កិច្ចដំណើរការចុះបញ្ជីពាក្យសុំ: ក្នុងរយៈពេល ៣ (បី) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបាននូវសំណើវិនិយោគ

តាមមាត្រា ៥ ចំណុច ៥.១ ក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគ ខេត្ត ក្រុងត្រូវ ÷

(ក) ចុះបញ្ជីសំណើវិនិយោគ និង ជូនដំណឹងទៅអ្នកដាក់ពាក្យសុំ អនុលោមទៅតាមកថាខ័ណ្ឌ ៦.៣ ប្រសិនបើមិនស្ថិតក្នុងកថាខ័ណ្ឌ (ខ) ឬ (គ)ទេ ឬ

(ខ) បដិសេធសំណើវិនិយោគនោះ ហើយជូនដំណឹងទៅអ្នកដាក់ពាក្យសុំវិញ អនុលោមទៅតាមកថាខ័ណ្ឌ ៦.៦ ប្រសិនបើសំណើវិនិយោគ ដែលលើកឡើងនោះ ពាក់ព័ន្ធទៅនឹងសកម្មភាពវិនិយោគ

(១) ដែលមាននៅក្នុងបញ្ជីអវិជ្ជមាន ឬ

(២) ដែលពីមុនបាន ឬ បច្ចុប្បន្នកំពុងដំណើរការដោយអ្នកវិនិយោគ ឬបុគ្គលផ្សេង ហើយដែលបានទទួលរួចហើយនូវការលើកទឹកចិត្តតាមច្បាប់ស្តីពីវិនិយោគ

(គ) បដិសេធសំណើវិនិយោគ ហើយជូនដំណឹងទៅអ្នកដាក់ពាក្យសុំវិញ ដោយអនុលោមទៅតាមកថាខ័ណ្ឌ ៦.៦ ប្រសិនបើសំណើវិនិយោគ មិនបានផ្តល់ជូននូវព័ត៌មានគ្រប់គ្រាន់ ដែលតម្រូវដោយកថាខ័ណ្ឌ ៥.១ ទេនោះ ។

(ឃ) ក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង មានសិទ្ធិក្នុងការពន្យាពេលចុះបញ្ជីសំណើវិនិយោគទាំងឡាយដែលមានលក្ខណៈពិសេស ពាក់ព័ន្ធដល់ផលប្រយោជន៍ជាតិ និងផលប៉ះពាល់ដល់បរិស្ថាន ដែលតម្រូវដាក់គម្រោងឆ្លងយន្តការច្រកចេញចូលតែមួយនៃក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ដោយត្រូវផ្តល់នូវហេតុផលច្បាស់លាស់ដល់អ្នកដាក់ពាក្យសុំឱ្យបានដឹង ក្នុងរយៈពេល ០៣ (បី) ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយថ្ងៃទទួលបានសំណើវិនិយោគ។

៦.២ ការកែតម្រូវសំណើវិនិយោគៈ ប្រសិនបើសំណើវិនិយោគដែលបានដាក់ជូនក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង មិនស្របទៅតាមមាត្រា៥នៃអនុក្រឹត្យនេះទេ ក្នុងរយៈពេល ០៣ (បី) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃទទួលសំណើនោះ ក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកដាក់ពាក្យសុំ ដោយស្នើសុំឱ្យកែតម្រូវសំណើវិនិយោគ ហើយដាក់សំណើនោះជាថ្មីជូនក្រុមប្រឹក្សា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ។

៦.៣ ការចេញវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ : ប្រសិនបើក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង យល់ព្រមចុះបញ្ជីសំណើវិនិយោគតាមកថាខ័ណ្ឌ ៦.១ (ក) ក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ត្រូវចេញវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ តាមគំរូដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធទី ៣ នៅក្នុងរយៈពេល ០៣ (បី) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលសំណើវិនិយោគ ហើយវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌនោះ ត្រូវធ្វើការបញ្ជាក់លើចំណុចដូចខាងក្រោម ÷

(ក) បញ្ជីស្តីពីរាល់ការយល់ព្រម ការអនុញ្ញាត អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬ បញ្ជីការសំខាន់នានាដែលជាតម្រូវការស្របច្បាប់សម្រាប់ដំណើរការរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ រួមទាំងការបញ្ជាក់ពីក្រសួង នាយកដ្ឋាន អាជ្ញាធរ មន្ទីរនានាចំណុះខេត្ត ក្រុង ឬភ្នាក់ងាររបស់រាជរដ្ឋាភិបាលដែលទទួលបន្ទុកការងារទាំងនេះ នៅពេលដែលអ្នកដាក់ពាក្យសុំមានលក្ខណៈវិនិច្ឆ័យសមស្របនឹងទទួលបានលិខិតទាំងនោះ។

(ខ) ការជ្រើសរើសដោយអ្នកដាក់ពាក្យសុំ អនុលោមតាមកថាខ័ណ្ឌ ៥.៥ ឬ ៥.៦ ឬ ៥.៧ ។

(គ) ការលើកទឹកចិត្តវិនិយោគ និង ការធានាលើការវិនិយោគ ដែលគម្រោងវិនិយោគមានសិទ្ធិទទួលបាន ប្រសិនបើវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរនឹងត្រូវចេញជូន ដោយរាប់បញ្ចូលទាំងរយៈពេលលើកលែងពន្ធលើប្រាក់ចំណេញ តាមមាត្រា ១៤ ចំណុច ១៤.១ នៃច្បាប់ស្តីពីវិនិយោគ ។

(ឃ) ការជ្រើសរើសដោយអ្នកដាក់ពាក្យសុំតាមមាត្រា ៥ ចំណុច ៥.៧ នៃអនុក្រឹត្យនេះ ប្រសិនបើមាន និង ផលបច្ច័យនៃភាពគ្មានសិទ្ធិ លើការទទួលបាននូវការលើកទឹកចិត្តវិនិយោគ ។

(ង) ការទទួលស្គាល់លើលក្ខន្តិកៈនៃនីតិបុគ្គល ដែលជាអ្នកអនុវត្តគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។

៦.៤ ការខកខានមិនបានចេញវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌៈ ប្រសិនបើក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ខកខានពុំបានចេញវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ តាមកថាខ័ណ្ឌ ៦.៣ ឬ ខកខានមិនបានចេញលិខិតបដិសេធ អនុលោមតាម កថាខ័ណ្ឌ ៦.៦ ក្នុងរយៈ ពេល ០៣ (បី) ថ្ងៃ នៃថ្ងៃធ្វើការទេ សំណើវិនិយោគត្រូវបានចាត់ទុកថាបានចុះបញ្ជី ហើយក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ត្រូវចេញវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ ជូនអ្នកដាក់ពាក្យសុំជាបន្ទាន់ ។

៦.៥ ព័ត៌មានដែលអមជាមួយវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌៈ ក្នុងវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ ក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ត្រូវចេញផងដែរនូវគោលការណ៍ណែនាំវិនិយោគ និង លក្ខណៈវិនិច្ឆ័យសម្រាប់វាយតម្លៃលើការទទួលបាននូវ ការយល់ព្រម ការអនុញ្ញាត អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬ បញ្ជីការ ដូចមានយោងនៅក្នុងកថាខ័ណ្ឌ ៦.៣ (ក) ។

៦.៦ លិខិតបដិសេធៈ ប្រសិនបើក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង បដិសេធចំពោះសំណើវិនិយោគណាមួយតាមកថាខ័ណ្ឌ ៦.១ (ខ) ក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ត្រូវចេញលិខិតបដិសេធជូនទៅអ្នកដាក់ពាក្យសុំ ដោយលិខិតនោះត្រូវបញ្ជាក់ ÷

(ក) មូលហេតុស្តីពីការមិនអាចទទួលសំណើវិនិយោគនោះបាន ។

(ខ) ព័ត៌មានបន្ថែម ដើម្បីផ្តល់លទ្ធភាពឱ្យក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង អាចចុះបញ្ជីសំណើវិនិយោគ ដែលបានកែតម្រូវនោះ ។

## មាត្រា ៧: ការចេញជូនអ្នកវិនិយោគនូវវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ

៧.១ ក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ត្រូវជួយសុំការយល់ព្រម ការអនុញ្ញាតផ្សេងៗ នៅពេលដែលក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ចេញវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ ដោយអនុលោមទៅតាមកថាខ័ណ្ឌ ៦.៣ រួចហើយ ក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ត្រូវទទួលយកជំនួសមុខឱ្យ អ្នកដាក់ពាក្យសុំ នូវការយល់ព្រម ការអនុញ្ញាត អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬ បញ្ជីការនានា ដែលមានចែងនៅក្នុងកថាខ័ណ្ឌ ៦.៣ (ក) ពីក្រសួង នាយកដ្ឋាន អាជ្ញាធរ មន្ទីរនានា ចំណុះខេត្ត ក្រុង ឬ ភ្នាក់ងារ ដែលមានការពាក់ព័ន្ធផ្សេងៗ របស់រាជរដ្ឋាភិបាល ។

៧.២ ការបង់ប្រាក់កក់: អ្នកវិនិយោគ មិនត្រូវបានកំណត់ឱ្យបង់ប្រាក់កក់សម្រាប់ធានាការវិនិយោគឡើយ លើកលែងតែករណីសម្បទានលើវិស័យហេដ្ឋារចនាសម្ព័ន្ធ ដែលកិច្ចសន្យាសម្បទាននោះបានតម្រូវឱ្យបង់។

៧.៣ ការចេញវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ: ប្រសិនបើអ្នកមានវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ ទទួលបាននូវរាល់ការយល់ព្រម ការអនុញ្ញាត អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬ បញ្ជីការនានា ដែលមានចែងក្នុងកថាខ័ណ្ឌ ៦.៣ (ក) រួចហើយនោះ ក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគ ខេត្ត ក្រុង ត្រូវចេញវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ។

៧.៤ រយៈពេលចេញវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ: ប្រសិនបើអ្នកមានវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ មិនបានទទួលនូវរាល់ ការយល់ព្រម ការអនុញ្ញាត អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬ បញ្ជីការនានា ដែលមានចែងនៅក្នុងកថាខ័ណ្ឌ ៦.៣ (ក) នៅក្នុងរយៈពេល ២៨ (ម្ភៃប្រាំបី ) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីចេញវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌមកទេនោះ ក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ត្រូវចេញវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ ។

៧.៥ ការសុំការយល់ព្រមនានាពីស្ថាប័នពាក់ព័ន្ធ: ការចេញវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរដោយក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង អនុលោមទៅតាមកថាខ័ណ្ឌ ៧.៤ មិនមែនជាការលើកលែងឱ្យអ្នកដាក់ពាក្យសុំរួចផុតពីកាតព្វកិច្ច ដែលត្រូវទទួលបាននូវរាល់ ការយល់ព្រម ការអនុញ្ញាត អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬបញ្ជីការនានា ដើម្បីគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដំណើរការដោយស្របច្បាប់នោះទេ ។

៧.៦ ការចាប់ផ្តើមគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់: គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ចាប់ផ្តើមនៅថ្ងៃចេញវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរសម្រាប់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នោះ ហើយចាប់ផ្តើមរយៈពេលគន្លឹះសម្រាប់ការគណនារយៈពេលលើកលែងពន្ធលើប្រាក់ចំណេញតាមមាត្រា ១៤ ចំណុច ១៤.១ នៃច្បាប់ស្តីពីវិនិយោគ និង កថាខ័ណ្ឌ ១៥.១ នៃអនុក្រឹត្យនេះតែម្តង។

៧.៧ កាតព្វកិច្ចស្នើសុំការយល់ព្រមផ្សេងៗ: គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវដាក់ពាក្យស្នើសុំការសម្រេចជាលាយលក្ខណ៍អក្សរជូន ក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង តាមនីតិវិធីដើម្បីទទួលបាននូវការយល់ព្រម លើរាល់ការប្តូរ អាស័យដ្ឋាន ទីស្នាក់ការ ការប្តូរទីតាំងអាជីវកម្ម ការប្តូរនាមករណ៍ ការប្តូរភាគហ៊ុន ឬការផ្លាស់ប្តូរលម្អិតផ្សេងៗទៀត ដែលមាននៅក្នុងសំណើវិនិយោគ និងនៅក្នុងលក្ខន្តិកៈរបស់អ្នកវិនិយោគ ក្នុងរយៈពេលមុនធ្វើការប្តូរ ១០(ដប់) ថ្ងៃ នៃថ្ងៃធ្វើការ ដើម្បីក្រុមប្រឹក្សា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង សម្រេចជូនយ៉ាងយូរក្នុងរយៈពេល ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ។

## មាត្រា ៨: ការដកហូត ឬ លុបចោលវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ

៨.១ ការដកហូតវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ: វិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរត្រូវបានដកហូតវិញ ចាប់ពីថ្ងៃចេញផ្តល់ជូនដោយក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ប្រសិនបើអ្នកវិនិយោគ ÷

(ក) ទទួលបាននូវវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ ឬ វិញ្ញាបនប័ត្របញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋ តាមរយៈឯកសារក្លែងបន្លំ ឬ មិនត្រឹមត្រូវ ឬ

(ខ) មិនបានចាប់ផ្តើមធ្វើសកម្មភាពក្នុងរយៈពេល ០៦ (ប្រាំមួយ) ខែ ក្រោយពេលទទួលបាននូវឯកសារទាំងអស់ដោយយោងទៅ តាមកថាខ័ណ្ឌ ៧.៣ លើកលែងករណីកិច្ចសន្យាសម្បទាន ដែលរយៈពេលនឹងកំណត់ជាក់ស្តែង តាមការព្រមព្រៀងគ្នាក្នុងកិច្ចសន្យា ។

៨.២ ការលុបចោលវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរៈ ប្រសិនបើអ្នកវិនិយោគស្នើសុំអោយក្រុមប្រឹក្សា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង លុបចោលវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ អនុលោមតាមមាត្រា ២១ថ្មី នៃច្បាប់ស្តីពីវិនិយោគ ក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ត្រូវលុបចោលវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរនោះតែនៅពេលដែលអ្នកវិនិយោគបានអនុវត្ត ស្របទៅតាមមាត្រា ២២ថ្មី និងមាត្រា ២៣ថ្មី នៃច្បាប់ស្តីពីវិនិយោគប៉ុណ្ណោះ ។

៨.៣ ការជូនដំណឹងអំពីការដកហូតវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរៈ ប្រសិនបើក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ដកហូតវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ ដោយអនុលោមទៅតាមមាត្រានេះ ក្រុមប្រឹក្សា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ស្តីពីការដកហូតនោះ ជូនទៅអ្នកវិនិយោគ។

៨.៤ ការតវ៉ាៈ អ្នកវិនិយោគដែលវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពររបស់ខ្លួន ត្រូវបានដកហូតដោយក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង តាមមាត្រានេះ អាចតវ៉ាជាលាយលក្ខណ៍អក្សរទៅសហប្រធានក្រុមប្រឹក្សាក្នុងរយៈពេល ២០ (ម្ភៃ) ថ្ងៃ នៃថ្ងៃធ្វើការ ចាប់ពីថ្ងៃទទួលបានការជូនដំណឹងជាលាយលក្ខណ៍អក្សរពីក្រុមប្រឹក្សា ឬ ពីអនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុងតាមកថាខ័ណ្ឌ ៨.៣ ។

៨.៥ ការបាត់បង់ការលើកទឹកចិត្តវិនិយោគ ៈ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពររបស់ខ្លួន ត្រូវបានដកហូត ឬលុបចោល មិនមានសិទ្ធិទាមទារការលើកទឹកចិត្តវិនិយោគណាមួយ ដែលមានចែងនៅក្នុងវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរទេ គិតចាប់ពីកាលបរិច្ឆេទដកហូត ឬលុបចោលនោះមក ។

## ជំពូកទី ៣

## ការទិញ និង ការរំលាយបញ្ចូលគ្នានៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់

### មាត្រា ៩ៈ ការរំលាយបញ្ចូលគ្នានៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់

៩.១ ប្រសិនបើ អ្នកវិនិយោគ ពីរ ឬ ច្រើន ឬអ្នកវិនិយោគ និង ជនណាមួយ ព្រមព្រៀងរំលាយបញ្ចូលគ្នា បង្កើតជានីតិបុគ្គលថ្មី ហើយនីតិបុគ្គលថ្មីនោះមានបំណងអនុវត្តគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់របស់អ្នកវិនិយោគ និងមានសិទ្ធិទទួលបាននូវការលើកទឹកចិត្ត និងការធានាលើការវិនិយោគដែលមានចែងនៅក្នុងវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរនៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ នីតិបុគ្គលថ្មីនោះ ត្រូវស្នើសុំការ

សម្រេចជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង តាមនីតិវិធី ដើម្បីចុះបញ្ជីជាអ្នកវិនិយោគ និង ស្នើសុំផ្ទេរវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរនៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មកអោយនីតិបុគ្គលថ្មីក្នុងរយៈពេល ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ មុនធ្វើការរំលាយបញ្ចូលគ្នា និងមុនការផ្ទេរវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ ។

៩.២ ក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ត្រូវពិនិត្យពាក្យស្នើសុំដែលមានចែងនៅក្នុងកថាខណ្ឌ ៩.១ មាត្រា ៩ នៃអនុក្រឹត្យនេះ ហើយត្រូវផ្តល់ទៅនីតិបុគ្គលថ្មីជាលាយលក្ខណ៍អក្សរនូវការយល់ព្រម ឬមិនយល់ព្រមនៃការចុះបញ្ជី និងការផ្ទេរវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ ក្នុងរយៈពេល ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃទទួលបានពាក្យស្នើសុំនោះ ។

**មាត្រា ១០: ការទិញយកគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដោយបុគ្គលដែលមិនបានចុះបញ្ជី**

១០.១ ប្រសិនបើបុគ្គលដែលមិនបានចុះបញ្ជី ទិញយកគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ហើយចង់ដំណើរការអនុវត្តគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នៃអ្នកវិនិយោគ និង ទទួលបាននូវសិទ្ធិលើការលើកទឹកចិត្ត និង ការធានាលើការវិនិយោគ ដែលមានបញ្ជាក់នៅក្នុងវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ បុគ្គលដែលទិញត្រូវស្នើសុំការសម្រេចជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង តាមនីតិវិធីដើម្បីចុះបញ្ជីជាអ្នកវិនិយោគ និងស្នើសុំផ្ទេរវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរនៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មកឱ្យនីតិបុគ្គលថ្មី ក្នុងរយៈពេល ១០ (ដប់ ) ថ្ងៃ នៃថ្ងៃធ្វើការ មុនការផ្ទេរវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ ។

១០.២ ក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ត្រូវពិនិត្យពាក្យស្នើសុំ ដែលមានចែងនៅក្នុងកថាខណ្ឌ ១០.១ មាត្រា ១០ នៃអនុក្រឹត្យនេះ ហើយត្រូវផ្តល់ជូនទៅនីតិបុគ្គលអ្នកទិញជាលាយលក្ខណ៍អក្សរនូវការយល់ព្រម ឬមិនយល់ព្រមនៃការចុះបញ្ជី និងការផ្ទេរវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ ក្នុងរយៈពេល ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃទទួលបានពាក្យស្នើសុំនោះ ។

១០.៣ ប្រសិនបើការផ្ទេរភាគហ៊ុនរបស់អ្នកវិនិយោគបណ្តាលអោយការ "គ្រប់គ្រង" ត្រូវបានទទួលដោយអ្នកត្រូវទទួលការផ្ទេរ អ្នកវិនិយោគត្រូវស្នើសុំទៅក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង តាមនីតិវិធីនូវការផ្ទេរឈ្មោះ និងអាស័យដ្ឋាននៃអ្នកត្រូវទទួលការផ្ទេរ ក្នុងរយៈពេល ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ មុនធ្វើការផ្ទេរភាគហ៊ុននោះ ដើម្បីក្រុមប្រឹក្សា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង សម្រេចជូនយ៉ាងយូរក្នុងរយៈពេល ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ ។

១០.៤ ចំពោះកថាខណ្ឌ ១០.៣ មាត្រា ១០ នៃអនុក្រឹត្យនេះ ពាក្យថា "គ្រប់គ្រង" សំដៅដល់ អ្នកកាន់កាប់ភាគហ៊ុនយ៉ាងតិច ២០ (ម្ភៃ) ភាគរយ នៃភាគហ៊ុនរបស់អ្នកវិនិយោគ ។

### មាត្រា ១១: ការទិញយកគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដោយអ្នកវិនិយោគផ្សេងទៀត

១១.១ ប្រសិនបើអ្នកវិនិយោគដែលបានចុះបញ្ជីមួយមានបំណង ទិញយកភាពជាម្ចាស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ របស់អ្នកវិនិយោគផ្សេងទៀត ហើយចង់ទទួលបាននូវការលើកទឹកចិត្តវិនិយោគ និងការធានាលើការវិនិយោគនៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលដំណើរការដោយអ្នកវិនិយោគនោះ អ្នកវិនិយោគដែលជាអ្នកទិញ ត្រូវស្នើសុំការសម្រេចជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង តាមនីតិវិធី នូវការទិញយក ក្នុងរយៈពេល ១០ (ដប់ ) ថ្ងៃ នៃថ្ងៃធ្វើការ មុនការទិញយកនោះ ដើម្បីទទួលបាននូវសិទ្ធិទាំងនោះ។

១១.២ ក្រុមប្រឹក្សា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ត្រូវពិនិត្យពាក្យស្នើសុំដែលមានចែងនៅក្នុងកថាខ័ណ្ឌ ១១.១ មាត្រា ១១ នៃអនុក្រឹត្យនេះ ហើយត្រូវផ្តល់ជូនទៅអ្នកវិនិយោគជាអ្នកទិញនោះ ជាលាយលក្ខណ៍អក្សរនូវការយល់ព្រម ឬមិនយល់ព្រមនៃការចុះបញ្ជី និងការផ្ទេរវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ ក្នុងរយៈពេល ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃទទួលបានពាក្យស្នើសុំនោះ។

### មាត្រា ១២: ការខកខានមិនបានចុះបញ្ជី ឬ សុំការសម្រេច

ប្រសិនបើ បុគ្គលថ្មី ឬអ្នកវិនិយោគដែលជាអ្នកទិញ ខកខានមិនបានស្នើសុំមកក្រុមប្រឹក្សា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង ដើម្បីចុះបញ្ជីវិនិយោគ អនុលោមទៅតាមមាត្រា ៩ ឬមាត្រា ១០ នៃអនុក្រឹត្យនេះ ឬអ្នកវិនិយោគដែលជាអ្នកទិញ ខកខានមិនបានសុំការសម្រេចទៅក្រុមប្រឹក្សា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត ក្រុង អនុលោមទៅតាមមាត្រា ១១ នៃអនុក្រឹត្យនេះ បុគ្គលថ្មី ឬអ្នកវិនិយោគដែលជាអ្នកទិញនោះ មិនមានសិទ្ធិទទួលបាននូវការលើកទឹកចិត្ត និងការធានាលើការវិនិយោគណាមួយរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ឡើយ ។

## ជំពូកទី ៤

## សម្ព័ន្ធអាជីវកម្ម

### មាត្រា ១៣: សម្ព័ន្ធអាជីវកម្ម

គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ អាចមានទ្រង់ទ្រាយជាសម្ព័ន្ធអាជីវកម្ម។ សម្ព័ន្ធអាជីវកម្មអាចបង្កើតឡើងរវាងនីតិបុគ្គលសញ្ជាតិខ្មែរនឹងនីតិបុគ្គលសញ្ជាតិខ្មែរ នីតិបុគ្គលសញ្ជាតិខ្មែរជាមួយនឹងនីតិបុគ្គលសញ្ជាតិបរទេស និង នីតិបុគ្គលសញ្ជាតិបរទេសជាមួយនឹងនីតិបុគ្គលសញ្ជាតិបរទេស រួមបញ្ចូលផងដែរជាសម្ព័ន្ធអាជីវកម្ម ជាមួយស្ថាប័ននានានៃរាជរដ្ឋាភិបាល។ មិនមានការដាក់កម្រិតកំណត់ដោយផ្អែកលើសញ្ជាតិ ឬសមាមាត្រនៃការដាក់ភាគហ៊ុនរបស់ ម្ចាស់ភាគហ៊ុននីមួយៗឡើយ លើកលែងតែសម្ព័ន្ធអាជីវកម្មនោះ ជាកម្មសិទ្ធិករ ឬ មានបំណងធ្វើជាកម្មសិទ្ធិករលើដីធ្លី ឬដើម្បីផលប្រយោជន៍លើដីធ្លីនៅក្នុងព្រះរាជាណាចក្រ

ចក្រកម្ពុជា។ ក្នុងករណីនេះ ការចូលរួមភាគហ៊ុន អតិបរមានៃបុគ្គលទាំងអស់ ដែលមិនមែនជានីតិបុគ្គលសញ្ជាតិខ្មែរនោះ មិនត្រូវអោយលើសពី ៤៩ (សែសិបប្រាំបួន) ភាគរយឡើយ ។

## ជំពូកទី ៥

## សារពើពន្ធ

### មាត្រា ១៤: គោលការណ៍ទូទៅ

១៤.១ ការទទួលខុសត្រូវចំពោះពន្ធអាករ: អ្នកវិនិយោគត្រូវមានកាតព្វកិច្ចចំពោះពន្ធ និង ត្រូវប្រតិបត្តិតាមបទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ ច្បាប់ស្តីពីសារពើពន្ធ ច្បាប់ស្តីពីវិនិយោគ និងបទប្បញ្ញត្តិពាក់ព័ន្ធ ។

១៤.២ ធនធានធម្មជាតិ: អត្រាពន្ធលើប្រាក់ចំណេញ អនុវត្តចំពោះប្រាក់ចំណេញដែលសម្រេចបានក្រោមកិច្ចសន្យាបែងចែកផលិតផលប្រេងកាត និងឧស្ម័នធម្មជាតិ ឬសម្រេចបានពីការធ្វើអាជីវកម្មលើធនធានធម្មជាតិ មានជាអាទិ៍ ព្រៃឈើ រ៉ែ មាស ឬត្បូងថ្មមានតម្លៃនានា ត្រូវកំណត់តាមកថាខ័ណ្ឌ ២ មាត្រា ២០ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ ។

១៤.៣ ការដាក់កម្រិត: ការលើកលែងទាំងស្រុង ឬ មួយផ្នែកនៃពន្ធអាករ និង ពន្ធគយ ត្រូវអនុវត្តចំពោះតែពន្ធលើប្រាក់ចំណេញ និងពន្ធគយ ដូចមានចែងនៅក្នុងអនុក្រឹត្យនេះតែប៉ុណ្ណោះ។ ការលើកលែងនេះ ពុំរាប់បញ្ចូលនូវពន្ធអាករដូចខាងក្រោមនេះទេ ÷

ក- ពន្ធលើប្រាក់បៀវត្ស ពន្ធកាត់ទុក ដូចបានកំណត់ក្នុងមាត្រា ២៥ និង ២៦ ថ្មីនៃច្បាប់ស្តីពីសារពើពន្ធ និង ពន្ធ លើប្រាក់ចំណេញបន្ថែមលើការបែងចែកភាគលាភ និង

ខ- អាករលើតម្លៃបន្ថែម អាករពិសេសលើទំនិញ និងសេវាមួយចំនួន អាករដែលត្រូវបង់នៅពេលនាំចូល និងពន្ធអាករដទៃទៀត ដូចមានចែងក្នុងច្បាប់មានសុពលភាពជាធរមាន ។

### មាត្រា ១៥: ពន្ធលើប្រាក់ចំណេញ

១៥.១ រយៈពេលលើកលែងពន្ធលើប្រាក់ចំណេញ : យោងតាមមាត្រា ១៤ ចំណុច ១៤.១ នៃច្បាប់ស្តីពីវិនិយោគ រយៈពេលលើកលែងពន្ធលើប្រាក់ចំណេញ ដែលរួមមាន រយៈពេលគន្លឹះ បូក រយៈពេល ០៣ (បី) ឆ្នាំ បូករយៈពេលអាទិភាព គឺត្រូវបានកំណត់ដូចមានចែងក្នុងមាត្រានេះ ។

១៥.២ រយៈពេលគន្លឹះ: សម្រាប់មាត្រា ១៤ ចំណុច ១៤.១ នៃច្បាប់ស្តីពីវិនិយោគ រយៈពេលគន្លឹះនៃរយៈពេលលើកលែងពន្ធលើប្រាក់ចំណេញ គឺជារយៈពេលចាប់ផ្តើមពីថ្ងៃចេញវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ និង បញ្ចប់នៅថ្ងៃចុងក្រោយនៃឆ្នាំសារពើពន្ធណាមួយដែលឆាប់ជាង ÷

ក- ប្រសិនបើ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មានប្រាក់ចំណេញ គឺជាឆ្នាំសារពើពន្ធមុនឆ្នាំដែលគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មានប្រាក់ចំណេញដំបូង និង

ខ- ប្រសិនបើ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មានប្រាក់ចំណូលពីសកម្មភាពវិនិយោគ ចំពោះការលក់ទំនិញឬសេវា គឺជាឆ្នាំសារពើពន្ធទី៣ បន្ទាប់ពីគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ទទួលបានប្រាក់ចំណូលដំបូង ។

សម្រាប់គោលដៅនៃកថាខ័ណ្ឌនេះ និងមាត្រា១៤ ចំណុច ១៤.១ នៃច្បាប់ស្តីពីវិនិយោគ ប្រាក់ចំណេញគឺសំដៅដល់ប្រាក់ចំណេញជាប់ពន្ធ ដែលគណនាទៅតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសារពើពន្ធដោយពុំគិតពីបទប្បញ្ញត្តិនៃការយោងការខាត ដូចមានចែងក្នុងមាត្រា ១៧ នៃច្បាប់ស្តីពីសារពើពន្ធ ។

១៥.៣ រយៈពេល ០៣ (បី) ឆ្នាំៈ គឺចាប់ផ្តើមគិតភ្លាមពីឆ្នាំសារពើពន្ធ បន្ទាប់ពីរយៈពេលគន្លឹះ និង ០២ (ពីរ)ឆ្នាំ បន្តបន្ទាប់មកទៀត ។

១៥.៤ រយៈពេលអាទិភាពៈ រយៈពេលអាទិភាព ត្រូវបានកំណត់នៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុដោយចាប់ផ្តើមគិតភ្លាមបន្ទាប់ពីឆ្នាំសារពើពន្ធទី៣ នៃរយៈពេល ០៣ (បី) ឆ្នាំ ដូចមានចែងនៅក្នុងកថាខ័ណ្ឌ ១៥.៣ ខាងលើ ។

១៥.៥ ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ សម្រាប់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលបានចុះបញ្ជីក្រោយថ្ងៃប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិនិយោគៈ ប្រាក់រំដោះពន្ធលើប្រាក់ចំណេញមិនត្រូវអនុវត្តចំពោះគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលទទួលបានការលើកលែងពន្ធលើប្រាក់ចំណេញ ដូចមានចែងក្នុងមាត្រា១៤ ចំណុច ១៤.១ នៃច្បាប់ស្តីពីវិនិយោគទេ ។

១៥.៦ ប្រាក់រំដោះពន្ធលើប្រាក់ចំណេញសម្រាប់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលបានទទួលការអនុញ្ញាតមុនពេលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគៈ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ណាដែលត្រូវអនុវត្តតាមកថាខ័ណ្ឌទី២ នៃមាត្រា ២៤ ថ្មីនៃច្បាប់ស្តីពីវិនិយោគ ត្រូវមានកាតព្វកិច្ចបង់ប្រាក់រំដោះប្រចាំខែ សម្រាប់ពន្ធលើប្រាក់ចំណេញតាមអត្រា ០១ (មួយ) ភាគរយនៃផលរបរ គិតរួមបញ្ចូលទាំងពន្ធអាករទាំងអស់ លើកលែងតែអាករលើតម្លៃបន្ថែម ដែលបានសម្រេចក្នុងខែមុន ដូចមានចែងនៅក្នុងមាត្រា ២៨ ថ្មីនៃច្បាប់ស្តីពីសារពើពន្ធ។ ផលរបររបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្នុងរយៈពេលលើកលែងពន្ធ ដែលកំណត់ដោយច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ត្រូវលើកលែងពីការបង់ប្រាក់រំដោះនេះ ។

១៥.៧ ដោយអនុលោមតាមមាត្រា ២៨ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មិនត្រូវជាប់ពន្ធអប្បបរមាទេ ។

## មាត្រា ១៦: ការលើកលែងពន្ធគយលើសម្ភារៈបរិក្ខារផលិតកម្ម សម្ភារៈសាងសង់ និង ធាតុចូលផលិតកម្ម

១៦.១ ការលើកលែងពន្ធគយ លើសម្ភារៈបរិក្ខារផលិតកម្ម និងសម្ភារៈសាងសង់របស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលបម្រើទីផ្សារក្នុងស្រុក : អនុលោមទៅតាមមាត្រា ១៤ ចំណុច ១៤.៥ នៃច្បាប់ស្តីពី

វិនិយោគ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលបម្រើទីផ្សារក្នុងស្រុក ត្រូវបានលើកលែងពន្ធគយ លើការនាំចូលសម្ភារៈបរិក្ខារផលិតកម្ម និងសម្ភារៈសាងសង់តែប៉ុណ្ណោះ ក្នុងករណីដែលគម្រោងប្រភេទនេះ មានលទ្ធភាពនាំចេញនូវផ្នែកណាមួយនៃផលិតផលដែលផលិតបានដោយផ្ទាល់ ឬ បានផ្គត់ផ្គង់ដល់ឧស្សាហកម្មនាំចេញ បរិមាណធាតុចូលផលិតកម្មដែលបានបង់ពន្ធនាំចូលរួយកទៅផលិតបម្រើការនាំចេញដោយផ្ទាល់ ឬដោយប្រយោលនោះ ត្រូវបានទទួលការលើកលែងពន្ធគយក្រោយពីការត្រួតពិនិត្យរបាយការណ៍ប្រចាំត្រីមាស ។

១៦.២ ការលើកលែងពន្ធគយ លើសម្ភារៈបរិក្ខារផលិតកម្ម សម្ភារៈសាងសង់ និងធាតុចូលផលិតកម្មរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បំរើឱ្យការនាំចេញ ៖ អនុលោមតាមមាត្រា ១៤ ចំណុច ១៤.៦ នៃច្បាប់ស្តីពីវិនិយោគ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលបម្រើឱ្យការនាំចេញត្រូវបានលើកលែងពន្ធគយលើការនាំចូល សម្ភារៈបរិក្ខារផលិតកម្ម សម្ភារៈសាងសង់ និងធាតុចូលផលិតកម្ម ។ ដោយឡែកគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បម្រើឱ្យការនាំចេញ ដែលស្ថិតនៅក្រោមយន្តការឃ្លាំងផលិតកម្ម ក្រោមការគ្រប់គ្រងរបស់គយ ការលើកលែងពន្ធគយត្រូវអនុវត្តទៅតាមច្បាប់ និង បទប្បញ្ញត្តិគយជាធរមានរបស់យន្តការនេះ។ ធាតុចូលផលិតកម្មដែលកែច្នៃហើយមិនបាននាំចេញ ត្រូវបង់ពន្ធគយ និង អាករឡើងវិញលើធាតុចូលផលិតកម្មនាពេលនាំចូល ក្រោយពីការត្រួតពិនិត្យរបាយការណ៍ប្រចាំត្រីមាស ។

១៦.៣ ការលើកលែងពន្ធគយ លើសម្ភារៈបរិក្ខារផលិតកម្ម សម្ភារៈសាងសង់ និង ធាតុចូលផលិតកម្ម របស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលជាប្រភេទឧស្សាហកម្មគាំទ្រ អនុលោមតាមមាត្រា ១៤ ចំណុច ១៤.៧ នៃច្បាប់ស្តីពីវិនិយោគ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលជាឧស្សាហកម្មគាំទ្រ ត្រូវបានលើកលែងពន្ធគយ លើការនាំចូលសម្ភារៈបរិក្ខារផលិតកម្ម សម្ភារៈសាងសង់ និង ធាតុចូលផលិតកម្ម។ ប៉ុន្តែក្នុងករណី ដែលគម្រោងទាំងនោះមិនបានធ្វើការផ្គត់ផ្គង់ ១០ (មួយរយ) ភាគរយ នៃផលិតផលដែលផលិតបានទៅដល់ឧស្សាហកម្មនាំចេញ ឬនាំចេញដោយផ្ទាល់ទេនោះ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទាំងនោះ ត្រូវបង់ពន្ធគយនិងអាករឡើងវិញលើធាតុចូលផលិតកម្មនាពេលនាំចូលនូវបរិមាណដែលមិនបានផ្គត់ផ្គង់ឱ្យឧស្សាហកម្មនាំចេញ ឬ នាំចេញដោយផ្ទាល់ ក្រោយពីការត្រួតពិនិត្យរបាយការណ៍ប្រចាំត្រីមាស។

១៦.៤ នីតិវិធីលើកលែងពន្ធគយៈ ក្រុមប្រឹក្សាត្រូវរៀបចំ ÷

ក-បង្កើតយន្តការអន្តរស្ថាប័ន ដែលមានសមាសភាពមកពីក្រុមប្រឹក្សា ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសម្រាប់ពិនិត្យតាមដានការលើកទឹកចិត្ត លើការនាំចូល និង ការប្រើប្រាស់នូវសម្ភារៈបរិក្ខារផលិតកម្ម សម្ភារៈសាងសង់ និង ធាតុចូលផលិតកម្មរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ តាមវិស័យវិនិយោគនីមួយៗ។

ខ-សេចក្តីណែនាំលម្អិតស្តីពីនីតិវិធីសម្រាប់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលត្រូវបានទទួលការលើកលែងពន្ធគយ ។

១៦.៥ ការផ្ទេរ ការលក់ សម្ភារៈបរិក្ខារផលិតកម្ម សម្ភារៈសាងសង់ ធាតុចូលផលិតកម្មៈ ប្រសិនបើ សម្ភារៈបរិក្ខារផលិតកម្ម សម្ភារៈសាងសង់ ធាតុចូលផលិតកម្ម ដែលបាននាំចូលក្រោមការលើកលែងពន្ធគយ អាករ ត្រូវបានលក់ ឬ ប្រើប្រាស់មិនចំគោលដៅតាមរូបភាពណាមួយ អ្នកវិនិយោគត្រូវ ÷

ក- ធ្វើការបង់ពន្ធគយ អាករ ក្នុងរយៈពេល ២៨ (ម្ភៃប្រាំបី) ថ្ងៃ នៃថ្ងៃធ្វើការ ទៅតាមចំនួនទឹកប្រាក់ដែលគណនាផ្អែកតាមច្បាប់ និង បទប្បញ្ញត្តិគយ ជាធរមាន ក្នុងករណីដែលការផ្ទេរ ឬការលក់ បានទទួលការអនុញ្ញាតជាមុនពីក្រុមប្រឹក្សា។

ខ- ធ្វើការបង់ពន្ធគយ អាករ និង ពិន័យ ក្នុងរយៈពេល ២៨ (ម្ភៃប្រាំបី) ថ្ងៃ នៃថ្ងៃធ្វើការ ទៅតាមចំនួនទឹកប្រាក់ដែលគណនាផ្អែកតាមច្បាប់ និងបទប្បញ្ញត្តិគយ ជាធរមាន ក្នុងករណីដែលការផ្ទេរ ឬការលក់នោះ មិនបានទទួលការអនុញ្ញាតជាមុន ពីក្រុមប្រឹក្សា។

គ- ទទួលរងការផ្អាកជាបណ្តោះអាសន្ននូវ ការអនុញ្ញាតឱ្យនាំចូល ការពិនិត្យលើសំណើសុំលើកលែងពន្ធគយដែលបានផ្តល់ឱ្យ នៅក្រោមច្បាប់ស្តីពីវិនិយោគ រួមទាំងការពិន័យផ្អែកគយផ្សេងៗទៀត ក្នុងករណីមានការខកខាន ការយឺតយូរ ក្នុងការបង់ពន្ធគយ អាករ និងការពិន័យ ដូចមានចែងក្នុងកថាខ័ណ្ឌ ក និង ខ នៃកថាខ័ណ្ឌ ១៦.៥ មាត្រា ១៦ នៃអនុក្រឹត្យនេះ។

១៦.៦ ការផ្ទេរ ការលក់ សម្ភារៈបរិក្ខារផលិតកម្ម សម្ភារៈសាងសង់ ធាតុចូលផលិតកម្ម ទៅឱ្យអ្នកវិនិយោគផ្សេងទៀត : អ្នកវិនិយោគ ឬ តំណាងរបស់អ្នកវិនិយោគ អាចដាក់សំណើជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាដើម្បីសុំការសម្រេច លើការផ្ទេរ ការលក់ ដោយគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ នូវសម្ភារៈបរិក្ខារផលិតកម្ម សម្ភារៈសាងសង់ ធាតុចូលផលិតកម្ម ដែលបាននាំចូលដោយលើកលែងពន្ធគយទៅឱ្យអ្នកវិនិយោគផ្សេងទៀត សម្រាប់ប្រើប្រាស់ក្នុងគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

## ជំពូកទី ៦

## កាតព្វកិច្ចរាយការណ៍ និង វិញ្ញាបនប័ត្របញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋ

### មាត្រា ១៧: កាតព្វកិច្ចរាយការណ៍

១៧.១ កាតព្វកិច្ចរាយការណ៍ស្តីពីសារពើពន្ធៈ ដូចបានកំណត់ក្នុងមាត្រា ១០៤ ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ ចាប់ពីថ្ងៃចេញវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ទាំងអស់ត្រូវដាក់លិខិតប្រកាសសារពើពន្ធប្រចាំខែសម្រាប់ខែនីមួយៗ និងលិខិតប្រកាសសារពើពន្ធប្រចាំឆ្នាំសម្រាប់ឆ្នាំសារពើពន្ធនោះ និងបង់ពន្ធអាករទាំងអស់តាមបទប្បញ្ញត្តិនៃពន្ធនីមួយៗ ជូននាយកដ្ឋានពន្ធដារ ដោយត្រូវដាក់ភ្ជាប់នូវវិញ្ញាបនប័ត្របញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋសម្រាប់ឆ្នាំសារពើពន្ធ ។

១៧.២ កាតព្វកិច្ចរាយការណ៍ពីការលើកលែងពន្ធគយៈ រាល់សម្ភារៈបរិក្ខារផលិតកម្ម និងសម្ភារៈសាងសង់នាំចូលដោយគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវតែមានការបំពេញបែបបទគយឱ្យបានសព្វគ្រប់ត្រឹមត្រូវ ។ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយការនាំចូល គម្រោងវិនិយោគមានលក្ខណៈ

សម្បត្តិគ្រប់គ្រាន់ ត្រូវដាក់ជូនក្រុមប្រឹក្សា និង នាយកដ្ឋានពន្ធដារ នូវច្បាប់ចម្លង ដែលមានការបញ្ជាក់ត្រឹមត្រូវលើឯកសារបំពេញបែបបទគយ ក្នុងនោះមានទាំងឯកសារបញ្ជាក់តម្លៃទំនិញពីភ្នាក់ងារដែលរដ្ឋាភិបាលបានជ្រើសតាំងឱ្យទទួលភារកិច្ចផង ។

**មាត្រា ១៨: វិញ្ញាបនប័ត្របញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋ**

១៨.១ វិញ្ញាបនប័ត្របញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋ: រៀងរាល់ឆ្នាំសារពើពន្ធនីមួយៗគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មិនអាចទាមទារ និងមិនមានសិទ្ធិទទួលបាននូវការលើកទឹកចិត្តវិនិយោគណាមួយទេ លើកលែង គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មិនទទួលបាននូវវិញ្ញាបនប័ត្របញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋ ។

១៨.២ ការចេញជាស្វ័យប្រវត្តិ: យោលទៅតាមការដកហូតដោយក្រុមប្រឹក្សាតាមកថាខ័ណ្ឌ ១៨.៤ និង ១៨.៥ ក្រុមប្រឹក្សា ត្រូវចេញវិញ្ញាបនបត្របញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋជូន គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្នុងរយៈពេល ៩០ (កៅសិប )ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីដំណាច់ឆ្នាំសារពើពន្ធនីមួយៗ ។

១៨.៣ ការខកខានមិនបានចេញ: ប្រសិនបើក្រុមប្រឹក្សា ខកខានមិនបានចេញវិញ្ញាបនបត្របញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋ ដូចបានតម្រូវក្នុងកថាខ័ណ្ឌ ១៨.២ ទេនោះ វិញ្ញាបនបត្របញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋនឹងត្រូវចាត់ទុកថា បានចេញជូនគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ប៉ុន្តែអាចនឹងត្រូវបានដកហូតវិញតាម កថាខ័ណ្ឌ ១៨.៤ និង ១៨.៥។

១៨.៤ សិទ្ធិពិនិត្យឡើងវិញ: ក្រុមប្រឹក្សាមានសិទ្ធិពិនិត្យឡើងវិញដើម្បីកំណត់ច្បាស់ថា គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលកាន់កាប់វិញ្ញាបនប័ត្របញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋនោះ បានផ្តល់រាល់ព័ត៌មានដែលតម្រូវ ស្របតាមកថាខ័ណ្ឌ ១៨.៦ ។

១៨.៥ ការបាត់បង់ការលើកទឹកចិត្តវិនិយោគ: ក្រុមប្រឹក្សាអាចដកហូតវិញ្ញាបនប័ត្របញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ប្រសិនបើក្រុមប្រឹក្សាយល់ថា គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មិនបានផ្តល់នូវព័ត៌មានដែលតម្រូវដោយមាត្រានេះ បន្ទាប់ពីការពិនិត្យសមហេតុផលឡើងវិញ តាមកថាខ័ណ្ឌ ១៨.៤ ហើយគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នោះនឹងបាត់បង់នូវសិទ្ធិនៃការទទួលរាល់ការលើកទឹកចិត្តវិនិយោគ ចាប់ពីថ្ងៃដកហូតវិញ្ញាបនប័ត្រនេះតទៅ ។

១៨.៦ ព័ត៌មានដែលត្រូវប្រគល់ជូន: គ្រប់អ្នកវិនិយោគទាំងអស់ ត្រូវដាក់ជូនទៅក្រុមប្រឹក្សានូវ ÷

(ក) របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ រួមមាន តារាងតុល្យការ របាយការណ៍លទ្ធផល តារាងចលនាសាច់ប្រាក់ និង កំណត់សម្គាល់ ដោយមិនឱ្យហួសពីថ្ងៃទី ៣១ ខែ មីនា នៃឆ្នាំបន្ទាប់ ។

(ខ) លិខិតបញ្ជាក់ពីការបំពេញកាតព្វកិច្ចសារពើពន្ធពីនាយកដ្ឋានពន្ធដារ ដែលបញ្ជាក់ថាអ្នកវិនិយោគបាន :

(១) បំពេញត្រឹមត្រូវ និងដាក់លិខិតប្រកាសសារពើពន្ធប្រចាំខែគ្រប់គ្រាន់ទាន់ពេលវេលា ព្រមទាំងទាំងលិខិតប្រកាសប្រចាំឆ្នាំនោះ ដែលតម្រូវដោយច្បាប់ស្តីពីសារពើពន្ធ ។

(ខ) បង់ពន្ធទាំងអស់ ប្រាក់ពន្ធ ការប្រាក់ និងប្រាក់ពន្ធបន្ថែម ដែលបានកំណត់សម្រាប់រយៈពេលជាប់ពន្ធ ដែលបានធ្វើសវនកម្មរួចដោយនាយកដ្ឋានពន្ធដារ ។

(គ) របាយការណ៍ប្រចាំត្រីមាសស្តីពីការនាំចូលជាក់ស្តែងនូវ សម្ភារៈបរិក្ខារផលិតកម្ម និងធាតុចូលផលិតកម្ម ដែលបម្រើឱ្យផលិតកម្ម និងរបាយការណ៍ប្រចាំត្រីមាសស្តីពីការនាំចេញជាក់ស្តែងនូវផលិតផលសម្រេចរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ព្រមទាំងតារាងអចលនៈទ្រព្យប្រចាំឆ្នាំ ។

(ឃ) បញ្ជីអង្កេតព័ត៌មានវិនិយោគទម្រង់ CIB 01S ។

## ជំពូកទី ៧
## កម្មសិទ្ធិ និង ការប្រើប្រាស់ដីធ្លី

### មាត្រា ១៩: កម្មសិទ្ធិ

១៩.១ កម្មសិទ្ធិ: កម្មសិទ្ធិដីធ្លី សម្រាប់បម្រើឱ្យគោលដៅនៃសកម្មភាពវិនិយោគ ដែលត្រូវផ្តល់ជូនរូបវន្តបុគ្គល ឬ នីតិបុគ្គលសញ្ជាតិខ្មែរ ត្រូវអនុលោមទៅតាមច្បាប់ជាធរមាន ។

១៩.២ ការចុះបញ្ជីកម្មសិទ្ធិ: ក្នុងការចុះបញ្ជីកម្មសិទ្ធិដីធ្លី អ្នកវិនិយោគត្រូវទៅបំពេញរាល់ទម្រង់បែបបទចុះបញ្ជីនៅរដ្ឋបាលសុរិយោដី ក្នុងមូលដ្ឋានដែលអចលនវត្ថុនោះតាំងនៅ ។

១៩.៣ ការកំណត់សិទ្ធិលើកម្មសិទ្ធិ: អនុលោមតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា រូបវន្តបុគ្គល ឬ នីតិបុគ្គលសញ្ជាតិបរទេស មិនអាចធ្វើជាកម្មសិទ្ធិករនៃដីធ្លីក្នុងព្រះរាជាណាចក្រកម្ពុជាបានឡើយ ។

### មាត្រា ២០ : ការប្រើប្រាស់ដីធ្លី

២០.១ នីតិបុគ្គលសញ្ជាតិខ្មែរ: ក្រៅពីសិទ្ធិកម្មសិទ្ធិ អ្នកវិនិយោគសញ្ជាតិខ្មែរមានសិទ្ធិប្រើប្រាស់ដីធ្លីតាមរូបភាពផ្សេងៗ ដែលមានជាធរមានដូចជា:.សម្បទាន ការជួល ការផ្ទេរ ការដាក់ប្រាតិភោគជាដើម ។

២០.២ នីតិបុគ្គលសញ្ជាតិបរទេស: នីតិបុគ្គលសញ្ជាតិបរទេសអាចប្រើប្រាស់ដីធ្លីតាមរូបភាពផ្សេងៗដូចជា សម្បទាន ការជួលរយៈពេលវែង ១៥ (ដប់ប្រាំ) ឆ្នាំឡើង ឬ លើស និងការជួលរយៈពេលខ្លី ហើយអាចបន្តជាថ្មីបាន។ ការប្រើប្រាស់ដីធ្លីនេះរាប់បញ្ចូលទាំងសិទ្ធិលើសំណង់ ការរៀបចំឬ ការកែលំអទាំងឡាយ ដែលបានធ្វើដោយអ្នកជួលក្នុងរយៈពេលកំណត់នៃកិច្ចសន្យា តែត្រូវអនុវត្តតាមច្បាប់ជាធរមាន។

២០.៣ ការជួលដីរបស់រដ្ឋ: រូបវន្តបុគ្គលឬ នីតិបុគ្គល ដែលបានជួលដីពីរដ្ឋ ត្រូវអនុវត្តទៅតាមបទប្បញ្ញត្តិ ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ។

២០.៤ ការជួលបន្ត: រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានទទួលការអនុញ្ញាតអោយជួលដីធ្លីពីរដ្ឋ អាចធ្វើការជួលបន្តទៅអោយតតីយជនបាន លុះត្រាតែមានការយល់ព្រមដោយជាក់លាក់ ឬ ការអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ចជាមុនសិន។

## ជំពូកទី ៨
## កម្លាំងពលកម្ម

### មាត្រា ២១ : ការប្រើប្រាស់កម្លាំងពលកម្ម

ក្រុមប្រឹក្សា មានភារកិច្ចណែនាំ និង សម្រួលដល់អ្នកវិនិយោគ ដើម្បីនាំមកជាមួយនូវសហព័ទ្ធ ជាជនបរទេស ដើម្បីទទួលបាននូវទិដ្ឋាការ សិទ្ធិស្នាក់នៅ និង លិខិតធ្វើដំណើរនានាត្រឹមត្រូវ ស្របទៅតាមច្បាប់ និង បទប្បញ្ញត្តិស្តីពីអន្តោប្រវេសន៍ ។

រាល់ការនាំមកនូវ បុគ្គលិក និង អ្នកជំនាញការខាងការគ្រប់គ្រង បុគ្គលិកបច្ចេកទេស កម្មករជំនាញ ដែលជាជនបរទេសរបស់អ្នកវិនិយោគដែលមិនអាចរកបាននៅក្នុងចំណោមប្រជាជនកម្ពុជា ក្រុមប្រឹក្សាត្រូវបង្កការងាយស្រួលជូនដល់អ្នកវិនិយោគ ដើម្បីអាចមានសិទ្ធិនាំនិយោជិតបរទេសទាំងនោះមកបំពេញការងារតាមតម្រូវការ ស្របតាមច្បាប់ស្តីពីការងារ ច្បាប់ស្តីពីអន្តោប្រវេសន៍ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ។

## ជំពូកទី ៩
## ទោសប្បញ្ញត្តិ

### មាត្រា ២២: ទោសប្បញ្ញត្តិ

ប្រសិនបើអ្នកវិនិយោគ មិនអនុវត្តតាមកាតព្វកិច្ចណាមួយដែលបានកំណត់ឱ្យខ្លួន តាមអនុក្រឹត្យនេះ ឬតាមច្បាប់ស្តីពីវិនិយោគ អ្នកវិនិយោគត្រូវទទួលរងនូវទោសប្បញ្ញត្តិ ដែលបានកំណត់ដោយមាត្រា ៨ ចំណុច ៨.១ មាត្រា ១២ មាត្រា ១៨ ចំណុច ១៨.៥ នៃអនុក្រឹត្យនេះ ឬ ច្បាប់ដទៃទៀត ស្តីពីការមិនបំពេញនូវកាតព្វកិច្ច ។

## ជំពូកទី ១០
## អន្តរប្បញ្ញត្តិ

### មាត្រា ២៣: ការទទួលស្គាល់ជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ នៃគម្រោងវិនិយោគដែលទទួលបានការអនុញ្ញាតមុនច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ

២៣.១ គម្រោងវិនិយោគទាំងឡាយ ដែលបានទទួលការអនុញ្ញាតដោយច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ និងដែលកំពុងធ្វើសកម្មភាពបច្ចុប្បន្ន មុនថ្ងៃចូលជាធរមាននៃអនុក្រឹត្យនេះ និងត្រូវបានទទួលស្គាល់ជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្រោយពេលដែលអ្នកវិនិយោគនោះ បានដាក់សំណើជាលាយលក្ខណ៍អក្សរជូនមកក្រុមប្រឹក្សា ដើម្បីកំណត់ថាជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ហើយទទួលអនុវត្តនូវកាតព្វកិច្ចទាំងឡាយដូចមានចែងក្នុងច្បាប់ស្តីពីវិនិយោគ និង អនុក្រឹត្យនេះ ។

ក្រុមប្រឹក្សា ត្រូវចេញលិខិតទទួលស្គាល់គម្រោងវិនិយោគខាងលើនោះ ថាជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្នុងរយៈពេលយ៉ាងយូរ ០៣ (បី)ថ្ងៃ នៃថ្ងៃធ្វើការ ជូនទៅអ្នកវិនិយោគវិញ។ ចំពោះគម្រោងវិនិយោគ ដែលពីមុនបានទទួលគោលការណ៍ឱ្យវិនិយោគកន្លងមក តែមិនបានធ្វើសកម្មភាពអ្វីឡើយ ឬបានធ្វើមួយរយៈ តែបានផ្អាកសកម្មភាពទៅវិញ ហើយមិនបានជូនដំណឹងពីការបញ្ឈប់ ឬផ្អាកសកម្មភាពនោះមកក្រុមប្រឹក្សា គម្រោងវិនិយោគនោះ ត្រូវធ្វើនិយ័តកម្មឯកសារបន្ថែមដើម្បីអាចទទួលបានសិទ្ធិជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មុននឹងចាប់ផ្តើមអនុវត្តគម្រោងជាបន្តទៅទៀត។

២៣.២ ការលើកទឹកចិត្តនានា របស់គម្រោងវិនិយោគ ដែលទទួលការអនុញ្ញាតមុនច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគៈ គម្រោងវិនិយោគ ដែលទទួលការអនុញ្ញាតមុនច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ ហើយបានទទួលស្គាល់ជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលមានសិទ្ធិទទួលបាននូវអត្រាពន្ធលើប្រាក់ចំណេញ ០៩ (ប្រាំបួន) ភាគរយ មុនពេលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា មានសិទ្ធិទទួលបានអត្រាពន្ធ ០៩ (ប្រាំបួន) ភាគរយនេះ សម្រាប់រយៈពេលអន្តរកាលមិនលើសពី ០៥ (ប្រាំ) ឆ្នាំ ដោយចាប់ផ្តើមពីឆ្នាំសារពើពន្ធបន្ទាប់ពីការប្រកាសចូលជាធរមាននូវច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យនេះ លុះត្រាតែអ្នកវិនិយោគនោះ បានបំពេញត្រឹមត្រូវនូវ កាតព្វកិច្ចទាំងឡាយ ដូចមានចែងក្នុងជំពូកទី ៦ នៃអនុក្រឹត្យនេះ។

គម្រោងវិនិយោគដែលទទួលការអនុញ្ញាតមុនច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ ហើយបានទទួលស្គាល់ជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និង ដែលទទួលបាននូវការលើកទឹកចិត្តជាលាយលក្ខណ៍អក្សរពីក្រុមប្រឹក្សា អាចបន្តទទួលការលើកទឹកចិត្តលើកលែងពន្ធលើប្រាក់ចំណេញ ពន្ធគយលើការនាំចូលសម្ភារៈបរិក្ខារផលិតកម្ម សម្ភារៈសាងសង់ និងធាតុចូលផលិតកម្មបានទៀត លុះត្រាតែអ្នកវិនិយោគនោះ បានបំពេញត្រឹមត្រូវនូវកាតព្វកិច្ចទាំងឡាយ ដូចមានចែងក្នុង ជំពូកទី ៦ នៃអនុក្រឹត្យនេះ។

## ជំពូកទី ១១

## អវសានបញ្ញត្តិ

### មាត្រា ២៤: និរាករណ៍

អនុក្រឹត្យលេខ ៨៨ អនក្រ/បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា អនុក្រឹត្យវិសោធនកម្ម លេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ១១ ខែមិថុនា ឆ្នាំ ១៩៩៩ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា អនុក្រឹត្យលេខ ១៣០ អនក្រ.បក ចុះថ្ងៃ ទី ២៦ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៩ និង បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២៥:**

រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង និង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធទាំងអស់ អភិបាលគ្រប់ខេត្ត ក្រុង ត្រូវទទួលអនុវត្ត អនុក្រឹត្យនេះតាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ខែកញ្ញា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

*កន្លែងទទួល:*

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ដូចមាត្រា ២៥
-ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី ១

## នៃអនុក្រឹត្យលេខ.១១១.អនក្រ.បក.ចុះថ្ងៃទី.២៧...ខែ.កញ្ញា.ឆ្នាំ ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

## បញ្ជីអវិជ្ជមាន (មាត្រា ៦.១)

**ផ្នែកទី ១ : សកម្មភាពវិនិយោគដែលហាមឃាត់ ដោយច្បាប់ និង អនុក្រឹត្យពាក់ព័ន្ធ**

១- ផលិតកម្ម កែច្នៃសារធាតុប្រព័ន្ធសរសៃប្រសាទ (Psychotropic Substances) និង សារធាតុ (Narcotic) ។

២- ផលិតកម្មគ្រឿងគីមីពុល ថ្នាំពុលកសិកម្ម និង ទំនិញផ្សេងទៀត តាមរយៈការប្រើប្រាស់ សារធាតុគីមី ដែលហាមឃាត់ ដោយបទប្បញ្ញត្តិអន្តរជាតិនានា ឬ អង្គការសុខភាពពិភពលោក ដែលធ្វើឱ្យប៉ះពាល់ដល់សុខភាពសាធារណៈ និង បរិស្ថាន ។

៣- ការកែច្នៃ ការផលិតអគ្គិសនី ដោយប្រើប្រាស់ កាកសំណល់គ្រប់ប្រភេទ ដែលនាំចូលពីបរទេស ។

៤- ការធ្វើអាជីវកម្ម ព្រៃឈើ ដែលច្បាប់ស្តីពីព្រៃឈើហាមឃាត់ ។

៥- សកម្មភាពវិនិយោគផ្សេងៗទៀត ដែលច្បាប់ហាមឃាត់ ។

**ផ្នែកទី ២ : សកម្មភាពវិនិយោគដែលមិនទទួលបាននូវការលើកទឹកចិត្ត**

១- សកម្មភាពពាណិជ្ជកម្ម អាហារីណ នីហារីណ លក់ដុំ លក់រាយ គ្រប់ប្រភេទ រួមទាំងហាងលក់ទំនិញរួចពន្ធ ។

២- សេវាកម្មដឹកជញ្ជូនគ្រប់ប្រភេទ ទាំងផ្លូវទឹក ផ្លូវគោក និងផ្លូវអាកាស លើកលែងតែការវិនិយោគវិស័យផ្លូវរថភ្លើង ។

៣- ភោជនីយដ្ឋាន ការ៉ាអូខេ រង្គសាល បារីយដ្ឋាន កន្លែងធ្វើសរសៃ កន្លែងហាត់កីឡា ដែលស្ថិតនៅក្រៅបរិវេណសណ្ឋាគារ ខ្នាតអន្តរជាតិ ។ ប៉ុន្តែ ទោះបីស្ថិតនៅក្នុងបរិវេណសណ្ឋាគារខ្នាតអន្តរជាតិក៏ដោយ ប្រសិនបើអ្នកវិនិយោគបានយកទីតាំងខាងលើនោះ ជួលបន្តឱ្យតតិយជនធ្វើអាជីវកម្ម អ្នកជួលដែលមិនមែនជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នឹងមិនទទួលបាននូវការលើកលែងពន្ធលើប្រាក់ចំណេញ ដែលសម្រាប់ផ្តល់ដល់អ្នកវិនិយោគ ស្របតាមច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិនិយោគនោះឡើយ ។

៤- សេវាកម្ម ការទេសចរណ៍ ភ្នាក់ងារទេសចរណ៍ ព័ត៌មាន និង ផ្សព្វផ្សាយទេសចរណ៍ ។

៥- អាជីវកម្ម សេវាកម្ម និង អាជីវកម្ម កាស៊ីណូ និង ល្បែងស៊ីសង គ្រប់ប្រភេទ ។

៦- សេវាកម្ម និង អាជីវកម្ម រូបិយវត្ថុ និង ហិរញ្ញវត្ថុ រួមមាន ធនាគារ ស្ថាប័នហិរញ្ញវត្ថុ ក្រុមហ៊ុនធានារ៉ាប់រង និង ប្រតិបត្តិការ ហិរញ្ញវត្ថុអន្តរការីយកម្ម គ្រប់ប្រភេទ ។

៧- សកម្មភាពដែលទាក់ទងទៅនឹង សារព័ត៌មាន និងប្រព័ន្ធឃោសនា មានជាអាទិ៍ វិទ្យុ ទូរទស្សន៍ កាសែត ទស្សនាវដ្តី ភាពយន្ត ផលិត ឬថតចម្លងវីដេអូ ល្ខោន ស្ទូឌីយោថត និង សកម្មភាពពាក់ព័ន្ធ ។

៨- សេវាកម្មវិជ្ជាជីវៈ ។

៩- សារពាង្គកាយកែច្នៃរស់ (LMOs) ដែលបង្កឱ្យមានគ្រោះថ្នាក់ដល់ជីវចំរុះ សុខភាពមនុស្ស និង បរិស្ថាន ។

១០- ការផលិត ឬការកែច្នៃផលិតផលឈើ ដែលប្រើប្រាស់ឈើមូលពីព្រៃឈើធម្មជាតិមានប្រភពផ្គត់ផ្គង់ស្របច្បាប់ក្នុងស្រុក ជាវត្ថុធាតុដើម។

១១- ការផលិត ផលិតផលពីថ្នាំជក់គ្រប់ប្រភេទ។

១២- ការផលិត ផលិតផលម្ហូបអាហារ និង ភេសជ្ជៈ ដែលមានទុនវិនិយោគសមមូលទាបជាង ៥០០.០០០ (ប្រាំរយពាន់) ដុល្លារអាមេរិក។

១៣- ការផលិត ផលិតផលសម្រាប់រោងចក្រវាយនភ័ណ្ឌ ដែលមានទុនវិនិយោគសមមូលទាបជាង ៥០០.០០០ (ប្រាំរយពាន់) ដុល្លារអាមេរិក។

១៤- ការផលិត សំលៀកបំពាក់ វាយនភ័ណ្ឌ ស្បែកជើង មួក ដែលមានទុនវិនិយោគសមមូលទាបជាង ៥០០.០០០ (ប្រាំរយពាន់) ដុល្លារអាមេរិក។

១៥- ការផលិត គ្រឿងសង្ហារឹម និង គ្រឿងតាំងភ្ជាប់ មិនប្រើប្រាស់ឈើធម្មជាតិ ដែលមានទុនវិនិយោគសមមូលទាបជាង ៥០០.០០០ (ប្រាំរយពាន់) ដុល្លារអាមេរិក។

១៦- ការផលិត ក្រដាស និងផលិតផលធ្វើពីក្រដាស ដែលមានទុនវិនិយោគសមមូលទាបជាង ៥០០.០០០ (ប្រាំរយពាន់) ដុល្លារអាមេរិក។

១៧- ការផលិត ធាតុគីមី ស៊ីម៉ងត៍ ជីកសិកម្ម គីមីកែច្នៃពីប្រេងកាត ដែលមានទុនវិនិយោគសមមូលទាបជាង ១.០០០.០០០ (មួយលាន) ដុល្លារអាមេរិក។

១៨- ការផលិត ផលិតផលពីកៅស៊ូ និង ផលិតផលធ្វើពីជ័រប្លាស្ទិក ដែលមានទុនវិនិយោគសមមូលទាបជាង ៥០០.០០០ (ប្រាំរយពាន់) ដុល្លារអាមេរិក។

១៩- ការផលិត ផលិតផលស្បែក និង ផលិតផលពាក់ព័ន្ធផ្សេងៗទៀត ដែលមានទុនវិនិយោគសមមូលទាបជាង ៣០០.០០០ (បីរយពាន់) ដុល្លារអាមេរិក។

២០- ការផលិត ផលិតផលធ្វើពីលោហៈគ្រប់ប្រភេទ ដែលមានទុនវិនិយោគសមមូលទាបជាង ៣០០.០០០ (បីរយពាន់) ដុល្លារអាមេរិក។

២១- ការផលិត សម្ភារៈបរិក្ខារអគ្គិសនី និង អេឡិចត្រូនិច និងសម្ភារៈការិយាល័យ ដែលមានទុនវិនិយោគសមមូលទាបជាង ៣០០.០០០ (បីរយពាន់) ដុល្លារអាមេរិក។

២២- ការផលិត ប្រដាប់ក្មេងលេង និង សម្ភារៈកីឡា ដែលមានទុនវិនិយោគសមមូលទាបជាង ៣០០.០០០ (បីរយពាន់) ដុល្លារអាមេរិក។

២៣- ការផលិត បំណែកយានយន្ត និង គ្រឿងបន្លាស់យានយន្ត ដែលមានទុនវិនិយោគសមមូលទាបជាង ៣០០.០០០ (បីរយពាន់) ដុល្លារអាមេរិក។

២៤- ការផ្គត់ផ្គង់ទឹកស្អាត ដែលមានទុនវិនិយោគសមមូលទាបជាង ៥០០.០០០ (ប្រាំរយពាន់) ដុល្លារអាមេរិក។

២៥- ឧស្សាហកម្មគាំទ្រដែលផលិតផល ១០០ (មួយរយ) ភាគរយ ផ្គត់ផ្គង់ឱ្យឧស្សាហកម្មនាំចេញ ដែលមានទុនវិនិយោគសមមូលទាបជាង ១០០.០០០ (មួយរយពាន់) ដុល្លារអាមេរិក។

២៦- មជ្ឈមណ្ឌលតាំងពិពណ៌ពាណិជ្ជកម្មអន្តរជាតិ និងសាលសន្និសីទ ដែលមានទុនវិនិយោគសមមូលទាបជាង ៨.០០០.០០០ (ប្រាំបីលាន) ដុល្លារអាមេរិក។

២៧- ការសាងសង់ផ្សារទំនើប ឬ មជ្ឈមណ្ឌលពាណិជ្ជកម្ម ដែលមានទុនវិនិយោគសមមូលទាបជាង ២.០០០.០០០ (ពីរលាន) ដុល្លារអាមេរិក មានទំហំតិចជាង ១០.០០០ (ដប់ពាន់) ម៉ែត្រក្រឡា និងមិនមានកន្លែងចតរថយន្តគ្រប់គ្រាន់។

២៨- ការផលិត ចំណីសត្វ ដែលមានទុនវិនិយោគសមមូលទាបជាង ២០០.០០០ (ពីររយពាន់) ដុល្លារអាមេរិក។

២៩- ការផលិត សម្ភារៈធ្វើពីកុលាលភាជន៍ ដែលមានទុនវិនិយោគសមមូលទាបជាង ៣០០.០០០ (បីរយពាន់)ដុល្លារអាមេរិក។

៣០- វិទ្យាស្ថានបង្ហាត់បង្រៀន និងអប់រំ ដែលធ្វើការបំពាក់បំប៉នលើមុខជំនាញ បច្ចេកវិទ្យា ឬ ពហុបច្ចេកទេស បំរើឱ្យវិស័យឧស្សាហកម្ម កសិកម្ម ទេសចរណ៍ ហេដ្ឋារចនាសម្ព័ន្ធ បរិស្ថាន វិស្វកម្ម វិទ្យាសាស្ត្រ និង សេវាកម្មផ្សេងទៀត ដែលមានទុនវិនិយោគសមមូលទាបជាង ៤.០០០.០០០ (បួនលាន) ដុល្លារអាមេរិក។

៣១- សណ្ឋាគារក្រោមកម្រិតផ្កាយ ៣ (បី)។

៣២- មជ្ឈមណ្ឌលទេសចរណ៍ ដែលមានសណ្ឋាគារមានបន្ទប់តិចជាង ១០០ (មួយរយ) បន្ទប់ ឬ មានសណ្ឋាគារបែបលំនៅដ្ឋាន តិចជាង ៣០ (សាមសិប) លំនៅដ្ឋាន និងមានរមណីយដ្ឋានដែលមានសេវាកម្មចម្រុះ ដែលមានទំហំតិចជាង ១០ (ដប់) ហិកតា។

៣៣- ទេសចរណ៍ធម្មជាតិ និង ការបង្កើតតំបន់ទេសចរណ៍ធម្មជាតិ ដែលមានផ្ទៃដីតិចជាង ១.០០០ (មួយពាន់)ហិកតា និងមានទុន វិនិយោគសមមូលទាបជាង ១.០០០.០០០ (មួយលាន) ដុល្លារអាមេរិក។

៣៤- រមណីយដ្ឋានដែលមានសេវាកម្មចម្រុះ រួមមាន សណ្ឋាគារ សួនកំសាន្ត កន្លែងហាត់កីឡា សួនសត្វ ដែលមានទំហំតិចជាង ៥០ (ហាសិប) ហិកតា។

៣៥- ចំណតរថយន្ត។

៣៦- មណ្ឌលឃ្លាំងទំនិញ។

៣៧- មន្ទីរពហុព្យាបាលជម្ងឺ ដែលមានគ្រែតិចជាង ៥០ (ហាសិប)គ្រែ មិនមានការបំពាក់នូវឧបករណ៍ទំនើប បន្ទប់ពិសោធន៍ បន្ទប់វះកាត់ បន្ទប់កាំរស្មីអ៊ិច បន្ទប់សង្គ្រោះបន្ទាន់ ឱសថស្ថាន ជណ្តើរយន្ត (ក្នុងករណីមានអាគារលើសពី ៣ (បី) ជាន់) រថយន្តសង្គ្រោះបន្ទាន់ សាលដាក់ដំកល់សព និងដែលមានទុនវិនិយោគសមមូលទាបជាង ១.០០០.០០០ (មួយលាន) ដុល្លារអាមេរិក។

៣៨- ផលិតកម្មឱសថសម័យ ដែលមានទុនវិនិយោគសមមូលទាបជាង ១.០០០.០០០ (មួយលាន) ដុល្លារអាមេរិក។

៣៩- ផលិតកម្មឱសថបូរាណ ដែលមានទុនវិនិយោគសមមូលទាបជាង ៥០០.០០០ (ប្រាំរយពាន់) ដុល្លារអាមេរិក។

៤០- ផលិតកម្មកសិកម្ម

| | |
|---|---|
| ៤០.១ ដំណាំស្រូវ | តិចជាង ១.០០០ (មួយពាន់) ហិកតា។ |
| ៤០.២ ដំណាំរូបិយវត្ថុគ្រប់ប្រភេទ | តិចជាង ៥០០ (ប្រាំរយ) ហិកតា។ |
| ៤០.៣ បន្លែ | តិចជាង ៥០ (ហាសិប) ហិកតា។ |

៤១- ផលិតកម្មបសុសត្វ

| | |
|---|---|
| ៤១.១ ការចិញ្ចឹមសត្វចតុបាទ | តិចជាង ១.០០០ (មួយពាន់) ក្បាល។ |

៤១.២ កសិដ្ឋានចិញ្ចឹមគោយកទឹកដោះ តិចជាង ១០០ ( មួយរយ ) ក្បាល ។

៤១.៣ កសិដ្ឋានចិញ្ចឹម បសុបក្សីយកសាច់ និង ស៊ុត តិចជាង ១០.០០០ ( ដប់ពាន់ ) ក្បាល ។

៤២- ផលិតកម្មជលផល

៤២.១ កសិដ្ឋានវារីវប្បកម្ម ទឹកសាប តិចជាង ៥ ( ប្រាំ ) ហិកតា ។

៤២.២ កសិដ្ឋានវារីវប្បកម្ម សមុទ្រ តិចជាង ១០ ( ដប់ ) ហិកតា ។

៤៣- ការដាំឈើ រុក្ខជាតិ និង ការចិញ្ចឹមសត្វព្រៃផ្សេងៗ ÷

៤៣.១ ការដាំដើមឈើ តិចជាង ១.០០០ ( មួយពាន់ ) ហិកតា ។

៤៣.២ ការដាំរុក្ខជាតិផ្សេងៗ តិចជាង ២០០ ( ពីររយ ) ហិកតា ។

៤៣.៣ ការចិញ្ចឹមថនិកសត្វព្រៃ តិចជាង ១០០ ( មួយរយ ) ក្បាល ។

៤៣.៤ ការចិញ្ចឹមបក្សីព្រៃ តិចជាង ៥០០ ( ប្រាំរយ ) ក្បាល ។

៤៣.៥ ការចិញ្ចឹមឧរង្គសត្វព្រៃ តិចជាង ១.០០០ ( មួយពាន់ ) ក្បាល ។

និយមន័យនៃចំណុច ៤៣ ខាងលើ នឹងកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

៤៤- ការបង្កក និង ការកែច្នៃនាំចេញ នូវជលផល និង កសិផល ÷

៤៤.១ ការកែច្នៃ និង បង្កកផលិតផលជលផល សំរាប់នាំចេញ ដែលមានទុនវិនិយោគសមមូលទាបជាង ៥០០.០០០ ( ប្រាំរយពាន់ ) ដុល្លារអាមេរិក ។

៤៤.២ ការកែច្នៃកសិផលគ្រប់ប្រភេទ ដើម្បីនាំចេញ ដែលមានទុនវិនិយោគសមមូលទាបជាង ៥០០.០០០ ( ប្រាំរយពាន់ ) ដុល្លារអាមេរិក ។

៤៥- ការផ្គត់ផ្គង់សេវាតម្លៃបន្ថែម នៃវិស័យសេវាទូរគមនាគមន៍គ្រប់ប្រភេទ ។

៤៦-ការអភិវឌ្ឍន៍ផ្នែកអចលនវត្ថុ ។

<u>**ផ្នែកទី ៣ : *សកម្មភាពវិនិយោគដែលមានលក្ខណៈពិសេស ហើយដែលត្រូវទទួលការលើកទឹកចិត្តផ្នែកពន្ធគយលើការនាំចូល តែមិនទទួលបានការលើកទឹកចិត្តផ្នែកពន្ធលើប្រាក់ចំណេញ :***</u>

១- សេវាទូរគមនាគមន៍មូលដ្ឋាន ។

២- សិក្សាស្រាវជ្រាវ ឧស្ម័ន ប្រេងកាត និងរ៉ែគ្រប់ប្រភេទ រួមទាំងមូលដ្ឋានផ្គត់ផ្គង់សំរាប់ឧស្ម័ន និងប្រេងកាត ។

## ឧបសម្ព័ន្ធទី ២

នៃអនុក្រឹត្យលេខ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា...ឆ្នាំ ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម
នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

## ពាក្យស្នើវិនិយោគនៅព្រះរាជាណាចក្រកម្ពុជា (មាត្រា ៥.២)

### I- **ចេនាសម្ព័ន្ធក្រុមហ៊ុន :**

*ក.ព័ត៌មានទូទៅ*

- ឈ្មោះ បុគ្គល មានរូបវ័ន្ត ឬ នីតិបុគ្គល) :........................................................................................................

- អាស័យដ្ឋាន:-ទីស្នាក់ការបុគ្គល : ...................................................................................Tel:.........................

Fax:...........................................E-mail :...............................................................................

-ឈ្មោះបុគ្គលមេ :..........................................................អាស័យដ្ឋាន.....................................................................

.....................................................Tel:.................................Fax:.........................

Website:..........................................E-mail:.........................................................................

- ទ្រង់ទ្រាយក្រុមហ៊ុន : ( *សូមគូស ✓ ក្នុងប្រអប់*☐ )

☐ ក្រុមហ៊ុនមូលធន (Corporation) ☐ ក្រុមហ៊ុនសហកម្មសិទ្ធិ (Partnership)

☐ ក្រុមហ៊ុនពាណិជ្ជកម្មបរទេស (Foreign Company)

*កំណត់សម្គាល់* : ក្រុមហ៊ុនមូលធនរួមមាន : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត និងក្រុមហ៊ុនឯកបុគ្គលទទួលខុសត្រូវមានកម្រិត (Single Member Private Limited Company)

- ទុនចុះបញ្ជី.......................................................................បរទេស...........% ក្នុងស្រុក................%

- លិខិតបញ្ជាក់ប្រាក់តម្កល់នៅធនាគារ ២៥%លេខ...........................................................

*ខ.សមាសភាពក្រុមហ៊ុន*

ម្ចាស់ភាគហ៊ុន

| នាមត្រកូល និងនាមខ្លួន | សញ្ជាតិ | លេខ និងកាលបរិច្ឆេទអត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន | អាស័យដ្ឋាន | អត្រាភាគហ៊ុន% |
|---|---|---|---|---|
| ១..........................<br>២..........................<br>៣..........................<br>៤.......................... | | | | |

សមាសភាពក្រុមប្រឹក្សាភិបាល (រួមទាំងគតិយជន)

| នាមត្រកូល និងនាមខ្លួន | សញ្ជាតិ | លេខ និងកាលបរិច្ឆេទ អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន | អាស័យដ្ឋាន | តួនាទីក្នុងក្រុមហ៊ុន | អ្នកដែលមានសិទ្ធិចុះហត្ថលេខា សម្រាប់កិច្ចការ |
|---|---|---|---|---|---|
| ១..........................<br>២..........................<br>៣.......................... | | | | | |

## II- ពាក្យស្នើសុំវិនិយោគ :

### *ក. ព័ត៌មានទូទៅ*

- សកម្មភាពវិនិយោគ : ........................................................................................................................

- វិស័យវិនិយោគ : ( *សូមគូស ✓ ក្នុងប្រអប់*☐ )

☐ កសិកម្ម-កសិ-ឧស្សាហកម្ម ☐សំណង់ស៊ីវិល ☐ ថាមពល ☐ ហិរញ្ញវត្ថុ ☐ ឧស្សាហកម្ម ☐ ធនធានរ៉ែ

☐ ទេសចរណ៍ ☐ ដឹកជញ្ជូន ☐ទូរគមនាគមន៍ ☐ទឹកស្អាត ☐តំបន់ឧស្សាហកម្ម ☐ផ្សេងៗ

- អ្នកដាក់ពាក្យសុំ :
  - ឈ្មោះ.................................................អាសយដ្ឋាន :..........................................................................
  - តួនាទីក្នុងក្រុមហ៊ុន : ..................................................Tel :...........................................Fax : ...........................
  - លិខិតប្រគល់សិទ្ធិ ( *បើសិនមិនមានតួនាទីក្នុងក្រុមហ៊ុន* ): លេខ ................ ចុះថ្ងៃទី..........ខែ..........ឆ្នាំ.............

- ទុនវិនិយោគសរុប : ..........................................................ក្នុងនោះទុនលើ :
  - សំណង់អាគារ/រៀបចំការដ្ឋាន ........................ ម² តម្លៃ:...............................USD អាគារមានស្រាប់ ☐ អាគារថ្មី ☐
  - សម្ភារៈបរិក្ខាផលិតកម្ម ( គ្រឿងចក្រ-គ្រឿងម៉ាស៊ីនផលិតកម្ម-សម្ភារៈបរិក្ខាផ្សេងៗ) តម្លៃ(USD) :...............................

    ( មានបញ្ជីជូនភ្ជាប់ តាមទម្រង់ដូចមានចែងក្នុងឧបសម្ព័ន្ធ )
  - សម្ភារៈការិយាល័យតម្លៃ (USD) : ....................................................................................................
  - ផ្សេងៗតម្លៃ (USD) : ........................................................................................................................

- ដីធ្លី (ទំហំ ម²) : ................................................................តម្លៃ ..................................USD

- ប្រភពទុនវិនិយោគ : ទុនផ្ទាល់:......................................ឥណទានធនាគាររយៈពេលវែង :...........................

  ឥណទានធនាគាររយៈពេលខ្លី :..............................................

- ទីតាំងវិនិយោគ : ដីឡូត៍លេខ..................ផ្លូវលេខ.........................ភូមិ :.........................ឃុំ សង្កាត់ :..........................

  ស្រុក/ខណ្ឌ :.................................ខេត្ត ក្រុង :..............................ទំហំ :................................ម²

- កម្មវិធីអនុវត្តគម្រោង :
  - ចាប់ផ្ដើមសាងសង់ : .......................................... ព្យាករណ៍បញ្ចប់ការសាងសង់.....................................
  - ពេលបំពាក់គ្រឿងម៉ាស៊ីន :............................... ចាប់ផ្ដើមដំណើរការផលិតកម្ម.......................................

- ព័ត៌មានស្ដីពីផលិតផល :

| ប្រភេទផលិតផល | ឯកតា | សមត្ថភាពផលិតប្រចាំឆ្នាំ | | | | ទីផ្សារ | |
|---|---|---|---|---|---|---|---|
| | | ឆ្នាំដំបូង | | ពេញផលិតកម្ម | | ក្នុងស្រុក គិតជា % | នាំចេញ គិតជា % |
| | | បរិមាណ | តម្លៃ | បរិមាណ | តម្លៃ | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

-តម្រូវការពលកម្ម

| ប្រភេទពលកម្ម | ពេលចាប់ផ្តើម | | ពេលពេញសមត្ថភាព | |
|---|---|---|---|---|
| | ក្នុងស្រុក | បរទេស | ក្នុងស្រុក | បរទេស |
| - អ្នកគ្រប់គ្រង | | | | |
| - វិស្វករ | | | | |
| - អ្នកបច្ចេកទេស | | | | |
| - ទីប្រឹក្សា | | | | |
| - បុគ្គលិកការិយាល័យ | | | | |
| - កម្មករជំនាញ | | | | |
| - កម្មករគ្មានជំនាញ | | | | |
| សរុប | | | | |

- តម្រូវការធាតុចូលផលិតកម្ម ( វត្ថុធាតុដើម ) ប្រចាំឆ្នាំ : *បំពេញតាមទម្រង់ដូចមានចែងក្នុងឧបសម្ព័ន្ធភ្ជាប់មកជាមួយ*
- តម្រូវការថាមពល និង ទឹក :
  - ធ្យូងថ្ម ឬអុសប្រចាំឆ្នាំ :...................................ម$^3$/ឆ្នាំ, ឧស្ម័ន:......................................តោន/ឆ្នាំ
  - ប្រេងឥន្ធនៈ :...................................................តោន ឬលីត្រ/ឆ្នាំ
  - អគ្គិសនី ( អនុភាពតម្លើង) :...............................MW តម្រូវការប្រចាំឆ្នាំ :...................................KWH
  - ប្រើប្រាស់ទឹក :...................................................ម$^3$/ឆ្នាំ

*ខ.ការជ្រើសរើសរវាង* : ☐ ការលើកលែងពន្ធលើប្រាក់ចំណេញ និងការធានាលើការវិនិយោគ

☐ ការរំលោះពិសេស និង ការធានាលើការវិនិយោគ

☐ ការធានាលើការវិនិយោគ ( មិនទាមទារការលើកទឹកចិត្ត)

*( ក្នុងចំណោមជម្រើសទាំងបីនេះ អ្នកវិនិយោគមានសិទ្ធិទទួលបានតែមួយប៉ុណ្ណោះ )*

*គ.ព័ត៌មានស្តីពីបរិស្ថាន* :

- រូបភាពនៃការដឹកជញ្ជូនវត្ថុធាតុដើម និងផលិតផលសម្រេចចេញ-ចូល ទីតាំងវិនិយោគ :

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................ប៉ាន់ស្មានបរិមាណ :

សំណល់រាវ :............................. ម$^3$/ខែ សំណល់រឹង :........................ម$^3$ ឬ តោន/ ខែ

ឧស្ម័នដែលត្រូវបញ្ចេញ : ......................................................../ ថ្ងៃ

- តារាងបរិស្ថាននៃកំហាប់ក្នុង :

*ដំណើរការបញ្ចេញទឹកស្អុយ*

- pH:............ - អាម៉ូញាក់ Ammonia ($NH_3$)............
- នីត្រាតអាសូត Nitrate Nitrogen............ - លោហៈធ្ងន់ Heavy Metal............
- ផេណុល Phenol ($C_6H_5OH$)............ - ប្រេង និងខ្លាញ់ Oil and Grease............
- ភាពល្អក់ Turbidity............ - ភាពចម្លងអគ្គិសនី Conductivity............
- ចំនួនសរុបនៃសារធាតុរឹងដែលរលាយក្នុងទឹក ............
- ចំនួនសរុបនៃសារធាតុរឹងដែលរងកករចុះទៅក្នុងទឹក............

*ការបំភាយភាគល្អិតតូចៗនៃឧស្ម័នក្នុងខ្យល់*

- កាបូនម៉ូណូអុកស៊ីត Carbon mono-oxide............ - អាសូតឌីអុកស៊ីត Nitrogen dioxide............
- អុកស៊ីតស៊ុលហ្វួរិច Sulfur Oxide............ - អូហ្ស៊ូន Ozone............
- សំណរ Lead............

- ទីតាំងដែលប្រើសម្រាប់បោះបង់សំណល់រឹង បង្ហូរសំណល់រាវ និងការបញ្ចេញឧស្ម័ន

............
............
............
............

- ប្រភពដែលមានសម្លេង និងភាពរំញ័រខ្ពស់កើនឡើង

............
............
............
............

- ទំហំផ្ទៃដីដែលនឹងគ្របដណ្តប់ សម្អេងករណីចាក់ដីបំពេញ-ការឈូសឆាយ និងការរានដីថ្មី

............
............
............
............

- ស្ថានភាពស្នាក់នៅរបស់បុគ្គលិក-កម្មករ

- ផ្គត់ផ្គង់ទឹកស្អាត :............
- សុខភាព-សុវត្ថិភាព :............
- អនាម័យ :............
- ការគ្រប់គ្រងសំណល់រឹង :............

*ឃ. ព័ត៌មានស្តីពីពន្ធដារ*

បំពេញតាមទម្រង់បែបបទ ( Form ) ដូចមានឧបសម្ព័ន្ធជូនភ្ជាប់ ។

*ង. ព័ត៌មានស្តីពីលក្ខន្តិកៈ*

ជូនភ្ជាប់មកជាមួយនូវលក្ខន្តិកៈរបស់ក្រុមហ៊ុន រូបថត លិខិតថតចម្លងលិខិតឆ្លងដែន ឬ អត្តសញ្ញាណប័ណ្ណ របស់ម្ចាស់ភាគហ៊ុននិមួយៗ ។

**III- ការធានា : ក្នុងនាមម្ចាស់គម្រោងសូមធានាអះអាងថា**

- គម្រោងនេះមិនស្ថិតក្នុងបញ្ជីអវិជ្ជមាន ដូចមានចែងក្នុងឧបសម្ព័ន្ធទី ១ ផ្នែកទី១ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជាទេ ។
- ព័ត៌មានខាងលើនេះ គឺពិតជាត្រឹមត្រូវ ដោយមិនមានចេតនាក្លែងបន្លំឡើយ ។

ធ្វើនៅ............ថ្ងៃទី.........ខែ ...............ឆ្នាំ...............

ហត្ថលេខា

## ឧបសម្ព័ន្ធទី ២-១

នៃអនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី ២៧ ខែកញ្ញា ....ឆ្នាំ ២០០៥

ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

### តារាងតម្រូវការសម្ភារៈបរិក្ខារផលិតកម្ម

សម្រាប់គម្រោងវិនិយោគ..............................................................................

| ល.រ | រាយមុខទំនិញ | ឯកតា | បរិមាណ | តម្លៃឯកត្តា (USD) | តម្លៃសរុប (USD) | ប្រភព | |
|---|---|---|---|---|---|---|---|
| | | | | | | ក្នុងស្រុក | នាំចូល |
| | 1 | 2 | 3 | 4 | 5 | 6 | 7 |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | សរុប | | | | | | |

## ឧបសម្ព័ន្ធទី ២-២

នៃអនុក្រឹត្យលេខ១១១.អនក្រ.បក.ចុះថ្ងៃទី២៧.ខែកញ្ញា....ឆ្នាំ ២០០៥
ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

### តារាងតម្រូវការធាតុចូលផលិតកម្ម

សម្រាប់គម្រោងវិនិយោគ.......................................................................

| ល.រ | រាយមុខទំនិញ | ឯកតា | តម្លៃឯកត្តា (USD) | តម្រូវការប្រចាំឆ្នាំ | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | | ក្នុងស្រុក | | នាំចូល | | |
| | | | | បរិមាណ | តម្លៃសរុប (USD) | បរិមាណ | តម្លៃសរុប (USD) | |
| | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | សរុប | | | | | | | |

# ឧបសម្ព័ន្ធទី ៣

នៃអនុក្រឹត្យលេខ១១១.អនក្រ.បក.ចុះថ្ងៃទី២៧.ខែកញ្ញា....ឆ្នាំ ២០០៥ ស្ដីពីការអនុវត្តច្បាប់ស្ដីពីវិសោធនកម្ម នៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

(មាត្រា ៦.៣)

បញ្ជីមានលក្ខខណ្ឌ នៃគម្រោងវិនិយោគ អនុលោមទៅតាមច្បាប់ស្ដីពីវិនិយោគ និង អនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

ឈ្មោះ អ្នកវិនិយោគ :..........................................................................................................

អាស័យដ្ឋាន នៃអ្នកវិនិយោគ :.................................................................................................

ការរាយលម្អិតអំពីគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់

..........................................................................................................................................

..........................................................................................................................................

ឈ្មោះ អាស័យដ្ឋាន និង លេខទំនាក់ទំនងលម្អិត របស់បុគ្គលតំណាងអ្នកវិនិយោគនៅកម្ពុជា...................................

..........................................................................................................................................

លិខិតយល់ព្រម ការអនុញ្ញាត អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬ ការចុះបញ្ជីដែលជាតម្រូវការ សម្រាប់ឱ្យគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មានលក្ខណៈស្របច្បាប់ក្នុងការអនុវត្តន៍ និងក្រសួង នាយកដ្ឋាន អាជ្ញាធរ ឬភ្នាក់ងាររាជរដ្ឋាភិបាល ដែលទទួលបន្ទុកចេញលិខិតទាំងនេះ នៅពេលអ្នកដាក់ពាក្យសុំបានបំពេញស្របតាមលក្ខណៈវិនិច្ឆ័យនៃសមត្ថកិច្ចពាក់ព័ន្ធ ។

ការអនុម័ត....... ក្រសួង លក្ខណៈវិនិច្ឆ័យ

ជម្រើសរបស់អ្នកវិនិយោគផ្អែកតាមមាត្រា ៥.៥ នៃអនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ..........................................................................................................

ជម្រើសរបស់អ្នកវិនិយោគផ្អែកតាមមាត្រា ៥.៧ នៃអនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ..........................................................................................................

ការលើកទឹកចិត្ត និងការធានាលើការវិនិយោគ ដែលអ្នកវិនិយោគមានសិទ្ធិទទួល ប្រសិនបើវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរត្រូវបានចេញជូន រួមទាំងរយៈពេលលើកលែងពន្ធលើប្រាក់ចំណេញ តាមមាត្រា ១៤.១ នៃច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ..........................................................................

..........................................................................................................................................

..........................................................................................................................................

លក្ខខណ្ឌរបស់អ្នកវិនិយោគដែលនឹងដំណើរការគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់..............................

..........................................................................................................................................

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៧០...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញសេចក្តីសម្រេចលេខ ៣២ សសរ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលរបៀបរបបការងារ និងការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

## ជំពូកទី ១
## ការរៀបចំនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**មាត្រា១ .-**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាហៅកាត់ថា "ក.អ.ក" មានសមាសភាពដូចតទៅ៖

| | |
|---|---|
| ១- សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា | ប្រធាន |
| ២- ឯកឧត្តម ជិន ប៊ុនស៊ាន ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស | អនុប្រធាន |
| ៣- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ឬតំណាង | សមាជិក |
| ៤- រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬតំណាង | សមាជិក |
| ៥- រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឬតំណាង | សមាជិក |
| ៦- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬតំណាង | សមាជិក |
| ៧- រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬតំណាង | សមាជិក |
| ៨- រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ឬតំណាង | សមាជិក |
| ៩- រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឬតំណាង | សមាជិក |
| ១០- រដ្ឋមន្ត្រីក្រសួង រ៉ែ និងថាមពល ឬតំណាង | សមាជិក |
| ១១- រដ្ឋមន្ត្រីក្រសួងផែនការ ឬតំណាង | សមាជិក |
| ១២- រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឬតំណាង | សមាជិក |
| ១៣- រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬតំណាង | សមាជិក |
| ១៤- រដ្ឋមន្ត្រីក្រសួងបរិស្ថាន ឬតំណាង | សមាជិក |
| ១៥- រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ឬតំណាង | សមាជិក |
| ១៦- រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ឬតំណាង | សមាជិក |
| ១៧- រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ឬតំណាង | សមាជិក |
| ១៨- រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ឬតំណាង | សមាជិក |
| ១៩- រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ឬតំណាង | សមាជិក |
| ២០- រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬតំណាង | សមាជិក |
| ២១- អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា ឬតំណាង | សមាជិក |
| ២២- ប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ឬតំណាង | សមាជិក |
| ២៣- អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | លេខាធិការ |

រដ្ឋមន្ត្រី ឬប្រធានស្ថាប័នឯទៀត នៃរាជរដ្ឋាភិបាល ត្រូវចូលរួមក្នុងការប្រជុំរបស់ "ក.អ.ក " តាមការអញ្ជើញរបស់ប្រធាន។ រដ្ឋមន្ត្រី ឬប្រធានស្ថាប័ន ដែលផ្តល់សិទ្ធិឱ្យតំណាងរបស់ខ្លួន ត្រូវផ្តល់សិទ្ធិសម្រេចពេញលេញសម្រាប់ការពិភាក្សា និងការសម្រេច។

**មាត្រា២ .-**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានរចនាសម្ព័ន្ធដូចតទៅ៖

១- គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា ហៅកាត់ "គ.ជ.នា" ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គលេខាធិការមួយរូប។

២- គណៈកម្មាធិការវិនិយោគកម្ពុជា ហៅកាត់ "គ.វ.ក" ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គលេខាធិការមួយរូប។

៣- គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ហៅកាត់ "គ.ស.ព" ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គលេខាធិការមួយរូប។

៤- អគ្គលេខាធិការដ្ឋាននៃ "ក.អ.ក" ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គលេខាធិការ "ក.អ.ក"។

**មាត្រា៣ .-**

អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា និងអគ្គលេខាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា មានអគ្គលេខាធិការរងមួយចំនួនរៀងៗខ្លួនសម្រាប់ជាជំនួយការក្នុងការងារ។ អគ្គលេខាធិការរងនីមួយៗ ត្រូវបំពេញកិច្ចការតាមភារកិច្ចដែលអគ្គលេខាធិការប្រគល់ឱ្យ ក្រោយពីបានពិភាក្សាឯកភាពជាមួយគណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" ។ អគ្គលេខាធិការមួយរូបៗត្រូវបំពេញការងារដោយផ្លាស់ប្ដូរយោបល់ជាប្រចាំជាមួយអគ្គលេខាធិការរងរបស់ខ្លួន។

**មាត្រា៤ .-**

គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា មានរចនាសម្ព័ន្ធដូចតទៅ៖

១- ផ្នែកគោលនយោបាយ និងសម្របសម្រួលហិរញ្ញប្បទានសហប្រតិបត្តិការ

២- ផ្នែកឯកសារ និងគ្រប់គ្រងព័ត៌មាន

៣- ផ្នែកគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការទ្វេភាគី ជាមួយបណ្ដាប្រទេសនៅទ្វីបអាស៊ី និងអូសេអានី

៤- ផ្នែកគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការទ្វេភាគី ជាមួយបណ្ដាប្រទេសនៅទ្វីបអឺរ៉ុប និងសហគមន៍អឺរ៉ុប និងទ្វីបអាមេរិក

៥- ផ្នែកគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការនៃស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ (ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិ។ល។)

៦- ផ្នែកគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការរបស់កម្មវិធីអភិវឌ្ឍន៍របស់សហប្រជាជាតិ និងបណ្ដាស្ថាប័ននៃអង្គការរបស់សហប្រជាជាតិ

៧- ផ្នែកគ្រប់គ្រងសម្របសម្រួល និងទំនាក់ទំនងជាមួយអង្គការមិនមែនរដ្ឋាភិបាល

៨- ផ្នែកវិភាគគម្រោងសហប្រតិបត្តិការ

៩- ផ្នែកភាពជាដៃគូ និងសុខដុមភាវូបនីយកម្មនៃកិច្ចសហប្រតិបត្តិការ

១០-ផ្នែករដ្ឋបាល។

**មាត្រា៥ .–**

គណៈកម្មាធិការវិនិយោគកម្ពុជា មានរចនាសម្ព័ន្ធដូចតទៅ៖

១- ផ្នែកទំនាក់ទំនងសាធារណៈ និងការជំរុញគម្រោងវិនិយោគឯកជន

២- ផ្នែកវិភាគគម្រោង និងការលើកទឹកចិត្ត

៣- ផ្នែកវាយតម្លៃខាងបរិស្ថាន

៤- ផ្នែកសម្របសម្រួលកិច្ចការអន្តរក្រសួង

៥- ផ្នែកវិភាគយុទ្ធសាស្ត្រនៃការវិនិយោគឯកជន

៦- ផ្នែកនីតិកម្ម និងច្បាប់វិនិយោគ

៧- ផ្នែកត្រួតពិនិត្យ និងតាមដានគម្រោងវិនិយោគ

៨- ផ្នែករដ្ឋបាល។

**មាត្រា៦ .–**

គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា មានរចនាសម្ព័ន្ធដូចតទៅ៖

១- ផ្នែកគោលនយោបាយ និងផែនការ

២- ផ្នែកប្រតិបត្តិការ និងគ្រប់គ្រង

៣- ផ្នែកចុះបញ្ជី និងសិក្សាគម្រោង

៤- ផ្នែករដ្ឋបាល។

**មាត្រា៧ .–**

អគ្គលេខាធិការដ្ឋាននៃ "ក.អ.ក" រួមមាន "ផ្នែកគាំទ្រ" ចំនួន ៤៖

១- ផ្នែកនីតិកម្ម និងដោះស្រាយវិវាទ

២- ផ្នែកផែនការនីយកម្មយុទ្ធសាស្ត្រ

៣- ផ្នែកគ្រប់គ្រងមន្ត្រី និងបុគ្គលិក

៤- ផ្នែកហិរញ្ញវត្ថុ និងរដ្ឋបាល។

**មាត្រា៨ .–**

ផ្នែក និងផ្នែកគាំទ្រនីមួយៗ មានថ្នាក់ស្មើនឹងនាយកដ្ឋាន ហើយដឹកនាំដោយប្រធានមួយរូប ព្រមទាំងមានអនុប្រធានមួយរូប ឬច្រើនរូបជាជំនួយការ។

**មាត្រា៩ .–**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានគណៈកម្មាធិការប្រតិបត្តិសម្រាប់ដឹកនាំការងារប្រចាំថ្ងៃ។ គណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានសមាសភាពដូចតទៅ៖

១- ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

២- អនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

៣- អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

៤- អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា

៥- អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា

៦- អគ្គលេខាធិការគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា។

## ជំពូកទី ២
## សមត្ថកិច្ច និងភារកិច្ចរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**មាត្រា១០ .-**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាស្ថាប័នប្រតិបត្តិរបស់រាជរដ្ឋាភិបាល ហើយមានភារកិច្ចដូចតទៅ៖

១- ជាសេនាធិការ និងជា "ច្រកចេញ-ចូលតែមួយ" របស់រាជរដ្ឋាភិបាលក្នុងកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ និងការវិនិយោគសាធារណៈ ការវិនិយោគឯកជន និងការបង្កើតនិងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស។

២- ទាក់ទងជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ ក្នុងគោលបំណងធ្វើឱ្យគេយល់ជ្រួតជ្រាបអំពីយុទ្ធសាស្ត្រ និងបណ្តាអាទិភាពរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍន៍ប្រទេស ដើម្បីសម្របសម្រួលការទទួល និងការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការឱ្យមានប្រសិទ្ធភាព ស្របតាមសេចក្តីត្រូវការ និងអាទិភាពរបស់ប្រទេសជាតិ ដោយប្រកាន់តួនាទីជាម្ចាស់ សម្រាប់សម្រេចលទ្ធផលជូនប្រទេសជាតិ។

៣- សម្របសម្រួលការងាររវាងក្រសួង និងស្ថាប័ននានា ដែលមានការពាក់ព័ន្ធជាមួយនឹងដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងជាមួយអ្នកវិនិយោគ។

៤- តម្រង់ទិសក្នុងការបែងចែក និងក្នុងការប្រើប្រាស់ធនធានសាធារណៈ និងធនធានឯកជនក្នុងកិច្ចការអភិវឌ្ឍន៍កម្ពុជា។

៥- បង្កលក្ខណៈងាយស្រួល និងសម្រួលកិច្ចការដល់ដៃគូអភិវឌ្ឍន៍ និងដល់អ្នកវិនិយោគ។

៦- ពិនិត្យ និងសម្រេចរាល់កិច្ចការនីតិសម្បទានិងអភិវឌ្ឍន៍ និងគម្រោងវិនិយោគរបស់ដៃគូអភិវឌ្ឍន៍ គម្រោងវិនិយោគឯកជន និងការបង្កើតនិងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស។

**មាត្រា១១ .-**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវសុំយោបល់សម្រេចពីគណៈរដ្ឋមន្ត្រីលើគម្រោងវិនិយោគទាំងឡាយដែលមានលក្ខណៈសម្បត្តិណាមួយដូចតទៅ៖

១- ទំហំទុនវិនិយោគសរុបចាប់ពី ៥០ លានដុល្លារអាមេរិក ឡើងទៅ

២- មានវេទយិតភាពខាងនយោបាយ

៣- ការរុករក និងការធ្វើអាជីវកម្មរ៉ែ និងធនធានធម្មជាតិ

៤- អាចបង្កគ្រោះថ្នាក់ដល់បរិស្ថាន

៥- គម្រោងយុទ្ធសាស្ត្ររយៈពេលវែង

៦- គម្រោងសម្បទាននៃវិស័យហេដ្ឋារចនាសម្ព័ន្ធ។

**មាត្រា១២ .-**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវទទួលខុសត្រូវចំពោះមុខគណៈរដ្ឋមន្ត្រី អំពីសកម្មភាពរបស់ខ្លួន។

**មាត្រា១៣ .-**

ក្នុងកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានភារកិច្ចដូចតទៅ៖

១- បំពេញតួនាទីជា "ច្រកចេញ-ចូលតែមួយ" និងជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការទាក់ទងជាមួយនឹងដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល ដែលផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការឥតសំណងដល់កម្ពុជា និងធ្វើជាចំណុចប្រមូលផ្តុំ ក្នុងការទាក់ទងរវាងស្ថាប័ននានានៃរាជរដ្ឋាភិបាល ដើម្បីសម្របសម្រួលការទទួល និង/ឬការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការទាំងនេះ។

២- រៀបចំ និងអនុវត្តយុទ្ធសាស្ត្រស្តីពីការកៀរគរ និងការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ដើម្បីពង្រឹងភាពជាម្ចាស់ និងភាពដឹកនាំរបស់រាជរដ្ឋាភិបាលក្នុងកិច្ចអភិវឌ្ឍន៍ ព្រមទាំងពង្រឹងភាពជាដៃគូជាមួយសហគមន៍ដៃគូអភិវឌ្ឍន៍។

៣- កៀរគរ និងវិភាជន៍ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់អនុវត្តបណ្តាគោលដៅអាទិភាពដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការអភិវឌ្ឍន៍តាមវិស័យ។

៤- ដឹកនាំផ្ទាល់កិច្ចការដែលពាក់ព័ន្ធនឹងការបង្កើនប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃហិរញ្ញប្បទានសហប្រតិបត្តិការ។

៥- ផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃដំណើរការរបស់ក្រុមការងារបច្ចេកទេសចម្រុះ។

៦- រៀបចំឯកសារចាំបាច់នានាសម្រាប់កិច្ចប្រជុំកម្រិតគោលនយោបាយជាមួយដៃគូអភិវឌ្ឍន៍ ដូចជា គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ និង "វេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា" ជាដើម ដោយសហការជាមួយបណ្តាក្រសួង និងស្ថាប័នដែលមានការពាក់ព័ន្ធ។

៧- ចូលរួមរៀបចំផែនការសេដ្ឋកិច្ច សង្គមកិច្ច និងផែនការតាមវិស័យសម្រាប់អភិវឌ្ឍន៍កម្ពុជា។

៨- ចូលរួមគ្រប់គ្រងកិច្ចការវិនិយោគសាធារណៈ ដោយសហការយ៉ាងជិតស្និទ្ធជាមួយនឹងក្រសួង និងស្ថាប័នទាំងឡាយដែលមានការពាក់ព័ន្ធ។ ការងារនេះពាក់ព័ន្ធសំខាន់ទៅនឹងការសម្របសម្រួល និងការតម្រង់ទិសក្នុងការបែងចែក និងការប្រើប្រាស់ធនធាននៅក្នុងប្រទេស និងធនធានដែលបានមកពីក្រៅប្រទេសដើម្បីកិច្ចការស្តារ និងអភិវឌ្ឍន៍កម្ពុជា។

៩- តាមការប្រគល់សិទ្ធិពីនាយករដ្ឋមន្ត្រី ចុះហត្ថលេខាតាងនាមរាជរដ្ឋាភិបាលជាមួយនឹងដៃគូអភិវឌ្ឍន៍ ដើម្បីទទួល និង/ឬបែងចែកហិរញ្ញប្បទានទាំងនោះ។

១០-ធ្វើរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំជូនរាជរដ្ឋាភិបាល ដើម្បីរាជរដ្ឋាភិបាលពិនិត្យ និងលើកឡើងនូវវិធានការចាំបាច់សម្រាប់កែលម្អ និងតម្រង់ទិសការងារនីតិសម្បទា និងអភិវឌ្ឍន៍។

**មាត្រា១៤ .-**

ក្នុងការគ្រប់គ្រងកិច្ចការវិនិយោគសាធារណៈ ទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលមានការពាក់ព័ន្ធទៅនឹងបណ្ដាក្រសួង និងស្ថាប័ននានានៃរាជរដ្ឋាភិបាល ត្រូវកំណត់ដូចតទៅ៖

១- "ក.អ.ក" ជាអ្នកសម្របសម្រួលក្នុងការកំណត់លំដាប់អាទិភាពនៃកម្មវិធី និងគម្រោងវិនិយោគរបស់ដៃគូអភិវឌ្ឍន៍សម្រាប់រយៈពេលមធ្យម និងរយៈពេលមួយឆ្នាំ។

២- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាបង្អួចការទូតផ្លូវការ។

៣- ក្រសួងផែនការ សហការជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធ ជាអ្នកដឹកនាំក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ៥ឆ្នាំ និងកម្មវិធីវិនិយោគសាធារណៈ។

៤- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាអ្នករៀបចំការព្យាករណ៍ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចរយៈពេលមធ្យម ជាអ្នករៀបចំថវិកាសម្រាប់អនុវត្តកម្មវិធីវិនិយោគសាធារណៈ និងជាអ្នកត្រួតពិនិត្យការប្រើប្រាស់ហិរញ្ញប្បទាន ព្រមទាំងទទួលបន្ទុកចរចារ និងគ្រប់គ្រងដោយផ្ទាល់នូវហិរញ្ញប្បទានជាការខ្ចី និងជំនួយបច្ចេកទេសដែលមានការពាក់ព័ន្ធ។

៥- ក្រសួងជំនាញជាអ្នករៀបចំផែនការអភិវឌ្ឍន៍ និងគម្រោងវិនិយោគសាធារណៈតាមវិស័យដោយសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងផែនការ, ជាមួយ "ក.អ.ក" និងជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងជាអ្នកអនុវត្តកម្មវិធី និងគម្រោងវិនិយោគសាធារណៈដែលមានការពាក់ព័ន្ធទៅនឹងសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា១៥ .-**

ក្រសួង និងស្ថាប័ន ត្រូវធ្វើការងារ និងបំពេញកាតព្វកិច្ចរបស់ខ្លួន ខាងការវិនិយោគសាធារណៈដោយសម្របសម្រួលការងារជាមួយគ្នាតាមរយៈយន្តការ "ច្រកចេញ-ចូលតែមួយ"។

**មាត្រា១៦ .-**

ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង និងស្ថាប័ន ត្រូវតាមដានការអនុវត្តកម្មវិធី និង/ឬគម្រោងស្របតាមសមត្ថកិច្ចរៀងៗខ្លួនដោយសម្របសម្រួលការងារជាមួយគ្នាតាមរយៈយន្តការ "ច្រកចេញ-ចូលតែមួយ។

**មាត្រា១៧ .-**

ក្នុងកិច្ចការវិនិយោគឯកជន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានភារកិច្ចដូចតទៅ៖

១- បំពេញតួនាទីជាយន្តការ "ច្រកចេញ-ចូលតែមួយ" និងជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការពិនិត្យ និងសម្រេចលើការវិនិយោគនានាដូចបានកំណត់នៅក្នុងមាត្រា៣ នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

២- ធ្វើការវិភាគ "ការប្រណាំងប្រជែងដណ្តើមឈ្នះ" លើទីផ្សារអន្តរជាតិសម្រាប់ប្រទេសកម្ពុជា លើកឡើងនូវទស្សនៈអនាគតអំពីកិច្ចការវិនិយោគឯកជនសម្រាប់ប្រទេសកម្ពុជា និងសម្រេចឱ្យបាននូវទស្សនៈនេះដោយធ្វើឱ្យប្រទេសកម្ពុជាក្លាយទៅជា "សាជីវកម្មកម្ពុជា"។ សហការ

ជាមួយក្រសួង និងស្ថាប័នដែលមានការពាក់ព័ន្ធ ដើម្បីរៀបចំយុទ្ធសាស្ត្រនៃការវិនិយោគឯកជន និងដើម្បីលើកគម្រោងនានាសម្រាប់ការវិនិយោគឯកជន។

៣- ផ្សព្វផ្សាយអំពីគម្រោងនានាសម្រាប់ការវិនិយោគឯកជន ដែលរាជរដ្ឋាភិបាលបានលើកឡើង និងផ្តល់គម្រោងទាំងនោះទៅឱ្យអ្នកវិនិយោគ តាមនីតិវិធីដែលមានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុងនៃ "ក.អ.ក"។

៤- សម្របសម្រួលការគ្រប់គ្រងគម្រោងសម្បទាននៃវិស័យហេដ្ឋារចនាសម្ព័ន្ធ។

៥- លើកគម្រោង និងផ្តល់យោបល់ជូនរាជរដ្ឋាភិបាលស្តីអំពីការរៀបចំ និងការកែលម្អច្បាប់ បទប្បញ្ញត្តិ និងលិខិតបទដ្ឋានផ្សេងៗ ដែលទាក់ទិននឹងការវិនិយោគឯកជន ក្នុងគោលបំណងបង្កើតលក្ខខណ្ឌដែលអនុគ្រោះ និងដែលលើកទឹកចិត្តដល់អ្នកវិនិយោគ ដើម្បីបង្កើនប្រសិទ្ធភាពការងារក្នុងវិស័យវិនិយោគឯកជន។

៦- រៀបចំចងក្រងឯកសារ និងលិខិតបទដ្ឋាននានាដែលទាក់ទិនទៅនឹងកិច្ចការវិនិយោគឯកជនសម្រាប់ផ្សព្វផ្សាយនៅក្នុងប្រទេស និងក្រៅប្រទេស។

៧- ធ្វើរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងលើកឡើងនូវវិធានការចាំបាច់សម្រាប់កែលម្អ និងតម្រង់ទិសការងារវិនិយោគឯកជន។

**មាត្រា១៨ .-**

ទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងការគ្រប់គ្រងកិច្ចការវិនិយោគឯកជនដែលមានការពាក់ព័ន្ធទៅនឹងបណ្តាក្រសួង និងស្ថាប័ននានានៃរាជរដ្ឋាភិបាល ត្រូវកំណត់ដូចតទៅ៖

១- "ក.អ.ក" បំពេញតួនាទីជា "ច្រកចេញ-ចូលតែមួយ" របស់រាជរដ្ឋាភិបាលក្នុងការត្រួតពិនិត្យ និងសម្រេចលើគម្រោងវិនិយោគឯកជននានា រាប់ទាំងសកម្មភាពរុករក-ស្រាវជ្រាវ-ការធ្វើអាជីវកម្មប្រេងកាត-ឧស្ម័ន និងធនធានធម្មជាតិផ្សេងៗ ទោះបីគម្រោងខ្លះមិនត្រូវបានទទួលការលើកទឹកចិត្តក៏ដោយ។

២- ក្រសួង និងស្ថាប័ននានាដែលមានការពាក់ព័ន្ធចូលរួមផ្តល់យោបល់ក្នុងការពិនិត្យ និងសម្រេចលើគម្រោងវិនិយោគឯកជននានា ក្នុងក្របខ័ណ្ឌនៃយន្តការ "ច្រកចេញ-ចូលតែមួយ"។

**មាត្រា១៩ .-**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រសួង-ស្ថាប័ននានាដែលមានការពាក់ព័ន្ធ ធ្វើការងារ និងបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការគ្រប់គ្រងការវិនិយោគឯកជន ដោយសម្របសម្រួលការងារជាមួយគ្នាតាមរយៈយន្តការ "ច្រកចេញ-ចូលតែមួយ"។

**មាត្រា២០ .-**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រួមជាមួយទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងផែនការ ក្រសួងពាណិជ្ជកម្ម និងក្រសួង ឬស្ថាប័នដែលមានការពាក់ព័ន្ធជាអ្នកតាមដានការអនុវត្តគម្រោងវិនិយោគឯកជនដែល "ក.អ.ក" បានផ្តល់ការអនុញ្ញាតហើយ ដោយសម្របសម្រួលការងារជាមួយគ្នាតាមរយៈយន្តការ "ច្រកចេញ-ចូលតែមួយ"។

**មាត្រា២១ .-**

ក្នុងកិច្ចការតំបន់សេដ្ឋកិច្ចពិសេស ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានភារកិច្ចដូចតទៅ៖

១- បំពេញតួនាទីជាយន្តការ "ច្រកចេញ-ចូលតែមួយ" និងជាសេនាធិការរបស់រាជរដ្ឋាភិបាល ក្នុងការពិនិត្យ និងសម្រេចលើសំណើសុំបង្កើតតំបន់សេដ្ឋកិច្ចពិសេស ទាំងតាមរូបភាពរដ្ឋ ឯកជនចម្រុះរដ្ឋ និងឯកជននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

២- ធ្វើការវិភាគ លើកផែនការយុទ្ធសាស្ត្រ ដើម្បីកំណត់ពីភូមិសាស្ត្រសំខាន់ៗ ដោយសហការជាមួយក្រសួង និងស្ថាប័នដែលមានការពាក់ព័ន្ធ ដើម្បីបង្កើតនូវតំបន់សេដ្ឋកិច្ចពិសេសនៅក្នុងប្រទេស និងលើកឡើងនូវទស្សនៈអនាគតអំពីកិច្ចការតំបន់សេដ្ឋកិច្ចពិសេស សម្រាប់ទាក់ទាញអ្នកអភិវឌ្ឍន៍តំបន់ និងអ្នកវិនិយោគក្នុងតំបន់ និងសម្រេចឱ្យបាននូវទស្សនៈនេះ ដោយធ្វើឱ្យប្រទេសកម្ពុជាក្លាយទៅជាតំបន់សាជីវកម្មទំនើបនាពេលអនាគត។

៣- ផ្សព្វផ្សាយអំពីគម្រោងនានាសម្រាប់ការវិនិយោគតំបន់សេដ្ឋកិច្ចពិសេស ដែលរាជរដ្ឋាភិបាលបានលើកឡើង និងផ្តល់គម្រោងទាំងនោះទៅឱ្យអ្នកអភិវឌ្ឍន៍តំបន់តាមគ្រប់ប្រព័ន្ធឃោសនានានាដែលមានប្រសិទ្ធភាព និងឆាប់រហ័ស។

៤- ផ្តួចផ្តើម និងសម្របសម្រួលការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសដែលជាអាទិភាពរបស់រាជ-រដ្ឋាភិបាល។

៥- លើកគម្រោង និងផ្តល់យោបល់ជូនរាជរដ្ឋាភិបាលស្តីពីការរៀបចំ និងការកែលម្អច្បាប់ បទប្បញ្ញត្តិនានា និងដែលទាក់ទិននឹងការវិនិយោគតំបន់សេដ្ឋកិច្ចពិសេសក្នុងគោលបំណងបង្កើតលក្ខខណ្ឌដែលអនុគ្រោះ និងដែលលើកទឹកចិត្តដល់អ្នកអភិវឌ្ឍន៍តំបន់ ដើម្បីបង្កើនប្រសិទ្ធភាពការងារក្នុងវិស័យវិនិយោគ។

៦- ចាត់តាំងការគ្រប់គ្រង ផ្តល់ការលើកទឹកចិត្ត និងការធានាលើការវិនិយោគ ការដោះស្រាយសំណូមពរនានា និងការធ្វើអធិការកិច្ចចំពោះតំបន់សេដ្ឋកិច្ចពិសេស។

៧- ចាត់បញ្ជូនមន្ត្រី ដើម្បីចូលរួមប្រចាំការអចិន្ត្រៃយ៍នៅតាមតំបន់តាមការចាំបាច់ និងតាមតម្រូវការ។

៨- ធ្វើរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងលើកឡើងនូវវិធានការចាំបាច់សម្រាប់កែលម្អបរិស្ថានវិនិយោគនៃតំបន់សេដ្ឋកិច្ចពិសេស និងតម្រង់ទិសការងារវិនិយោគតំបន់។

**មាត្រា២២ .-**

ទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងការគ្រប់គ្រងកិច្ចការតំបន់សេដ្ឋកិច្ចពិសេសដែលមានការពាក់ព័ន្ធទៅនឹងបណ្តាក្រសួង និងស្ថាប័ននានានៃរាជរដ្ឋាភិបាល ត្រូវកំណត់ដូចតទៅ៖

១- "ក.អ.ក" បំពេញតួនាទីជា "ច្រកចេញ-ចូលតែមួយ" របស់រាជរដ្ឋាភិបាល ក្នុងការត្រួតពិនិត្យ និងសម្រេចចុះបញ្ជីលើសំណើបង្កើតតំបន់សេដ្ឋកិច្ចពិសេស។

២- ក្រសួង និងស្ថាប័ននានាដែលមានការពាក់ព័ន្ធចូលរួមផ្ដល់យោបល់ក្នុងការពិនិត្យ និងសម្រេចលើគម្រោងបង្កើតតំបន់សេដ្ឋកិច្ចពិសេសក្នុងក្របខ័ណ្ឌនៃយន្តការ "ច្រកចេញ-ចូលតែមួយ"។

៣- "ក.អ.ក" សហការជាមួយក្រសួង និងស្ថាប័នដែលមានការពាក់ព័ន្ធ ដើម្បីរៀបចំបង្កើតរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសប្រចាំតំបន់នីមួយៗ និងណែនាំការចេញលិខិតអនុញ្ញាតនានារបស់រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ជូនដល់អ្នកវិនិយោគក្នុងតំបន់នៅនឹងកន្លែងនៃតំបន់នីមួយៗ ឱ្យបានឆាប់រហ័ស និងមានប្រសិទ្ធភាព។

## ជំពូកទី ៣
## ការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**មាត្រា២៣ .-**

ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានតួនាទីដូចតទៅ៖

១- ទទួលខុសត្រូវរួមលើការងាររបស់ "ក.អ.ក"

២- ធ្វើជាអធិបតីនៃអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" និងនៃអង្គប្រជុំពេញអង្គរបស់ "ក.អ.ក"

៣- កោះប្រជុំវិសាមញ្ញរបស់គណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" និងប្រជុំវិសាមញ្ញពេញអង្គរបស់ "ក.អ.ក"

៤- ទទួលខុសត្រូវក្នុងការគ្រប់គ្រងថវិការបស់ "ក.អ.ក"។

**មាត្រា២៤ .-**

នាយករដ្ឋមន្ត្រីដឹកនាំផ្ទាល់លើការកំណត់គោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេស និងការអនុវត្ត និងតាមដានគោលនយោបាយ និងយុទ្ធសាស្ត្រនេះ។

**មាត្រា២៥ .-**

អនុប្រធាននៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានតួនាទីដូចតទៅ៖

១- ទទួលខុសត្រូវរួមលើការងាររបស់ "ក.អ.ក" ក្នុងករណីដែលប្រធាន "ក.អ.ក" អវត្តមាន។

២- ទទួលខុសត្រូវក្នុងការដឹកនាំ និងគ្រប់គ្រងការងារប្រចាំថ្ងៃរបស់ "ក.អ.ក"។

៣- ទទួលបន្ទុកលើក និងស្នើគោលនយោបាយ និងយុទ្ធសាស្ត្រ ស្ដីពីការកៀរគរ និងគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ ដោយសម្របសម្រួលជាមួយប្រធានស្ថាប័នដែលមានការពាក់ព័ន្ធ។

៤- ទទួលបន្ទុកសម្របសម្រួលការងារភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍ជាមួយតួអង្គអភិវឌ្ឍន៍ដោយសហការជិតស្និទ្ធជាមួយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងប្រធានស្ថាប័នពាក់ព័ន្ធផ្សេងទៀត។

៥- ទទួលបន្ទុកការងាររបស់គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា ដែលផ្ដោតជាសំខាន់ទៅលើការសម្របសម្រួលលើកិច្ចការវិនិយោគសាធារណៈ និងកិច្ចការកៀរគរ និងសម្របសម្រួលហិរញ្ញប្បទានសហប្រតិបត្តិការ នៅក្នុងដែនសមត្ថកិច្ចនៃគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា។

៦- ទទួលបន្ទុកលើក និងស្នើគោលនយោបាយ, យុទ្ធសាស្ត្រ និងផែនការយុទ្ធសាស្ត្រ ជំរុញការវិនិយោគឯកជន និងកិច្ចការដឹកនាំ អនុវត្ត និងតាមដានការអនុវត្តគោលនយោបាយការងារអភិវឌ្ឍន៍វិស័យឯកជន យុទ្ធសាស្ត្រ និងផែនការយុទ្ធសាស្ត្រនេះ។

៧- ធ្វើជាអធិបតីនៃអង្គប្រជុំរបស់យន្តការ "ច្រកចេញ-ចូលតែមួយ" ដែលរៀបចំឡើងដោយ "គ.វ.ក" ដើម្បីពិនិត្យសម្រេចក្នុងយន្តការ "ច្រកចេញ-ចូលតែមួយ" លើការងារវិនិយោគឯកជន។

៨- ទទួលបន្ទុកពិនិត្យ និងសម្រេចលើគម្រោងវិនិយោគឯកជនដែលមានលក្ខណៈសាមញ្ញ ដូចជារោងចក្រកាត់ដេរ រោងចក្រស្បែកជើង និងឧស្សាហកម្មគាំទ្រជាដើម ព្រមទាំងបណ្ដាគម្រោងដែលមិនទាមទារការលើកទឹកចិត្តផងដែរ។

៩- ទទួលបន្ទុកកិច្ចការវិនិយោគផ្សេងៗ នៅក្នុងក្របខ័ណ្ឌអាស៊ានដែលជាប្រការស្របគ្នាទៅនឹងការរៀបចំរបស់អាស៊ាន។

១០-ទទួលបន្ទុកក្នុងការសម្របសម្រួលការងារអន្តរក្រសួងរវាង "ក.អ.ក" ជាមួយនឹងក្រសួងស្ថាប័ននានានៃរាជរដ្ឋាភិបាល។

១១-បំពេញការងារដទៃទៀតដែលប្រធាន "ក.អ.ក" ប្រគល់សិទ្ធិ។

**មាត្រា២៦ .-**

អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានតួនាទីដូចតទៅ៖

១- គ្រប់គ្រងការងាររបស់អគ្គលេខាធិការដ្ឋាននៃ "ក.អ.ក"។

២- ទទួលបន្ទុកសម្របសម្រួល និងតាមដានការងាររបស់គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា ការងាររបស់គណៈកម្មាធិការវិនិយោគកម្ពុជា និងការងាររបស់គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេស។

៣- ធ្វើជាសេនាធិការបច្ចេកទេសឱ្យ "ក.អ.ក" ក្នុងការដឹកនាំ អនុវត្ត និងតាមដានការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រពាណិជ្ជកម្ម ឧស្សាហកម្ម វិនិយោគឯកជន និងការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស។

៤- រៀបចំកម្មវិធីការងាររបស់ "ក.អ.ក" និងរៀបចំរបៀបវារៈ និងសំណុំឯកសារផ្សេងៗ សម្រាប់អង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" និងអង្គប្រជុំពេញអង្គរបស់ "ក.អ.ក" ។

៥- សម្របសម្រួលការរៀបចំរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំអំពីការងារនីតិសម្បទា និងអភិវឌ្ឍន៍ ការងារវិនិយោគឯកជន និងការងារតំបន់សេដ្ឋកិច្ចពិសេស ដើម្បីដាក់ជូន គណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" ពិនិត្យ និងសម្រេច មុននឹងធ្វើជូនរាជរដ្ឋាភិបាល។

៦- ចូលរួមក្នុងអង្គប្រជុំរបស់យន្តការ "ច្រកចេញ-ចូលតែមួយ" ដើម្បីពិនិត្យ និងសម្រេចលើកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ និងការវិនិយោគឯកជន ។

៧- ទទួលបន្ទុកជាអគ្គលេខាធិការនៃ "វេទិការាជរដ្ឋាភិបាល និងផ្នែកឯកជន"។

៨- បំពេញការងារដទៃទៀតដែលប្រធាន "ក.អ.ក" ឬអនុប្រធាន "ក.អ.ក" ប្រគល់សិទ្ធិ។

**មាត្រា២៧ .-**

អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា មានតួនាទីដូចតទៅ៖

១- គ្រប់គ្រងការងាររបស់ "គ.ជ.នា"។

២- រៀបចំរបៀបវារៈ និងឯកសារសម្រាប់អង្គប្រជុំនៃយន្តការ "ច្រកចេញ-ចូលតែមួយ" ដែលមានការទាក់ទងទៅនឹងកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ និងចូលរួមក្នុងអង្គប្រជុំរបស់យន្តការនេះ ដើម្បីពិនិត្យ និងសម្រេចលើកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍។

៣- រៀបចំ និងតាមដានការអនុវត្តយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ដោយឈរលើគោលការណ៍នៃភាពជាម្ចាស់ និងជាអ្នកដឹកនាំរបស់ព្រះរាជាណាចក្រកម្ពុជា ដើម្បីលើកកម្ពស់ប្រសិទ្ធភាព ក្នុងការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការ។

៤- ទទួលបន្ទុកជាអគ្គលេខាធិការនៃ "វេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា" និងយន្តការពិគ្រោះយោបល់ដទៃទៀត។

៥- ដឹកនាំកិច្ចពិគ្រោះយោបល់ទ្វេភាគីជាមួយដៃគូអភិវឌ្ឍន៍ និងចុះហត្ថលេខាលើកម្មវិធីសហប្រតិបត្តិការឥតសំណងទ្វេភាគីជាមួយដៃគូអភិវឌ្ឍន៍។

៦- ធ្វើការតាមដានលើការអនុវត្តកម្មវិធី និងគម្រោងវិនិយោគសាធារណៈផ្សេងៗ ដោយសហការជាមួយបណ្តាក្រសួង និងស្ថាប័នជំនាញដែលពាក់ព័ន្ធ ហើយធ្វើរបាយការណ៍បូកសរុប និងលើកយោបល់ជូនគណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" ដើម្បីពិនិត្យ និងចាត់វិធានការកែតម្រូវ ក្នុងករណីចាំបាច់។

៧- ជួយដល់អគ្គលេខាធិការ "ក.អ.ក" ក្នុងការរៀបចំសំណុំឯកសារចាំបាច់ដែលមានការទាក់ទងទៅនឹងកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ សម្រាប់អង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" និងសម្រាប់អង្គប្រជុំពេញអង្គរបស់ "ក.អ.ក"។

៨- ជួយដល់អគ្គលេខាធិការ "ក.អ.ក" ក្នុងការរៀបចំរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំលើផ្នែកការងារពាក់ព័ន្ធទៅនឹងកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ ដើម្បីដាក់ជូនគណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" ពិនិត្យ និងសម្រេចមុននឹងធ្វើជូនរាជរដ្ឋាភិបាល។

៩- បំពេញការងារដទៃទៀតដែលទាក់ទិនទៅនឹងកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ ដែលប្រធាន ឬអនុប្រធាន "ក.អ.ក" ប្រគល់សិទ្ធិ។

**មាត្រា២៨ .-**

អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា មានតួនាទីដូចតទៅ៖

១- គ្រប់គ្រងការងាររបស់ "គ.វ.ក"។

២- រៀបចំរបៀបវារៈ និងឯកសារសម្រាប់អង្គប្រជុំយន្តការ "ច្រកចេញ-ចូលតែមួយ" ដែលមានការទាក់ទងទៅនឹងកិច្ចការវិនិយោគឯកជន និងចូលរួមក្នុងអង្គប្រជុំរបស់យន្តការនេះ ដើម្បីពិនិត្យ និងសម្រេចលើកិច្ចការវិនិយោគឯកជន។

៣- ជួយដល់អគ្គលេខាធិការ "ក.អ.ក" ក្នុងការរៀបចំសំណុំឯកសារចាំបាច់ដែលមានការទាក់ទិនទៅនឹងកិច្ចការវិនិយោគឯកជន សម្រាប់អង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" និងសម្រាប់អង្គប្រជុំពេញអង្គរបស់ "ក.អ.ក"។

៤- ធ្វើការតាមដានលើការអនុវត្តកម្មវិធី និងគម្រោងវិនិយោគឯកជនផ្សេងៗ ដោយសហការជាមួយបណ្តាក្រសួង និងស្ថាប័នជំនាញ ដែលមានការពាក់ព័ន្ធ ហើយធ្វើរបាយការណ៍បូកសរុប និងលើកយោបល់ជូនគណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" ដើម្បីពិនិត្យ និងចាត់វិធានការកែតម្រូវ ក្នុងករណីចាំបាច់។

៥- ជួយដល់អគ្គលេខាធិការ "ក.អ.ក" ក្នុងការរៀបចំរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំលើផ្នែកការងារពាក់ព័ន្ធទៅនឹងកិច្ចការវិនិយោគឯកជន ដើម្បីដាក់ជូនគណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" ពិនិត្យ និងសម្រេច មុននឹងធ្វើជូនរាជរដ្ឋាភិបាល។

៦- ទទួលការងារនៃតំបន់វិនិយោគអាស៊ាន (AIA) ដោយសម្របសម្រួលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ។

៧- បំពេញការងារដទៃទៀតដែលទាក់ទិនទៅនឹងកិច្ចការវិនិយោគឯកជន ដែលប្រធាន ឬអនុប្រធាន "ក.អ.ក" ប្រគល់សិទ្ធិ។

**មាត្រា២៩ .-**

អគ្គលេខាធិការគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា មានតួនាទីដូចតទៅ៖

១- គ្រប់គ្រងការងាររបស់ "គ.ស.ព"។

២- រៀបចំរបៀបវារៈ និងឯកសារសម្រាប់អង្គប្រជុំយន្តការ "ច្រកចេញ-ចូលតែមួយ" ដែលមានការទាក់ទងទៅនឹងកិច្ចការតំបន់សេដ្ឋកិច្ចពិសេស។

៣- ធ្វើជាអធិបតីនៃអង្គប្រជុំរបស់យន្តការ "ច្រកចេញ-ចូលតែមួយ" ដែលរៀបចំឡើងដោយគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ដើម្បីពិនិត្យសម្រេចក្នុងយន្តការ "ច្រកចេញ-ចូលតែមួយ"។

៤- ជួយដល់អគ្គលេខាធិការ "ក.អ.ក" ក្នុងការរៀបចំសំណុំឯកសារចាំបាច់ ដែលមានការទាក់ទិនទៅនឹងកិច្ចការតំបន់សេដ្ឋកិច្ចពិសេស សម្រាប់អង្គប្រជុំពេញអង្គរបស់គណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" និងសម្រាប់អង្គប្រជុំពេញអង្គរបស់ "ក.អ.ក"។

៥- ធ្វើការតាមដានលើការអនុវត្តកម្មវិធី និងការវិវត្តនៃគម្រោងតំបន់សេដ្ឋកិច្ចពិសេសនានា ដោយសហការជាមួយបណ្តាក្រសួង និងស្ថាប័នជំនាញដែលមានការពាក់ព័ន្ធ ហើយធ្វើ

របាយការណ៍បូកសរុប និងលើកយោបល់ជូនគណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" ដើម្បីពិនិត្យ និងចាត់វិធានការកែតម្រូវក្នុងករណីចាំបាច់។

៦- ជួយដល់អគ្គលេខាធិការ "ក.អ.ក" ក្នុងការរៀបចំរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំលើផ្នែកការងារពាក់ព័ន្ធទៅនឹងកិច្ចការតំបន់សេដ្ឋកិច្ចពិសេស ដើម្បីដាក់ជូនគណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" ពិនិត្យ និងសម្រេច មុននឹងផ្ញើជូនរាជរដ្ឋាភិបាល។

៧- បំពេញការងារដទៃទៀត ដែលទាក់ទងនឹងកិច្ចការតំបន់សេដ្ឋកិច្ចពិសេស ដែលប្រធាន "ក.អ.ក" ប្រគល់សិទ្ធិ។

**មាត្រា៣០ ._**

សមាជិកនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានភារកិច្ចដូចតទៅ៖

១- ចូលរួមក្នុងការកំណត់ទស្សនទាន និងគោលនយោបាយនៃកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍គម្រោងកិច្ចការវិនិយោគឯកជន និងគម្រោងតំបន់សេដ្ឋកិច្ចពិសេស ព្រមទាំងចូលរួមក្នុងការកំណត់លំដាប់អាទិភាពនៃកម្មវិធី គម្រោងវិនិយោគនានា និងគម្រោងបង្កើតតំបន់សេដ្ឋកិច្ចពិសេស ទាំងផ្នែកសាធារណៈ និងទាំងផ្នែកឯកជន។

២- ចូលរួមក្នុងការត្រួតពិនិត្យការអនុវត្តគោលនយោបាយ កម្មវិធីគម្រោងវិនិយោគនានា និងគម្រោងតំបន់សេដ្ឋកិច្ចពិសេសដែលក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានអនុម័តទាំងខាងផ្នែកសាធារណៈទាំងខាងផ្នែកឯកជន និងទាំងខាងផ្នែកតំបន់សេដ្ឋកិច្ចពិសេស។

៣- ពិនិត្យ និងអនុម័តរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំ អំពីកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ កិច្ចការវិនិយោគឯកជន កិច្ចការតំបន់សេដ្ឋកិច្ចពិសេស មុននឹងផ្ញើជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច។

**មាត្រា៣១ ._**

ក្នុងករណីចាំបាច់ប្រធាន "ក.អ.ក" អាចកោះប្រជុំវិសាមញ្ញរបស់គណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" ឬប្រជុំវិសាមញ្ញពេញអង្គរបស់ "ក.អ.ក"។

**មាត្រា៣២ ._**

ការប្រព្រឹត្តទៅនៃអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" និងអង្គប្រជុំពេញអង្គរបស់ "ក.អ.ក" ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនៃ "ក.អ.ក"។

**មាត្រា៣៣ ._**

ការអនុវត្តការងារនៃយន្តការ "ច្រកចេញ-ចូលតែមួយ" របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងការពិនិត្យលើកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ លើការវិនិយោគឯកជន និងកិច្ចការតំបន់សេដ្ឋកិច្ចពិសេស ត្រូវរៀបចំឡើងតាមរបៀបរបបជាគោលការណ៍ដូចខាងក្រោម៖

ទី១- សម្រាប់គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា៖

ក- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទីស្ដីការគណៈរដ្ឋមន្ត្រី និងក្រសួងផែនការ ត្រូវចាត់មន្ត្រីរបស់ខ្លួន ថ្នាក់ប្រធាននាយកដ្ឋានមួយរូបឱ្យមកអមគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា។ មន្ត្រីរូបនោះត្រូវ៖

- មានសមត្ថភាពការងារតាមមុខជំនាញរបស់ខ្លួន
- ទទួលការប្រគល់សិទ្ធិពីប្រធានស្ថាប័នរបស់ខ្លួន ហើយស្ថិតរមូតក្នុងការទាក់ទងជាមួយប្រធានស្ថាប័នរបស់ខ្លួន ពិសេសធ្វើរបាយការណ៍ និងលើកមតិស្នើសុំយោបល់ពីប្រធានស្ថាប័នរបស់ខ្លួន
- ស្ថិតរមូតក្នុងការងារក្នុងក្របខ័ណ្ឌគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា
- ចេះភាសាបរទេសមួយ ឬពីរ ជាពិសេសភាសាអង់គ្លេស។

ខ- ក្រសួង និងស្ថាប័នដទៃទៀតនៃរាជរដ្ឋាភិបាល ក៏ត្រូវមានតំណាងចូលរួមក្នុងយន្តការ "ច្រកចេញ-ចូលតែមួយ" នេះដែរ តែត្រូវចូលរួមតាមលក្ខណៈ "អែដហុក" តាមការអញ្ជើញរបស់អគ្គលេខាធិការ "គ.ជ.នា" ចំពោះតែកិច្ចការវិនិយោគសាធារណៈណាដែលពាក់ព័ន្ធទៅនឹងសមត្ថកិច្ចនៃក្រសួង-ស្ថាប័នទាំងនោះ។

គ- អគ្គលេខាធិការ "គ.ជ.នា" មានកាតព្វកិច្ចផ្ដល់សំណុំឯកសារសព្វគ្រប់ ដែលត្រូវរួមគ្នាពិនិត្យ និងឯកភាពក្នុងអង្គប្រជុំនៃយន្តការ "ច្រកចេញ-ចូលតែមួយ" ដល់តំណាងក្រសួង និងស្ថាប័នដែលមានការពាក់ព័ន្ធក្នុងរយៈពេលមួយសប្ដាហ៍មុន ដើម្បីប្រធានស្ថាប័ន ដែលមានការពាក់ព័ន្ធអាចពិនិត្យ និងផ្ដល់យោបល់ជាយថាហេតុ តាមរយៈមន្ត្រីដែលជាតំណាងរបស់ខ្លួន។

ឃ-ក្រោយពីរៀបចំ និងប្រមូលផ្ដុំនូវបណ្ដាឯកសារចាំបាច់នានាបានចប់សព្វគ្រប់ តាមបែបបទជាធរមានហើយ អគ្គលេខាធិការ "គ.ជ.នា" ត្រូវរៀបចំបញ្ចូលកម្មវិធី ឬគម្រោងនោះទៅក្នុងអង្គប្រជុំនៃយន្តការ "ច្រកចេញ–ចូលតែមួយ" ដើម្បីពិនិត្យ និងសម្រេច។

ង-អគ្គលេខាធិការ "គ.ជ.នា" ត្រូវរៀបចំសំណុំឯកសារ និងព័ត៌មានផ្សេងៗដែលជាលទ្ធផលនៃកិច្ចប្រជុំរបស់យន្តការ "ច្រកចេញ–ចូលតែមួយ" បញ្ជូនទៅអគ្គលេខាធិការ "ក.អ.ក" ដើម្បីរៀបចំដាក់ជូនអង្គប្រជុំគណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" ពិនិត្យ និងសម្រេច។

ទី២- សម្រាប់គណៈកម្មាធិការវិនិយោគកម្ពុជា៖

ក-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទីស្ដីការគណៈរដ្ឋមន្ត្រី ក្រសួងផែនការ ក្រសួងពាណិជ្ជកម្ម និងក្រសួងរ៉ែ និង ថាមពល ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត ត្រូវចាត់មន្ត្រីរបស់ខ្លួន ថ្នាក់ប្រធាននាយកដ្ឋានមួយរូបឱ្យមកអមគណៈកម្មាធិការវិនិយោគកម្ពុជា។ មន្ត្រីរូបនោះត្រូវ៖

- មានសមត្ថភាពការងារតាមមុខជំនាញរបស់ខ្លួន
- ទទួលការប្រគល់សិទ្ធិពីប្រធានស្ថាប័នរបស់ខ្លួន ហើយស្ថិតរមូតក្នុងការទាក់ទងជាមួយប្រធានស្ថាប័នរបស់ខ្លួន ពិសេសធ្វើរបាយការណ៍ និងលើកមតិស្នើសុំយោបល់ពីប្រធានស្ថាប័នរបស់ខ្លួន

- ស្អិតរមួតក្នុងការងារក្នុងក្របខ័ណ្ឌគណៈកម្មាធិការវិនិយោគកម្ពុជា
- ចេះភាសាបរទេសមួយ ឬពីរ ជាពិសេសភាសាអង់គ្លេស។

ខ- ក្រសួង និងស្ថាប័នដទៃទៀតនៃរាជរដ្ឋាភិបាល ក៏ត្រូវមានតំណាងចូលរួមក្នុងយន្តការ "ច្រកចេញ-ចូលតែមួយ" នេះដែរ តែត្រូវចូលរួមតាមលក្ខណៈ "អែដហុក" តាមការអញ្ជើញរបស់អគ្គលេខាធិការ "គ.វ.ក" ចំពោះតែកិច្ចការវិនិយោគឯកជនណាដែលពាក់ព័ន្ធទៅនឹងសមត្ថកិច្ចនៃក្រសួង-ស្ថាប័នទាំងនោះ។

គ- អគ្គលេខាធិការ "គ.វ.ក" មានកាតព្វកិច្ចផ្តល់សំណុំឯកសារសព្វគ្រប់ ដែលត្រូវរួមគ្នាពិនិត្យ និងសម្រេចក្នុងអង្គប្រជុំនៃយន្តការ "ច្រកចេញ-ចូលតែមួយ" ដល់តំណាងក្រសួង និងស្ថាប័នដែលមានការពាក់ព័ន្ធ ក្នុងរយៈពេលមួយសប្តាហ៍មុន ដើម្បីប្រធានស្ថាប័នដែលមានការពាក់ព័ន្ធអាចពិនិត្យ និងផ្តល់យោបល់ជាយថាហេតុ តាមរយៈមន្ត្រីដែលជាតំណាងរបស់ខ្លួន។

ឃ- ក្រោយពីរៀបចំ និងប្រមូលផ្តុំនូវបណ្តាឯកសារចាំបាច់នានាបានចប់សព្វគ្រប់ តាមបែបបទជាធរមានហើយ អគ្គលេខាធិការ "គ.វ.ក." ត្រូវរៀបចំបញ្ចូលកម្មវិធី ឬគម្រោងនោះទៅក្នុងអង្គប្រជុំនៃយន្តការ "ច្រកចេញ-ចូលតែមួយ" ដើម្បីពិនិត្យ និងសម្រេច។

ង- អគ្គលេខាធិការ "គ.វ.ក." ត្រូវរៀបចំសំណុំឯកសារ និងព័ត៌មានផ្សេងៗ ដែលជាលទ្ធផលនៃកិច្ចប្រជុំរបស់យន្តការ "ច្រកចេញ-ចូលតែមួយ" បញ្ជូនទៅអគ្គលេខាធិការ "ក.អ.ក" ដើម្បីរៀបចំដាក់ជូនអង្គប្រជុំគណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" ពិនិត្យ និងសម្រេច។

ទី៣- សម្រាប់គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា៖

ក- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ក្រសួងពាណិជ្ជកម្ម ក្រសួង រ៉ែ និង ថាមពល ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀតត្រូវចាត់មន្ត្រីរបស់ខ្លួនថ្នាក់ប្រធាននាយកដ្ឋានមួយរូបឱ្យមកអមគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា។ មន្ត្រីរូបនោះត្រូវ៖

- មានសមត្ថភាពការងារតាមមុខជំនាញរបស់ខ្លួន
- ទទួលការប្រគល់សិទ្ធិពីប្រធានស្ថាប័នរបស់ខ្លួន ហើយស្អិតរមួតក្នុងការទាក់ទងជាមួយប្រធានស្ថាប័នរបស់ខ្លួន ពិសេសធ្វើរបាយការណ៍ និងលើកមតិស្នើសុំយោបល់ពីប្រធានស្ថាប័នរបស់ខ្លួន
- ស្អិតរមួតក្នុងការងារក្នុងក្របខ័ណ្ឌគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា
- ចេះភាសាបរទេសមួយ ឬពីរ ជាពិសេសភាសាអង់គ្លេស។

ខ- ក្រសួង និងស្ថាប័នដទៃទៀតនៃរាជរដ្ឋាភិបាល ក៏ត្រូវមានតំណាងចូលរួមក្នុងយន្តការ "ច្រកចេញ-ចូលតែមួយ" នេះដែរ តែត្រូវចូលរួមតាមលក្ខណៈ "អែដហុក" តាមការអញ្ជើញរបស់អគ្គលេខាធិការ "គ.ស.ព" ចំពោះតែកិច្ចការតំបន់សេដ្ឋកិច្ចពិសេសណាដែលពាក់ព័ន្ធទៅនឹងសមត្ថកិច្ចនៃក្រសួង និងស្ថាប័នទាំងនោះ។

គ- អគ្គលេខាធិការ "គ.ស.ព" មានភារកិច្ចផ្តល់សំណុំឯកសារសព្វគ្រប់ដែលត្រូវរួមគ្នាពិនិត្យ និងសម្រេចក្នុងអង្គប្រជុំនៃយន្តការ "ច្រកចេញ-ចូលតែមួយ" ដល់តំណាងក្រសួង និងស្ថាប័នដែលមានការពាក់ព័ន្ធ ក្នុងរយៈពេលមួយសប្តាហ៍មុន ដើម្បីប្រធានស្ថាប័នដែលមានការពាក់ព័ន្ធអាចពិនិត្យ និងផ្តល់យោបល់ជាយថាហេតុ តាមរយៈមន្ត្រីដែលជាតំណាងរបស់ខ្លួន។

ឃ-ក្រោយពីរៀបចំ និងប្រមូលផ្តុំនូវបណ្តាឯកសារចាំបាច់នានា បានចប់សព្វគ្រប់តាមបែបបទជាធរមានហើយ អគ្គលេខាធិការ "គ.ស.ព" ត្រូវរៀបចំបញ្ចូលកម្មវិធី ឬគម្រោងនោះទៅក្នុងអង្គប្រជុំនៃយន្តការ "ច្រកចេញ-ចូលតែមួយ" ដើម្បីពិនិត្យ និងសម្រេច។

ង- អគ្គលេខាធិការ "គ.ស.ព" ត្រូវរៀបចំសំណុំឯកសារ និងព័ត៌មានផ្សេងៗ ដែលជាលទ្ធផលនៃកិច្ចប្រជុំរបស់យន្តការ "ច្រកចេញ-ចូលតែមួយ" បញ្ជូនទៅអគ្គលេខាធិការ "ក.អ.ក" ដើម្បីរៀបចំដាក់ជូនអង្គប្រជុំគណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" ពិនិត្យ និងសម្រេច។

ទី៤- ក្រោយពីទទួលបានគ្រប់គ្រាន់នូវឯកសារ និងព័ត៌មានផ្សេងៗពីអគ្គលេខាធិការ "គ.ជ.នា" អគ្គលេខាធិការ "គ.វ.ក" អគ្គលេខាធិការ "គ.ស.ព" មក អគ្គលេខាធិការ "ក.អ.ក" ត្រូវរៀបចំសំណុំឯកសារទាំងអស់នោះតាមលំដាប់ ហើយដាក់ចូលក្នុងរបៀបវារៈនៃអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" ពិនិត្យ និងសម្រេច។

**មាត្រា៣៤ .-**

សេចក្តីលម្អិតអំពីការរៀបចំ និងការប្រព្រឹត្តទៅនៃយន្តការ "ច្រកចេញ-ចូលតែមួយ" របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវកំណត់នៅក្នុងបទបញ្ជាផ្ទៃក្នុងនៃ "ក.អ.ក"។

**មាត្រា៣៥ .-**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានក្របខ័ណ្ឌមន្ត្រីរាជការ និងមានខ្ទង់ចំណូល និងចំណាយថវិការបស់ខ្លួន។ ការគ្រប់គ្រងចំណូល និងចំណាយថវិកានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវស្ថិតនៅក្រោមច្បាប់ស្តីពីហិរញ្ញវត្ថុ។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា៣៦ .-**

អនុក្រឹត្យនេះ ជំនួសអនុក្រឹត្យលេខ ៤៨៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៣។

**មាត្រា៣៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈ

អភិបាលរាជធានី និងអភិបាលនៃគណៈអភិបាលគ្រប់ខេត្តទាំងអស់ និងសមាសភាព ដូចមានក្នុងមាត្រា១ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល:***

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១២០ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការរៀបចំនិងការប្រព្រឹត្តទៅនៃអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើត **អនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត** សរសេរអក្សរកាត់ **អ.គ.វ.រ.ខ.** ជាសេនាធិការឱ្យរដ្ឋបាលរាជធានី ខេត្ត ដើម្បីជាយន្តការក្នុងការពិនិត្យសម្រេចលើការវិនិយោគឯកជន និងការដោះស្រាយវិវាទពាក់ព័ន្ធនឹងគម្រោងវិនិយោគ។

## ជំពូកទី២
## សមាសភាព

**មាត្រា២.-**

**អ.គ.វ.វ.ខ.** មានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- | អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត | ប្រធាន |
| ២- | អភិបាលរងនៃគណៈអភិបាលរាជធានី ខេត្ត ១រូប | អនុប្រធាន |
| ៣- | នាយករដ្ឋបាលនៃរដ្ឋបាលរាជធានី ខេត្ត | សមាជិក |
| ៤- | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥- | ប្រធានមន្ទីរពាណិជ្ជកម្ម | សមាជិក |
| ៦- | ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិក |
| ៧- | ប្រធានមន្ទីររ៉ែ និងថាមពល | សមាជិក |
| ៨- | ប្រធានមន្ទីរសុខាភិបាល | សមាជិក |
| ៩- | ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១០- | ប្រធានមន្ទីរបរិស្ថាន | សមាជិក |
| ១១- | ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី | សមាជិក |
| ១២- | ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៣- | ប្រធានមន្ទីរផែនការ | សមាជិក |
| ១៤- | ប្រធានមន្ទីរធនធានទឹក និងឧតុនិយម | សមាជិក |
| ១៥- | ប្រធានមន្ទីរទេសចរណ៍ | សមាជិក |
| ១៦- | ប្រធានមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ១៧- | ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៨- | តំណាងសាខាគយ និងរដ្ឋាករាជធានី ខេត្ត | សមាជិក |
| ១៩- | តំណាងទីចាត់ការពន្ធដាររាជធានី ឬ តំណាងសាខាពន្ធដារខេត្ត | សមាជិក |
| ២០- | នាយកទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្ត | លេខាធិការ។ |

សមាសភាពជាក់ស្តែង ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋបាលរាជធានី ខេត្ត។

## ជំពូកទី៣
## តួនាទី និងភារកិច្ច

**មាត្រា៣.-**

**អ.គ.វ.វ.ខ.** មានតួនាទី និងភារកិច្ចពិនិត្យ និងសម្រេចលើការចុះបញ្ជី ការផ្តល់ការលើកទឹកចិត្ត ការធានា ការទិញ ការលក់ ការរួមបញ្ចូលគ្នា ការលុប និងការដោះស្រាយវិវាទនានាពាក់ព័ន្ធនឹងគម្រោងវិនិយោគឯកជន

ដែលមានទុនវិនិយោគសមមូលនឹង៥ (ប្រាំ) លានដុល្លារអាមេរិកចុះ នៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលរាជធានី ខេត្ត សាមីនីមួយៗ ស្របតាមនីតិវិធីដែលកំណត់ដោយអនុក្រឹត្យដោយឡែក និងស្របតាមបទប្បញ្ញត្តិនានានៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី៤

## កិច្ចដំណើរការការងារ

**មាត្រា៤.-**

សមាសភាពដែលមានចែងក្នុងមាត្រា ២ ខាងលើ ត្រូវអញ្ជើញចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធាន ក្នុងករណីប្រធានអវត្តមាន។

ករណីដែលប្រធានអវត្តមាន **អ.គ.វ.រ.ខ.** អាចដំណើរការប្រជុំក្រោមអធិបតីភាពរបស់អនុប្រធាន តាមការប្រគល់សិទ្ធិរបស់ប្រធាន។

**មាត្រា៥.-**

**អ.គ.វ.រ.ខ.** អាចអញ្ជើញតំណាង ឬមន្ត្រីជំនាញពីក្រសួង ស្ថាប័ន មន្ទីរ អង្គភាពពាក់ព័ន្ធ អភិបាលរងនៃគណៈអភិបាលរាជធានី ខេត្ត និងតំណាងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ពាក់ព័ន្ធ ដែលមិនមែនជាសមាជិក **អ.គ.វ.រ.ខ.** ចូលរួមក្នុងកិច្ចប្រជុំ តាមការចាំបាច់។

**មាត្រា៦.-**

ទីចាត់ការផែនការ និងវិនិយោគនៃរដ្ឋបាលរាជធានី ខេត្ត ត្រូវបំពេញតួនាទីជាលេខាធិការដ្ឋាន សម្រាប់ដោះស្រាយការងារប្រចាំថ្ងៃរបស់ **អ.គ.វ.រ.ខ.**។

**អ.គ.វ.រ.ខ.** ត្រូវប្រើប្រាស់អង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ជាច្រកសម្រាប់ការទទួល និងការផ្តល់សេវារដ្ឋបាលជូនវិនិយោគិនក្នុងការពិនិត្យ និងសម្រេចលើការវិនិយោគ និងការដោះស្រាយវិវាទវិនិយោគ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលរាជធានី ខេត្ត។

**មាត្រា៧.-**

**អ.គ.វ.រ.ខ.** មានសិទ្ធិប្រើប្រាស់ត្រារបស់រដ្ឋបាលរាជធានី ខេត្តសាមីសម្រាប់កិច្ចដំណើរការការងាររបស់ខ្លួន។

**មាត្រា៨.-**

**អ.គ.វ.រ.ខ.** ត្រូវធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ផ្តល់ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា ដើម្បីធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល។

**អ.គ.វ.រ.ខ.** ត្រូវធ្វើសេចក្តីរាយការណ៍ជាទៀងទាត់ជូនក្រុមប្រឹក្សារាជធានី ខេត្ត របស់ខ្លួនក្នុងការអនុវត្តការងារវិនិយោគ។

## ជំពូកទី៥

## ប្រតិភូកម្មសិទ្ធិអំណាច

**មាត្រា៩.-**

គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវធ្វើប្រតិភូកម្មសិទ្ធិអំណាចជូនមន្ទីរ អង្គភាពខ្សែបណ្តោយរបស់ក្រសួង ស្ថាប័ននៅថ្នាក់រាជធានី ខេត្ត ឬរដ្ឋបាលរាជធានី ខេត្ត ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន

ដើម្បីសម្រេចលើកិច្ចការពាក់ព័ន្ធដល់ការចេញលិខិតអនុញ្ញាត អាជ្ញាបណ្ណនានា ក្នុងការចុះបញ្ជីគម្រោងវិនិយោគ ការផ្ដល់ការលើកទឹកចិត្ត ការធានា ការទិញ ការលក់ ការរួមបញ្ចូលគ្នា ការលុបគម្រោង និងការដោះស្រាយវិវាទ វិនិយោគដែលមានទុនវិនិយោគសមមូលនឹង ៥ (ប្រាំ) លានដុល្លារអាម៉េរិកចុះ។

គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវរួសរាន់ចេញលិខិតបទប្បញ្ញត្តិស្ដីពីការណែនាំអនុវត្តជាក់ស្ដែង និងធ្វើការបណ្ដុះបណ្ដាលមុខជំនាញដល់គ្រប់មន្ទីរ អង្គភាពខ្សែបណ្ដោយរបស់ខ្លួនក្នុងរាជធានី ខេត្ត ជាសមាជិកនៃ **អ.គ.វ.រ.ខ.** តាមសមត្ថកិច្ចរៀងៗខ្លួន ដើម្បីធានាឱ្យដំណើរការនៃយន្តការនេះប្រព្រឹត្តទៅមានភាពរលូន និងមានប្រសិទ្ធភាពខ្ពស់។

**អ.គ.វ.រ.ខ.** ត្រូវចាប់ផ្ដើមអនុវត្តការងាររបស់ខ្លួន បន្ទាប់ពីគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធបានធ្វើប្រតិភូកម្មសិទ្ធិអំណាចជូនគ្រប់មន្ទីរ អង្គភាពខ្សែបណ្ដោយរបស់ខ្លួន ដូចមានចែងក្នុងមាត្រានេះ។ ការធ្វើប្រតិភូកម្មសិទ្ធិអំណាចនេះត្រូវធ្វើក្នុងរយៈពេលមិនលើសពី ៣០(សាមសិប) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីរដ្ឋបាលរាជធានី ខេត្ត ចេញសេចក្ដីសម្រេចកំណត់ពីសមាសភាពជាក់ស្ដែងនៃ **អ.គ.វ.រ.ខ.**។

## ជំពូកទី៦

## គម្រោងវិនិយោគដែលមិនត្រូវឆ្លងយន្តការ អ.គ.វ.រ.ខ.

**មាត្រា១០.-**

គម្រោងវិនិយោគដូចខាងក្រោម មិនឆ្លងការពិនិត្យសម្រេចក្នុងការចុះបញ្ជីគម្រោងវិនិយោគ ការផ្ដល់ការលើកទឹកចិត្ត និងការធានាលើការវិនិយោគរបស់ **អ.គ.វ.រ.ខ.** ទេ ដោយត្រូវឆ្លងតាមយន្តការរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា៖

១- គម្រោងវិនិយោគដែលមានទុនវិនិយោគចាប់ពី ៥ (ប្រាំ) លានដុល្លារអាម៉េរិកឡើងទៅ។

២- គម្រោងវិនិយោគដែលមានទីតាំងស្ថិតក្នុងដែនសមត្ថកិច្ចរបស់រាជធានី ខេត្ត ចាប់ពី២(ពីរ) ឡើងទៅ។

៣- គម្រោងវិនិយោគដែលស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស។

៤- គម្រោងវិនិយោគស្ថិតក្រោមច្បាប់ស្ដីពីភាពជាដៃគូរវាងរដ្ឋ និងឯកជន។

៥- គម្រោងវិនិយោគដែលមានវេទយិតភាពខាងនយោបាយ ឬអាចបង្កគ្រោះថ្នាក់ដល់បរិស្ថាន ឬប៉ះពាល់ដល់សន្តិសុខជាតិ ឬប៉ះពាល់ដល់ការងារអភិរក្ស និងការពារជីវៈចម្រុះ ធនធានធម្មជាតិ និងសម្បត្តិវប្បធម៌ជាតិ។

៦- គម្រោងវិនិយោគពាក់ព័ន្ធនឹងការរុករក និងការធ្វើអាជីវកម្មរ៉ែ និងធនធានធម្មជាតិ។

៧- គម្រោងវិនិយោគពាក់ព័ន្ធនឹងវិស័យថាមពល។

៨- គម្រោងវិនិយោគដែលស្ថិតនៅក្នុងបញ្ជីអវិជ្ជមានដែលនៅជាធរមាន។

មុខងារក្នុងការផ្ដល់សេវារដ្ឋបាលពាក់ព័ន្ធនឹងការចុះបញ្ជីការធ្វើអាជីវកម្មរ៉ែ និងថាមពលដែលបានធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបន្តអនុវត្តតាមស្មារតីនៃអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្ដីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្ដល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ជំពូកទី៧
## អន្តរប្បញ្ញត្តិ

**មាត្រា១១.-**

គម្រោងវិនិយោគទាំងឡាយ ដែលត្រូវបានចុះបញ្ជី និងទទួលបានការលើកទឹកចិត្តដោយអនុលោមតាមច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០៧/នស/៩៤ ចុះថ្ងៃទី ៥ ខែសីហា ឆ្នាំ១៩៩៤, ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ និងអនុក្រឹត្យពាក់ព័ន្ធនានា ត្រូវបន្តឋានៈជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នៅក្រោយអនុក្រឹត្យនេះចូលជាធរមាន។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**មាត្រា១២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងសមាសភាពដូចមានចែងក្នុងមាត្រា២ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ៦កើត ខែ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៣ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការកែសម្រួលមាត្រា១៥**

**នៃអនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥**

**ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## សម្រេច

**មាត្រាមួយ.-**

មាត្រា ១៥ នៃអនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានធ្វើការកែសម្រួលដូចតទៅ ៖

**មាត្រា ១៥.- ថ្មី ពន្ធលើប្រាក់ចំណូល**

**១៥.១.** យោងកថាខណ្ឌ ១ នៃមាត្រា១៤ថ្មី នៃច្បាប់ស្តីពីវិនិយោគ រយៈពេលលើកលែងពន្ធលើប្រាក់ចំណូលរួមមាន រយៈពេលគន្លឹះ បូករយៈពេល ៣ (បី) ឆ្នាំ បូករយៈពេលអាទិភាព ។

**១៥.២.** រយៈពេលគន្លឹះនៃរយៈពេលលើកលែងពន្ធលើប្រាក់ចំណូល ជារយៈពេលដែលចាប់ផ្តើមពីថ្ងៃចេញវិញ្ញាបនបត្រចុះបញ្ជីស្ថាពរ និងបញ្ចប់នៅថ្ងៃចុងក្រោយនៃឆ្នាំជាប់ពន្ធណាមួយដែលឆាប់ជាងគេក្នុងចំណោម៖

**ក-** ឆ្នាំជាប់ពន្ធមុនឆ្នាំដែលគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មានប្រាក់ចំណូលជាប់ពន្ធដំបូង ឬ

**ខ-** ឆ្នាំជាប់ពន្ធទី៣ បន្ទាប់ពីគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទទួលបានប្រាក់ចំណូលដំបូងពីការផ្គត់ផ្គង់ទំនិញ ឬ សេវាដែលជាសកម្មភាពអាជីវកម្មរបស់ខ្លួន ទោះបីពុំមានប្រាក់ចំណូលជាប់ពន្ធក៏ដោយ ។

សម្រាប់គោលដៅនៃកថាខណ្ឌនេះ និង កថាខណ្ឌ ១ នៃមាត្រា ១៤ នៃច្បាប់ស្តីពីវិនិយោគ ប្រាក់ចំណូលជាប់ពន្ធ សំដៅដល់ប្រាក់ចំណូលសុទ្ធ ដែលគណនាទៅតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសារពើពន្ធ ដោយពុំគិតពីបទប្បញ្ញត្តិនៃការយោងខាត ដូចមានចែងក្នុងមាត្រា ១៧ នៃច្បាប់ស្តីពីសារពើពន្ធទេ ។

**១៥.៣.** រយៈពេល ០៣ (បី) ឆ្នាំ គឺជារយៈពេល ០៣ (បី) ឆ្នាំ ដែលចាប់ផ្តើមគិតបន្ទាប់ពីរយៈពេលគន្លឹះត្រូវបានបញ្ចប់ ។

**១៥.៤.** រយៈពេលអាទិភាពត្រូវបានកំណត់ដោយច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ ដោយចាប់ផ្តើមគិតបន្ទាប់ពីឆ្នាំទី៣ នៃរយៈពេល ០៣ (បី) ឆ្នាំ ដូចមានចែងក្នុងកថាខណ្ឌ ១៥.៣ ខាងលើបានបញ្ចប់ ។

១៥.៥ ប្រាក់រំដោះពន្ធលើប្រាក់ចំណូលមិនត្រូវអនុវត្តចំពោះគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នៅក្នុងរយៈពេលលើកលែងពន្ធលើប្រាក់ចំណូល ដូចមានចែងក្នុងកថាខណ្ឌ ១ នៃមាត្រា ១៤ថ្មី នៃច្បាប់ស្តីពីវិនិយោគ ។

១៥.៦. គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មានកាតព្វកិច្ចកាន់កត់ត្រាបញ្ជិកាគណនេយ្យឱ្យបានត្រឹមត្រូវ តាមច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ និងបទប្បញ្ញត្តិដទៃទៀតនៃព្រះរាជាណាចក្រកម្ពុជា ។

១៥.៧. ក្នុងករណីគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មិនបានកាន់កត់ត្រាបញ្ជិកាគណនេយ្យត្រឹមត្រូវ ពន្ធអប្បបរមាត្រូវអនុវត្តតាមអត្រា ០១ (មួយ) ភាគរយនៃផលរបរ គិតរួមបញ្ចូលទាំងពន្ធអាករទាំងអស់ លើកលែងតែអាករលើតម្លៃបន្ថែម ដូចមានចែងនៅក្នុងមាត្រា ២៤ ថ្មី (ពីរ) នៃច្បាប់ស្តីពីសារពើពន្ធ ។

១៥.៨. គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលស្នើសុំពង្រីកសកម្មភាពវិនិយោគរបស់ខ្លួនត្រូវបានទទួលការលើកទឹកចិត្តនូវរយៈពេលលើកលែងពន្ធលើប្រាក់ចំណូល តែក្នុងករណីដែលការពង្រីកគម្រោងនោះធ្វើឡើងតាមរូបភាពណាមួយដូចខាងក្រោម÷

- ការពង្រីកផលិតកម្មដែលមានស្រាប់
- ការពង្រីកតាមរយៈការធ្វើពិពិធកម្មមុខសញ្ញាផលិតកម្មដែលស្ថិតក្នុងខ្សែស្រឡាយផលិតផលជាមួយគ្នា
- ការពង្រីកតាមរយៈការបំពាក់បច្ចេកវិទ្យាទំនើបថ្មីដែលលើកកម្ពស់ផលិតភាព ឬការពារបរិស្ថាន
- ការពង្រីកហេដ្ឋារចនាសម្ព័ន្ធបម្រើឱ្យសេវាទូរគមនាគមន៍មូលដ្ឋាន

១៥.៩. **"ការពង្រីក គ.ល.គ"** សំដៅដល់ការពង្រីកសកម្មភាពវិនិយោគ របស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលទទួលបានវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬពីអនុគណៈកម្មាធិការវិនិយោគរាជធានីខេត្ត។

១៥.១០. **"ទុនពង្រីក គ.ល.គ"** សំដៅដល់ទុនវិនិយោគពង្រីកគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលត្រូវប្រើប្រាស់សម្រាប់តែការវិនិយោគលើសម្ភារៈសាងសង់ និងសម្ភារៈបរិក្ខារផលិតកម្មថ្មី។

១៥.១១. ទុនពង្រីក គ.ល.គ ត្រូវមានចំនួនយ៉ាងតិចស្មើនឹងទុនអប្បបរមា ដូចមានចែងក្នុងផ្នែកទី២ ឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

១៥.១២. ការពង្រីក គ.ល.គ ត្រូវទទួលបាននូវរយៈពេលលើកលែងពន្ធលើប្រាក់ចំណូល តាមរូបមន្ត÷ រយៈពេលគន្លឹះ បូករយៈពេល ០៣ ឆ្នាំ បូករយៈពេលអាទិភាព ដែល ÷

- រយៈពេលគន្លឹះ ត្រូវចាប់ផ្តើមគិតពីពេលទទួលបាននូវការទទួលស្គាល់ជាគម្រោងពង្រីក គ.ល.គ និងត្រូវបញ្ចប់នៅពេលដែលគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលពង្រីកនេះ ទទួលបានប្រាក់ចំណូលដំបូង
- រយៈពេលអាទិភាព ត្រូវកំណត់ដោយអនុលោមតាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងជាធរមាន

- ចំណែកនៃប្រាក់ចំណូលដែលត្រូវលើកលែងពន្ធសម្រាប់ការពង្រីក គ.ល.គ ស្មើនឹងប្រាក់ចំណូលសរុប គុណនឹងអត្រាទុនពង្រីក គ.ល.គ។ អត្រាទុនពង្រីក គ.ល.គ ស្មើនឹងទុនពង្រីក គ.ល.គ ចែកនឹងទុនវិនិយោគសរុប។ ទុនវិនិយោគសរុបស្មើនឹងទុនវិនិយោគចាស់ បូកនឹងទុនពង្រីក គ.ល.គ ដែលត្រូវទទួលបានការលើកទឹកចិត្ត។ រូបមន្តនៃការគណនាមានដូចខាងក្រោម ÷

$$\text{បចល.} = \text{បចស.} \times \text{អទព.}$$

$$\text{អទព.} = \frac{\text{ទព.}}{\text{ទស.}}$$

$$\text{ទស.} = \text{ទច.} + \text{ទព.}$$

បចល. = ប្រាក់ចំណូលដែលត្រូវទទួលការលើកទឹកចិត្តលើកលែងពន្ធលើប្រាក់ចំណូល

បចស. = ប្រាក់ចំណូលសរុប

អទព. = អត្រាទុនពង្រីក គ.ល.គ

ទច. = ទុនវិនិយោគចាស់

ទព. = ទុនពង្រីក គ.ល.គ ដែលត្រូវទទួលការលើកទឹកចិត្ត

ទស. = ទុនវិនិយោគសរុប

- ប្រាក់រំដោះពន្ធលើប្រាក់ចំណូលលើការពង្រីក គ.ល.គ មិនត្រូវបានអនុវត្តក្នុងរយៈពេលលើកលែងពន្ធលើប្រាក់ចំណូល។

**១៥.១៣.** ការទទួលស្គាល់ គ.ល.គ មានលក្ខណៈពង្រីក និង ការពិនិត្យផ្តល់ ឬ ការដកហូតការលើកទឹកចិត្តចំពោះ គ.ល.គ មានលក្ខណៈពង្រីក ត្រូវធ្វើឡើងតាមរយៈយន្តការអន្តរស្ថាប័ន ដឹកនាំដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោយមានការចូលរួមពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដោយអនុលោមតាមនីតិវិធី និងគោលការណ៍ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ យន្តការអន្តរស្ថាប័ន ជាសេនាធិការ និង ត្រូវបង្កើតឡើងតាមរយៈប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**១៥.១៤.** គ.ល.គ ដែលស្នើសុំពង្រីក ត្រូវដាក់ពាក្យសុំមកយន្តការអន្តរស្ថាប័ន ។ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវឆ្លើយតបវិញក្នុងរយៈពេលយ៉ាងយូរ ៤៥ ថ្ងៃ បន្ទាប់ពីទទួលបានពាក្យស្នើសុំ ។

**១៥.១៥.** ការលើកទឹកចិត្តដូចក្នុងចំណុច ១៥.១២ ខាងលើ មិនត្រូវបានអនុញ្ញាតទេចំពោះ÷

- ការទិញឬផ្ទេរគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ផ្សេងទៀត ដែលបានទទួលការលើក-ទឹកចិត្តពន្ធលើប្រាក់ចំណូលរួចហើយ
- ការបំពេញបន្ថែមបង្គ្រប់ទុនវិនិយោគចាស់

**មាត្រា៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួងស្ថាប័ន និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធទាំងអស់ អភិបាលរាជធានី-ខេត្ត ត្រូវទទួលអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៩កើត ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**អនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

Sean B. Chin

**ជិន ប៊ុនស៊ាន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...៩៩១.....សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១២

# ប្រកាសរួម
## ស្តីពី
## ការផ្តល់សេវាសាធារណៈរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ និងអនុក្រឹត្យពាក់ព័ន្ធ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៤៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- ប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់
- សារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់
- តាមការចាំបាច់របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ស ម្រេ ច

**ប្រការ ១** :

អនុញ្ញាតឱ្យក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អនុវត្តការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ដើម្បីជាគុណប្រយោជន៍ថវិកាជាតិ។

កម្រងសេវាសាធារណៈនេះ មានបញ្ជាក់លម្អិតអំពីតម្លៃសេវា រយៈពេលផ្តល់សេវា និងសុពលភាព ទៅតាមប្រភេទសេវាសាធារណៈនីមួយៗ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់មកជាមួយនឹងប្រកាសរួមនេះ។

**ប្រការ ២** :

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវបិទផ្សាយជាសាធារណៈ ជាពិសេសនៅកន្លែងផ្តល់សេវា នូវស្តង់ដារសេវាក្នុងនោះរួមមាន ៖ តារាងតម្លៃ ទម្រង់ឯកសារ និងនីតិវិធីសម្រាប់ការផ្តល់សេវា ពាក់ព័ន្ធនឹងការប្រមូលចំណូលខាងលើនេះ។

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវរៀបចំឱ្យមានកន្លែងទទួលបណ្តឹងតវ៉ា ដែលអាចកើតមានឡើងដោយថាហេតុជាពិសេសក្នុងករណីមានការអនុវត្តខុសពីស្តង់ដារសេវា ឬមានការយកកម្រៃលើសការកំណត់ ឬមានការយឺតយ៉ាវជាដើម។

**ប្រការ ៣** :

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានភារកិច្ចប្រមូលចំណូល ទទួលខុសត្រូវប្រាក់ចំណូលដែលប្រមូលបាន និងបង់ប្រាក់ចំណូលចូលថវិកាជាតិ ក្នុងនោះ ត្រូវចុះកិច្ចបញ្ជិកាគណនេយ្យ ស្តីពីកិច្ចប្រតិបត្តិការចំណូល និងកត់ត្រាតាមដានប្រាក់ចំណូលនៅក្នុងជំពូក គណនី អនុគណនី នៃមាតិកាថវិកា ព្រមទាំងធ្វើសលាកប័ត្រចំណូល។

**ប្រការ ៤** :

ការបែងចែកភារកិច្ចលើការគ្រប់គ្រង ការប្រមូលចំណូល ពីការផ្តល់សេវាសាធារណៈ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវកំណត់ដោយប្រកាសរបស់អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវផ្ញើសេចក្តីប្រកាសនេះចំនួនមួយច្បាប់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីជូនជ្រាបជាព័ត៌មាន និងសម្រាប់តាមដានការអនុវត្តចំណូល។

**ប្រការ ៥** :

រាល់ការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់មកជាមួយប្រកាសរួមនេះ ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ ដែលបានបើកផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្របតាមប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ និងសារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ៦** :

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវកំណត់ទីតាំងដាក់លាក់ និងមានមន្រ្តីប្រចាំការដែលមានលក្ខណៈជាច្រកចេញចូលតែមួយ នៅទីតាំងដែលបានកំណត់ ដើម្បីទទួលបម្រើសេវាជូនអតិថិជនឱ្យបានទាន់ពេលវេលាតាមការកំណត់។

**ប្រការ ៧** :

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវធ្វើរបាយការណ៍ ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ដើម្បីផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

**ប្រការ ៨** :

កម្រងសេវាសាធារណៈ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធនៃប្រកាសរួមនេះ អាចកែប្រែបាន តាមការចាំបាច់តាមរយៈប្រកាសរួម។

**ប្រការ ៩** :

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសរួមនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ១០** :

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រោមឱវាទក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

| | |
|---|---|
| **ឧបនាយករដ្ឋមន្ត្រី** | **រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី** |
| **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** | **អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា** |
| **អាត ឈន់** | **សុខ ចិន្តា សោភា** |

ចម្លងជូន:
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- អាជ្ញាធរសេវនកម្មជាតិ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អង្គភាពប្រឆាំងអំពើពុករលួយ
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- សភាពាណិជ្ជកម្មកម្ពុជា

«ដើម្បីជូនជ្រាប»
- ដូចប្រការ ១០ «ដើម្បីអនុវត្ត»
- ឯកសារ - កាលប្បវត្តិ

## តារាងឧបសម្ព័ន្ធ

## ភ្ជាប់នឹងប្រកាសរួមលេខ ៩៩១ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២

## ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| **តម្លៃសេវានៃគណៈកម្មាធិការវិនិយោគកម្ពុជា** | | | | |
| 1 | ការផ្តល់សេវាពិគ្រោះយោបល់ | អត់គិតថ្លៃ | | |
| 2 | រៀបចំកម្មវិធីទស្សនកិច្ចស្វែងយល់របស់គណៈប្រតិភូវិនិយោគ | អត់គិតថ្លៃ | | |
| 3 | ផ្តល់ឯកសារពាក់ព័ន្ធនឹងការវិនិយោគ | អត់គិតថ្លៃ | | |
| 4 | ផ្តល់សេវាមគ្គុទេសក៏ | អត់គិតថ្លៃ | | |
| 5 | សេវារៀបចំឱ្យមានការជួបគ្នារវាងអ្នកវិនិយោគក្នុងស្រុក និងបរទេស | អត់គិតថ្លៃ | | |
| 6 | ការសម្របសម្រួលសុំទិដ្ឋាការ | អត់គិតថ្លៃ | | |
| 7 | ការសម្របសម្រួលចុះបញ្ជី | អត់គិតថ្លៃ | | |
| 8 | សុំលុបឈ្មោះក្រុមហ៊ុន | អត់គិតថ្លៃ | 15ថ្ងៃ | |
| 9 | សុំបញ្ជាក់ដើមទុនវិនិយោគ | អត់គិតថ្លៃ | 5ថ្ងៃ | |
| 10 | កែតម្លៃយថាប្រភេទទំនិញ | អត់គិតថ្លៃ | 15ថ្ងៃ | |
| 11 | បិទក្រុមហ៊ុន | អត់គិតថ្លៃ | 10ថ្ងៃ | |
| 12 | ផ្អាកសកម្មភាពផលិតកម្ម | អត់គិតថ្លៃ | 10ថ្ងៃ | |
| 13 | បំពេញបែបបទសុំដកប្រាក់ | អត់គិតថ្លៃ | 28ថ្ងៃ | |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 14 | ពន្យាសុពលភាពលិខិតនាំចូល | អត់គិតថ្លៃ | 3ថ្ងៃ | 6ខែ |
| 15 | វិញ្ញាបនបត្របញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋ C.O.C | អត់គិតថ្លៃ | 10ថ្ងៃ | |
| 16 | ប្តូរយថាប្រភេទទំនិញ | អត់គិតថ្លៃ | 15ថ្ងៃ | |
| 17 | សំណើសុំបន្ថែមលើបញ្ជីនាំចូលចាស់ | អត់គិតថ្លៃ | 10ថ្ងៃ | |
| 18 | ប្តូរមុខសញ្ញាផលិតកម្ម | អត់គិតថ្លៃ | 15ថ្ងៃ | |
| 19 | នាំចូលផ្ទាំងក្រណាត់ចាក់តាមរូបភាព OPA | 2,000,000 | 3ថ្ងៃ | |
| 20 | ប្តូរទីស្នាក់ការក្រុមហ៊ុន | អត់គិតថ្លៃ | 10ថ្ងៃ | |
| 21 | សុំកម្ទេចគ្រឿងម៉ាស៊ីនចាស់ៗ | អត់គិតថ្លៃ | 15ថ្ងៃ | |
| 22 | ផ្ទេរគ្រឿងម៉ាស៊ីន | 2,000,000 | 15ថ្ងៃ | |
| 23 | នាំចេញគ្រឿងម៉ាស៊ីន | 2,000,000 | 15ថ្ងៃ | |
| 24 | លក់គ្រឿងម៉ាស៊ីនចាស់ៗ | 2,000,000 | 15ថ្ងៃ | |
| 25 | សំណើសុំនាំចូលដោយពន្ធនាំចូលជាបន្ទុករបស់រដ្ឋ | 4,000,000 | 15ថ្ងៃ | 12ខែ |
| 26 | ពង្រីកផលិតកម្ម | 2,000,000 | 15ថ្ងៃ | |
| 27 | បន្ថែមមុខសញ្ញាផលិតកម្ម | អត់គិតថ្លៃ | 15ថ្ងៃ | |
| 28 | ផ្ទេរភាគហ៊ុន | 2,000,000 | 10ថ្ងៃ | |
| 29 | ប្តូរទីតាំងរោងចក្រ | 2,000,000 | 10ថ្ងៃ | |
| 30 | ប្តូរនាមករណ៍ក្រុមហ៊ុន | 2,000,000 | 10ថ្ងៃ | |
| 31 | ប្តូរអភិបាល ឬប្តូរអ្នកតំណាង | 2,000,000 | 10ថ្ងៃ | |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 32 | បន្ថយ-បន្ថែមដើមទុនចុះបញ្ជី | 2,000,000 | 10ថ្ងៃ | |
| 33 | ការទិញ និងរំលាយបញ្ចូលគ្នា | 4,000,000 | 10ថ្ងៃ | |
| 34 | ការពិនិត្យ និងអនុម័តផែនការមេនៃបណ្តាកោះ និងឆ្នេរ | 40,000,000 | 30ថ្ងៃ | |
| 35 | គម្រោងវិនិយោគថ្មី | | | |
| | - ឧស្សាហកម្ម | 15,000,000 | 28ថ្ងៃ | |
| | - ទេសចរណ៍ | 15,000,000 | 28ថ្ងៃ | |
| | - ហេដ្ឋារចនាសម្ព័ន្ធ | 15,000,000 | 28ថ្ងៃ | |
| | - កសិកម្ម | 15,000,000 | 28ថ្ងៃ | |
| | - រ៉ែ និងធនធានធម្មជាតិ | 15,000,000 | 28ថ្ងៃ | |
| 36 | ការងារចុះពិនិត្យគម្រោងវិនិយោគថ្មី(ទោះជាប៉ុន្មានលើកក៏ដោយ) | | | |
| | - តិចជាង 100 គម | 6,000,000 | | |
| | - ពី 101-200 គម | 8,000,000 | | |
| | - ពី 201 គមឡើង | 10,000,000 | | |
| **គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា** | | | | |
| 1 | ការផ្តល់សេវាពិគ្រោះយោបល់ | អត់គិតថ្លៃ | | |
| 2 | រៀបចំកម្មវិធីទស្សនកិច្ចស្វែងយល់របស់គណៈប្រតិភូវិនិយោគ | អត់គិតថ្លៃ | | |
| 3 | ផ្តល់ឯកសារពាក់ព័ន្ធនិងការវិនិយោគ | អត់គិតថ្លៃ | | |
| 4 | ផ្តល់សេវាមគ្គុទេសក៍ | អត់គិតថ្លៃ | | |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 5 | សេវារៀបចំឱ្យមានការជួបគ្នារវាងអ្នកវិនិយោគក្នុងស្រុក និងបរទេស | អត់គិតថ្លៃ | | |
| 6 | ការសម្របសម្រួលសុំទិដ្ឋាការ | អត់គិតថ្លៃ | | |
| 7 | ការសម្របសម្រួលចុះបញ្ជី | អត់គិតថ្លៃ | | |
| 8 | សុំលុបឈ្មោះក្រុមហ៊ុន | អត់គិតថ្លៃ | 3ថ្ងៃ | |
| 9 | សុំបញ្ជាក់ដើមទុនវិនិយោគ | អត់គិតថ្លៃ | 3ថ្ងៃ | |
| 10 | កែតម្លៃយថាប្រភេទទំនិញ | អត់គិតថ្លៃ | 3ថ្ងៃ | |
| 11 | បិទក្រុមហ៊ុន | អត់គិតថ្លៃ | 3ថ្ងៃ | |
| 12 | ផ្អាកសកម្មភាពផលិតកម្ម | អត់គិតថ្លៃ | 3ថ្ងៃ | |
| 13 | បំពេញបែបបទសុំដកប្រាក់កក់ | អត់គិតថ្លៃ | 3ថ្ងៃ | |
| 14 | ពន្យាសុពលភាពលិខិតនាំចូល | អត់គិតថ្លៃ | 3ថ្ងៃ | 6ខែ |
| 15 | វិញ្ញាបនប័ត្របញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋ C.O.C | អត់គិតថ្លៃ | 3ថ្ងៃ | |
| 16 | ប្តូរយថាប្រភេទទំនិញ | អត់គិតថ្លៃ | 3ថ្ងៃ | |
| 17 | សំណើសុំបន្ថែមលើបញ្ជីនាំចូលចាស់ | អត់គិតថ្លៃ | 3ថ្ងៃ | |
| 18 | ប្តូរមុខសញ្ញាផលិតកម្ម | អត់គិតថ្លៃ | 3ថ្ងៃ | |
| 19 | នាំចូលផ្ទាំងក្រណាត់ចាក់តាមរូបភាព OPA | 2,000,000 | 3ថ្ងៃ | |
| 20 | ប្តូរទីស្នាក់ការក្រុមហ៊ុន | អត់គិតថ្លៃ | 5ថ្ងៃ | |
| 21 | សុំកម្ទេចគ្រឿងម៉ាស៊ីនចាស់ៗ | អត់គិតថ្លៃ | 5ថ្ងៃ | |
| 22 | ផ្ទេរគ្រឿងម៉ាស៊ីន | 2,000,000 | 5ថ្ងៃ | |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្ដល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 23 | នាំចេញគ្រឿងម៉ាស៊ីន | 2,000,000 | 5ថ្ងៃ | |
| 24 | លក់គ្រឿងម៉ាស៊ីនចាស់ៗ | 2,000,000 | 3ថ្ងៃ | |
| 25 | សំណើសុំនាំចូល - ដោយពន្ធនាំចូលជាបន្ទុករបស់រដ្ឋ | 1,600,000 | 3ថ្ងៃ | 12ខែ |
| 26 | ពង្រីកផលិតកម្ម | 2,000,000 | 5ថ្ងៃ | |
| 27 | បន្ថែមមុខសញ្ញាផលិតកម្ម | អត់គិតថ្លៃ | 5ថ្ងៃ | |
| 28 | ផ្ទេរភាគហ៊ុន | 2,000,000 | 5ថ្ងៃ | |
| 29 | ប្ដូរនាមករណ៍ក្រុមហ៊ុន | 2,000,000 | 5ថ្ងៃ | |
| 30 | ប្ដូរអភិបាល ឬប្ដូរអ្នកតំណាង | 2,000,000 | 5ថ្ងៃ | |
| 31 | បន្ថយ-បន្ថែមដើមទុនចុះបញ្ជី | 2,000,000 | 5ថ្ងៃ | |
| 32 | ការទិញ និងរំលាយបញ្ចូលគ្នា | 4,000,000 | 5ថ្ងៃ | |
| 33 | គម្រោងវិនិយោគថ្មី | 15,000,000 | 28ថ្ងៃ | |

**គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា**

| | | | | |
|---|---|---|---|---|
| 1 | កាពិនិត្យ និងអនុម័តពាក្យសុំនាំចូលឧបករណ៍ សម្ភារៈមធ្យោបាយដោយ រដ្ឋទទួលបន្ទុកបង់ពន្ធជំនួសសម្រាប់ការអនុវត្តន៍គម្រោងវិនិយោគក្នុងក្រប ខ័ណ្ឌជំនួយទ្វេភាគី ពហុភាគី និង អង្គការក្រៅរដ្ឋាភិបាលទាំងអស់ | 200,000 | 10ថ្ងៃ | 2ខែ |

# ឧបសម្ព័ន្ធទី២

# បញ្ជីតារាង និងរូបភាព

# ឧបសម្ព័ន្ធទី២៖ បញ្ជីតារាង និងរូបភាព

## ទី១៖ រូបភាពបង្ហាញអំពីស្ថានភាពវិនិយោគផ្ទាល់នៅកម្ពុជា គិតត្រឹមចុងឆ្នាំ២០២១



**ទី២៖** រូបភាពបង្ហាញអំពីផែនទីនៃតំបន់សេដ្ឋកិច្ចពិសេសនៅក្នុងប្រទេសកម្ពុជា



**ទី៣៖** រូបភាពបង្ហាញអំពីផែនទីនៃតំបន់សេដ្ឋកិច្ចពិសេសនៅក្នុងប្រទេសកម្ពុជា



**ទី៤៖** តារាងប្រៀបធៀបការលើកទឹកចិត្តរវាងជម្រើសទី១ និងជម្រើសទី២

**តារាងប្រៀបធៀបជម្រើសទាំង ២**

| ជម្រើសទី១ | ជម្រើសទី២ |
|---|---|
| លើកលែងពន្ធលើប្រាក់ចំណូល (ពី ៣ ដល់ ៩ ឆ្នាំ) | កាត់កងចំណាយជាក់លាក់ផ្សេងៗរហូតដល់ ២០០% រយៈពេល ៩ ឆ្នាំ |
| ការលើកទឹកចិត្តបង់ពន្ធតាមអត្រាកំណើនតាមពេលធៀបទៅនឹងទឹកប្រាក់ពន្ធត្រូវបង់ | កាត់កងចំណាយមូលធនតាមរយៈរំលស់ពិសេស |
| លើកលែងប្រាក់រំដោះពន្ធលើប្រាក់ចំណូលក្នុងរយៈពេលលើកលែងពន្ធ | លើកលែងប្រាក់រំដោះពន្ធលើប្រាក់ចំណូលក្នុងរយៈពេលជាក់លាក់ណាមួយ |
| លើកលែងពន្ធអប្បបរមា | ដូចគ្នា |
| លើកលែងអាករនាំចេញ | ដូចគ្នា |

**ទី៥៖** រូបភាពបង្ហាញអំពីអតិផរណារបស់ប្រទេសកម្ពុជាគិតជាភាគរយពីឆ្នាំ២០១៦ មកដល់ឆ្នាំ២០២០



**ទី៦៖** រូបភាពបង្ហាញអំពីការបញ្ចេញឧស្ម័នកាបូនិកក្នុងចំណោមមនុស្សម្នាក់នៅតំបន់អាស៊ាន




**ទី៧៖** រូបភាពបង្ហាញអំពីតួលេខរបស់ RCEP



**ទី៨៖** រូបភាពបង្ហាញអំពីប្រាក់ឈ្នួលប្រចាំខែអប្បបរមា នៅក្នុងពិភពលោកឆ្នាំ២០២១-២០២១ គិតជាដុល្លារអាមេរិក




**ទី៩៖** តារាងបង្ហាញអំពីការដាក់សំណើទៅស្ថាប័នមានសមត្ថកិច្ចតាមទំហំទឹកប្រាក់

| ទុនវិនិយោគ | ស្ថាប័នមានសមត្ថកិច្ច | តម្លៃសេវារដ្ឋបាល |
|---|---|---|
| សមមូលនឹង ៥.000.000 $ ចុះ | អនុគណៈកម្មាធិការរាជធានី ខេត្ត | ១៥.000.000 ៛ |
| ចាប់ពី ៥.000.000 $ ឡើង | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ១៥.000.000 ៛ |

**ទី១០៖** រូបភាពបង្ហាញអំពីនីតិវិធីនៃការចុះបញ្ជីតាមរយៈថ្នាលបច្ចេកវិទ្យាព័ត៌មាន



**ទី១១៖** រូបភាពបង្ហាញអំពីនីតិវិធីនៃការស្នើសុំសម្រាប់ការទិញ និងរំលាយបញ្ចូលគ្នា




**ទី១២៖** រូបភាពបង្ហាញអំពីសំណើសុំវិញ្ញាបនបត្របញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋ C.O.C



**ទី១៣៖** ទំហំវិនិយោគពីបរទេសនៅក្នុងប្រទេសកម្ពុជា




Source: National Bank of Cambodia

**ទី១៤៖** ការវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័តតាមវិស័យ



**ទី១៥៖** ការវាយតម្លៃកំណើនសេដ្ឋកិច្ចកម្ពុជា នៅចុងឆ្នាំ២០២១



# ឧបសម្ព័ន្ធទី៣

# ឯកសារបន្ថែម

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**
**គណ:កម្មាធិការវិនិយោគកម្ពុជា**

# ពាក្យស្នើសុំវិនិយោគនៅព្រះរាជាណាចក្រកម្ពុជា

## I- រចនាសម្ព័ន្ធក្រុមហ៊ុន ÷

***ក. ពត៌មានទូទៅ÷***

- ឈ្មោះក្រុមហ៊ុន : ..........................................................................................
- អាស័យដ្ឋាន : - ទីស្នាក់ការក្រុមហ៊ុន : ..........................................................................................
..........................................................................................
- ក្រុមហ៊ុនមេឈ្មោះ : ..........................................................................................
អាស័យដ្ឋាន : ..........................................................................................
Tel: ............................................ Fax: ..............................................
Website: ..................................... E-mail: ...........................................
- ទ្រង់ទ្រាយក្រុមហ៊ុន : (*សូមគូស ✓ ក្នុងប្រអប់*)
☐ ក្រុមហ៊ុនមូលធន (Corporation) ☐ ក្រុមហ៊ុនសហកម្មសិទ្ធិ (Partnership)
☐ ក្រុមហ៊ុនពាណិជ្ជកម្មបរទេស

***កំណត់សម្គាល់***: ក្រុមហ៊ុនមូលធនរួមមាន : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ក្រុមហ៊ុនសាធារណៈទទួលខុសត្រូវមានកម្រិត និងក្រុមហ៊ុនឯកបុគ្គលទទួលខុសត្រូវមានកម្រិត (Single Limited Company)

- ទុនចុះបញ្ជី : ................................................. បរទេស : ............ ក្នុងស្រុក :...............
- លិខិតបញ្ជាក់ប្រាក់តម្កល់នៅធនាគារ ២៥% លេខ : ......................

***ខ. សមាសភាពក្រុមហ៊ុន***

**ម្ចាស់ភាគហ៊ុន**

| នាមត្រកូល និងនាមខ្លួន | សញ្ជាតិ | លេខ និងកាលបរិច្ឆេទ អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន | អាស័យដ្ឋាន | អត្រាភាគហ៊ុន% |
|---|---|---|---|---|
| ១. ...........................<br>២. ...........................<br>៣. ...........................<br>៤. ........................... | | | | |

**សមាសភាពក្រុមប្រឹក្សាភិបាល (រួមទាំងតតីយជន)**

| នាមត្រកូល និងនាមខ្លួន | សញ្ជាតិ | លេខ និងកាលបរិច្ឆេទ អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន | អាស័យដ្ឋាន | តួនាទីក្នុងក្រុមហ៊ុន | អ្នកដែលមានសិទ្ធិ ចុះហត្ថលេខា សម្រាប់កិច្ចការ |
|---|---|---|---|---|---|
| ១. ........................... <br> ២. ........................... <br> ៣. .......................... <br> ៤. ........................... | | | | | |

## II- ពាក្យស្នើសុំវិនិយោគ :

### ក. ព័ត៌មានទូទៅ

- មុខសញ្ញាវិនិយោគ : ........................................................................................................
- វិស័យវិនិយោគ : ( *សូមគូស ✓ ក្នុងប្រអប់*)

  ☐ កសិកម្ម-កសិ-ឧស្សាហកម្ម ☐ សំណង់ស៊ីវិល ☐ ថាមពល ☐ ហិរញ្ញវត្ថុ ☐ ឧស្សាហកម្ម ☐ ធនធានរ៉ែ
  ☐ ទេសចរណ៍ ☐ ដឹកជញ្ជូន ☐ ទូរគមនាគមន៍ ☐ ទឹកស្អាត ☐ តំបន់ឧស្សាហកម្ម ☐ ផ្សេងៗ
- អ្នកដាក់ពាក្យសុំវិនិយោគ :
  - ឈ្មោះ ........................................... អាស័យដ្ឋាន :.....................................................
  - តួនាទីក្នុងក្រុមហ៊ុន :............................ Tel : ........................... Fax :...........................
  - លិខិតប្រគល់សិទ្ធិ ( *បើសិនមិនមានតួនាទីក្នុងក្រុមហ៊ុន*): លេខ............... ចុះថ្ងៃទី..... ខែ.......ឆ្នាំ......
- ទុនវិនិយោគសរុប : ......................................... ក្នុងនោះទុនលើ :
  - ដីធ្លី (ទំហំ ម$^2$) : ............................ តម្លៃ : .............................. USD
  - សំណង់អាគារ/រៀបចំការដ្ឋាន :............ ម$^2$ តម្លៃ.......................USD ☐អាគារមានស្រាប់ ☐អាគារថ្មី
  - សម្ភារៈបរិក្ខារផលិតកម្ម (គ្រឿងចក្រ-គ្រឿងម៉ាស៊ីនផលិតកម្ម-សម្ភារៈបរិក្ខារផ្សេងៗ) តម្លៃ (USD): ................................................. (មានបញ្ជីជូនភ្ជាប់ តាមទំរង់ដូចមានចែងក្នុងឧបសម្ព័ន្ធ)
  - ការិយាល័យតម្លៃ (USD) : .................................
  - ផ្សេងៗតម្លៃ (USD):.........................................
- ប្រភពទុនវិនិយោគ : ទុនផ្ទាល់ :................................... ឥណទានធនាគាររយៈពេលវែង : ....................

  ឥណទានធនាគាររយៈពេលខ្លី : ..............................
- ទីតាំងវិនិយោគ : ដីឡូត៍លេខ................. ផ្លូវលេខ ................ ភូមិ....................... ឃុំ/ សង្កាត់................

  ស្រុក/ ខណ្ឌ:................ ខេត្ត/ ក្រុង : ............ ទំហំ :.................... ម$^2$
- កម្មវិធីអនុវត្តគម្រោង :
  - ចាប់ផ្តើមសាងសង់:.............................. ព្យាករណ៍បញ្ចប់ការសាងសង់:................................
  - ពេលបំពាក់គ្រឿងម៉ាស៊ីនៈ ...................... ចាប់ផ្តើមដំណើរការផលិតកម្ម:..............................
- ពត៌មានស្តីពីផលិតផល :

| ប្រភេទផលិតផល | ឯកតា | សមត្ថភាពផលិតប្រចាំឆ្នាំ | | | | ទីផ្សារ | |
|---|---|---|---|---|---|---|---|
| | | ឆ្នាំដំបូង | | ពេញផលិតកម្ម | | | |
| | | បរិមាណ | តម្លៃ | បរិមាណ | តម្លៃ | ក្នុងស្រុក គិតជា% | នាំចេញ គិតជា % |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

- តម្រូវការពលកម្ម

| ប្រភេទពលកម្ម | ពេលចាប់ផ្តើម | | ពេលពេញសមត្ថភាព | |
|---|---|---|---|---|
| | ក្នុងស្រុក | បរទេស | ក្នុងស្រុក | បរទេស |
| - អ្នកគ្រប់គ្រង | | | | |
| - វិស្វករ | | | | |
| - អ្នកបច្ចេកទេស | | | | |
| - ទីប្រឹក្សា | | | | |
| - បុគ្គលិកការិយាល័យ | | | | |
| - បុគ្គលិកជំនាញ | | | | |
| - បុគ្គលិកគ្មានជំនាញ | | | | |
| សរុប | | | | |

- តម្រូវការធាតុចូលផលិតកម្ម (វត្ថុធាតុដើម) ប្រចាំឆ្នាំ: *បំពេញតាមទម្រង់ដូចមានចែងក្នុងឧបសម្ព័ន្ធភ្ជាប់មកជាមួយ*
- តម្រូវការថាមពល និងទឹក :
    - ធ្យូងថ្ម ឬអុសប្រចាំឆ្នាំ : ..................... ម៣/ឆ្នាំ, ឧស្ម័ន : ..................................... តោន/ឆ្នាំ
    - ប្រេងឥន្ធនៈ : ................................ តោន ឬលីត្រ/ឆ្នាំ
    - អគ្គិសនី (អនុភាពតម្លើង) : ................ MW តម្រូវការប្រចាំឆ្នាំ : ............................ KWH
    - ប្រើប្រាស់ទឹក :............................... ម៣/ឆ្នាំ,

***ខ- <u>ការជ្រើសរើសរបាង :</u>*** ☐ ការលើកលែងពន្ធលើប្រាក់ចំណេញ ☐ រំលោះពិសេស

☐ ដើម្បីទទួលបានតែការធានាលើការវិនិយោគ (មិនទាមទារការលើកទឹកចិត្ត)

*(ក្នុងចំណោមជម្រើសទាំងបីនេះ វិនិយោគិនមានសិទ្ធិទទួលបានតែមួយប៉ុណ្ណោះ)*

***គ- <u>ពត៌មានស្តីពីបរិស្ថាន :</u>***

- រូបភាពនៃការដឹកជញ្ជូនវត្ថុធាតុដើម និងផលិតផលសម្រេច ចេញ-ចូល ទីតាំងវិនិយោគ:

.....................................................................................................................

.....................................................................................................................

....................................................................................................................................

....................................................................................................................................

ប៉ាន់ស្មានបរិមាណ :

សំណល់រាវ :.............................$m^3$/ខែ សំណល់រឹង :.........................ម៣ ឬតោន/ខែ

ឧស្ម័នដែលត្រូវបញ្ចេញ : .................................................................../day

- តារាងប៉ាន់ស្មាននៃកំហាប់ក្នុង :

*ដំណើរការបញ្ចេញទឹកស្អុយ*

- pH :................................................ - អាម៉ូញាក់ Ammonia ($NH_3$) ................................
- នីត្រាតអាស៊ូត Nitrate Nitrogen.............. - លោហៈធ្ងន់ Heavy Metal..................................
- ផេណុល Phenol ($C_6H_5OH$)................... - ប្រេង និងខ្លាញ់ Oil and Grease...........................
- ភាពល្អក់ Turbidity ............................. - ភាពចម្លងអគ្គិសនី Conductivity ...........................
- ចំនួនសរុបនៃសារធាតុរឹងដែលរលាយក្នុងទឹក.......................................................................
- ចំនួនសរុបនៃសារធាតុរឹងដែលរងកករចុះទៅក្នុងទឹក..............................................................

ការបំភាយភាគល្អិតតូចៗនៃឧស្ម័នក្នុងខ្យល់

- កាបូនម៉ូណូអុកស៊ីត Carbon mono-oxide........... - អាស៊ូតឌីអុកស៊ីត Nitrogen Dioxide................
- អុកស៊ីតស៊ុលផួរិច Sulfur Oxide ....................... - អូស្សូន Ozone...........................................
- សំណរ Lead................................................

- ទីតាំងដែលប្រើសម្រាប់បោះបង់សំណល់រឹង បង្ហូរសំណល់រាវ និងការបញ្ចេញឧស្ម័ន

....................................................................................................................................

....................................................................................................................................

....................................................................................................................................

....................................................................................................................................

- ប្រភពដែលមានសម្លេង និងភាពរំញ័រខ្ពស់កើនឡើង

....................................................................................................................................

....................................................................................................................................

....................................................................................................................................

....................................................................................................................................

- ទំហំផ្ទៃដីដែលនឹងគ្របដណ្តប់ សម្រាប់ករណីចាក់ដីបំពេញ - ការឈូសឆាយ និងការរានដីថ្មី

....................................................................................................................................

....................................................................................................................................

....................................................................................................................................

....................................................................................................................................

- ស្ថានភាពស្នាក់នៅរបស់បុគ្គលិក - កម្មករ
- ផ្គត់ផ្គង់ទឹកស្អាត : ..........................................................................................................
- សុខភាព - សុវត្ថិភាព :..........................................................................................................
- អនាម័យ :............................................................................................................................
- ការគ្រប់គ្រងសំណល់រឹង : ......................................................................................................

***ឃ- ព័ត៌មានស្តីពីពន្ធដារ***

បំពេញតាមទម្រង់បែបបទ (Form) ដូចមានឧបសម្ព័ន្ធជូនភ្ជាប់

## III- ការធានា : ក្នុងនាមម្ចាស់គម្រោងសូមធានាអះអាងថា

- គម្រោងនេះមិនស្ថិតក្នុងបញ្ជីគម្រោងហាមឃាត់ ដូចមានចែងក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យ ស្តីពីការអនុវត្តន៍ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិនិយោគទេ។
- ព័ត៌មានខាងលើនេះ គឺពិតជាត្រឹមត្រូវ ដោយមិនមានចេតនាក្លែងបន្លំឡើយ។

ធ្វើនៅ .......................ថ្ងៃទី ........ខែ ..........ឆ្នាំ ............

ហត្ថលេខា

**<u>ឧបសម្ព័ន្ធទី ១</u>**

តារាងតម្រូវការសម្ភារៈបរិក្ខារផលិតកម្ម

សម្រាប់គម្រោងវិនិយោគ..................................................

| ល.រ | រាយមុខទំនិញ | ឯកតា | បរិមាណ | តម្លៃឯកតា (USD) | តម្លៃសរុប (USD) | ប្រភព | |
|---|---|---|---|---|---|---|---|
| | | | | | | ក្នុងស្រុក | នាំចូល |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | **សរុប** | | | | | | |

## <u>ឧបសម្ព័ន្ធទី ២</u>

តារាងតម្រូវការធាតុចូលផលិតកម្ម

សម្រាប់គម្រោងវិនិយោគ...................................................

| ល.រ | រាយមុខទំនិញ | ឯកតា | បរិមាណ | តម្លៃឯកតា (USD) | តម្លៃសរុប (USD) | ប្រភព | |
|---|---|---|---|---|---|---|---|
| | | | | | | ក្នុងស្រុក | នាំចូល |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | **សរុប** | | | | | | |

## ឧបសម្ព័ន្ធទី ១

## បញ្ជីគម្រោងហាមឃាត់ (សេចក្តីព្រាង)[1]

- សកម្មភាព ឬវិស័យដែលច្បាប់ហាមឃាត់..........................................................................
- ការផលិត ឬការកែច្នៃវត្ថុដែលពាក់ព័ន្ធដល់កិច្ចការវប្បធម៌..................................................
- ការផលិត ឬផលិតកម្ម ឈើអារ ឈើចំណិត ក្តារបន្ទះ ឬផលិតអំពីឈើ ដោយប្រើឈើម្ហូលក្នុងស្រុកជាវត្ថុធាតុដើម ..........................................................................................................
- ផលិតកម្មនៃ DBSA...................................................................................................
- ការផលិត ឬផលិតកម្មគ្រឿងគីមីពុលដែលមានប៉ះពាល់ទៅលើសុខភាពសហគមន៍ ឬមានប៉ះពាល់ចំពោះបរិស្ថាន ..........................................................................................................
- ការផលិត ឬផលិតកម្មគ្រឿងគីមីពុល ឬការប្រើប្រាស់សមាសធាតុពុល......................................
- ការផលិតសារធាតុ Psychotropic ....................................................................................
- ការផលិតថ្នាំញៀនណាកូទីន..............................................................................................
- ផលិតកម្មអាវុធ ឬគ្រាប់រំសេវ...........................................................................................
- ការផលិតគ្រឿងផ្ទុះ ឬកាំជ្រួច...........................................................................................
- ផលិតកម្មទំនិញទាក់ទងទៅនឹងការការពារ ឬសន្តិសុខជាតិ.....................................................
- រាល់សកម្មភាពពាណិជ្ជកម្មគ្រប់ប្រភេទ..................................................................................
- សេវាកម្មដឹកជញ្ជូនគ្រប់ប្រភេទ.........................................................................................
- ហាងទំនិញរួចពន្ធ ..........................................................................................................
- ភោជនីយដ្ឋាន ការ៉ាអូខេ រង្គសាល និងកន្លែងធ្វើសរសៃផ្សេងៗទៀត ដែលស្ថិតនៅក្រៅបរិវេណសណ្ឋាគារខ្នាតអន្តរជាតិ...................................................................................................................
- មជ្ឈមណ្ឌលពាណិជ្ជកម្ម......................................................................................................
- សកម្មភាពដែលទាក់ទងនឹងសារពត៌មាន និងប្រព័ន្ធឃោសនា (វិទ្យុ ទូរទស្សន៍ សារពត៌មាន) .............
- លក់រាយ និងលក់ដុំ..........................................................................................................
- សេវាផ្នែកជំនាញ ............................................................................................................

[1] *បញ្ជីគម្រោងហាមឃាត់នេះ នឹងយកតាមអនុក្រឹត្យថ្មី ស្តីពីការអនុវត្តន៍ច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលនឹងអនុម័តក្នុងពេលឆាប់ៗខាងមុខនេះ។*

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
COUNCIL FOR THE DEVELOPMENT OF CAMBODIA

## សេចក្តីសង្ខេបពិសេស

# ច្បាប់ស្តីពីវិនិយោគ



# អ្វីដែលអ្នកត្រូវដឹង

កម្ពុជាបានអនុម័តច្បាប់ស្តីពីវិនិយោគ នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ ក្នុងគោលបំណង បង្កើតនូវក្របខ័ណ្ឌគតិយុត្តដែលបើកចំហ មានតម្លាភាព អាចប៉ាន់ប្រមាណជាមុនបាន ដើម្បីទាក់ទាញ និងលើកកម្ពស់គុណភាព ប្រសិទ្ធភាព និងប្រសិទ្ធផល នៃការវិនិយោគ ដោយបុគ្គលសញ្ជាតិខ្មែរឬបរទេស ក្នុងប្រទេសកម្ពុជា។

ច្បាប់ស្តីពីវិនិយោគមានវិសាលភាពអនុវត្តចំពោះរាល់គម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ហៅកាត់ថា "គ.ល.គ." គម្រោងពង្រីកនៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ហៅកាត់ថា "គ.ព.គ.ល.គ." និង គម្រោងវិនិយោគដែលទទួលបានត្រឹមតែការធានាលើការវិនិយោគហៅកាត់ថា "គ.ធ.វ." ដែលបានចុះបញ្ជីនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬ នៅអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត។

## ការលើកទឹកចិត្តវិនិយោគ

ច្បាប់នេះផ្តល់ការលើកទឹកចិត្តវិនិយោគលើ វិស័យ និងសកម្មភាពសំខាន់ៗ តាមរយៈយន្តការនៃការលើកទឹកចិត្តផ្នែកពន្ធជាមូលដ្ឋាន ការលើកទឹកចិត្តបន្ថែម និងការលើកទឹកចិត្តពិសេស។

**សូមអានបន្ថែមនៅទំព័រទី ៣**







## ការធានាវិនិយោគ

កញ្ចប់មួយនៃវិធានការការពារ (ការធានា) ត្រូវបានផ្តល់ជូនវិនិយោគិន និងទ្រព្យសម្បត្តិរបស់ពួកគេនៅក្នុងច្បាប់ ដើម្បីធានាសុវត្ថិភាពនិងស្ថិរភាព។

**សូមអានបន្ថែមនៅទំព័រទី ៨**

## បែបបទនីតិវិធី

ការណែនាំជាមូលដ្ឋានចំពោះទិដ្ឋភាពបច្ចេកទេសដែលមានចែងក្នុងច្បាប់ថ្មី រួមមានដូចជា ការស្នើសុំចុះបញ្ជី និង ការផ្ទេរនូវគម្រោងវិនិយោគជាដើម។

**សូមអានបន្ថែមនៅទំព័រទី ១១**





# វាក្យស័ព្ទសំខាន់ៗ ដែលប្រើនៅក្នុងច្បាប់ស្តីពីវិនិយោគ

## វាក្យស័ព្ទគន្លឹះ

**គម្រោងវិនិយោគ** សំដៅដល់គម្រោងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ គម្រោងពង្រីកនៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងគម្រោងវិនិយោគដែលទទួលបានត្រឹមតែការធានាលើការវិនិយោគ។

**គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់** សរសេរជាអក្សរកាត់ គ.ល.គ សំដៅដល់គម្រោងវិនិយោគដែលទទួលបានវិញ្ញាបនបត្រចុះបញ្ជីពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត។

**គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បម្រើឱ្យការនាំចេញ** សំដៅដល់ គ.ល.គ ដែលបានលក់ឬបានផ្ទេរសមាមាត្រណាមួយនៃផលិតផលរបស់ខ្លួនទៅឱ្យអ្នកទិញ ឬអ្នកទទួលនៅក្រៅព្រះរាជាណាចក្រកម្ពុជា។

**គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលជាប្រភេទឧស្សាហកម្មគាំទ្រ** សំដៅដល់ គ.ល.គ ដែលផលិតផលរបស់ខ្លួនក្នុងសមាមាត្រណាមួយត្រូវផ្គត់ផ្គង់ដល់ឧស្សាហកម្មនាំចេញ។

**គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បម្រើទីផ្សារក្នុងស្រុក** សំដៅដល់ គ.ល.គ ដែលមិនបម្រើឱ្យការនាំចេញ។

**គម្រោងពង្រីកនៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់**
សរសេរជាអក្សរកាត់ គ.ព.គ.ល.គ សំដៅដល់ការពង្រីកនៃ គ.ល.គ ដែលធ្វើឡើងតាមរូបភាពណាមួយ មានជាអាទិ៍ ការពង្រីកផលិតកម្មដែលមានស្រាប់ ការពង្រីកតាមរយៈការធ្វើពិពិធកម្មមុខសញ្ញាផលិតកម្មដែលស្ថិតក្នុងខ្សែស្រឡាយផលិតផលជាមួយគ្នា ការពង្រីកតាមរយៈការបំពាក់បច្ចេកវិទ្យាទំនើបថ្មីដែលលើកកម្ពស់ផលិតភាព ឬការពារបរិស្ថាន ការពង្រីកហេដ្ឋារចនាសម្ព័ន្ធបម្រើឱ្យសេវាទូរគមនាគមន៍មូលដ្ឋាន ឬការពង្រីកក្រោមរូបភាពផ្សេងទៀតដែលនឹងត្រូវកំណត់ដោយអនុក្រឹត្យ។

**គម្រោងវិនិយោគដែលទទួលបានត្រឹមតែការធានាលើការវិនិយោគ**
សរសេរជាអក្សរកាត់ គ.ធ.វ. សំដៅដល់គម្រោងវិនិយោគដែលបានចុះបញ្ជីនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬនៅអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត ដោយមានបញ្ជាក់ច្បាស់ថាជា គ.ធ.វ. ប៉ុន្តែពុំទទួលបានការលើកទឹកចិត្តផ្នែកសារពើពន្ធ។

## មាត្រា២៤នៃច្បាប់ស្តីពីវិនិយោគ

**វិស័យនិងសកម្មភាពវិនិយោគដូចខាងក្រោម ត្រូវទទួលការលើកទឹកចិត្ត៖**

| | |
|---|---|
| ១ | ឧស្សាហកម្មដែលមានបច្ចេកវិទ្យាខ្ពស់ ប្រកបដោយនវានុវត្តន៍ និងការស្រាវជ្រាវ និងអភិវឌ្ឍន៍ |
| ២ | ឧស្សាហកម្ម ឬកម្មន្តសាលថ្មីៗ ផ្តល់តម្លៃបន្ថែមខ្ពស់ មាននវានុវត្តន៍ និងភាពប្រកួតប្រជែងខ្ពស់ |
| ៣ | ឧស្សាហកម្មបម្រើឱ្យខ្សែច្រវាក់ផលិតកម្មតំបន់និងសកលលោក |
| ៤ | ឧស្សាហកម្មគាំទ្រពាក់ព័ន្ធនឹងវិស័យកសិកម្ម ទេសចរណ៍ កម្មន្តសាល ឧស្សាហកម្មបម្រើឱ្យខ្សែច្រវាក់ផលិតកម្មតំបន់និងសកលលោក និងឧស្សាហកម្មតភ្ជាប់បណ្តាញផ្គត់ផ្គង់ |
| ៥ | ឧស្សាហកម្មគ្រឿងអគ្គិសនីនិងអេឡិចត្រូនិក |
| ៦ | ឧស្សាហកម្មគ្រឿងបន្លាស់ បង្គុំ និងតម្លើង |
| ៧ | ឧស្សាហកម្មមេកានិកនិងគ្រឿងម៉ាស៊ីន |
| ៨ | កសិកម្ម កសិឧស្សាហកម្ម ឧស្សាហកម្មកែច្នៃផលិតផលកសិកម្ម ឧស្សាហកម្មកែច្នៃចំណីអាហារដែលបម្រើទីផ្សារក្នុងស្រុក ឬការនាំចេញ |

| | |
|---|---|
| ៩ | សហគ្រាសធុនតូចនិងមធ្យមក្នុងវិស័យអាទិភាព និងការអភិវឌ្ឍបណ្តុំសហគ្រាសធុនតូច និងមធ្យម សួនឧស្សាហកម្ម និងសួនវិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍ |
| ១០ | ឧស្សាហកម្មទេសចរណ៍និងសកម្មភាពពាក់ព័ន្ធនឹងទេសចរណ៍ |
| ១១ | ការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស |
| ១២ | ឧស្សាហកម្មឱជីថល |
| ១៣ | ការវិនិយោគក្នុងវិស័យអប់រំ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការជំរុញផលិតភាព |
| ១៤ | ការវិនិយោគក្នុងវិស័យសុខាភិបាល |
| ១៥ | ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត |
| ១៦ | ការវិនិយោគក្នុងវិស័យឡូជីស្ទីក |
| ១៧ | ការវិនិយោគក្នុងការគ្រប់គ្រង ការការពារបរិស្ថាន និងការអភិរក្សជីវៈចម្រុះ និងសេដ្ឋកិច្ចចក្រា |
| ១៨ | ការវិនិយោគក្នុងវិស័យថាមពលបៃតង បច្ចេកវិទ្យាដែលរួមចំណែកដល់ការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ |
| ១៩ | វិស័យនិងសកម្មភាពវិនិយោគផ្សេងទៀតដែលមិនមានចែងក្នុងច្បាប់នេះ ក្នុងករណីដែលរាជរដ្ឋាភិបាលយល់ឃើញថាមានសក្តានុពលដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច។ |







# ការលើកទឹកចិត្តជាមូលដ្ឋាន

សកម្មភាពវិនិយោគដែលបានចុះបញ្ជីជា គ.ល.គ. មានសិទ្ធិជ្រើសរើសកញ្ចប់លើកទឹកចិត្តជាមូលដ្ឋានជា ០២ ជម្រើសដូចខាងក្រោម÷

ជម្រើសទី១÷ ការលើកលែងពន្ធលើប្រាក់ចំណូល÷ ការលើកលែងពន្ធលើប្រាក់ចំណូលសម្រាប់រយៈពេលពី ៣ ទៅ ៩ ឆ្នាំ ទៅតាមវិស័យនិងសកម្មភាពវិនិយោគ គិតចាប់ពីពេលទទួលបានប្រាក់ចំណូលលើកដំបូង។ វិស័យ និងសកម្មភាពវិនិយោគ ព្រមទាំងរយៈពេលលើកលែងពន្ធលើប្រាក់ចំណូល នឹងត្រូវកំណត់ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងនិង/ ឬអនុក្រឹត្យ។

**បន្ទាប់ពីផុតរយៈពេលលើកលែងពន្ធលើប្រាក់ចំណូល** គ.ល.គ. មានសិទ្ធិទទួលបានការលើកទឹកចិត្តឱ្យបង់ពន្ធលើប្រាក់ចំណូលតាមអត្រាកំណើនតាមពេលធៀបទៅនឹងប្រាក់ពន្ធត្រូវបង់សរុបដូចតទៅ÷ ២៥% សម្រាប់ ២ ឆ្នាំដំបូង, ៥០% សម្រាប់ ២ ឆ្នាំបន្ទាប់, និង ៧៥% សម្រាប់ ២ ឆ្នាំចុងក្រោយ។

លើសពីនេះទៀតជម្រើសនេះរួមបញ្ចូល÷

- ការលើកលែងប្រាក់រំដោះពន្ធលើប្រាក់ចំណូលក្នុងអំឡុងពេលលើកលែងពន្ធលើប្រាក់ចំណូល
- ការលើកលែងពន្ធអប្បបរមា ដោយត្រូវមានរបាយការណ៍សវនកម្មឯករាជ្យ
- ការលើកលែងអាករនាំចេញ លើកលែងតែមានចែងដោយឡែកនៅក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត

ជម្រើសទី២÷ ការរំលស់ពិសេស÷

- សិទ្ធិកាត់កងចំណាយមូលធនតាមរយៈការរំលស់ពិសេសដែលមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន
- សិទ្ធិកាត់កងរហូតដល់ ២០០% លើចំណាយជាក់លាក់ផ្សេងទៀតសម្រាប់រយៈពេលរហូតដល់ ៩ ឆ្នាំ។ វិស័យ និង សកម្មភាពវិនិយោគ និងចំណាយជាក់លាក់ ព្រមទាំងរយៈពេលកាត់កងចំណាយ ត្រូវកំណត់ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រង និង/ ឬអនុក្រឹត្យ

- ការលើកលែងប្រាក់រំដោះពន្ធលើប្រាក់ចំណូលក្នុងរយៈពេលជាក់លាក់ណាមួយទៅតាមវិស័យនិងសកម្មភាពវិនិយោគដែលត្រូវកំណត់ក្នុងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង និង/ ឬអនុក្រឹត្យ
- ការលើកលែងពន្ធអប្បបរមាដោយត្រូវមានរបាយការណ៍សវនកម្មឯករាជ្យ
- ការលើកលែងអាករនាំចេញ លើកលែងតែមានចែងដោយឡែកនៅក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត។

**បន្ថែមពីលើការលើកទឹកចិត្តក្នុងជម្រើសទី១ ឬជម្រើសទី២÷**

**ក.** គ.ល.គ. ដែលបម្រើឱ្យការនាំចេញ និង គ.ល.គ. ដែលជាប្រភេទឧស្សាហកម្មគាំទ្រដល់ គ.ល.គ បម្រើឱ្យការនាំចេញ មានសិទ្ធិនាំចូលដោយពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋនូវសម្ភារៈសាងសង់ បរិក្ខារសំណង់ សម្ភារៈបរិក្ខារផលិតកម្ម និងធាតុចូលផលិតកម្ម

**ខ.** គ.ល.គ. បម្រើទីផ្សារក្នុងស្រុកមានសិទ្ធិនាំចូលដោយពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែមសម្រាប់ការនាំចូលសម្ភារៈសាងសង់ បរិក្ខារសំណង់ និងសម្ភារៈបរិក្ខារផលិតកម្ម ។ ការលើកទឹកចិត្តចំពោះធាតុចូលផលិតកម្មត្រូវកំណត់ក្នុងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង និង/ ឬអនុក្រឹត្យ។

# ការលើកទឹកចិត្តបន្ថែម

ក្រៅពីការលើកទឹកចិត្តជាមូលដ្ឋាន សកម្មភាពវិនិយោគដែលបានចុះបញ្ជីជា គ.ល.គ. ទទួលបានការលើកទឹកចិត្តបន្ថែម ដូចខាងក្រោម÷

- ការលើកលែងអាករលើតម្លៃបន្ថែមចំពោះការទិញធាតុចូលផលិតកម្មដែលផលិតក្នុងស្រុកសម្រាប់បម្រើដល់ការអនុវត្ត គ.ល.គ.
- ការកាត់កងចំណាយក្នុងអត្រា ១៥០% ពីមូលដ្ឋានគិតពន្ធចំពោះសកម្មភាពណាមួយដូចខាងក្រោម÷
    - ក. ការស្រាវជ្រាវ អភិវឌ្ឍន៍ និងនវានុវត្តន៍
    - ខ. ការអភិវឌ្ឍធនធានមនុស្ស តាមរយៈការផ្ដល់ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងជំនាញដល់កម្មករនិយោជិតខ្មែរ
    - គ. ការសាងសង់កន្លែងស្នាក់នៅ កន្លែងបរិភោគអាហារ ឬអាហារដ្ឋានតម្លៃសមរម្យ ទារកដ្ឋាន និងសុខុបត្ថម្ភវត្ថុ ដទៃទៀតសម្រាប់កម្មករ/និយោជិត

ឃ. ការធ្វើទំនើបកម្មលើគ្រឿងម៉ាស៊ីនដើម្បីបម្រើខ្សែច្រវាក់ផលិតកម្ម និង
ង. ការផ្តល់ការលើកកម្ពស់សុខុមាលភាពដល់កម្មករនិយោជិតខ្មែរ ដូចជាការផ្តល់មធ្យោបាយដឹកជញ្ជូនប្រកបដោយផាសុកភាពដល់កម្មករនិយោជិតក្នុងការធ្វើដំណើរទៅមកពីកន្លែងស្នាក់នៅទៅរោងចក្រ កន្លែងស្នាក់នៅ កន្លែងបរិភោគអាហារ ឬអាហារដ្ឋានដែលមានតម្លៃសមរម្យ ទារកដ្ឋាន និងសុខុបត្ថម្ភវត្ថុដទៃទៀត

- ការលើកលែងពន្ធលើប្រាក់ចំណូលចំពោះការពង្រីក គ.ល.គ. ដែលត្រូវកំណត់ដោយអនុក្រឹត្យ។

# ការលើកទឹកចិត្តពិសេស

វិស័យ និងសកម្មភាពវិនិយោគជាក់លាក់ណាមួយដែលមានសក្តានុពលខ្ពស់ក្នុងការរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ អាចទទួលការលើកទឹកចិត្តពិសេសដោយឡែកផ្សេងទៀតដែលត្រូវកំណត់នៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង។



# “ការផ្តល់ការលើកទឹកចិត្តគ្រប់ជ្រុងជ្រោយដល់ការវិនិយោគក្នុងវិស័យដែលប្រកបដោយនវានុវត្តន៍ និងចីរភាពគឺជាការវិវឌ្ឍដ៏វិជ្ជមាន”



## ការធានាវិនិយោគ

ជំពូកទី៥ នៃច្បាប់នេះ ចែងអំពីការធានា និងការការពារវិនិយោគ។ “ វិនិយោគិន” សំដៅដល់បុគ្គលអនុវត្តគម្រោងវិនិយោគ ដែលបានចុះបញ្ជីនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬ នៅអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត។

**ការមិនរើសអើងក្នុងករណីដែលមានការខូចខាតការវិនិយោគ៖** វិនិយោគិននឹងទទួលបាននូវប្រព្រឹត្តកម្មមិនរើសអើង ទាក់ទងនឹងបដិទាន  សំណង ឬ ដំណោះស្រាយជាតម្លៃសេដ្ឋកិច្ចផ្សេងទៀត ក្នុងករណីដែលការវិនិយោគរបស់ខ្លួនបាន ទទួលរងនូវការខូចខាតដោយសារជម្លោះប្រដាប់អាវុធ ឬកលិយុគស៊ីវិល ឬការដាក់ប្រទេសជាតិនៅក្នុងភាពអាសន្ន ប្រសិនបើមានច្បាប់ និងគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការធ្វើបដិទានឬផ្តល់សំណងសមរម្យណាមួយនោះ។

**ការមិនរើសអើងចំពោះសញ្ជាតិបរទេស៖** វិនិយោគិនបរទេសមិនត្រូវជាកម្មវត្ថុនៃការរើសអើងដោយសារមូលហេតុសញ្ជាតិបរទេស លើកលែងតែកម្មសិទ្ធិលើដីធ្លីដូចដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងបទប្បញ្ញត្តិទាំងឡាយជាធរមាន។

**ការមិនធ្វើជាតូបនីយកម្ម៖** រដ្ឋមិនត្រូវធ្វើជាតូបនីយកម្ម ដែលនាំឱ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់វិនិយោគិន ក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ។

**ការមិនធ្វើអស្សាមិករណ៍៖** រដ្ឋមិនត្រូវធ្វើអស្សាមិករណ៍ដែលនាំឱ្យប៉ះពាល់ដល់គម្រោងវិនិយោគដែលបានទទួលការអនុម័តនោះឡើយ ទោះបីដោយផ្ទាល់ឬដោយប្រយោល ឬតាមរយៈវិធានការប្រហាក់ប្រហែលនឹងការធ្វើអស្សាមិករណ៍ក្តី លើកលែងតែក្នុងករណីបម្រើប្រយោជន៍សាធារណៈ ដែលការធ្វើអស្សាមិករណ៍នេះត្រូវអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម៖

១. ភាពមិនរើសអើង
២. សំណងដោយសមរម្យនិងយុត្តិធម៌ និង
៣. អនុលោមតាមច្បាប់និងនីតិវិធីអស្សាមិករណ៍ជាធរមាន។

**ការមិនកំណត់ថ្លៃ៖** រាជរដ្ឋាភិបាលកម្ពុជាមិនត្រូវកំណត់ថ្លៃលើផលិតផល ឬសេវានានាដែលបង្កើតដោយគម្រោងវិនិយោគនោះទេ។

**ការទិញ និងបង្វិលទៅបរទេសនៃរូបិយបណ្ណបរទេសដោយសេរី៖** អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន វិនិយោគិនមានសិទ្ធិទិញរូបិយបណ្ណបរទេសដោយសេរី និងធ្វើការបង្វិលទៅបរទេសនូវរូបិយបណ្ណបរទេសទាំងអស់នោះ ដើម្បីទូទាត់កាតព្វកិច្ចខាងហិរញ្ញវត្ថុដែលពាក់ព័ន្ធនឹងការវិនិយោគរបស់ខ្លួនតាមរយៈប្រព័ន្ធធនាគារដែលជាអន្តរការីប្រតិស្រុតិ។

**ការការពារកម្មសិទ្ធិបញ្ញា៖** កម្មសិទ្ធិបញ្ញារបស់វិនិយោគិនត្រូវបានការពារដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញានៃព្រះរាជាណាចក្រកម្ពុជា។

**កម្មសិទ្ធិដីធ្លី៖** កម្មសិទ្ធិលើដីធ្លីរបស់វិនិយោគិនសម្រាប់បម្រើឱ្យគោលដៅអនុវត្តគម្រោងវិនិយោគត្រូវបានអនុញ្ញាតចំពោះតែបុគ្គលដែលមានសញ្ជាតិខ្មែរស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ វិនិយោគិនមានសិទ្ធិប្រើប្រាស់ដីធ្លីតាមរយៈជាអាទិ៍សម្បទានដីសេដ្ឋកិច្ច ឬសិទ្ធិជួលអចិន្ត្រៃយ៍ និងការជួលដែលមានអំឡុងពេលកំណត់ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ផ្សេងៗ៖** វិនិយោគិនក៏មានសិទ្ធិដូចខាងក្រោម៖
១. សិទ្ធិជួលនិយោជិតបរទេសដើម្បីគ្រប់គ្រង ឬប្រតិបត្តិការគម្រោងវិនិយោគក្នុងចំនួនមិនលើសពីចំនួនដែលកំណត់ដោយច្បាប់ និងលិខិតបទដ្ឋាន

គតិយុត្តជាធរមាន ក្នុងករណីដែលពុំអាចរកនិយោជិតខ្មែរដែលមានជំនាញដើម្បីគ្រប់គ្រង ឬប្រតិបត្តិការគម្រោងវិនិយោគនោះ។ ការអនុញ្ញាត ឱ្យជួលនិយោជិតបរទេសគឺត្រូវពិនិត្យទៅតាមស្ថានភាពជាក់ស្តែង និងពុំមានលក្ខណៈអចិន្ត្រៃយ៍ទេ។

២. សិទ្ធិទទួលបានការអនុញ្ញាតស្នាក់នៅបណ្តោះអាសន្នរយៈពេលវែង សម្រាប់ខ្លួនឯងផ្ទាល់ សហព័ទ្ធ និងកូន ដែលជាអនីតិជនក្នុងអំឡុងពេលដែលគម្រោងវិនិយោគរបស់ខ្លួនមានប្រតិបត្តិការ។

៣. សិទ្ធិស្នើសុំការអនុញ្ញាតស្នាក់នៅបណ្តោះអាសន្នរយៈពេលវែងសម្រាប់និយោជិតបរទេស សហព័ទ្ធ និងកូនដែលជាអនីតិជនក្នុងអំឡុងពេលកិច្ចសន្យាការងារនៅមានសុពលភាព។

៤. សិទ្ធិទទួលបានបណ្ណការងារ និងសៀវភៅការងារសម្រាប់ខ្លួនឯងផ្ទាល់ និងនិយោជិតបរទេសរបស់ខ្លួន។
ក.អ.ក. ឬអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត ត្រូវចេញលិខិតបញ្ជាក់អំពីឋានៈជាវិនិយោគិនជូនបុគ្គលពាក់ព័ន្ធក្នុងគម្រោងវិនិយោគ ទៅតាមការស្នើសុំរបស់វិនិយោគិន ដើម្បីប្រើប្រាស់សម្រាប់ការស្នើសុំការអនុញ្ញាតស្នាក់នៅបណ្តោះអាសន្នរយៈពេលវែង បណ្ណការងារនិងសៀវភៅការងារ និងគោលបំណងចាំបាច់ដទៃទៀតស្របតាមនីតិវិធីជាធរមាន។



# នីតិវិធីនៃការចុះបញ្ជី និងការអនុវត្តគម្រោងវិនិយោគ

បុគ្គលដែលមានបំណងអនុវត្ត គ.ល.គ. ឬ គ.ព.គ.ល.គ. ឬ គ.ធ.វ. ត្រូវដាក់សំណើសុំចុះបញ្ជីជាលាយលក្ខណ៍អក្សរនៅ ក.អ.ក ឬអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត។ យោងតាមច្បាប់ថ្មី សំណើសុំចុះបញ្ជីគម្រោងវិនិយោគអាចត្រូវបានធ្វើឡើងតាមអនឡាញ។ សំណើសុំចុះបញ្ជីគម្រោងវិនិយោគត្រូវភ្ជាប់មកជាមួយនូវព័ត៌មានដែលនឹងកំណត់នៅក្នុងអនុក្រឹត្យ។ ក.អ.ក. ត្រូវពិនិត្យ និងសម្រេចលើសំណើតាមរយៈយន្តការច្រកចេញ-ចូលតែមួយ ដែលជាយន្តការពិនិត្យ និងសម្រេចក្នុងការចុះបញ្ជីគម្រោងវិនិយោគដោយតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលប្រចាំការនៅ ក.អ.ក. ទៅតាមការចាត់តាំងនិងប្រតិភូកម្មសិទ្ធិអំណាចពីប្រធានក្រសួង ស្ថាប័ន ក្រោមការសម្របសម្រួលរបស់ ក.អ.ក.។ ប្រសិនបើគម្រោងវិនិយោគដែលត្រូវបានស្នើសុំនោះ មិនស្ថិតក្នុងបញ្ជីអវិជ្ជមានដែលនឹងត្រូវកំណត់ដោយឡែកក្នុងអនុក្រឹត្យ ក.អ.ក. នឹងចេញវិញ្ញាបនបត្រចុះបញ្ជីជូនអ្នកដាក់ពាក្យសុំក្នុងអំឡុងពេលមិនលើសពី ២០ ថ្ងៃនៃថ្ងៃធ្វើការ។

ព័ត៌មានបន្ថែមអាចរកបានតាមរយៈ÷ www.cdc.gov.kh
សំរាប់ការចុះបញ្ជីតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន÷ https://qip.cdc.gov.kh/login

គម្រោងវិនិយោគដែលទទួលបានវិញ្ញាបនបត្រចុះបញ្ជីអាចត្រូវបានអនុវត្តដោយស្វ័យប្រវត្តិ។ ការទទួលបានវិញ្ញាបនបត្រចុះបញ្ជីមិនមែនជាការលើកលែងឱ្យគម្រោងវិនិយោគរួចផុតពីការទទួលនូវលិខិតអនុញ្ញាតតាមការកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិនានាឡើយ។ រាល់គម្រោងវិនិយោគជាកម្មវត្ថុនៃការតាមដាននិងត្រួតពិនិត្យ តាមរយៈយន្តការច្រកចេញ-ចូលតែមួយ ដែលសម្របសម្រួលដោយ ក.អ.ក. ដើម្បីធានាបាននូវអនុលោមភាពគតិយុត្ត និងលក្ខខណ្ឌនានាដែលជាមូលហេតុនៃការទទួលបានវិញ្ញាបនបត្រចុះបញ្ជី។ អ្នកអនុវត្តគម្រោងវិនិយោគត្រូវផ្តល់របាយការណ៍ស្តីពីការអនុវត្តគម្រោងវិនិយោគតាមកាលវិភាគជាក់លាក់ដែលកំណត់ដោយ ក.អ.ក.។ ទម្រង់និងបែបបទលម្អិតនៃគំរូរបាយការណ៍ត្រូវកំណត់ដោយសេចក្តីណែនាំរបស់ ក.អ.ក.។

នីតិវិធីចុះបញ្ជីគម្រោងវិនិយោគនៅអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក។

## ការទិញ ការលក់ ឬការរួមបញ្ចូលគ្នានៃគម្រោងវិនិយោគ

សិទ្ធិ បុព្វសិទ្ធិ ឬសិទ្ធិដទៃទៀត ដែល គ.ល.គ. បានទទួលមិនអាចផ្ទេរទៅតតិយជនណាមួយបានទេ លើកលែងតែការផ្ទេរតាមរយៈការទិញ ការលក់ និងការរួមបញ្ចូលគ្នានៃគម្រោងវិនិយោគ។ គម្រោងវិនិយោគអាចត្រូវបានទិញ លក់ ឬរួមបញ្ចូលគ្នាដោយមិនបាត់បង់ការលើកទឹកចិត្ត ការធានាលើការវិនិយោគ និងកាតព្វកិច្ចទាំងឡាយដែលនៅមានបន្ត ប្រសិនបើការទិញ ការលក់ ឬការរួមបញ្ចូលគ្នានោះ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមានហើយត្រូវបានធ្វើឡើងតាមរយៈការស្នើសុំជាលាយលក្ខណ៍អក្សរទៅក.អ.ក. ឬទៅអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត ដែលនីតិវិធីលម្អិតត្រូវកំណត់ដោយអនុក្រឹត្យ។

## ការលុបគម្រោងវិនិយោគ

គម្រោងវិនិយោគអាចត្រូវបានលុបក្នុងករណីណាមួយដូចខាងក្រោម÷

១. អលទ្ធភាពក្នុងការអនុវត្ត គ.ល.គ. បន្តទៀត។

២. នីតិបុគ្គលដែលអនុវត្ត គ.ល.គ. ត្រូវបានរំលាយ។

៣. ការខកខានអនុវត្តកាតព្វកិច្ចដែលបានកំណត់ក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

៤. តាមសំណើរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ លើគម្រោងដែលមានផលប៉ះពាល់ធ្ងន់ធ្ងរជាអាទិ៍ដល់បរិស្ថាន ឬសន្តិសុខជាតិ ឬផលប្រយោជន៍សាធារណៈ ឬសុខុមាលភាពប្រជាពលរដ្ឋ ឬតាមសំណើរបស់វិនិយោគិន។

នីតិវិធីលម្អិតស្តីពីការលុបគម្រោងវិនិយោគត្រូវកំណត់ដោយអនុក្រឹត្យ។

ទោះបីជាគម្រោងវិនិយោគត្រូវបានលុបក៏ដោយ វិនិយោគិនមិនអាចរួចផុតពីកាតព្វកិច្ចសារពើពន្ធ និងកាតព្វកិច្ចដ៏ទៃផ្សេងៗទៀតឡើយ។ វិនិយោគិនអាចធ្វើការតវ៉ាចំពោះការលុបគម្រោងវិនិយោគបាន តាមរយៈការដាក់ពាក្យតវ៉ាជាលាយលក្ខណ៍អក្សរទៅក.អ.ក. ឬទៅអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត ស្របតាមនីតិវិធីជាធរមាន។

ក្នុងករណីមានការតវ៉ា ក.អ.ក. ឬអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត ត្រូវធ្វើសេចក្តីសម្រេចចំពោះការតវ៉ាខាងលើ។ ក្នុងករណីមិនពេញចិត្តនឹងសេចក្តីសម្រេចចំពោះការតវ៉ាខាងលើ វិនិយោគិនដែលបានតវ៉ា អាចដាក់ពាក្យបណ្តឹងទៅតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។

## វិវាទ និងការដោះស្រាយវិវាទ

វិវាទរវាងវិនិយោគិននិងវិនិយោគិនពាក់ព័ន្ធទៅនឹងគម្រោងវិនិយោគអាចត្រូវបាន ដោះស្រាយតាមយន្តការសម្របសម្រួលដោយ ក.អ.ក. ឬ ដោយអនុគណៈកម្មាធិការ វិនិយោគរាជធានី ខេត្ត តាមនីតិវិធីជាធរមាន តាមការស្នើសុំជាលាយលក្ខណ៍អក្សរទៅ ក.អ.ក. ឬ អនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត ដោយភាគីវិវាទណាមួយ។

ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ បន្ទាប់ពីទទួលបានសំណើសុំជាលាយលក្ខណ៍អក្សរដែល ស្នើសុំសម្របសម្រួល ក.អ.ក.ឬអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត ត្រូវចាត់ចែង រៀបចំការសម្របសម្រួលជាមួយវិនិយោគិននិងអង្គពាក់ព័ន្ធដទៃទៀតទៅតាមការចាំបាច់ សំដៅទទួលបានដំណោះស្រាយសមរម្យមួយ។

ប្រសិនបើការដោះស្រាយតាមយន្តការសម្របសម្រួលខាងលើពុំទទួលបានជោគជ័យ វិវាទ អាចត្រូវបានដោះស្រាយតាមរយៈ÷

១. មជ្ឈត្តការជាតិឬមជ្ឈត្តការអន្តរជាតិដែលយល់ព្រមដោយគូវិវាទ
២. តុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។

## អន្តរប្បញ្ញត្តិ

ការវិនិយោគដែលទទួលបានការអនុញ្ញាត និងទទួលបានការលើកទឹកចិត្តក្រោមច្បាប់ស្តីពី វិនិយោគឆ្នាំ១៩៩៤ និងឆ្នាំ២០០៣ នឹងត្រូវបានចាត់ទុកថាជា គ.ល.គ. ក្រោមច្បាប់នេះ។ ការវិនិយោគដែលពុំបានទទួលការលើកទឹកចិត្ត ប៉ុន្តែបានទទួលការធានាការវិនិយោគ ក្រោមច្បាប់ស្តីពីវិនិយោគឆ្នាំ១៩៩៤ និងឆ្នាំ២០០៣ នឹងត្រូវបានចាត់ទុកជា គ.ធ.វ.។ គ.ល.គ. ដែលមានសិទ្ធិទទួលបាននូវការលើកលែងពន្ធលើប្រាក់ចំណូល មុនពេលប្រកាស ឱ្យប្រើនូវច្បាប់នេះ ហើយដែលសិទ្ធិទទួលបាននេះត្រូវបានអនុម័តជាលាយលក្ខណ៍អក្សរ ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាឬដោយអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត ត្រូវ បន្តទទួលបាននូវសិទ្ធិនិងការលើកលែងពន្ធលើប្រាក់ចំណូលត្រឹមទំហំដែលនៅសេសសល់ តែប៉ុណ្ណោះ។

ក.អ.ក. នឹងបន្តអនុវត្តភារកិច្ចរហូតដល់មានការប្រកាសឱ្យប្រើព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (សូមមើលមាត្រា ៤-៨ នៃច្បាប់ថ្មីសម្រាប់ ព័ត៌មានលម្អិត)។

# អ្វីជាទិសដៅបន្ទាប់?

ច្បាប់ស្តីពីវិនិយោគបង្កើតឱ្យមាននូវក្របខ័ណ្ឌច្បាប់ថ្មីដែលមានលក្ខណៈអំណោយផលដល់ការវិនិយោគ ជាពិសេសបង្កើតនូវក្របខ័ណ្ឌលើកទឹកចិត្តវិនិយោគដ៏សំខាន់មួយសម្រាប់វិស័យ និងសកម្មភាពវិនិយោគចំនួន ១៩ រួមទាំងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល ការគ្រប់គ្រងនិងការពារបរិស្ថាន ប្រសិទ្ធផលថាមពល ទេសចរណ៍ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ឡូជីស្ទីក និងការស្រាវជ្រាវ និងអភិវឌ្ឍន៍ និងហេដ្ឋារចនាសម្ព័ន្ធ ។ល។ ច្បាប់នេះត្រូវបានរំពឹងថានឹងបង្កើនសមត្ថភាពប្រកួតប្រជែង និងភាពទាក់ទាញរបស់កម្ពុជាក្នុងស្មារតីនៃការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ច គាំទ្រនវានុវត្តន៍ និងជំរុញការស្តារសេដ្ឋកិច្ចឡើងវិញ ក្នុងដំណាក់កាលនៃការរាតត្បាតរបស់ជំងឺកូវីដ-១៩។



## ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

អាសយដ្ឋាន៖ វិមានរដ្ឋាភិបាល តិរវិថីព្រះស៊ីសុវត្ថិ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
គេហទំព័រ ៖ www.cdc.gov.kh

## គណៈកម្មាធិការវិនិយោគកម្ពុជា (CIB)

ទូរស័ព្ទ៖ ០៩៩ ៧៩៩ ៦៧៩ / ០៩៨ ៧៩៩ ៦៧៩ (Hotline)
អ៊ីម៉ែល៖ helpdesk@cdc.gov.kh
info@cdc.gov.kh
គេហទំព័រ ៖ www.cdc.gov.kh

តុចិន អ៊ីម៉ែល៖ chinadesk@cdc.gov.kh
តុអឺរ៉ុប អ៊ីម៉ែល៖ eudesk@cdc.gov.kh និង CC to info@eurocham-cambodia.org
តុជប៉ុន អ៊ីម៉ែល៖ japandesk@cdc.gov.kh
តុកូរ៉េ អ៊ីម៉ែល៖ koreadesk@cdc.gov.kh

## ម៉ោងធ្វើការ

ពីថ្ងៃ ចន្ទ ដល់ ថ្ងៃ សុក្រ
ពេលព្រឹក ៧:៣០ - ១១:៣០
ពេលរសៀល ២:០០ - ៥:៣០

Facebook
ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
Council for the Development of Cambodia

Telegram & WhatsApp
+855 99 799 679
+855 98 799 679